ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា



# ឯកសារស្ដីពីការអប់រំបរិយាបន្ន

សម្រាប់គ្រូឧទ្ទេស

ឆ្នាំ២០១៧

# មាតិកា


**បុព្វកថា** ....... iii

**អារម្ភកថា** ....... iv

**គណៈកម្មការរៀបចំ និងចងក្រងឯកសារ** ....... v

**អក្សរកាត់** ....... vii

**សេចក្តីផ្តើម** ....... ១

**ផ្នែកទី១ ការយល់ដឹងពីការអប់រំបរិយាបន្ន** ....... ៥

**សេចក្តីផ្តើម** ....... ៦

មេរៀនទី១ ការស្វែងយល់ពីការអប់រំបរិយាបន្ន ....... ៧

មេរៀនទី២ ការកំណត់រកកុមារដែលមានហានិភ័យដោយការផាត់ចេញ ....... ១៨

មេរៀនទី៣ ការផ្តោតលើកុមារពិការ ....... ២៣

មេរៀនទី៤ ការប្រើប្រាស់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ (Holistic Approach) ....... ៣០

មេរៀនទី៥បរិយាកាសសាលារៀនបរិយាបន្ន ....... ៣៧

មេរៀនទី៦ ការយល់ដឹងពីវិធីសាស្ត្រពីររួមគ្នា (Twin Track Approach) ....... ៤៣

**ផ្នែកទី២ ការស្វែងយល់អំពីវិធីបង្រៀនអប់រំបរិយាបន្នយាបន្ន** ....... ៤៩

មេរៀនទី៧ ការបង្ហាញវិធីបង្រៀនការអប់រំបរិយាបន្ន ....... ៥០

មេរៀនទី៨ការស្វែងយល់ពហុបញ្ញា និងរបៀបរៀន ....... ៥៨

មេរៀនទី៩ ការកំណត់ឧបសគ្គចំពោះការរៀន ....... ៦៥

មេរៀនទី១០ ការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិត ....... ៧១

មេរៀនទី១១ ការដាក់បញ្ចូលកុមារទាំងអស់នៅក្នុងការរៀន ....... ៧៨

មេរៀនទី១២ ការអនុវត្តការជួយជ្រោមជ្រែង និងភាពផ្សេងៗគ្នារបស់សិស្ស ....... ៨២

មេរៀនទី១៣ ការអភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងល្អ ........ ៩៣

មេរៀនទី១៥ ការផលិតសម្ភារបង្រៀន និងរៀននៅមូលដ្ឋាន ........ ១១៦

មេរៀនទី១៦ ការកំណត់ និងការផ្តល់ការគាំទ្រចាំបាច់បន្ថែម ........ ១១៨

មេរៀនទី១៧ វិន័យវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ........ ១៤៥

មេរៀនទី១៨ ការវាយតម្លៃដោយសមធម៌ ........ ១៥០

**ផ្នែកទី៣ ការក្លាយខ្លួនជាគ្រូបង្រៀនសកម្ម** ........ ១៥៦

មេរៀនទី១៩ ការរៀនបែបសកម្ម ........ ១៥៧

**សេចក្តីសន្និដ្ឋាន** ........ ១៦៦

**សេចក្តីថ្លែងអំណរគុណ** ........ ១៦៨

**ឯកសារយោង** ........ ១៧០

# បុព្វកថា

ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពត្រង់ចំណុចទី៤ "ការអប់រំបរិយាបន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា" ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំយកចិត្តទុកដាក់លើកកម្ពស់គុណភាពអប់រំ ជាពិសេសបង្កើនអត្រាឡើងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សា ផ្តោតសំខាន់លើការអនុវត្តសិទ្ធិកុមារជាមូលដ្ឋាន ដែលធានាសមធម៌នៃការចូលរៀនរបស់កុមារគ្រប់ប្រភេទ។

ក្រោមកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំ និងចងក្រងឯកសារសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនស្តីពីការអប់រំបរិយាបន្ន ដើម្បីលើកកម្ពស់គុណភាពការបណ្តុះបណ្តាលគ្រូបង្រៀន។ ឯកសារនេះបង្កើតឡើងក្នុងគោលបំណងបណ្តុះបណ្តាល និងរំព្រឹតការលោកគ្រូ អ្នកគ្រូឱ្យយល់ដឹងពីខ្លឹមសារ វិធីបង្រៀន និងសារៈប្រយោជន៍នៃកម្មវិធីសិក្សាអប់រំបរិយាបន្ន ដើម្បីរួមចំណែកលើកកម្ពស់គុណភាពបង្រៀន និងរៀន នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងនៅតាមសាលារៀនឱ្យកាន់តែប្រសើរឡើង។

ដើម្បីធានាឱ្យការប្រើប្រាស់ឯកសារនេះមានប្រសិទ្ធភាពខ្ពស់លោកគ្រូអ្នកគ្រូគប្បី៖

១ យកចិត្តទុកដាក់សិក្សាស្វែងយល់កម្មវិធី ខ្លឹមសារ វិធីបង្រៀនការអប់រំបរិយាបន្ន ឱ្យបានច្បាស់ ដើម្បីជាជំនួយក្នុងការរៀបចំផែនការបង្រៀន និងរៀនឱ្យទទួលបានលទ្ធផលខ្ពស់។

២ យកចិត្តទុកដាក់ចូលរួមអនុវត្តឱ្យអស់លទ្ធភាព ដោយភាពទន់ភ្លន់សមស្របតាមពេលវេលា និងមជ្ឈដ្ឋានជាក់ស្តែង។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាឯកសារនេះជាទុនក្នុងការសិក្សាស្រាវជ្រាវ ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការគ្រូសារថ្មី អង្គការយូនីសេហ្វ ដៃគូអភិវឌ្ឍនានា និងក្រុមការងារដែលបានយកអស់កម្លាំងកាយ ចិត្ត និងបញ្ញាស្មារតីក្នុងការរៀបចំ និងចងក្រងឯកសារការអប់រំបរិយាបន្នកាន់តែប្រសើរឡើង។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កក្កដា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ឯកសារសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនស្តីពីការអប់រំបរិយាបន្នត្រូវបានរៀបចំ និងចងក្រងឡើងដោយក្រុមការងាររបស់ក្រសួងអប់រំ យុវជន និងកីឡារួមមាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នាយកដ្ឋានអប់រំពិសេស និងអង្គការគ្រួសារថ្មី។

ឯកសារសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនស្តីពីការអប់រំបរិយាបន្នមាន៣ផ្នែកគឺ៖

ផ្នែកទី១ ការយល់ដឹងពីការអប់រំបរិយាបន្នមាន៦មេរៀន

ផ្នែកទី២ ការយល់ដឹងពីវិធីបង្រៀនការអប់រំបរិយាបន្នមាន៩មេរៀន

ផ្នែកទី៣ ការក្លាយខ្លួនជាគ្រូបង្រៀនសកម្មមាន១មេរៀន។

មេរៀននីមួយៗមាន៖

- រយៈពេលបង្រៀន
- វត្ថុបំណង
- សកម្មភាព
- សម្ភារបង្រៀន និងរៀន
- ការណែនាំសម្រាប់សកម្មភាពបង្រៀន។

ឯកសារនេះរៀបចំ និងចងក្រងឡើងក្នុងគោលបំណងបណ្តុះបណ្តាលគ្រូបង្រៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងនៅតាមសាលារៀនឱ្យបានយល់ដឹងពីកម្មវិធី ខ្លឹមសារ វិធីបង្រៀន និងសារៈសំខាន់នៃការអប់រំបរិយាបន្នដើម្បីលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែមានគុណភាពខ្ពស់ និងប្រសិទ្ធភាព។

ឯកសារនេះគឺជាទុនដ៏សំខាន់និងមានសារៈប្រយោជន៍ចំពោះលោកគ្រូ អ្នកគ្រូយកទៅអនុវត្តជាក់ស្តែងក្នុងការបង្រៀន និងរៀន។

ក្រុមការងារយើងខ្ញុំ រង់ចាំទទួលយោបល់ជួយកែលម្អក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូទាំងអស់ដោយក្តីសោមនស្សរីករាយ។

**ក្រុមការងាររៀបចំ និងចងក្រងឯកសារ**

# គណៈកម្មការរៀបចំ និងចងក្រងឯកសារ

## គណៈកម្មការគ្រប់គ្រង

| | |
|---|---|
| ១. ឯកឧត្តមបណ្ឌិត ណាត ប៊ុនរឿន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ២. លោក ង៉ោ ប៉េងឡុង | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៣. លោក ថោង រិទ្ធី | ប្រធាននាយកដ្ឋានអប់រំពិសេស |
| ៤. លោក ម៉ៅ សំរិទ្ធី | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៥. លោក អួន អូរ៉េ | អគ្គនាយកអង្គការគ្រួសារថ្មី |
| ៦. លោក ជុំ ចាន់រ៉ា | មន្ត្រីអប់រំអង្គការយូនីសេហ្វ |
| ៧. លោកស្រី វ៉ាឆែល ម៉ាក់ខាធី | មន្ត្រីអប់រំអង្គការយូនីសេហ្វ |
| ៨. លោកស្រី ស្ទីណា ហោកគីឡា | មន្ត្រីអប់រំអង្គការយូនីសេហ្វ |

## គណៈកម្មការបច្ចេកទេស

| | |
|---|---|
| ១. លោកស្រី គីរ៉ាន ដាតានី ភីត | ទីប្រឹក្សាបច្ចេកទេស |
| ២. លោកស្រី សាន់ ឌ្រីន ចាក់ខូតបូហាន | ទីប្រឹក្សាបច្ចេកទេស |
| ៣. លោកស្រី ប៉ែន ថាវី | អនុប្រធាននាយកដ្ឋានអប់រំពិសេស |
| ៤. លោក មួង ចាន់ទូច | ប្រធានការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៥. លោក សំ សុវណ្ណតារា | ប្រធានការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៦. លោក ភាង ប៊ុនណៃ | ប្រធានការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៧. លោក ទឹម សាហែន | ប្រធានការិយាល័យ នាយកដ្ឋានអប់រំពិសេស |
| ៨. លោក ធាន វាសនា | អនុប្រធានការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៩. លោកស្រី ផន សុភា | អនុប្រធានការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ១០. លោកស្រី សៀក សុខនី | អនុប្រធានការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ១១. លោក យិត សុភ័ក្រ្ត | អនុប្រធានការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ១២. លោក លាង ស៊ុនហ៊ាង | អនុប្រធានការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ១៣. លោក អៀត វុទ្ធី | អនុប្រធានការិយាល័យ នាយកដ្ឋានអប់រំពិសេស |
| ១៤. លោក ប៉ែន ចាន់កាណាប់ | អនុប្រធានការិយាល័យ នាយកដ្ឋានអប់រំពិសេស |
| ១៥. លោក ងិន វិត | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ១៦. លោក ឈុន រិទ្ធី | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ១៧. លោកស្រី ណៃត ពេជ្រចិន្តា | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ១៨. លោកស្រី តាន់ លីហួង | ជំនួយការបច្ចេកទេសនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ១៩. លោក ជា ផុន | ជំនួយការបច្ចេកទេសនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |

២០. លោកស្រី នៅ សុភួង	គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការខេត្តតាកែវ
២១. លោក ឡៅ វុត្ថា	គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការខេត្តតាកែវ
២២. លោក ទ្រី រតនា	គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពត
២៣. លោកស្រី វ៉ែន ផាតថា	គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញ
២៤. លោកស្រី សៅ ដួងច័ន្ទភិរក្ស	គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ចាម
២៥. លោកស្រី នាង ផល្លា	ប្រធានសម្របសម្រួលកម្មវិធីអប់រំកុមារពិការភ្នែកអង្គការគ្រួសារថ្មី
២៦. លោក ហង់ គឹមឈាន់	អ្នកសម្របសម្រួលកម្មវិធីអប់រំកុមារគថ្លង់អង្គការគ្រួសារថ្មី
២៧. លោកស្រី គង់ កន្និថា	អ្នកសម្របសម្រួលអភិវឌ្ឍកម្មវិធីសិក្សាអង្គការគ្រួសារថ្មី
២៨. លោក វន វី	អនុប្រធានអ្នកសម្របសម្រួលកម្មវិធីអប់រំកុមារពិការភ្នែកអង្គការគ្រួសារថ្មី
២៩. លោក ស៊ឹង ចន្ទី	គ្រូបង្គោលផ្នែកគថ្លង់អង្គការគ្រួសារថ្មី

**គណៈកម្មការបច្ចេកទេសកុំព្យូទ័រ**

១. លោក ជួន ចាន់ពិសិដ្ឋ	មន្ត្រីនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ
២. លោក អ៊ុក ដារ៉ា	មន្ត្រីនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ
៣. លោក លឹម សេង	មន្ត្រីនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ
៤. លោក ជាប សារិន	មន្ត្រីនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ
៥. លោក ជិន លី	មន្ត្រីផ្នែកទំនាក់ទំនងអង្គការគ្រួសារថ្មី។

**អ្នកនិពន្ធ**:

Kiran Dattani Pitt – karma.pitt@gmail.com

Sandrine Bahan-Jacquot-bohan.jacquot@gmail.com

# អក្សរកាត់

| | |
|---|---|
| AAR Japan | **អង្គការជំនួយ និងសង្គ្រោះជប៉ុន (Association of Aid and Relief Japan)** |
| CAST | មជ្ឈមណ្ឌលបច្ចេកវិទ្យាអនុវត្តពិសេស (Center for Applied Special Technology) |
| CBM | Christian Blind Mission (ឥឡូវពួកគេប្រើប្រាស់អក្សរកាត់ ពីព្រោះពួកគេផ្តល់សេវាដល់ជនពិការទាំងអស់ មិនសម្រាប់តែជនពិការភ្នែកនោះទេ) |
| CCAMH | មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងមនុស្សពេញវ័យ |
| CCOSC | កម្មវិធីដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា |
| COCD | អង្គការកម្ពុជាសម្រាប់កុមារ និងការអភិវឌ្ឍ |
| DAC | ក្រុមប្រឹក្សាសកម្មភាពពិការភាព |
| DDSP | កម្មវិធីសេវាកម្មអភិវឌ្ឍន៍ជនពិការ |
| DPO | អង្គការជនពិការ |
| EENET | បណ្តាញបង្កើតការអប់រំ (Enabling Education Network) |
| EFA | ការអប់រំសម្រាប់ទាំងអស់គ្នា |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំ |
| GCE | យុទ្ធនាការសកលសម្រាប់ការអប់រំ |
| IE | ការអប់រំបរិយាបន្ន |
| IEP | ផែនការអប់រំសិស្សម្នាក់ៗ |
| INGO | អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ |
| KPF | មូលនិធិកុមារពិការ |
| KT | អង្គការគ្រួសារថ្មី |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| NEP | ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| PECS | ប្រព័ន្ធប្រាស្រ័យទាក់ទងផ្លាស់ប្តូររូបភាព |
| PST | គរុសិស្ស |
| PTTC | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត |
| RSO | អង្គការសាលារៀនទន្សាយ |
| SaLT | អ្នកព្យាបាលដោយនិយាយ និងភាសា |
| SDG | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |
| StC | អង្គការ Save the Children |
| TLM | សម្ភារបង្រៀន និងរៀន |

| | |
|---|---|
| TOT | គ្រូឧទ្ទេស |
| TTD | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| UDL | ប្លង់សកលសម្រាប់ការរៀន |
| UNCRPD | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ |
| UNICEF | មូលនិធិកុមារអង្គការសហប្រជាជាតិ |
| UNESCO | អង្គការសហប្រជាជាតិ ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| WHO | អង្គការសុខភាពពិភពលោក |

# សេចក្តីផ្តើម

វិធីបង្រៀនការអប់រំបរិយាបន្នជាច្រើន ដែលផ្តោតលើកុមារពិការត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ ២០០៣ ដោយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល (NGOs) ដែលធ្វើការក្នុងវិស័យអប់រំ។ កម្មវិធីអប់រំបរិយាបន្នដែលបានបង្កើតកន្លងមកគឺសម្រាប់តែរយៈពេល២៨ម៉ោងតែប៉ុណ្ណោះ ហេតុនេះវាគ្របដណ្តប់តែមួយផ្នែកនៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនទាំងមូល។ សម្ភារ និងធនធាននៅក្នុងឯកសារស្តីពីការអប់រំបរិយាបន្ននេះមានប្រយោជន៍សម្រាប់គ្រូឧទ្ទេស (TOTs) ដូច្នេះហើយ គោលបំណងចម្បងនៃឯកសារអប់រំបរិយាបន្នគឺពុំមែនធ្វើការចម្លងកម្មវិធីអប់រំដែលមានស្រាប់នោះទេ ប៉ុន្តែធ្វើការបូកបញ្ចូលសម្ភារមានស្រាប់ដែលមានប្រយោជន៍។ ជាលទ្ធផល យើងបានឯកសារអប់រំបរិយាបន្នមួយដែលគ្រូបង្រៀននឹងយល់ដឹងពីរបៀបដែលពួកគេអាចដាក់បញ្ចូលកុមារទាំងអស់នៅក្នុងថ្នាក់រៀនរបស់ពួកគេ។

អ្វីដែលជាតម្លៃបន្ថែមនៃឯកសារដែលត្រូវបានរៀបចំឡើងវិញនេះ គឺដើម្បីបូកបញ្ចូលអ្វីដែល Kaplan និង Lewis[1] និយាយយ៉ាងច្បាស់ថា *"ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន ជាពិសេសកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបណ្តុះចរិយាសម្បទា ចំណេះសម្បទា និងសមត្ថភាពគ្រូបង្រៀន និងមានឥទ្ធិពលលើការបង្រៀននាពេលបន្ទាប់។ ប្រសិនបើយើងចង់លើកកម្ពស់ការអប់រំបរិយាបន្ននោះសារៈសំខាន់ស្ថិតនៅត្រង់ថា គ្រូបង្រៀនកំពុងសិក្សាពីគោលវិធីអប់រំបរិយាបន្នមានបទពិសោធ និងប្រតិបត្តិគោលវិធីនោះក្នុងការរៀន និងបង្រៀនតាំងពីថ្ងៃចូលរៀនដំបូងនៃការអភិវឌ្ឍវិជ្ជាជីវៈរបស់គេ"*។

ដូច្នេះ ការផ្តោតសំខាន់នៃឯកសារនេះគឺបង្ហាញពីវិធីបង្រៀនការអប់រំបរិយាបន្នតាមបែបចូលរួមធ្វើសកម្មភាពច្រើនជាងការសិក្សាតែទ្រឹស្តី។

គោលបំណងនៃឯកសារការអប់រំបរិយាបន្ននេះគឺដើម្បី៖

- ផ្តល់ព័ត៌មានទូលំទូលាយ និងចំណេះដឹងដល់គ្រូឧទ្ទេសពីការអនុវត្តការអប់រំបរិយាបន្ននៅជុំវិញពិភពលោក ដែលអាចអនុវត្តនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។
- ណែនាំគ្រូឧទ្ទេស តាមរយៈសម្ភារនិងធនធានរៀន បង្រៀនច្រើនយ៉ាង ដើម្បីឱ្យពួកគេអាចជ្រើសរើសសម្រាប់បណ្តុះបណ្តាលគរុសិស្ស ។
- ផ្តល់វិធីបង្រៀន ឬគរុកោសល្យផ្សេងៗ ដែលគ្រូឧទ្ទេសអាចប្រើប្រាស់ដើម្បីអភិវឌ្ឍសមត្ថភាពនៅក្នុងការអប់រំបរិយាបន្នសម្រាប់គរុសិស្ស។
- ផ្តល់ព័ត៌មានដល់គ្រូឧទ្ទេស ពីរបៀបដែលពួកគេអាចប្រើប្រាស់អប់រំបរិយាបន្ន ដើម្បីផ្តល់ប្រយោជន៍ដល់គរុសិស្សទាំងអស់នៅក្នុងថ្នាក់រៀន។
- បង្ហាញដល់គរុសិស្សពីរបៀបដែលពួកគេអាចអនុវត្តវិធីរៀន និងបង្រៀនសកម្មនៅក្នុងថ្នាក់រៀន។

[1] គោលការណ៍ណែនាំតស៊ូមតិទី៣ស្តីពីកម្មវិធីសិក្សា ក្នុងការលើកកម្ពស់ការអប់រំគ្រូបង្រៀនបរិយាបន្ន ទំព័រ១-២

ឯកសារនេះត្រូវបានបែងចែកជា៣ផ្នែកគឺៈ ការយល់ដឹងពីការអប់រំបរិយាបន្ន ការយល់ដឹងពីវិធីបង្រៀនការអប់រំបរិយាបន្ន និងការក្លាយខ្លួនជាគ្រូបង្រៀនសកម្ម។ តារាងខ្លឹមសារលម្អិតមានដូចខាងក្រោមៈ

| មេរៀន | | | សកម្មភាព | វិធី | រយៈពេល |
|---|---|---|---|---|---|
| **ផ្នែកទី១ ការយល់ដឹងពីការអប់រំបរិយាបន្ន** | | | | | |
| មេរៀនទី១ | ការស្វែងយល់ពីការអប់រំបរិយាបន្ន | ១.១ | ការស្វែងយល់បញ្ញត្តិនៃការអប់រំបរិយាបន្ន | បញ្ចាំងវីដេអូ និងពិភាក្សាក្រុម | ៤៥នាទី |
| | | ១.២ | ការអប់រំបរិយាបន្ននៅក្នុងការអនុវត្តជាក់ស្តែង | សិក្សាលើករណីសិក្សា | ៤៥នាទី |
| | | ១.៣ | ការយល់ដឹងពីរបៀបដែលឥរិយាបថរបស់យើងបណ្តាលឱ្យមានបរិយាបន្ន ឬការផាត់ចេញ | ពិភាក្សាក្រុម | ៣០នាទី |
| មេរៀនទី២ | ការកំណត់រកកុមារដែលមានហានិភ័យដោយការផាត់ចេញ | ២.១ | ការកំណត់រកកុមារដែលមានហានិភ័យដោយការផាត់ចេញ | ស្វែងរកប័ណ្ណកុមារបោះបង់ចោលការសិក្សា និងពិភាក្សាក្រុម | ៣០នាទី |
| មេរៀនទី៣ | ការផ្តោតលើកុមារពិការ | ៣.១ | ការស្វែងយល់ពីនិយមន័យពិការភាព និងផលប៉ះពាល់ | ពិភាក្សាក្រុម | ៣០នាទី |
| | | ៣.២ | ការពិចារណាឥរិយាបថចំពោះជនពិការនៅក្នុងបរិបទកម្ពុជា | បញ្ចាំងវីដេអូ និងពិភាក្សាក្រុម | ៤៥នាទី |
| | | ៣.៣ | គំរូនៃប្រភេទពិការភាពផ្សេងៗ | អាន និងពិភាក្សាក្រុម | ៣០នាទី |
| | | ៣.៤ | ស្នាដៃរបស់ជនពិការ | បញ្ចាំងវីដេអូ៤ខ្សែ | ៣០នាទី |
| មេរៀនទី៤ | ការប្រើប្រាស់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ (holistic approach) | ៤.១ | ការស្វែងយល់ពីធាតុផ្សំនៃវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ | ពិភាក្សាក្រុម | ៣០នាទី |
| | | ៤.២ | ការចូលរួម និងផ្តល់សិទ្ធិអំណាចដល់សហគមន៍ | សិក្សាលើករណីសិក្សា | ៤៥នាទី |
| មេរៀនទី៥ | បរិយាកាសសាលារៀនបរិយាបន្ន | ៥.១ | ការកែលម្អសាលារៀនទាំងមូលឆ្ពោះទៅរកការអប់រំបរិយាបន្ន | អានគំរូ និងពិភាក្សាក្រុម បំពេញបញ្ជីត្រួត | ៣០នាទី |
| | | ៥.២ | ការវាយតម្លៃសាលារៀនដែលឮមានលក្ខណៈបរិយាបន្ន | ពិនិត្យ និងសង្កេតរូបភាព | ៤៥នាទី |
| មេរៀនទី៦ | ការសយល់ដឹងពីវិធីសាស្ត្រពីររួមគ្នា (twin track Approach) | ៦.១ | ការយល់ដឹងពីវិធីសាស្ត្រពីររួមគ្នា (twin track approach) | អាន ពិភាក្សា និងសិក្សាលើករណីសិក្សា | ៤៥នាទី |
| **ផ្នែកទី២ ការយល់ដឹងពីវិធីបង្រៀនការអប់រំបរិយាបន្ន** | | | | | |
| មេរៀនទី៧ | ការបង្ហាញវិធីបង្រៀនការអប់រំបរិយាបន្ន | ៧.១ | លក្ខណៈសម្បត្តិគ្រូបង្រៀនបរិយាបន្ន | លេងល្បែងប័ណ្ណ | ៣០នាទី |
| | | ៧.២ | ការបំពេញតម្រូវការផ្សេងៗរបស់កុមារ | បញ្ចាំងវីដេអូ និងសួរសំណួរ | ៣០នាទី |
| មេរៀនទី៨ | ការស្វែងយល់ពីពហុបញ្ញា និងរបៀបរៀន | ៨.១ | ការស្វែងយល់បញ្ញត្តិនៃពហុបញ្ញា | អាន និងផ្គូរផ្គង | ៤៥នាទី |
| | | ៨.២ | ការទាញយកប្រយោជន៍ពីរបៀបរៀនខុសៗគ្នា | លេងល្បែងប៊ីងហ្គោ | ៣០នាទី |

| មេរៀន | | សកម្មភាព | | វិធី | រយៈពេល |
|---|---|---|---|---|---|
| មេរៀនទី៩ | ការកំណត់ឧបសគ្គចំពោះការសិក្សា | ៩.១ | ការកំណត់ឧបសគ្គចំពោះការសិក្សា | ពន្យល់ដ្យាក្រាមសារគន្លឹះ ពិភាក្សាលើករណីសិក្សា និងបញ្ចាំងវីដេអូ | ៤៥នាទី |
| មេរៀនទី១០ | ការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិត | ១០.១ | ការកំណត់និយមន័យនៃការលេង | បញ្ចាំងវីដេអូ និងសួរសំណួរ | ២០នាទី |
| | | ១០.២ | ការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិតក្នុងការអនុវត្តកម្មវិធីសិក្សា | បញ្ចាំងវីដេអូ និងបង្ហាញផែនការមេរៀន | ៤៥នាទី |
| មេរៀនទី១១ | ការដាក់បញ្ចូលកុមារទាំងអស់ទៅក្នុងការរៀន | ១១.១ | ការឆ្លើយតបទៅនឹងភាពចម្រុះនៅក្នុងថ្នាក់រៀន | បញ្ចាំងវីដេអូ និងពិភាក្សាក្រុម | ៤៥នាទី |
| មេរៀនទី១២ | ការអនុវត្តការជួយជ្រោមជ្រែង និង ការសម្របសម្រួលតាមភាពផ្សេងៗគ្នារបស់សិស្ស | ១២.១ | ការប្រើប្រាស់ការជួយជ្រោមជ្រែង | បញ្ចាំងវីដេអូ និងសួរសំណួរពិភាក្សា | ៣០នាទី |
| | | ១២.២ | ការសម្របសម្រួលតាមភាពផ្សេងៗគ្នារបស់សិស្សនៅក្នុងថ្នាក់រៀន | បញ្ចាំងវីដេអូ និងបំពេញតារាងត្រួត ពិនិត្យ បញ្ចាំងឌីវីឌី | ៣០នាទី |
| | | ១២.៣ | ការរៀបចំកិច្ចតែងការ ដោយមានការជួយជ្រោមជ្រែង និងសម្របសម្រួលតាមភាពផ្សេងៗគ្នារបស់សិស្ស | និងធ្វើកិច្ចតែងការ | ៩០នាទី |
| មេរៀនទី១៣ | ការអភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងល្អ | ១៣.១ | ការយល់ដឹងពីជំនាញចាំបាច់ដើម្បីប្រាស្រ័យទាក់ទង | អានសារ និងសួរសំណួរ | ៣០នាទី |
| | | ១៣.២ | ការកំណត់ការពិបាកក្នុងការប្រាស្រ័យទាក់ទង | បង្ហាញពីរ៉ាមីតសួរសំណួរ និងបញ្ចាំងវីដេអូរួចសួរសំណួរ | ៤៥នាទី |
| | | ១៣.៣ | ការបំពេញតម្រូវការគាំទ្រការប្រាស្រ័យទាក់ទង | បង្ហាញរូបភាព វីដេអូ សួរសំណួរ | ៦០នាទី |
| មេរៀនទី១៤ | ការប្រើប្រាស់វិធីបង្រៀន និងរៀនសកម្ម | ១៤.១ | ការកំណត់វិធីបង្រៀន និងរៀនសកម្ម និងអកម្ម | បង្ហាញដ្យាក្រាមនិងបំពេញតារាងត្រួតពិនិត្យ | ៣០នាទី |
| | | ១៤.២ | ការប្រើប្រាស់វិធីរៀនបែបសហការប្រកបដោយប្រសិទ្ធភាព | បញ្ចាំងវីដេអូ និងបំពេញតារាង | ៤៥នាទី |
| មេរៀនទី១៥ | ការផលិតសម្ភារបង្រៀន និង រៀននៅក្នុងមូលដ្ឋាន | ១៥.១ | ការផលិតសម្ភារបង្រៀន និងរៀននៅក្នុងមូលដ្ឋាន | បញ្ចាំងវីដេអូ សួរសំណួរ | ២០នាទី |
| | | ១៥.២ | ការផលិតសម្ភារបង្រៀននិងរៀនដោយខ្លួនឯង | បញ្ចាំងវីដេអូ សួរសំណួរ | ៤៥នាទី |
| មេរៀនទី១៦ | ការកំណត់ និងផ្តល់ការគាំទ្រចាំបាច់បន្ថែម | ១៦.១ | ការកំណត់ និងផ្តល់ការគាំទ្រចាំបាច់បន្ថែម | អាន និងសួរសំណួរ | ៣០នាទី |
| | | ១៦.២ | ការយល់ដឹងពីពិការភាពផ្សេងៗ | អាន និងសួរសំណួរលើករណីសិក្សា | ៤៥នាទី |
| | | ១៦.៣ | ការកំណត់ឈ្មោះឧបករណ៍ជំនួយ | បង្ហាញរូបភាព សួរសំណួរ | ៣០នាទី |

| មេរៀន | | សកម្មភាព | វិធី | រយៈពេល |
|---|---|---|---|---|
| | | ១៦.៤ ពង្រីកការយល់ដឹងរបស់អ្នកពីការបង្រៀនកុមារពិការ | បញ្ចាំងវីដេអូ អាន និង ពិភាក្សាក្រុម | ៩០នាទី |
| | | ១៦.៥ ការរៀបផែនការដើម្បីបំពេញសេចក្តីត្រូវការរបស់សិស្សម្នាក់ៗ | អានករណីសិក្សា និងពិភាក្សាក្រុម | ៩០នាទី |
| មេរៀនទី១៧ | វិន័យវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព | ១៧.១ ការបង្កើនការយល់ដឹងពីទណ្ឌកម្មលើរាងកាយ | អាននិយមន័យ | ២០នាទី |
| | | ១៧.២ ការយល់ដឹងពីភាពខុសគ្នារវាងទណ្ឌកម្ម និងវិន័យ | សិក្សាលើករណីសិក្សា | ៤៥នាទី |
| មេរៀនទី១៨ | ការវាយតម្លៃដោយសមធម៌ | ១៨.១ ការពន្យល់ពីការវាយតម្លៃដោយសមធម៌ | បង្ហាញរូបត្លុកសួរសំណួរ និងសិក្សា ករណីសិក្សា | ៣០នាទី |
| | | ១៨.២ ការផ្តល់ដំណោះស្រាយសមស្រប | ពិភាក្សាក្រុម | ៤៥នាទី |
| **ផ្នែកទី៣ ការក្លាយខ្លួនជាគ្រូបង្រៀនសកម្ម** | | | | |
| មេរៀនទី១៩ | ការរៀនបែបសកម្ម | ១៩.១ ការពន្យល់ការរៀនជានិរន្តរ | បង្ហាញដ្យាក្រាមពិភាក្សា | ៣០នាទី |
| | | ១៩.២ ការស្វែងរកដំណោះស្រាយខ្លួនឯង | ពិភាក្សាក្រុម | ៤៥នាទី |

**សេចក្តីសន្និដ្ឋាន**

# ផ្នែកទី១
# ការយល់ដឹងពីការអប់រំបរិយាបន្ន

# សេចក្តីផ្តើម

ផ្នែកទី១មាន៦មេរៀនដែលនិយាយលម្អិតអំពី តើ" ការអប់រំបរិយាបន្ន "មានន័យយ៉ាងដូចម្តេច? និងតើយុទ្ធសាស្ត្រអ្វីដែលអាចធ្វើបាននៅកម្រិតថ្នាក់ជាតិ កម្រិតស្រុក និងសហគមន៍? និងតើអ្វីដែលគ្រូបង្រៀនអាចធ្វើបានដើម្បីឱ្យមានលក្ខណៈអប់រំបរិយាបន្ននៅក្នុងថ្នាក់រៀន?

នៅក្នុងមេរៀនទី១ សកម្មភាពទីមួយត្រូវបានរៀបចំឡើងដើម្បីឱ្យគរុសិស្សគិត និងឆ្លុះបញ្ចាំងលើអត្ថន័យ និងគោលគំនិតរួមនៃការអប់រំបរិយាបន្ន ដែលកន្លងមកយល់ថា ការអប់រំបរិយាបន្នគឺផ្តោតតែទៅលើកុមារពិការ។ សកម្មភាពទីពីរមានករណីសិក្សានៃសាលារៀនពីរ ដែលបង្ហាញពីរបៀបការអប់រំបរិយាបន្នអាចត្រូវអនុវត្ត និងធាតុផ្សំចាំបាច់សម្រាប់សាលារៀនមួយមានលក្ខណៈអប់រំបរិយាបន្ន។ សកម្មភាពទី៣បង្ហាញពី តើឥរិយាបថដែលមានឥទ្ធិពលទៅលើកុមារណាម្នាក់ដែលត្រូវបានដាក់បញ្ចូល ឬត្រូវបានផាត់ចេញពីការអប់រំយ៉ាងដូចម្តេច? ប្រសិនបើឥរិយាបថរបស់យើងបង្ហាញថាកុមារគឺជាបញ្ហា នោះនឹងមិនមានអ្វីត្រូវបានធ្វើឡើង ដើម្បីផ្លាស់ប្តូរនោះទេ។ ប៉ុន្តែប្រសិនបើយើងមើលឃើញថាប្រព័ន្ធអប់រំគឺជាបញ្ហាការផ្លាស់ប្តូរអាចធ្វើបាន ដើម្បីឱ្យកុមារទាំងអស់អាចទទួលបានការអប់រំ។

សកម្មភាពនៅក្នុងមេរៀនទី២អាចឱ្យគរុសិស្សស្វែងយល់ថាតើកុមារមួយណាត្រូវបានផាត់ចេញពីការអប់រំនៅក្នុងសហគមន៍របស់ពួកគេ និងតើអ្វីអាចធ្វើបាននៅកម្រិតមូលដ្ឋាន ដើម្បីផ្លាស់ប្តូរស្ថានភាពពីមុន?

មេរៀនទី៣ផ្តោតលើកុមារពិការ ពីព្រោះក្រុមកុមារនេះគឺជាក្រុមងាយរងគ្រោះជាងគេនៅក្នុងការទទួលបានការអប់រំ។ បញ្ហា និងគំនិតដែលមាននៅក្នុងមេរៀននេះបង្ហាញថា តើឥរិយាបថរបស់យើង និងសង្គមមានឥទ្ធិពលដូចម្តេចទៅលើជីវិតជនពិការ? មេរៀននេះមានសកម្មភាពមួយពីគំរូនៃប្រភេទពិការ និងការទទួលស្គាល់គំរូនៃប្រភេទពិការ សិទ្ធិមនុស្សដែលមានលក្ខណៈប្រសើរជាងគំរូនៅក្នុងសង្គម។ ចុងបញ្ចប់មេរៀននេះមានវីដេអូ និងរូបភាពនៃស្នាដៃរបស់ជនពិការនៅក្នុងប្រទេសកម្ពុជា។

មេរៀនទី៤បង្ហាញពីគោលគំនិតនៃការប្រើប្រាស់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ (holistic approach) នៅក្នុងការអនុវត្តការអប់រំបរិយាបន្នដែលបង្ហាញថា ដើម្បីសម្រេចបានការអប់រំបរិយាបន្នពិតប្រាកដ នោះកំណែទម្រង់រចនាសម្ព័ន្ធ ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការផ្តល់សិទ្ធិអំណាចដល់សហគមន៍ត្រូវតែដើរទន្ទឹមគ្នា។ វាក៏បង្ហាញផងដែរថា ការអប់រំបរិយាបន្នគឺជាការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនៅក្នុងផ្នែកទាំងបីនេះមិនមែនជាការទទួលខុសត្រូវរបស់គ្រូបង្រៀនតែឯងនោះទេ។

មេរៀនទី៥សកម្មភាពចំនួនពីរផ្តោតលើធាតុផ្សំសំខាន់ៗនៃការធ្វើឱ្យសាលារៀនប្រសើរឡើង ក៏ដូចជារបៀបដែលបរិយាកាសសាលារៀនអាចត្រូវបានផ្លាស់ប្តូរ ដើម្បីអាចឱ្យកុមារពិការទទួលបានការអប់រំ។

មេរៀនទី៦បង្ហាញពីវិធីសាស្ត្រពីររួមគ្នា( Twin track approach) ដែលក្នុងនោះក៏បានបង្ហាញពីការបញ្ជ្រាបការអប់រំសម្រាប់កុមារងាយរងគ្រោះទាំងអស់ និងការផ្តល់សិទ្ធិអំណាចដល់កុមារម្នាក់ៗ។

# មេរៀនទី១ ការស្វែងយល់ពីការអប់រំបរិយាបន្ន





© Michael Pitt

## ឯកសារជំនួយសម្រាប់ផ្នែកទី១៖

- ឯកសារអប់រំបញ្ចូលគ្នារបស់ក្រសួងអប់រំ យុវជន និងកីឡា(២០១២) មេរៀនស្តីពីការអប់រំបរិយាបន្ន សូចនាករសម្រាប់ការអប់រំបរិយាបន្នប្រកបដោយគុណភាព និងការយល់ដឹងពីពិការភាព។
- ទទួលយកភាពចម្រុះ៖ ឧបករណ៍សម្រាប់ការបង្កើតបរិយាកាសអ្នកសិក្សាមេត្រី សម្រាប់ការអប់រំបរិយាបន្នដោយ UNESCO (២០១៥)[2]
- ការអប់រំបរិយាបន្ន៖ ករណីដែលមានធនធានតិចតួចដោយ Sue Stubbs (២០០៨)[3]
- ប្រែក្លាយសាលារៀនឱ្យមានលក្ខណៈអប់រំបរិយាបន្ន ដោយអង្គការ Save the Children ចក្រភពអង់គ្លេស (២០០៨)[4]
- សំឡេងកុមារ៖ ទស្សនៈកុមារលើការអប់រំបរិយាបន្ន ដោយ The Altas Alliance (២០០៨)
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (២០០៨)

[2] UNESCO (២០១៥ ធនធានអនឡាញ) *ទទួលយកភាពចម្រុះ៖ បង្កើតបរិយាកាសអ្នកសិក្សាមេត្រី* UNESCO បាងកក

[3] Stubbs, S. (២០០៨) *ការអប់រំបរិយាបន្ន ករណីដែលមានធនធានតិចតួច* The Atlas Alliance អូស្លូ ប្រទេសណ័រវេ

[4] Save the Children (២០០៨) *បង្កើតសាលារៀនបរិយាបន្ន* Save the Children ទីក្រុងឡុង ចក្រភពអង់គ្លេស

### សកម្មភាព ១.១ ស្វែងយល់បញ្ញត្តិនៃការអប់រំបរិយាបន្ន

### រយៈពេល៖ ៤៥នាទី

### វត្ថុបំណង៖

- ពន្យល់បានពីបញ្ញត្តិនៃការអប់រំបរិយាបន្ន
- កំណត់បានពីអត្ថប្រយោជន៍នៃការអប់រំបរិយាបន្ន។

### សម្ភារបង្រៀន និងរៀន ៖

- វីដេអូ១ខ្សែ ឈ្មោះថា "សេចក្ដីផ្ដើមនៃការអប់រំបរិយាបន្ន"
- វីដេអូ២ខ្សែ របស់អង្គការ EENET ឈ្មោះ "សំឡេងកុមារ"
- វីដេអូ១ខ្សែ របស់អង្គការ UNESCO ឈ្មោះ "ពិភពលោកសម្រាប់បរិយាបន្ន"
- ក្រដាសផ្ទាំងធំ LCD។

### សកម្មភាពបង្រៀន៖

ក. បែងចែកគរុសិស្សជាក្រុមតូចៗ(ប្រាប់ពួកគេកុំឱ្យអានសៀវភៅសិក្សានៅពេលធ្វើសកម្មភាពនេះ)។

សំណួរ៖ "តើការអប់រំបរិយាបន្នមានន័យយ៉ាងដូចម្ដេចចំពោះអ្នក?"

ខ. តំណាងក្រុមរាយការណ៍លទ្ធផលនៃការពិភាក្សា

គ. គ្រូសំយោគចម្លើយ

ឃ. បញ្ចាំងវីដេអូស្ដីពី *សេចក្ដីផ្ដើមនៃការអប់រំបរិយាបន្ន*។

ង. សំណួរពិភាក្សា៖ តើអ្នកមានការផ្លាស់ប្ដូរទស្សនៈដូចម្ដេច បន្ទាប់ពីបានមើលវីដេអូស្ដីពីការអប់រំបរិយាបន្ន?

ច. ឱ្យគរុសិស្សពិភាក្សាពីអត្ថប្រយោជន៍នៃការអប់រំបរិយាបន្ន ដោយសរសេរទស្សនៈរបស់ពួកគេ បន្ទាប់មកអាននិយមន័យ និងអត្ថប្រយោជន៍នៃការអប់រំបរិយាបន្នក្នុងសៀវភៅសិក្សា។ និយមន័យ និងអត្ថប្រយោជន៍នេះគួររៀបចំត្រៀមទុកមុននៅលើផ្ទាំងក្រដាស ឬនៅផ្ទាំងបញ្ចាំង LCD ។

ឆ. ឱ្យអានផ្នែកស្ដីពីអ្វីជាការអប់រំបរិយាបន្នជាកិច្ចការផ្ទះ។

ឱ្យគរុសិស្សមើលវីដេអូ (បើមានពេល) ឈ្មោះថា សំឡេងកុមារ (២វីដេអូ) និងពិភពលោកនៃបរិយាបន្ន បន្ទាប់ពីចប់សកម្មភាពដើម្បីពង្រីកការយល់ដឹងរបស់ពួកគេពីការអប់រំបរិយាបន្ន។

### និយមន័យនៃការអប់រំបរិយាបន្ន[5]

> អង្គការ UNESCO ឱ្យនិយមន័យការអប់រំបរិយាបន្នគឺជា "វិធីសាស្ត្រសកម្មនៃការឆ្លើយតបដោយវិជ្ជមានទៅកាន់ភាពចម្រុះគ្នានៃសិស្ស និងការមើលឃើញភាពខុសគ្នារបស់សិស្សមិនមែនជាបញ្ហា ប៉ុន្តែជាឱកាសសម្រាប់ធ្វើឱ្យការសិក្សាប្រសើរឡើង"។

[5] UNESCO (២០០៥) *គោលការណ៍ណែនាំសម្រាប់បរិយាបន្ន ការធានាការទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា* UNESCO បារាំង ទំព័រ ១២-១៤

ធាតុផ្សំដែលចាំបាច់នៅក្នុងការកំណត់និយមន័យការអប់រំបរិយាបន្ន៖

| **ការអប់រំបរិយាបន្នគឺជា** | **ការអប់រំបរិយាបន្នមិនមែនជា** |
|---|---|
| ការស្វាគមន៍ភាពចម្រុះ | កំណែទម្រង់ការអប់រំពិសេសតែឯងនោះទេ ប៉ុន្តែជាកំណែទម្រង់ទាំងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ |
| ការផ្តល់អត្ថប្រយោជន៍ដល់សិស្សទាំងអស់ មិនមែនផ្តោតតែលើសិស្សដែលត្រូវបានផាត់ចេញ | ការឆ្លើយតបតែទៅនឹងភាពចម្រុះនោះទេ ប៉ុន្តែក៏ជាការលើកកម្ពស់គុណភាពអប់រំសម្រាប់សិស្សទាំងអស់ |
| ការដាក់បញ្ចូលកុមារដែលមានអារម្មណ៍ថាត្រូវបានផាត់ចេញទៅក្នុងសាលារៀន | សាលារៀនពិសេស ប៉ុន្តែជាការគាំទ្របន្ថែមដល់សិស្សនៅក្នុងប្រព័ន្ធសាលារៀនទូទៅ |
| ការទទួលបានការអប់រំដោយស្មើភាព | ការបំពេញសេចក្តីត្រូវការកុមារពិការប៉ុណ្ណោះនោះទេ |
| ការផ្តល់ឱ្យដោយជាក់លាក់ដល់ក្រុមកុមារដោយមិនផាត់ពួកគេចេញ។ | ការបំពេញសេចក្តីត្រូវការកុមារម្នាក់ដោយប៉ះពាល់ដល់កុមារម្នាក់ទៀតនោះទេ។ |

ជាពិសេសជាងនេះ នៅមានធាតុផ្សំសំខាន់បួនទៀតនៅក្នុងការកំណត់បញ្ញត្តិនៃការអប់រំបរិយាបន្ន។ ធាតុទាំងបួនមានដូចខាងក្រោម៖

- ការអប់រំបរិយាបន្នគឺជាដំណើរការស្វែងរកមិនមានទីបញ្ចប់ ដើម្បីរុករកមធ្យោបាយកាន់តែប្រសើរនៃការឆ្លើយតបទៅនឹងភាពចម្រុះ។ វាគឺជាការរៀនពីរបៀបរស់នៅជាមួយភាពខុសគ្នា និងរៀនពីភាពខុសគ្នា។ ការធ្វើបែបនេះ ភាពខុសគ្នាត្រូវបានមើលឃើញថាជាកត្តាជំរុញកាន់តែវិជ្ជមានសម្រាប់ជំរុញការរៀននៅក្នុងចំណោមកុមារ និងមនុស្សពេញវ័យ។
- ការអប់រំបរិយាបន្នគឺជាការកំណត់អត្តសញ្ញាណ និងការលុបបំបាត់ឧបសគ្គ។ ដូច្នេះ វាទាក់ទងនឹងការប្រមូលរៀបចំ និងវាយតម្លៃព័ត៌មានពីធនធានច្រើនយ៉ាង ដើម្បីរៀបចំផែនការសម្រាប់ការធ្វើឱ្យប្រសើរឡើងលើគោលនយោបាយ និងការអនុវត្ត។ វាគឺជាការប្រើប្រាស់ភស្តុតាងច្រើនប្រភេទដើម្បីជំរុញភាពច្នៃប្រឌិត និងការដោះស្រាយបញ្ហា។
- ការអប់រំបរិយាបន្នទាក់ទងទៅនឹងវត្តមាន ការចូលរួម និងការសម្រេចរបស់សិស្សទាំងអស់។ "វត្តមាន" សំដៅទៅដល់ទីកន្លែងដែលកុមារត្រូវបានអប់រំ និងការមករៀនទៀងទាត់។ "ការចូលរួម" ទាក់ទងទៅនឹងគុណភាពនៃបទពិសោធរបស់សិស្ស ដូច្នេះត្រូវតែរួមបញ្ចូលទស្សនៈរបស់ពួកគេ។ ចំណែក "ការសម្រេច" គឺសំដៅទៅដល់លទ្ធផលនៃការសិក្សានៅក្នុងកម្មវិធីសិក្សាទាំងមូល មិនមែនគ្រាន់តែលទ្ធផលប្រឡងនោះទេ។
- ការអប់រំបរិយាបន្នទាក់ទងទៅនឹងការផ្តោតជាពិសេសលើក្រុមសិស្សដែលងាយរងគ្រោះពីការបាត់បង់ឱកាស ការផាត់ចេញ ឬការបរាជ័យ។ នេះបញ្ជាក់ពីការទទួលខុសត្រូវផ្នែកសីលធម៌ ដើម្បីធានាថា

ក្រុមដែលងាយរងគ្រោះបំផុតត្រូវបានត្រួតពិនិត្យតាមដានដោយយកចិត្តទុកដាក់ និងនៅក្នុងករណីចាំបាច់ វិធានការត្រូវបានធ្វើឡើងដើម្បីធានាវត្តមាន ការចូលរួមនិងការសម្រេចរបស់ពួកគេនៅក្នុងប្រព័ន្ធអប់រំ។

## សកម្មភាព ១.២ ការអប់រំបរិយាបន្ននៅក្នុងការអនុវត្តជាក់ស្តែង

**រយៈពេល៖ ៤៥នាទី**

**វត្ថុបំណង៖**

- កំណត់ធាតុផ្សំសំខាន់ៗ សម្រាប់សាលារៀនបរិយាបន្ន។

**សម្ភារបង្រៀន និងរៀន៖**

- ករណីសិក្សាចំនួន២ នៃសាលារៀននៅប្រទេសឡាវ ដោយ Peter Grimes។

**សកម្មភាពបង្រៀន៖**

ក. ឱ្យគរុសិស្សធ្វើការជាក្រុមតូចៗ។

ខ. ឱ្យគរុសិស្សអានករណីសិក្សាទាំងពីរពីប្រទេសឡាវ។

សំណួរពិភាក្សា៖

-តើសាលារៀនមួយណាជាសាលារៀនបរិយាបន្ន?

-តើកត្តាអ្វីខ្លះដែលធ្វើឱ្យសាលារៀននោះមានលក្ខណៈបរិយាបន្ន?

គ. តំណាងក្រុមរាយការណ៍(សរសេរចម្លើយរបស់ពួកគេនៅលើផ្ទាំងក្រដាស)។

ឃ. សំយោគ។

ង. ឱ្យគរុសិស្សប្រៀបធៀបចម្លើយជាមួយចម្លើយនៅលើផ្ទាំងក្រដាស ដែលគ្រូឧទ្ទេសបានបង្ហាញ។ (តើកន្លែងណាដែលគំនិតរបស់គេមានលក្ខណៈបរិយាបន្ន និងកន្លែងណាដែលមិនមានលក្ខណៈបរិយាបន្ន)។

## ករណីសិក្សាចំនួនពីរ ដោយ Peter Grimes[6]

### ករណីសិក្សាទី១

សាលារៀន បាន ហាន គឺជាសាលារៀនអប់រំបរិយាបន្នក្នុងភូមិ បាន ហាន នៅខេត្តសាយ៉ាប៊្វរី ដែលមានចម្ងាយប្រមាណ ១៥គីឡូម៉ែត្រពីក្រុងហុងសា។ ប្រជាជនសរុបមានចំនួន ២,១៤៧នាក់ ដែលក្នុងនោះ ៤៨% ជាស្ត្រី។ ប្រជាពលរដ្ឋក្នុងសហគមន៍គឺជាជនជាតិឡាវលុមទាំងអស់។ អ្នកភូមិភាគច្រើនជាកសិករ ហើយភូមិនេះនឹងត្រូវរងផលប៉ះពាល់ដោយវិធីផ្លូវថ្នល់ ដែលតម្រូវឱ្យសាលារៀនត្រូវសាងសង់ឡើងវិញ។ សាលារៀនក្នុងមូលដ្ឋានគឺជាសាលារៀនបរិយាបន្ន និងមានឈ្មោះបានហានដែរ។ សាលារៀននេះមានសាលាមត្តេយ្យសិក្សានៅជាប់ជាមួយ ដែលមានកុមារចូលរៀនចំនួន៧៤នាក់។ នៅក្នុងសាលាបឋមសិក្សាមានកុមារ១៦០នាក់រៀននៅថ្នាក់ទី១ដល់ទី៥។ មានកុមារដែលមានតម្រូវការពិសេស១១នាក់ចុះឈ្មោះចូលរៀន ទោះបីមិនមានសិស្សពិការណាម្នាក់អាចបន្តការសិក្សានៅសាលាមធ្យមសិក្សាបឋមភូមិស្រុកនោះទេ។ មានគ្រូបង្រៀន ១៣នាក់ដែលរស់នៅក្នុងភូមិនេះទាំងអស់។ ទិន្នន័យលទ្ធផលរបស់សាលារៀនបានបង្ហាញថា ការចុះឈ្មោះចូលរៀននៅសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សាមាន១០០%។ ចំនួនសិស្សបោះបង់ចោលការសិក្សា និងទៅរៀនមិនទៀងទាត់ ដោយសារភាពភាពក្រីក្រមានកម្រិតទាប។ សាលារៀននេះគឺជាសាលារៀនស្នូលសម្រាប់តំបន់នោះ និងសកម្មយ៉ាងខ្លាំងក្នុងការសហការជាមួយសាលារៀនផ្សេងៗទៀតក្នុងមូលដ្ឋាន។ ក្រុមឪពុកម្តាយ និងគ្រូបង្រៀនក៏សកម្មយ៉ាងខ្លាំងផងដែរ និងមានការគាំទ្រយ៉ាងល្អពីសហគមន៍។ គុណភាពនៃការអប់រំដែលផ្តល់ដោយសាលារៀននេះត្រូវបានវិនិច្ឆ័យជាទូទៅថា មានកម្រិតខ្ពស់នៅក្នុងបរិបទប្រទេសឡាវ។

### កត្តាដែលធ្វើឱ្យសាលារៀន បាន ហាន ជាសាលារៀនបរិយាបន្ន

- ឪពុកម្តាយភាគច្រើនឱ្យតម្លៃការអប់រំ និងធានាថា កូនរបស់ពួកគេទៅសាលារៀន
- សហគមន៍អាចមានលទ្ធភាពបង់ថ្លៃសាលា ចូលរួមវិភាគទានដល់ថ្លៃគ្រូស្ម័គ្រចិត្ត (តម្លៃ ៨,០០០គីបក្នុង១ឆ្នាំ សម្រាប់សិស្ស១នាក់ សៀវភៅ ឯកសណ្ឋាន ។ល។)
- គ្រូបង្រៀនត្រូវបានបណ្តុះបណ្តាលលើការអប់រំបរិយាបន្ន
- គ្រូបង្រៀនគឺជាអ្នកភូមិនោះ
- ការគ្រប់គ្រងសាលារៀនល្អ
- សាលារៀនសកម្មក្នុងតំបន់នោះ
- អ្នកភូមិភាគច្រើនមានចំណូលគួរសម
- គុណតម្លៃវប្បធម៌នៃការអប់រំក្នុងប្រព័ន្ធ

---

[6] Grimes, P. (២០០៨) *ការអប់រំប្រែកបដោយគុណភាពសម្រាប់ទាំងអស់គ្នា* Save the Children ប្រទេសស៊ុយអែត និង SIDA ប្រទេសឡាវ ទំព័រ ១២៧-១២៩

**ករណីសិក្សាទី២**

សាលារៀនក្នុងភូមិសាមគ្គីហ្សីត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣។ សាលាបឋមសិក្សា **បានសាមគ្គី**គឺ សម្រាប់បម្រើភូមិចំនួន២គឺភូមិសាមគ្គីហ្សី និងហ្ស៊ីរណា។ ប្រជាជនសរុបរបស់ភូមិសាមគ្គីមានចំនួន៦៩៨នាក់ហើយគឺជាជនជាតិឡាវធៀងទាំងអស់។ អ្នកភូមិភាគច្រើនក្រីក្រ និងពឹងផ្អែកលើការធ្វើស្រែចំការចិញ្ចឹមជីវិត។ នៅក្នុងសាលារៀនមានកុមារចំនួន ២២៦នាក់ រៀនថ្នាក់ទី១ ដល់ទី៥។ គ្រូបង្រៀន៥នាក់ធ្វើការនៅក្នុងសាលារៀន ប៉ុន្តែមិនមាននរណាម្នាក់រស់នៅក្នុងភូមិនោះទេ។ សិស្សមានអាយុពី៦ ដល់១៨ឆ្នាំ និងមានកុមារ៥១នាក់មានអាយុចន្លោះពី១៣ ដល់១៨ឆ្នាំ។ នៅក្នុងសហគមន៍កុមារ៣៣% អាយុចន្លោះពី៦ ដល់១០ឆ្នាំ មិនដែល ចូលរៀនហើយក្នុងចំណោមនោះមានកុមារ៣០នាក់ ស្មើនឹង៧៦% ជាក្មេងស្រី។ មានតែកុមារ២៦% ដែលបន្តការសិក្សានៅមធ្យមសិក្សាបឋមភូមិ។ មានបញ្ហាប្រឈមជាច្រើននៅក្នុងការធានាវត្តមានចូលរៀនរបស់សិស្សទាំងអស់ ឧទាហរណ៍នៅថ្នាក់ទី១សិស្ស៥០% អវត្តមានរៀងរាល់ថ្ងៃ។ គុណភាពនៃការអប់រំផ្តល់ឱ្យដោយសាលាត្រូវបានវិនិច្ឆ័យជាទូទៅថាខ្សោយនៅក្នុងបរិបទប្រទេសឡាវ។

កត្តាដែលរារាំងសាលារៀនបានសាមគ្គីមិនឱ្យមានលក្ខណៈបរិយាបន្ន

- មិនមែនជាសាលារៀនបរិយាបន្ន
- ឳពុកម្តាយមានកូនច្រើន និងពុំមានលទ្ធភាពបញ្ជូនកូនទៅសាលារៀន ភាពក្រីក្រ
- សាលារៀនមានសិស្សលើសចំនួន
- កុមារមានភាសាកំណើតផ្សេងៗគ្នាមិនអាចនិយាយភាសាឡាវបាន
- គ្រូបង្រៀនមិនរស់នៅក្នុងភូមិ
- មិនមានវិក្រឹតការសម្រាប់គ្រូបង្រៀន
- ឳពុកម្តាយមានការអប់រំទាប
- សាលារៀនមធ្យមសិក្សាបឋមភូមិស្ថិតនៅឆ្ងាយពីភូមិ

## សកម្មភាព ១.៣ ការស្វែងយល់ពីឥរិយាបថដែលបណ្ដាលឱ្យមានបរិយាបន្ន ឬការផាត់ចេញ

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង៖**

- ប្រាប់បានពីឥរិយាបថរបស់សង្គមចំពោះការអប់រំបរិយាបន្ន
- កំណត់បានកត្តាដែលគាំទ្រការអប់រំបរិយាបន្ន ឬបណ្ដាលឱ្យមានការផាត់ចេញ។

**សកម្មភាពបង្រៀន៖**

ក. ឱ្យគរុសិស្សធ្វើការជាពីរក្រុមដើម្បីឆ្លើយសំណួរខាងក្រោមក្នុងមួយក្រុម១សំណួរ។

សំណួរ៖

- ចូរកំណត់កត្តាទាំងឡាយដែលផ្ដោតលើ *កុមារជាបញ្ហា* ដែលមិនទទួលបានការអប់រំ ។
- ចូរកំណត់កត្តាដែលផ្ដោតលើ *ប្រព័ន្ធអប់រំជាបញ្ហា* ដែលកុមារជាច្រើនមិនទទួលបានការអប់រំ។

ខ. តំណាងក្រុមរាយការណ៍។

គ. គ្រូសំយោគ (បង្ហាញគំរូបរិយាបន្ន ឬការផាត់ចេញនៅទំព័របន្ទាប់ )។

**ពន្យល់ដ្យាក្រាមនៅទំព័របន្ទាប់៖**

នៅពេលសង្គមគិតថា **កុមារគឺជាបញ្ហា** សម្រាប់ការមិនទទួលបានការអប់រំ សង្គមនោះដាក់កំហុសទៅលើកុមារ។ បន្ទាប់មកសហគមន៍ ឪពុកម្ដាយ នាយកសាលា និងគ្រូបង្រៀនគិតថា ពួកគេមិនមានការទទួលខុសត្រូវអ្វីទាំងអស់ ដើម្បីធ្វើការផ្លាស់ប្ដូរអាកប្បកិរិយានិងសកម្មភាពពួកគេ។ ការធ្វើបែបនេះបណ្ដាលឱ្យមានការផាត់ចេញ ហើយកុមារត្រូវបានបោះបង់ដោយគ្រួសារ សហគមន៍ ប្រព័ន្ធអប់រំ និងមិនអាចក្លាយជាសមាជិកសកម្មដើម្បីចូលរួមជាមួយគ្រួសារ សហគមន៍ និងសាលារៀន។

នៅពេលសង្គមគិតថា **ប្រព័ន្ធអប់រំគឺជាបញ្ហា** សង្គមនោះដាក់ការទទួលខុសត្រូវលើប្រព័ន្ធអប់រំ ដើម្បីធ្វើការផ្លាស់ប្ដូរ និងដាក់បញ្ចូលកុមារទាំងអស់នៅក្នុងការអប់រំ។ ការធ្វើបែបនេះជួយដល់ការដាក់បញ្ចូលកុមារដែលងាយបាត់បង់ឱកាស។ នៅក្នុងសាលារៀន គ្រូបង្រៀនយល់ថា ពួកគេត្រូវធ្វើការផ្លាស់ប្ដូរវិធីបង្រៀនដើម្បីឱ្យកុមារទាំងអស់អាចរៀន និងទទួលបានការអប់រំ។

> "កុមារ និងមនុស្សវ័យជំទង់ទាំងអស់របស់ពិភពលោកមានភាពខ្លាំង សេចក្ដីត្រូវការ ក្ដីសង្ឃឹម និងការរំពឹងទុករបស់ពួកគេមានសិទ្ធិទទួលបានការអប់រំ។ ប្រព័ន្ធអប់រំរបស់យើង មិនមែនជាប្រព័ន្ធអប់រំដែលផ្ដល់សិទ្ធិដល់កុមារតែមួយក្រុមនោះទេ។ ដូច្នេះប្រព័ន្ធអប់រំរបស់ប្រទេសមួយត្រូវតែកែសម្រួល ដើម្បីបំពេញតម្រូវការអប់រំរបស់កុមារទាំងអស់។
>
> - ដោយ Radhika Alkazi និង Shabnam Aggarwal[7]

[7] Radhika Alkazi និង Shabnam Aggarwal (២០១៤-២០១៥) នៅលើទំព័រមុខ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំទី៤.

### គំរូការអប់រំបរិយាបន្ន និងការផាត់ចេញ[8]










[8] កែសម្រួលពី UNESCO (២០០៥) *គោលការណ៍ណែនាំសម្រាប់បរិយាបន្ន: ការធានាការទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា* UNESCO ប៉ារីស ប្រទេសបារាំង

## ឯកសារអានបន្ថែម និងលំហាត់សម្រាប់គរុសិស្សពង្រឹងចំណេះដឹងពីការអប់រំបរិយាបន្ន

សម្រាប់ព័ត៌មានបន្ថែមពីប្រធានបទខាងក្រោម សូមអានមេរៀនពីសៀវភៅអប់រំបញ្ចូលគ្នាដែលមាននៅក្នុងឌីវីឌី(DVD)៖

- សៀវភៅការអប់រំបញ្ចូលគ្នា
    - ការអប់រំបញ្ចូលគ្នា សមាហរណកម្ម និងពិសេស (ឬការអប់រំដាច់ដោយឡែក) ទំព័រ ១៦-១៩
- សូចនាករសម្រាប់ការអប់រំបញ្ចូលគ្នាប្រកបដោយគុណភាព
    - សូចនាករវាស់ស្ទង់គុណភាពនៃការអប់រំបញ្ចូលគ្នា ទំព័រ៣០-៣១ (បំពេញកម្រងសំណួរ)
- អានផ្ទាំងរូបភាព "ការអប់រំបរិយាបន្នប្រកបដោយគុណភាព៖ លុបបំបាត់ការផាត់ចេញ[9]

ផ្ទាំងរូបភាពនេះផ្តល់សេចក្តីសង្ខេបនៃសូចនាករវាស់ស្ទង់គុណភាពនៃការអប់រំបរិយាបន្ន ដែលជាព័ត៌មានមានប្រយោជន៍។



© Michael Pitt

[9] IDDC/EENET (២០១២) *ការអប់រំបរិយាបន្នប្រកបដោយគុណភាព លុបបំបាត់ការផាត់ចេញ*

# មេរៀនទី២  ការកំណត់រកកុមារដែលមានហានិភ័យដោយការផាត់ចេញ



© Michael Pitt

## សកម្មភាព ២.១ ការកំណត់រកកុមារដែលមានហានិភ័យដោយការផាត់ចេញ

### រយៈពេល៖ ៣០នាទី

### វត្ថុបំណង ៖

- កំណត់បានពីហានិភ័យរបស់កុមារដែលបណ្តាលមកពីការផាត់ចេញ ឬបោះបង់ចោលការសិក្សា
- កំណត់បានវិធីផ្សេងៗដែលអាចជួយឱ្យកុមារត្រូវបានផាត់ចេញបានចូលរៀន។

### សម្ភារបង្រៀន និងរៀន៖

- ប័ណ្ណកុមារដែលបោះបង់ចោលការសិក្សា។

### សកម្មភាពបង្រៀន៖

ក.ឱ្យគរុសិស្សបំពេញប័ណ្ណ ក "ប័ណ្ណសម្រាប់កុមារដែលបោះបង់ចោលការសិក្សា"[10] នៅក្នុងសៀវភៅរៀងៗខ្លួន។

ខ. ពិភាក្សាលើគំនិតដែលពួកគេឆ្លើយពីវិធីដែលកុមារត្រូវបានផាត់ចេញបានចូលរៀន ។ ប្រើប្រាស់ព័ត៌មាននៅទំព័របន្ទាប់ ដើម្បីធ្វើការពិភាក្សា៖



© Michael Pitt

[10] កែសម្រួលពី INEE (២០០៩) *ការអប់រំក្នុងស្ថានភាពអាសន្ន: ការដាក់បញ្ចូលអ្នកគ្រប់គ្នានៅក្នុងការអប់រំ* INEE កូនសៀវភៅណែនាំស្តីពីការអប់រំ បរិយាបន្ន UNHCR ក្រុងហ្សឺណែវ ទំព័រ ៤៣-៤៤

## ប័ណ្ណ ក សម្រាប់កុមារដែលបោះបង់ចោលការសិក្សា

### ក្មេងប្រុស

**ពិពណ៌នាមិត្តភក្តិ សាច់ញាតិ ឬអ្នកជិតខាង ដែលមិនអាចទៅសាលារៀន**

ចម្លើយរំពឹងទុក:
ចម្លើយនេះអាស្រ័យលើស្ថានភាពរបស់គរុសិស្សម្នាក់ៗ

**ហេតុអ្វីពួកគេមិនអាចទៅសាលារៀន?**

ចម្លើយរំពឹងទុក:

- ភាពក្រីក្រ
- ពិការភាព
- ជនចំណាកស្រុក
- ជនភៀសខ្លួន
- ជនជាតិភាគតិច
- ជនជាតិសាសនាភាគតិច
- ភាសាផ្សេងគ្នា
- សុខភាពខ្សោយ ឈឺ
- វីរុស HIV ឬ ជំងឺអេដស៍
- កម្មករកុមារ
- ឪពុកម្តាយនៅឆ្ងាយ

សម្រាប់ក្មេងស្រី:

- ឪពុកម្តាយយល់ថាមិនមានសារៈសំខាន់ឱ្យក្មេងស្រីទទួលការអប់រំ
- ត្រូវមើលថែបងប្អូន



**តើជីវិតរបស់ពួកគេខុសពីជីវិតរបស់អ្នកយ៉ាងដូចម្តេច ដោយសារតែពួកគេមិនបានទៅសាលារៀន?**

- គ្មានការអប់រំ
- គ្មានការងារ
- ភាពក្រីក្រ
- គ្មានការរំពឹងទៅអនាគត
- ក្រៀមក្រំ
- គ្មានតម្លៃ
- ប្រាក់ចំណូលទាប
- ជីវិតគ្រួសារគ្មានស្នេហភាព
- ។ល។

សម្រាប់ក្មេងស្រី:

- អាចត្រូវធ្វើការនៅក្នុងបរិយាកាសមានការរំលោភបំពាន
- ត្រូវគេជិះជាន់
- ត្រូវពឹងផ្អែកលើអ្នកដទៃជានិច្ច

**តើមានវិធីណាដែលអ្នកអាចជួយក្មេងប្រុសនេះឱ្យបានទៅសាលារៀន?**

- និយាយទៅកាន់ក្មេងប្រុសនេះ ដើម្បីស្វែងរកមូលហេតុដែលមិនទៅសាលារៀន
- ប្រាប់បញ្ហានេះទៅកាន់នាយកសាលា ឪពុកម្តាយ ឬប្រធានសហគមន៍
- ពិនិត្យមើល តើមាន NGO ណាដែលអាចជួយបាន
- ពិនិត្យមើល តើត្រូវពិនិត្យសុខភាពឬទេ។ បន្ទាប់មកត្រូវពិនិត្យមើលតើពួកគេមាន "ប័ណ្ណក្រីក្រ" ឬទេ។
- ពិភាក្សាជាមួយប្រធានសហគមន៍ ដើម្បីពិនិត្យមើលប្រសិនបើគេអាចជួយបាន
- ។ល។

សម្រាប់ក្មេងស្រី:

- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិក្នុងការទទួលបានការអប់រំ
- និយាយទៅកាន់គណៈកម្មការឃុំ សង្កាត់ ទទួលបន្ទុកស្ត្រី និងកុមារ (CCWC)

ចម្លើយរំពឹងទុកសម្រាប់ប័ណ្ណទាំងពីរមានជាអក្សរពណ៌ខៀវខាងលើ

**ប័ណ្ណ ខ សម្រាប់កុមារដែលបាត់បង់ឱកាសទទួលបានការអប់រំ**

## ក្មេងស្រី

ពិពណ៌នាមិត្តភក្តិ សាច់ញាតិ ឬអ្នកជិតខាង ដែលមិនអាចទៅសាលារៀន

ហេតុអ្វីពួកគេមិនអាចទៅសាលារៀន?



តើជីវិតរបស់ពួកគេខុសគ្នាពីជីវិតរបស់អ្នកយ៉ាងដូចម្ដេច នៅពេលពួកគេធំឡើង?

តើមានវិធីណាអ្នកអាចជួយក្មេងស្រីនេះឱ្យទៅសាលារៀនបាន?

**កុមារបាត់បង់ឱកាស**[11]

| | |
|---|---|
| កុមារនៅតំបន់ជម្លោះ | កុមារត្រូវបានរំលោភបំពាន |
| កុមាររស់នៅតាមផ្លូវ | កម្មករកុមារ |
| ជនជាតិដើម | កុមារជនភៀសខ្លួន ឬបាត់បង់ទីលំនៅ |
| ទាហានកុមារ | ក្រុមកាន់សាសនាភាគតិច |
| កុមារពិការ | ជនចំណាកស្រុក |
| កុមារី | កុមាររងគ្រោះដោយភាពក្រីក្រ |
| ប្រជាជនជនបទ | កម្មករកុមារតាមផ្ទះ |
| កុមារដែលផ្លាស់ប្តូរទីលំនៅញឹកញាប់ | ជនជាតិភាគតិច |
| កុមារកំព្រា | ក្រុមប្រើប្រាស់ភាសាភាគតិច |
| កុមារផ្ទុកវីរុសHIV ឬជំងឺអេដស៍ | |



© Michael Pitt

[11] UNESCO (២០០៦) *គោលនយោបាយណែនាំ បរិយាបន្ននៅក្នុងការអប់រំ* UNESCO: ប្រទេសបារាំង ទំព័រ៧

# មេរៀនទី៣ ការផ្ដោតលើកុមារពិការ





© Michael Pitt

## សកម្មភាព ៣.១ ការស្វែងយល់និយមន័យពិការភាព និងផលប៉ះពាល់

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង៖**

- កំណត់បានពីនិយមន័យពិការភាព និងផលប៉ះពាល់។

**សម្ភារបង្រៀន និងរៀន៖**

- សៀវភៅសម្រាប់គរុសិស្សក្នុងផ្នែកនិយមន័យពិការភាព។

**សកម្មភាពបង្រៀន ៖**

ក. បែងចែកគរុសិស្សជាក្រុមតូចៗឱ្យអាននិងពិភាក្សានិយមន័យពិការភាពក្នុងសៀវភៅដោយពិចារណាលើសំណួរខាងក្រោម៖

- តើនិយមន័យមួយណាដែលផ្អែកលើគោលការណ៍សិទ្ធិមនុស្ស? ហេតុអ្វីអ្នកសន្និដ្ឋានដូច្នេះ?

ខ. តំណាងក្រុមរាយការណ៍។

គ.គ្រូសំយោគ។

*<u>ចម្លើយរំពឹងទុក</u>*

និយមន័យពិការភាពនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (UNCRPD)[12]

**និយមន័យទី១ នៅក្នុងសៀវភៅសម្រាប់គរុសិស្ស**

ជនពិការសំដៅលើអ្នកទាំងឡាយណាដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទា ផ្លូវចិត្ត សតិបញ្ញា ឬញាណដឹង ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានាអាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គមដោយស្មើភាពគ្នាជាមួយអ្នកដទៃបាន។

និយមន័យពិការភាព នៅក្នុងច្បាប់ស្តីពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិជនពិការ[13]

**និយមន័យទី២ នៅក្នុងសៀវភៅសម្រាប់គរុសិស្ស**

ជនពិការសំដៅទៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬសតិបញ្ញាបណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬសកម្មភាពនានាប្រចាំថ្ងៃដូចជាជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងៗទៀតដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី។

---

[12] UN (២០០៨) *អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ* UN: ញូយ៉ក មាត្រា១ ទំព័រ៤

[13] រាជរដ្ឋាភិបាលកម្ពុជា (២០០៩) *ច្បាប់ស្តីពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិជនពិការ* ទំព័រ១

### ចំណុចខាងក្រោមគួរលើកឡើង នៅក្នុងការពិភាក្សាសម្រាប់សំណួរទី១ ៖

| និយមន័យទី១ (UNCRPD) | និយមន័យទី២ (ច្បាប់កម្ពុជា) |
|---|---|
| មានមូលដ្ឋានលើសិទ្ធិ | មើលឃើញមនុស្សមាន"ការខ្វះខាត" |
| ពួកគេជាមនុស្ស | មើលឃើញមនុស្សជាអ្នករំខានជីវិតខ្លួនឯង |
| ពិចារណាដល់ពិការភាពដែលមានទំនាក់ទំនងទៅនឹងឧបសគ្គបង្កើតឡើងដោយសង្គម | មិនមានលើកឡើងពីសង្គម និងការទទួលខុសត្រូវរបស់សង្គម |
| មានបរិយាបន្ន ដោយសារពិនិត្យមើលឧបសគ្គរបស់សង្គម | ពុំមានបរិយាបន្នដោយសារឧបសគ្គត្រូវបានបង្កើតដោយមនុស្សខ្លួនឯង |
| ឧបសគ្គបញ្ឈប់មនុស្សពីការចូលរួម | មិនមានការទទួលខុសត្រូវលើសង្គមសម្រាប់ការធ្វើឱ្យមានឧបសគ្គ |

### បន្ថែមចំណុចពាក់ព័ន្ធទាំងឡាយ ដែលលើកឡើងដោយគរុសិស្សនៅខាងលើ

កុមារមិនមែនជាជនពិការ ដោយសារតែពួកគេមិនអាចដើរ សរសេរ ឬមើលឃើញនោះទេ។
ពួកគេពិការដោយសារសង្គមផាត់ពួកគេចេញ។ ការអប់រំបរិយាបន្នគឺជាជំហានដំបូងដើម្បីផ្លាស់ប្តូរសង្គម។

ដោយអង្គការ UNICEF[14]

[14] ដកស្រង់ពីទំព័រហ្វេសប៊ុក UNICEF ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤

## សកម្មភាព ៣.២ ការពិនិត្យមើលឥរិយាបថចំពោះជនពិការក្នុងបរិបទកម្ពុជា

**រយៈពេល៖ ៤៥នាទី**

**វត្ថុបំណង៖**

- កំណត់បានឥរិយាបថរបស់យើង និងអ្នកដទៃទៅកាន់ជនពិការ។

**សម្ភារបង្រៀន និងរៀន ៖**

- វីដេអូ ឈ្មោះ "ពិការភាពក្នុងវដ្តជីវិត វិនិយោគទៅលើកុមារ" ដោយអង្គការ UNICEF (២០១៣)
- វីដេអូ ឈ្មោះ "សុខ មិត្តរបស់ខ្ញុំ" ផលិតដោយអង្គការ Handicap International កម្ពុជា។

**សកម្មភាពបង្រៀន**

ក. សំណួរបំផុស (៥នាទី)៖

១.តើអ្នកស្គាល់នរណាដែលពិការឬទេ?

២.តើពួកគេទទួលបានការអប់រំ និងការយកចិត្តទុកដាក់ពីគ្រួសារ និងសហគមន៍ឬទេ?

ខ. បញ្ចាំងវីដេអូរបស់អង្គការ UNICEF មានចំណងជើងថា "ពិការភាពក្នុងវដ្តជីវិតវិនិយោគទៅលើកុមារ"[15]

គ. សំណួរពិភាក្សា៖ តើអ្វីដែលបណ្តាលឱ្យជីវិតកុមារពិការផ្លាស់ប្តូរ?

ឃ. តំណាងក្រុមរាយការណ៍

ង. សំយោគ

- ប្រសិនបើមានពេលវេលានៅសល់ គរុសិស្សអាចមើលវីដេអូឈ្មោះ "សុខ មិត្តរបស់ខ្ញុំ"[16]។

---

[15] វីដេអូ UNICEF (២០១៣) *ពិការភាពក្នុងវដ្តជីវិត៖ វិនិយោគទៅលើកុមារ* UNICEF

[16] Handicap International កម្ពុជា និង Meta Arts, វីដេអូកម្ពុជា (២០១០) *សុខ មិត្តរបស់ខ្ញុំ* ភ្នំពេញ

## សកម្មភាព ៣.៣ ការសិក្សាអំពីគំរូផ្សេងៗគ្នានៃពិការភាព

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង៖**

- កំណត់គំរូដែលល្អ និងកំពុងត្រូវប្រើប្រាស់នៅប្រទេសកម្ពុជា។

**សម្ភារបង្រៀន និងរៀន៖**

- អត្ថបទអានពីគំរូនៃពិការភាពដោយ CBM។

**សកម្មភាពបង្រៀន**

ក. ឱ្យគរុសិស្សអានអត្ថបទដកស្រង់ ដែលមានចំណងជើង "គំរូផ្សេងៗគ្នានៃពិការភាព" ដោយអង្គការ CBM ដែលមាននៅក្នុងសៀវភៅសិក្សា។

ខ. ពិភាក្សាក្រុមពីគំរូទាំងនោះ និងកំណត់គំរូដែលត្រូវប្រើប្រាស់នៅកម្ពុជា ផ្អែកតាមគំនិតរបស់ពួកគេ។
-តើគំរូមួយណាដែលល្អជាងគេ ដែលបំពេញសិទ្ធិជនពិការ?

គ. តំណាងក្រុមរាយការណ៍

ឃ. សំយោគ

**ចម្លើយរំពឹងទុក៖**

*គំរូដែលអនុវត្តនៅកម្ពុជាគឺជាគំរូសង្គម ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង វាប្រែប្រួលនៅចន្លោះគំរូសប្បុរសធម៌ និងវេជ្ជសាស្ត្រ។ គំរូដែលល្អជាងគេគឺ គំរូសិទ្ធិមនុស្ស។*

### គំរូពិការភាពដោយ CBM[17]

**គំរូសប្បុរសធម៌៖** ពិការភាពគឺជាអ្វីដែលមនុស្សរងទុក្ខវេទនា។ គំរូនេះសន្មតថា មនុស្សពិការត្រូវជាអ្នកទទួលការថែរក្សា ការព្យាបាល ឬការការពារ។ វិធីសាស្ត្រនេះមានលក្ខណៈគាំពារមិនរំពឹងថាជនពិការអាចធ្វើការចូលរួមចំណែកច្រើន ដូច្នេះហើយទើបឱ្យតម្លៃជនពិការទាប។

**គំរូវេជ្ជសាស្ត្រ៖** នេះគឺជាគំរូប្រពៃណីនៃពិការភាពផ្តោតលើភាពអន់ខ្សោយដែលតម្រូវឱ្យមានការព្យាបាលឬកែប្រែដើម្បីឱ្យបុគ្គលនោះក្លាយជាសមាជិកធម្មតានៃសង្គម។ នេះមានន័យថា ប្រសិនបើបុគ្គលម្នាក់មិនអាចត្រូវបានព្យាបាលបានទេពួកគេមិនអាចចូលរួមដោយស្មើភាពនៅក្នុងសង្គមនោះទេ។ ដូច្នេះគំរូវេជ្ជសាស្ត្រហាក់បីដូចជាផ្តោតទៅលើភាពអន់ខ្សោយ ឬការខ្វះខាតប៉ុណ្ណោះ។

**គំរូសេដ្ឋកិច្ច៖** គំរូនេះឱ្យតម្លៃមនុស្សផ្អែកលើកម្រិតផលិតកម្មរបស់ពួកគេ។ ពិការភាពត្រូវបានមើលឃើញជាសម្ពាធទៅលើសង្គម ដោយសារជនពិការមិនសូវមានផលិតកម្ម។ អន្តរាគមន៍ត្រូវបានធ្វើឡើងនៅពេលពួកគេមានប្រយោជន៍សេដ្ឋកិច្ច និងនៅពេលមានការពិបាកហិរញ្ញវត្ថុទៅលើសហគមន៍ គ្រួសារ ឬនៅពេលរដ្ឋាភិបាលកាត់បន្ថយថវិកា។

**គំរូសង្គម៖** គំរូនេះកំណត់ការរើសអើងមិនមែនដោយសារភាពអន់ខ្សោយនោះទេ ប៉ុន្តែជាលទ្ធផលនៃការកម្រិតដោយបរិបទជាក់លាក់ណាមួយនៅក្នុងសង្គមដែលពួកគេរស់នៅ។ ការលុបបំបាត់ឧបសគ្គពិការភាពនៅក្នុងបរិយាកាសនោះអាចកាត់បន្ថយផលប៉ះពាល់នៃភាពអន់ខ្សោយ។ គំរូនេះទទួលស្គាល់សិទ្ធិក្នុងការព្យាបាល

[17] CBM (២០១២) *ការបង្កើតបរិយាបន្នដោយងាយស្រួល៖ កម្មវិធីណែនាំខ្លី សម្រាប់ពិការភាពក្នុងការអភិវឌ្ឍ* CBM: ប្រទេសអាឡឺម៉ង់ ទំព័រ ៣

វេជ្ជសាស្ត្រ និងឧបករណ៍គាំទ្រសមស្រប ដូចជាឈើច្រត់ ឬរទេះរុញ និងការចូលរួមរបស់សហគមន៍។ គំរូនេះផ្លាស់ប្តូរការទទួលខុសត្រូវសម្រាប់"បរិយាបន្ន" ពីបុគ្គលដែលត្រូវការព្យាបាល ទៅកាន់សង្គមដែលជនពិការរស់នៅឱ្យកាន់តែមានបរិយាបន្ន តាមរយៈការលុបបំបាត់ឧបសគ្គ។

**គំរូសិទ្ធិមនុស្ស៖** គំរូសិទ្ធិមនុស្សយកសិទ្ធិមនុស្សជាសកលជាចំណុចចាប់ផ្តើម។ ជនពិការមានសិទ្ធិចូលរួមរាល់សកម្មភាពនៅក្នុងសង្គម ដោយស្មើភាពជាមួយអ្នកដទៃ។ ការអភិវឌ្ឍបរិយាបន្នសម្រាប់ជនពិការគួរយកវិធីសាស្ត្រផ្អែកលើសិទ្ធិជាមូលដ្ឋាន។ វិធីសាស្ត្រនេះបូកបញ្ចូលទស្សនៈគំរូសង្គម ដែលឧបសគ្គខាងក្រៅត្រូវបានកំណត់ដំណាលគ្នាទៅនឹងជនពិការជាចំណុចស្នូលនៅក្នុងការទទួលបានសិទ្ធិរបស់ពួកគេ។ គំរូផ្អែកលើសិទ្ធិជាមូលដ្ឋានប្រើប្រាស់ការលើកកម្ពស់ការយល់ដឹងការចូលរួមដោយមធ្យោបាយសមស្របទូលំទូលាយ និងវិធីសាស្ត្រពីររួមគ្នា (twin track) ជាគោលការណ៍អភិវឌ្ឍបរិយាបន្នសម្រាប់ជនពិការ។

**លំហាត់ត្រូវធ្វើនៅផ្ទះ**

អានមេរៀន "ការយល់ដឹងពីពិការភាព"( សៀវភៅការអប់រំបញ្ចូលគ្នា) ដែលមាននៅក្នុងDVD ដើម្បីស្វែងយល់ពីបញ្ញត្តិខាងក្រោម៖

- ភាពខុសគ្នារវាងភាពអន់ខ្សោយ និងពិការភាព (ទំព័រ ១-៤)
- អនុសញ្ញាអន្តរជាតិ (ទំព័រ ៤-៧)
- ឥរិយាបថចំពោះជនពិការ (ទំព័រ ៨-១២)

  - ប្រសិនបើមានពេល គ្រូបង្រៀនអាចសម្តែងតួ ដែលមាននៅទំព័រទី១១ ។

## សកម្មភាព ៣.៤ ស្នាដៃរបស់ជនពិការ

## រយៈពេល៖ ៣០នាទី

## វត្ថុបំណង៖

- កំណត់បានពីអ្វីដែលជនពិការអាចសម្រេចបាន។

## សម្ភារបង្រៀន និងរៀន៖

- រឿងជោគជ័យនៃគម្រោង Aspiro អង្គការគ្រួសារថ្មី - នាង សារិទ្ធ នាយក និងអ្នកគ្រប់គ្រង Epic Arts សម្តែង បទចម្រៀង "Happy" ដោយ Pharrell Williams
- រឿងជោគជ័យនៃគម្រោង Aspiro អង្គការគ្រួសារថ្មី សុគន្ធ ព្រហ្មវីរៈ ជំនួយការនៅក្រសួងការបរទេសកម្ពុជា
- ការសម្តែងគ្រាប់តាមបែបកំប្លែងបទចម្រៀង "Shake It Off" ដោយ Epic Arts

## សកម្មភាពបង្រៀន៖

ក. បញ្ចាំងវីដេអូ ដែលត្រូវបានកំណត់នៅក្នុងផ្នែកសម្ភារបង្រៀន និងរៀន

សំណួរពិភាក្សា៖

- ចូរកំណត់ប្រភេទពិការភាពខុសៗគ្នា ដែលមាននៅក្នុងវីដេអូ។
- តើអ្នកមានអារម្មណ៍ដូចម្តេចជាមួយនឹងស្នាដៃរបស់មនុស្សនៅក្នុងវីដេអូទាំងនេះ?

ខ. ប្រមូលចម្លើយគរុសិស្ស រួចសំយោគ

ស្នាដៃដែលជនពិការអាចសម្រេចបាន[18]៖









[18] រូបភាពដោយ យិន រតនា នៃអង្គការ AAR ជប៉ុន លើកលែងរូបភាពអ្នកចម្រៀងដោយ Michael Pitt





The Phnom Penh Post

HONDA


# មេរៀនទី៤ ការប្រើប្រាស់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ ( Holistic Approach )





## សកម្មភាព ៤.១ ការស្វែងយល់ពីធាតុផ្សំនៃវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ (holistic approach)

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង ៖**

- កំណត់បានធាតុផ្សំបីផ្សេងគ្នានៃវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ (holistic approach)
- អនុវត្តធាតុផ្សំទាំងបីនៅក្នុងបរិបទប្រទេសកម្ពុជា។

**សកម្មភាពបង្រៀន៖**

ក. ឱ្យគរុសិស្សធ្វើការជាបីក្រុមអានសេចក្តីថ្លែងការណ៍របស់ UNESCO

ខ. ពិភាក្សាក្រុម៖

សំណួរ៖

- ចូរស្វែងយល់គំរូការសម្រេចបានការអប់រំបរិយាបន្នដែលមានធាតុផ្សំគន្លឹះទាំង៣ដូចខាងក្រោម៖
    ១.កំណែទម្រង់រចនាសម្ព័ន្ធ
    ២.ការផ្តល់សិទ្ធិអំណាចដល់សហគមន៍
    ៣.ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ
- តើប្រធានបទនេះ មានន័យយ៉ាងដូចម្តេច សម្រាប់បរិបទប្រទេសកម្ពុជា?

គ.តំណាងក្រុមរាយការណ៍

ឃ.សំយោគ

(គរុសិស្សអានការពន្យល់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងពេលនោះដែរ)។

អង្គការ UNESCO (២០០៦)[19] ពិពណ៌នាការអប់រំបរិយាបន្នគឺជា៖

"ដំណើរការនៃការដោះស្រាយ និងឆ្លើយតបទៅនឹងភាពចម្រុះនៃសេចក្តីត្រូវការរបស់សិស្សទាំងអស់តាមរយៈការអនុវត្តបរិយាបន្ននៅក្នុងការសិក្សា វប្បធម៌ និងសហគមន៍ និងការកាត់បន្ថយការផាត់ចេញពីការអប់រំ និងក្នុងការអប់រំ។ ដំណើរការនេះទាក់ទងទៅដល់ការកែប្រែផ្លាស់ប្តូរ និងកែសម្រួលក្នុងខ្លឹមសារ វិធីសាស្ត្រ រចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រ ជាមួយនឹងចក្ខុវិស័យរួមដែលគ្របដណ្តប់កុមារក្នុងចន្លោះអាយុសមស្របទាំងអស់ និងមានជំនឿមុតមាំថា វាគឺជាការទទួលខុសត្រូវរបស់ប្រព័ន្ធអប់រំទូទៅក្នុងការអប់រំកុមារទាំងអស់"។

**ចម្លើយរំពឹងទុក**

**១.កំណែទម្រង់រចនាសម្ព័ន្ធ៖**

ធាតុផ្សំនេះទាក់ទងទៅនឹងការធ្វើការកែប្រែច្បាប់ គោលនយោបាយរបស់កម្ពុជា ដែលអាចឱ្យការអប់រំបរិយាបន្នត្រូវបានអនុវត្ត ដើម្បីកម្ពុជាអាចសម្រេចគោលដៅការអប់រំសម្រាប់ទាំងអស់គ្នា។ ធាតុផ្សំនេះទាក់ទង

[19] UNESCO (២០០៦) *គោលនយោបាយណែនាំស្តីពី បរិយាបន្នក្នុងការអប់រំ* UNESCO បារាំង ទំព័រ ៨-៩

ទៅនឹងការកែប្រែរចនាសម្ព័ន្ធនៅថ្នាក់ជាតិ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ នៅថ្នាក់ជាតិច្បាប់ត្រូវកែប្រែបន្ទាប់មកត្រូវរៀបចំគោលនយោបាយថ្នាក់ជាតិ។ សម្រាប់ថ្នាក់រាជធានី ខេត្តនិងក្រុង ស្រុក ខណ្ឌ គោលនយោបាយទាំងនេះត្រូវអនុវត្ត ដើម្បីឆ្លុះបញ្ចាំងពីការអប់រំសម្រាប់កុមារទាំងអស់។ នាយកដ្ឋានអប់រំពិសេសដើរតួសំខាន់នៅក្នុងការបង្កើតគោលនយោបាយអប់រំបរិយាបន្ន ដែលត្រូវបានដាក់ឱ្យអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា។

**២.ការផ្តល់សិទ្ធិអំណាចដល់សហគមន៍៖**

ធាតុផ្សំនេះរួមមានសហគមន៍កំណត់ក្រុមកុមារងាយរងគ្រោះដែលត្រូវបានផាត់ចេញពីសាលារៀន។ ជាមួយអង្គការសង្គមស៊ីវិល សហគមន៍ត្រូវបានផ្តល់សិទ្ធិអំណាច ដើម្បីតស៊ូមតិសម្រាប់ការអប់រំកុមារបាត់បង់ឱកាស ពីព្រោះប្រព័ន្ធអប់រំមិនអាចបំពេញសេចក្តីត្រូវការរបស់ពួកគេ។ ដំណើរការតស៊ូមតិនេះមានការចូលរួមពីឪពុកម្តាយ ក៏ដូចជាគ្រូបង្រៀន និងនៅក្នុងករណីខ្លះមានកុមារខ្លួនឯង។

**៣.ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ៖**

ធាតុផ្សំនេះជាប់ទាក់ទងលើសពីការបណ្តុះបណ្តាលគ្រូបង្រៀននៅកម្រិតឧត្តមសិក្សា និងក្រោយឧត្តមសិក្សានេះគឺជាការផ្តល់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ។ ប៉ុន្តែកត្តាសំខាន់មួយទៀតនៅក្នុងធាតុផ្សំនេះគឺការសិក្សាដែលគ្រូបង្រៀនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រេចបាននៅពេលពួកគេបង្រៀនកុមារដែលមាន សេចក្តីត្រូវការផ្សេងៗគ្នានៅក្នុងថ្នាក់រៀនបរិយាបន្ន។ តម្រូវការក្នុងការសិក្សាត្រូវបានចែករំលែកដល់គរុសិស្ស ហើយវាអាចសម្រេចបានតាមរយៈគ្រូបង្រៀនដែលមានបទពិសោធ។

**ទិដ្ឋភាពទូទៅនៃធាតុផ្សំគន្លឹះនៅក្នុងវិធីសាស្រ្តគ្រប់ជ្រុងជ្រោយ** [20]




[20] Sierra, H. T. A និង Towell, D. (២០១១) ជំរុញការអប់រំបរិយាបន្ន សម្រាប់អនាគតបរិយាបន្ន ទីក្រុងឡុង: មជ្ឈមណ្ឌលសម្រាប់អនាគតបរិយាបន្ន ទំព័រ ១៤

## គោលគំនិតនៃវិធីសាស្ត្រគ្រប់ជ្រុងជ្រោយៈ

វិធីសាស្ត្រគ្រប់ជ្រុងជ្រោយមានន័យថាការចូលរួម និងបង្កើតប្រព័ន្ធអប់រំទាំងមូល។ ដើម្បីធានាឱ្យមានការអប់រំបរិយាបន្ន យើងត្រូវដោះស្រាយធាតុផ្សំទាំងបីផ្នែក រួមមានកំណែទម្រង់រចនាសម្ព័ន្ធ ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ។ ការផ្តោតតែលើធាតុផ្សំតែមួយ ឧទាហរណ៍ការអភិវឌ្ឍជំនាញវិជ្ជាជីវៈនឹងមិនធ្វើឱ្យមានការអប់រំបរិយាបន្ននោះទេ។ ប្រព័ន្ធអប់រំមានច្រើនផ្នែក ដូច្នេះវាត្រូវការផ្លាស់ប្តូរប្រព័ន្ធទាំងមូល ។

ដើម្បីធ្វើកំណែទម្រង់រចនាសម្ព័ន្ធ រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើតច្បាប់ ដែលគាំទ្រការអប់រំបរិយាបន្ន និងបន្ទាប់មកបង្កើតគោលនយោបាយបរិយាបន្ន។ កត្តាសំខាន់បំផុតនៅក្នុងគោលនយោបាយថ្មីណាមួយត្រូវមានផែនការអនុវត្តច្បាស់លាស់ជាមួយធនធានត្រូវបានកំណត់សម្រាប់គោលបំណងនេះ។ ការធ្វើបែបនេះបង្កើតចក្ខុវិស័យសម្រាប់ការអប់រំបរិយាបន្ន។

សម្រាប់ធាតុផ្សំ*ការផ្តល់សិទ្ធិអំណាចដល់សហគមន៍* កុមារដែលមិនអាចទទួលបានការអប់រំ គ្រួសាររបស់ពួកគេ ថ្នាក់ដឹកនាំនៅមូលដ្ឋាន និងនាយកសាលារៀនត្រូវធ្វើការរួមគ្នាដើម្បីសម្រេចបានបរិយាបន្ន។ គ្រួសារថ្នាក់ដឹកនាំនៅមូលដ្ឋាន និងនាយកសាលារៀនត្រូវអនុវត្តចក្ខុវិស័យនៃការអប់រំបរិយាបន្ននៅកម្រិតមូលដ្ឋាន។

ឯកសារនេះគឺជាជំហានមួយឆ្ពោះទៅកាន់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈគ្រូបង្រៀន។ ទន្ទឹមនឹងនេះ តម្រូវការសំខាន់មួយទៀតសម្រាប់គ្រូបង្រៀនគឺការគាំទ្រពីនាយកសាលារៀន មាតាបិតាសិស្ស និងសហគមន៍ដើម្បីឱ្យពួកគេអាចប្រើប្រាស់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់ពួកគេក្នុងការបង្កើតថ្នាក់រៀនបរិយាបន្ន។

តារាងខាងក្រោម [21] បង្ហាញពីរបៀបនៃការផ្លាស់ប្តូរនៅកម្រិតទាំងបីអាចសម្រេចបានៈ

| **មធ្យោបាយ** | **វិធីសាស្ត្រសំខាន់** | **ជំហរ** | **ទម្រង់នៃការវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ការផ្តោតទៅលើ** |
|---|---|---|---|---|---|
| ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ | ការអភិវឌ្ឍសហគមន៍ | ស្តាប់ ជំរុញឱ្យធ្វើបាន | បញ្ហារបស់សហគមន៍ ឬសេចក្តីប្រាថ្នា | ការផ្លាស់ប្តូរឥរិយាបថ ការផ្តល់សិទ្ធិអំណាច | ជនពិការ គ្រួសាររបស់ពួកគេ អង្គការ និងអ្នកពាក់ព័ន្ធ |
| កំណែទម្រង់រចនាសម្ព័ន្ធ | ជំនួយបច្ចេកទេស | ផ្តល់ដំបូន្មាន ប្រឹក្សាយោបល់ | គោលនយោបាយ និងលទ្ធផល | ការអនុវត្តការបំពេញមុខងារ | គោលនយោបាយ ច្បាប់ ដំណើរការអនុវត្ត និងធនធាន |
| ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ | ការអប់រំ និងការបណ្តុះបណ្តាល | ការបង្រៀន ការគាំទ្រ | ការវិភាគតម្រូវការបណ្តុះបណ្តាល | សមត្ថភាពនៅក្នុងការអនុវត្ត | គ្រូបង្រៀន និងការរំពឹងទុកវិជ្ជាជីវៈផ្សេងទៀត និងជំនាញ |

[21] Sierra, H.T.A និង Towell, D. (២០១១) *ជំរុញការអប់រំបរិយាបន្នសម្រាប់អនាគតបរិយាបន្ន* ទីក្រុងឡុង មជ្ឈមណ្ឌលសម្រាប់អនាគតបរិយាបន្ន ទំព័រ១៥

## សកម្មភាព ៤.២ ការចូលរួម និងផ្តល់សិទ្ធិអំណាចដល់សហគមន៍

**រយៈពេល៖ ៤៥នាទី**

**វត្ថុបំណង៖**

- ប្រាប់បានអត្ថប្រយោជន៍នៃការចូលរួមរបស់សហគមន៍
- កំណត់បានពីឥទ្ធិពលនៃការចូលរួមរបស់សហគមន៍។

**សម្ភារបង្រៀន និងរៀន៖**

- ករណីសិក្សា[22]

**សកម្មភាពបង្រៀន៖**

ក. ឱ្យគរុសិស្ស អានករណីសិក្សារៀងៗខ្លួន។

ខ. ពិភាក្សាក្រុម

សំណួរ៖

១.តើអ្វីដែលអ្នកបានយល់ដឹងពីករណីសិក្សានេះ?

២.តើការយល់ដឹងនេះនឹងជួយដល់ការអនុវត្តរបស់អ្នកជាគ្រូបង្រៀនយ៉ាងដូចម្តេច?

### ករណីសិក្សា ការចូលរួមរបស់សហគមន៍

នៅក្នុងគម្រោងមួយដែលអង្គការ AAR ជប៉ុន កំពុងអនុវត្តនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ក្រុមការងារមួយត្រូវបានបង្កើតនៅក្នុងដំណាក់កាលដំបូង។ ក្រុមការងារនេះមិនត្រឹមតែមានមន្ត្រីរដ្ឋាភិបាលពីថ្នាក់ខេត្ត ស្រុក និងនាយកសាលានោះទេ ប៉ុន្តែក៏មានសមាជិកសហគមន៍ដូចជាប្រធានឃុំ សមាជិកក្រុម ប្រឹក្សាឃុំ មន្ត្រីមណ្ឌលសុខភាព ប្រធានក្រុមជួយខ្លួនឯង (Self Help Groups) និងឪពុកម្តាយកុមារពិការ។

ឧទាហរណ៍វិជ្ជមានមួយនៃការចូលរួមរបស់សហគមន៍គឺរឿងរបស់រិទ្ធី។ សមាជិកក្រុមការងារម្នាក់បានទៅផ្ទះរបស់រិទ្ធី ពីព្រោះរិទ្ធីបានអវត្តមានពីសាលារៀនអស់រយៈពេលមួយខែ។ នាងបានរកឃើញមូលហេតុបីយ៉ាងដែលធ្វើឱ្យរិទ្ធីនៅផ្ទះ។ ១. រិទ្ធីឈឺត្រចៀកខ្លាំង ២. ឪពុកម្តាយរបស់រិទ្ធីរស់នៅបែកគ្នា ៣. គ្រូបង្រៀនយកប្រាក់រាល់ថ្ងៃដែលរិទ្ធីអវត្តមាន។ ម្តាយរបស់រិទ្ធីត្រូវចំណាយប្រាក់ច្រើន តែគាត់មិនមានលទ្ធភាព។

សមាជិកក្រុមការងារបានលើកទឹកចិត្តគ្រួសារ និងរិទ្ធីឱ្យត្រឡប់ទៅសាលារៀនវិញ ហើយនិយាយថានឹងទៅនិយាយជាមួយគ្រូបង្រៀន។ ការធ្វើបែបនេះបានធ្វើឱ្យគ្រូបង្រៀនឈប់ទាមទារប្រាក់។

នៅពេលដែលបុគ្គលិករបស់អង្គការ AAR ជប៉ុនបានដឹងព័ត៌មាននេះ គាត់បាននិយាយជាមួយគ្រួសាររិទ្ធីក៏ដូចជាសាលា ដែលអាចឱ្យរិទ្ធីត្រឡប់ទៅសាលារៀនវិញ។ គ្រូបង្រៀនត្រូវបានស្នើសុំឱ្យតាមដានមើលដំបៅត្រចៀករបស់រិទ្ធី និងធានាថា រិទ្ធីទទួលបានលទ្ធផលសិក្សាវិជ្ជមាន។

[22] ករណីសិក្សាដោយអង្គការ AAR ជប៉ុន កម្ពុជា

គ.តំណាងក្រុមរាយការណ៍

ឃ.សំយោគ

**ចម្លើយរំពឹងទុកៈ**

១.តើអ្វីដែលអ្នកបានយល់ដឹងពីករណីសិក្សានេះ?

- សហគមន៍ទទួលយកកុមារពិការ។
- សហគមន៍ដឹងថា កុមារពិការមានសិទ្ធិក្នុងការអប់រំ។
- សមាជិកសហគមន៍មានអារម្មណ៍ទទួលបានសិទ្ធិអំណាចទៅជួបគ្រួសារកុមារពិការ។
- សហគមន៍មានភាពជាម្ចាស់ នៅក្នុងការធ្វើការជាមួយគ្រួសារទាំងអស់។
- ឪពុកម្ដាយមិនត្រូវបានបោះបង់ឱ្យដោះស្រាយបញ្ហាតែខ្លួនឯង។
- សហគមន៍អាចគាំទ្រឪពុកម្ដាយកុមារពិការ។
- សហគមន៍យល់ដឹងពីសិទ្ធិក្នុងការអប់រំរបស់កុមារពិការកាន់តែច្បាស់។
- សហគមន៍ទទួលខុសត្រូវដោះស្រាយបញ្ហា ដែលសមាជិកសហគមន៍ជួបប្រទះ។

២.តើការយល់ដឹងនេះ នឹងជួយដល់ការអនុវត្តរបស់អ្នកជាគ្រូបង្រៀនយ៉ាងដូចម្ដេច?

- ជាគ្រូបង្រៀនម្នាក់ ខ្ញុំនឹងធ្វើការជាមួយសមាជិកសហគមន៍ ដែលជាផ្នែកនៃគណៈកម្មការទ្រទ្រង់សាលារៀន។ ពួកគេអាចដឹងមូលហេតុដែលកុមារមិនទៅសាលារៀន។
- ខ្ញុំក៏ត្រូវធ្វើការជាមួយឪពុកម្ដាយ ដើម្បីបង្កើតទំនាក់ទំនងល្អ និងប្រសិនបើកុមារពិការមានបញ្ហាណាមួយ ពួកគេអាចមកជួបនិងពិភាក្សាជាមួយខ្ញុំ។
- ប្រសិនបើខ្ញុំមានបញ្ហាជាមួយកុមារណាម្នាក់នៅក្នុងថ្នាក់រៀន ខ្ញុំអាចចែករំលែកបញ្ហានេះជាមួយគណៈកម្មការទ្រទ្រង់សាលារៀន ដូច្នេះពួកគេអាចចំណាយពេលវេលាបានច្រើនជាមួយកុមារនោះ និងគ្រួសារកុមារនោះ ដើម្បីឱ្យដឹងឫសគល់បញ្ហាដែលកំពុងកើតឡើងចំពោះកុមារនោះ។

## សមាជិកសហគមន៍ចូលរួមនៅក្នុងការកំណត់អត្តសញ្ញាណកុមារពិការ[23]





[23] រូបភាពដោយអង្គការ AAR ជប៉ុន

# មេរៀនទី៥ បរិយាកាសសាលារៀនបរិយាបន្ន

## ការទទួលបានរូបវន្តនៅក្នុងសាលារៀន

| | |
|---|---|
| សាលាបឋមសិក្សា ពុកឫស្សី  | សាលាបឋមសិក្សា ពុកឫស្សី  |
| សាលាបឋមសិក្សា ពុកឫស្សី  | សាលាបឋមសិក្សា តា ឯក  |
| សាលាបឋមសិក្សា តា ឯក  | សាលាបឋមសិក្សា តា ឯក  |

## សកម្មភាព ៥.១ ការកែលម្អសាលារៀនទាំងមូលឆ្ពោះទៅរកការអប់រំបរិយាបន្ន

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង៖**

- កំណត់បានកត្តាដែលអាចធ្វើឱ្យការអប់រំបរិយាបន្ននៅក្នុងសាលារៀនប្រសើរឡើង។

**សម្ភារបង្រៀន និងរៀន៖**

- ផ្ទាំងរូបភាព(Poster)សាលារៀនសម្រាប់ទាំងអស់គ្នារបស់អង្គការ Save the Children។

**សកម្មភាពបង្រៀន**

- ឱ្យគរុសិស្សធ្វើការងារជាដៃគូ។
- ឱ្យគរុសិស្សអានគំរូនៅទំព័របន្ទាប់ ពី ឬបីនាទី។
- បន្ទាប់មកឱ្យពួកគេពិភាក្សា និងសរសេរកត្តាណាមួយដែលមាននៅក្នុងសាលារៀនរបស់ពួកគេ និងមួយណាដែលមិនមាន។
- អានកត្តានីមួយៗនិងឱ្យពួកគេលើកដៃប្រសិនបើកត្តានោះមាននៅក្នុងសាលារៀនរបស់ពួកគេ។
- ឱ្យក្រុមមួយកំណត់កត្តាដែលមិនមាននៅក្នុងសាលារៀន (កត្តាដែលមានចំនួនអ្នកលើកដៃតិចជាងគេ) និងពិភាក្សាពីវិធីដែលអាចកែលម្អកត្តាទាំងនេះបាន។

ចម្លើយដែលពាក់ព័ន្ធនឹងបរិបទមូលដ្ឋាន ពីរបៀបដែលអាចកែលម្អបានគួរកត់ត្រានៅផ្នែកខាងក្រោមនេះ៖



© Michael Pitt

# កត្តាកែលម្អសាលារៀន[24]




បរិយាកាសសាលារៀនបរិយាបន្នមានលក្ខណៈទូលំទូលាយលើសពីការទទួលបានសម្ភាររូបវ័ន្ត។ វាផ្តោតសំខាន់លើអ្វីដែលកើតឡើងនៅពេលកុមារនៅក្នុងថ្នាក់រៀន ហើយគំរូខាងលើបង្ហាញថា តើបញ្ហាអ្វីដែលសំខាន់សម្រាប់បរិយាកាសសាលារៀនបរិយាបន្ន។

[24] ផ្ទាំងរូបភាពសាលារៀនសម្រាប់ទាំងអស់គ្នា/EENET (២០០២)

## សកម្មភាព ៥.២ ការវាយតម្លៃសាលារៀនដែលមានលក្ខណៈបរិយាបន្ន

**វត្ថុបំណង៖**

- កំណត់បានសម្ភាររូបវន្តសាលារៀនដែលមានលក្ខណៈបរិយាបន្ន។

**រយៈពេល៖ ៤៥នាទី**

**សម្ភារបង្រៀន និងរៀន៖**

- តារាងត្រួតពិនិត្យបង្កើតដោយ Nafisa Baboo បង្ហាញនៅទំព័របន្ទាប់។

**សកម្មភាពបង្រៀន ៖**

- ឱ្យគរុសិស្សដើរមើលជុំវិញបរិវេណសាលា និងប្រើតារាងត្រួតពិនិត្យនៅទំព័របន្ទាប់។

សម្រាប់គោលបំណងនៃលំហាត់នេះ ប្រសិនបើគរុសិស្សមិនអាចចូលមើលនៅសាលារដ្ឋបានពួកគេអាចមើលនៅ សាលាគរុកោសល្យ និងវិក្រឹតការខេត្ត។

កម្រងសំណួរនេះត្រូវបានកែសម្រួលពីកម្រងសំណួរដែលបង្កើតដោយ Nafisa Baboo ពីអង្គការ Light for the World។

**គូសចម្លើយ និងផ្តល់យោបល់នៅក្នុងប្រអប់៖**

| ល.រ | សំណួរ | បាទ/ចាស | ទេ | យោបល់ |
|---|---|---|---|---|
| ១ | តើមានស្លាកសញ្ញាណែនាំផ្លូវទៅកាន់សាលារៀនឬទេ? | | | |
| ២ | តើសាលារៀនរបស់អ្នកផ្តល់មធ្យោបាយធ្វើដំណើរសម្រាប់កុមារពិការ ដែលមានបញ្ហាចលនាឬទេ? | | | |
| ៣ | តើមានស្លាកឈ្មោះសាលារៀនឬទេ? | | | |
| ៤ | តើផ្លូវចូលសាលារាបស្មើ និងគ្មានឧបសគ្គឬទេ? | | | |
| ៥ | តើសន្តិសុខយាមស្វាគមន៍ និងជួយភ្ញៀវឬទេ? | | | |
| ៦ | តើបុគ្គលិកទទួលភ្ញៀវមានភាពកក់ក្តៅ និងរាក់ទាក់ឬទេ? | | | |
| ៧ | តើមានក្តារខៀនព័ត៌មានដែលផ្តល់ព័ត៌មានមានប្រយោជន៍សម្រាប់ភ្ញៀវ និងឪពុកម្តាយឬទេ? | | | |
| ៨ | តើសាលារៀនមានព្រឹត្តិបត្រ ឬប្រព័ន្ធទំនាក់ទំនងជាមួយឪពុកម្តាយឬទេ? | | | |
| ៩ | តើផ្ទាំងតាំងបង្ហាញវប្បធម៌ផ្សេងៗ បង្ហាញពីអ្វីដែលមាននៅក្នុងសាលារៀន និងស្នាដៃផ្សេងៗឬទេ? | | | |
| ១០ | តើផ្លូវដើរនៅផ្នែកនានានៃសាលារៀនរាបស្មើ និងគ្មានឧបសគ្គឬទេ? | | | |
| ១១ | តើទ្វារ ធំល្មមសម្រាប់រទេះរុញ ចេញ ចូលឬទេ? | | | |

| ល.រ | សំណួរ | បាទ/ចាស | ទេ | យោបល់ |
|---|---|---|---|---|
| ១២ | តើជណ្ដើរទាំងអស់មានបង្កាន់ដៃឬទេ? | | | |
| ១៣ | តើមានជម្រាលសមស្របនៅកន្លែងមានកាំជណ្ដើរឬទេ? | | | |
| ១៤ | តើកាំជណ្ដើរមានលាបពណ៌លឿង សឬទេ? | | | |
| ១៥ | តើមានស្លាកសញ្ញាសម្គាល់ទីកន្លែងគ្រោះថ្នាក់ឬទេ ? (ឧ. រណ្ដៅ)? | | | |
| ១៦ | តើមានស្លាកសញ្ញាសម្គាល់បន្ទប់ និងច្រកចូលចេញឬទេ? (ឧ. បណ្ណាល័យ បន្ទប់ដាក់សម្ភារ)? | | | |
| ១៧ | តើស្លាកសញ្ញាមើលឃើញច្បាស់ល្អ និងអាចយល់បានឬទេ? | | | |
| ១៨ | តើតុក្នុងថ្នាក់រៀនរៀបចំឱ្យអ្នកដែលមានរទេះរុញ ឈើច្រត់ អាចផ្លាស់ទីដោយសុវត្ថិភាព និងអាចទៅកាន់កន្លែងផ្សេងៗ នៅក្នុងថ្នាក់រៀនឬទេ? | | | |
| ១៩ | តើកុមារដែលប្រើរទេះរុញអាចប្រើប្រាស់តុបានឬទេ? | | | |
| ២០ | តើប្រដាប់ខ្វងខ្មៅដៃក្នុងថ្នាក់រៀន ដាក់នៅកម្ពស់ដែលអ្នកទាំងអស់គ្នាអាចយកដល់ឬទេ? | | | |
| ២១ | តើកម្ពស់តុសមល្មមឬទេ? | | | |
| ២២ | តើមានសម្ភារសិក្សា និងសម្ភារជំនួយបង្រៀនឬទេ? | | | |
| ២៣ | តើផ្ទាំងរូបភាពទាំងអស់ច្បាស់ និងអាចមើលឃើញឬទេ? | | | |
| ២៤ | តើពណ៌ និងកម្ពស់ក្ដារខៀនសមស្របឬទេ? | | | |
| ២៥ | តើថ្នាក់រៀនទាំងអស់មានខ្យល់ចេញចូលល្អឬទេ? | | | |
| ២៦ | តើពន្លឺនៅក្នុងថ្នាក់រៀនសមស្របឬទេ? | | | |
| ២៧ | តើមានកម្រាល និងរបាំងស្រូបសំឡេងរំខានឬទេ? | | | |
| ២៨ | តើមានបង្គន់ដែលអាចប្រើប្រាស់បាន (បង្គន់មានទីធ្លាទូលាយ និងមានបង្កាន់ដៃនៅក្នុងបង្គន់) ឬទេ? | | | |
| ២៩ | តើបង្គន់ស្អាត និងមានសុវត្ថិភាពឬទេ? | | | |
| ៣០ | តើមានក្បាលម៉ាស៊ីនទឹកសម្រាប់ផឹក ដាក់នៅកន្លែងដែលអ្នកគ្រប់គ្នាអាចប្រើប្រាស់បានឬទេ? | | | |
| ៣១ | តើកម្ពស់ក្បាលម៉ាស៊ីនទឹកអាចឱ្យ ក្មេងទាំងអស់ប្រើបានដែរឬទេ? | | | |
| ៣២ | តើក្បាលម៉ាស៊ីនទឹកងាយបើក និងបិទឬទេ? | | | |
| ៣៣ | តើមានបន្ទប់សម្រាប់ក្មេងស្រីផ្លាស់ប្ដូរសម្លៀកបំពាក់ឬទេ? | | | |
| ៣៤ | តើមានកម្មវិធីអាហារូបត្ថម្ភនៅសាលារៀនឬទេ? | | | |
| ៣៥ | ប្រសិនបើនៅក្នុងសាលារៀនមានកាំជណ្ដើរ តើមាន | | | |

| ល.រ | សំណួរ | បាទ/ចាស | ទេ | យោបល់ |
|---|---|---|---|---|
| | ច្រកជម្រាលចូលទៅកាន់បន្ទប់ឬទេ? | | | |
| ៣៦ | តើមានធុងសំរាមនៅជិតបន្ទប់ទឹកឬទេ? | | | |
| ៣៧ | តើមានសម្ភារលាងដៃនៅជិតបន្ទប់ទឹកឬទេ? | | | |
| ៣៨ | តើមានខ្យល់ចេញចូលល្អនៅក្នុងបង្គន់ឬទេ? | | | |
| ៣៩ | តើមានពន្លឺគ្រប់គ្រាន់នៅក្នុងបង្គន់ឬទេ? | | | |
| ៤០ | តើមានកន្លែងសុវត្ថិភាព ដែលកុមារធម្មតា និងកុមារពិការអាចលេងបានដែរឬទេ? | | | |
| ៤១ | តើមានឧបករណ៍ និងទីកន្លែងសម្រាប់កីឡា និងការកំសាន្តឬទេ? | | | |

# មេរៀនទី៦ ការយល់ដឹងពីវិធីសាស្ត្រពីររួមគ្នា (Twin Track Approach)

**គំរូពន្យល់វិធីសាស្ត្រពីររួមគ្នា (Twin Track Approach)[25]**




គោលគំនិតនៃវិធីសាស្ត្រពីររួមគ្នាត្រូវបានពន្យល់នៅក្នុងការពិពណ៌នានៃវិធីសាស្ត្រទី១ និងវិធីសាស្ត្រទី២ នៅក្នុងគំរូខាងលើ។ នៅពេលដោះស្រាយវិធីសាស្ត្រទី១វាទទួលបានលទ្ធផលសង្គមបរិយាបន្ន ហើយនៅពេលដោះស្រាយវិធីសាស្ត្រទី២វាទទួលបានលទ្ធផលការអប់រំបរិយាបន្ន ប៉ុន្តែវិធីសាស្ត្រទាំងពីរចាំបាច់ដើម្បីទទួលបានលទ្ធផលបរិយាបន្នពិតប្រាកដរបស់កុមារទាំងអស់នៅក្នុងការអប់រំ និងនៅក្នុងសង្គម។

[25] គំរូនេះត្រូវបានដកស្រង់ពីអង្គការ Light for the World

## សកម្មភាព ៦.១ ការយល់ដឹងពីវិធីសាស្ត្រពីររួមគ្នា (twin track approach)

### រយៈពេល៖ ៤៥នាទី

### វត្ថុបំណង៖

- ប្រាប់បានធាតុផ្សំ និងឧបសគ្គនៃការអប់រំបរិយាបន្នរបស់វិធីសាស្ត្រពីររួមគ្នា
- កំណត់បានធាតុផ្សំ និងឧបសគ្គនៃការអប់រំបរិយាបន្នរបស់វិធីសាស្ត្រពីររួមគ្នា។

### សម្ភារបង្រៀន និងរៀន៖

- គំរូចំនួនពីរនៃវិធីសាស្ត្រពីររួមគ្នា និងករណីសិក្សា។

### សកម្មភាពបង្រៀន ៖

ក. ឱ្យគរុសិស្សអាន និងស្វែងយល់ពីវិធីសាស្ត្រពីររួមគ្នាដែលបង្ហាញនៅក្នុងដ្យាក្រាមនៅទំព័របន្ទាប់។

ខ. ពិភាក្សាក្រុម

សំណួរ៖

- ចូរកំណត់ឧបសគ្គចំបងដែលមាននៅក្នុងករណីសិក្សាទាំងពីរ ដែលបានផ្ដល់ឱ្យ។
- ចូរកំណត់ធាតុផ្សំពីរនៃវិធីសាស្ត្រពីររួមគ្នា នៅក្នុងករណីសិក្សាទាំងពីរ។

គ.តំណាងក្រុមរាយការណ៍

ឃ.សំយោគ

វិធីសាស្ត្រពីររួមគ្នា (twin track approach)[26]




[26] DfID (២០០៤) *Disability* KAR Overseas Development Group ទំព័រ ៦

## វិធីសាស្ត្រពីររួមគ្នា [27]

**វិធីសាស្ត្រទី១:**
ការកែប្រែជាលក្ខណៈប្រព័ន្ធទូលំទូលាយ ឧ. គោលនយោបាយ ច្បាប់ ការផ្លាស់ប្តូរសាលារៀនទាំងមូល ។ល។

=

បញ្ញាបពិការភាព

- ច្បាប់ជាតិ
- សមធម៌
- បណ្តុះបណ្តាលគ្រូបង្រៀន



ការអប់រំបរិយាបន្ន

**វិធីសាស្ត្រទី២:**
បំពេញសេចក្តីត្រូវការបុគ្គល ឧ. លុបបំបាត់ឧបសគ្គ ដែលជួបប្រទះដោយកុមារម្នាក់ៗ

=

ផ្តល់សិទ្ធិអំណាចដល់

- វិធីសិក្សា
- ផែនការការអប់រំសម្រាប់សិស្សម្នាក់ៗ

---

[27] កែសម្រួលពី CBM (២០១២) *ការបង្កើតបរិយាបន្នឲ្យងាយស្រួល* ទំព័រ ២៣

## ករណីសិក្សាពីរនៅប្រទេសកម្ពុជា ដែលប្រើប្រាស់វិធីសាស្ត្រពីររួមគ្នា (twin track approach) [28]

### ១. ដោះស្រាយឧបសគ្គនៅក្នុងសាលារៀន

សុភាពគឺជាក្មេងប្រុសអាយុ១៦ឆ្នាំមានជំងឺដោនស៊ិនដ្រូម (Down's Syndrome) ដែលត្រូវបានបណ្តេញចេញពីសាលារៀនដោយសារតែបញ្ហាអាកប្បកិរិយា។ សុភាពតែងតែវាយតប់ក្មេងដទៃនៅពេលក្មេងនោះលេងសើច និងចំអកឱ្យវា។ មេរៀនលើកកម្ពស់ការយល់ដឹងជាមួយសិស្ស ដោយប្រើសៀវភៅភ្ញុករឿងគំនូរជីវចល និងផ្ទាំងរូបភាពបានលើកកម្ពស់សារអំពីការអត់ធ្មត់ និងការឱ្យតម្លៃភាពខុសៗគ្នា និងភាពចម្រុះគ្នា។ មេរៀននេះបានជួយបង្កើតសាមគ្គីភាពក្នុងចំណោមសិស្សទាំងអស់។

ឥឡូវសុភាពបានត្រឡប់មករៀននៅក្នុងសាលារៀនវិញ។ វាបានអភិវឌ្ឍបំណិនជីវិតរបស់វាហើយអាកប្បកិរិយារបស់សុភាពបានផ្លាស់ប្តូរយ៉ាងច្រើនចាប់តាំងពីមិត្តភក្តិនៅសាលារៀនរបស់វារាក់ទាក់ និងមានទំនាក់ទំនងវិជ្ជមានជាងមុន។

គ្រូបង្រៀនចល័តបានរៀបចំមេរៀនប្រចាំខែលើការធ្វើឱ្យការប្រាស្រ័យទាក់ទងជាមួយកុមារ ការគ្រប់គ្រងអាកប្បកិរិយា ការគ្រប់គ្រងថ្នាក់រៀន និងការកសាងទំនុកចិត្តរបស់កុមារបានប្រសើរឡើង។ មេរៀនទាំងនេះមានគោលបំណងរួមចំណែកកែលម្អគុណភាពអប់រំ។ គ្រូបង្រៀនមួយចំនួនមានភាពសកម្មក្នុងការអនុវត្តវិធីសាស្ត្រថ្មីទាំងនេះ ហើយមានឥទ្ធិពលដល់គ្រូបង្រៀនដទៃបន្តិចម្តងៗ។ គ្រូបង្រៀនរបស់សុភាពពេញចិត្តយ៉ាងខ្លាំងជាមួយនឹងការបណ្តុះបណ្តាលស្តីពីបទបញ្ជាផ្ទៃក្នុងថ្នាក់រៀន ពីព្រោះបទបញ្ជាផ្ទៃក្នុងដែលច្បាស់លាស់កំណត់ និងដាក់ឱ្យប្រើប្រាស់ដោយមានការចូលរួមពីសិស្សអាចឱ្យគ្រូបង្រៀនផ្តោតអារម្មណ៍លើការបង្រៀន និងគាំទ្រសិស្សច្រើនជាងការដាក់ពិន័យ។

ជារៀងរាល់ឆ្នាំ មេរៀនមួយចំនួនស្តីពីការបង្កើតសម្ភារបង្រៀន និងរៀនត្រូវបានរៀបចំនៅក្នុងសាលារៀននីមួយៗ។ សម្ភារដែលត្រូវបានបង្កើតឡើងទាំងនោះមានប្រយោជន៍សម្រាប់គាំទ្រវិធីរៀនផ្សេងៗ និងការរៀនតាមរយៈការលេង ដែលកែលម្អគុណភាពនៃការបង្រៀន។ សម្ភារបង្កើតឡើងនៅក្នុងមេរៀនទាំងនេះមានប្រយោជន៍ដល់សិស្សទាំងអស់ ហើយការកែសម្រួលអាចបំពេញសេចក្តីត្រូវការជាក់លាក់របស់កុមារពិការ។ ឧទាហរណ៍ គ្រូបង្រៀនប្រចាំថ្នាក់របស់រតនៈបានបង្កើតប័ណ្ណដែលមានពាក្យសរសេរជាភាសាខ្មែរ និងអក្សរប្រៃយ៍។ ការធ្វើបែបនេះ រតនៈអាចចូលរួមក្នុងការលេងជាមួយមិត្តរួមថ្នាក់។

---

[28] Bouille, S (២០១៣) *អភិវឌ្ឍគ្រូបង្រៀនចល័ត ដែលគាំទ្រវិធីសាស្ត្រពីររួមគ្នា (Twin-Track Approach) សម្រាប់ការអប់រំបរិយាបន្ន* កម្ពុជា Enabling Education Review ច្បាប់ចេញផ្សាយទី ២, EENET: Manchester

**ឧបសគ្គចម្បងនៅក្នុងករណីសិក្សារបស់សុភាព ដែលអាចរារាំងបរិយាបន្ន**
**ប្រសិនបើឧបសគ្គទាំងនោះមិនត្រូវបានដោះស្រាយ៖**

| **កម្រិតយុទ្ធសាស្ត្រ** | **កម្រិតបុគ្គល** |
|---|---|
| គ្រូបង្រៀនអាចមិនដឹងអំពីរបៀបបង្រៀនសុភាព | សុភាពត្រូវបានចំអក និងរើសអើង |
| ប្រហែលគ្រូមិនទទួលបានការបណ្តុះបណ្តាល | សុភាពត្រូវបានស្តីបន្ទោស |
| កុមារដទៃអាចបន្តចំអកឱ្យសុភាព | តម្រូវការសិក្សារបស់សុភាពប្រហែលមិនត្រូវបានគ្រូយកមកពិចារណា |
| សាលារៀនមិនទាន់ត្រៀមខ្លួនដាក់បញ្ចូលសុភាព | សុភាពត្រូវបានបោះបង់ចោលប្រឈមមុខនឹងការចំអក |
| ការលើកកម្ពស់ការយល់ដឹងជាមួយសិស្ស និងសហគមន៍ឪពុកម្តាយមិនត្រូវបានធ្វើឡើង | គ្រូបង្រៀនប្រហែលមិនប្រើគរុកោសល្យ ឬវិធីសាស្ត្របង្រៀនផ្សេងៗទៀត |
| គ្រូបង្រៀនអាចនៅតែមិនយល់ដឹងអំពីការបង្កើតសម្ភារបង្រៀនរៀន ដែលធ្វើឱ្យគុណភាពអប់រំសម្រាប់ទាំងអស់គ្នាបានប្រសើរឡើង | ការចំអកធ្វើឱ្យសុភាពវាយតប់កុមារដទៃ ដែលមានន័យថាសុភាពត្រូវបានដាត់ចេញ |
| គ្រូបង្រៀនប្រហែលជាមិនទទួលបានការបណ្តុះបណ្តាលលើការអប់រំបរិយាបន្ន។ | សុភាព និងសិស្សដទៃចូលរួមបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ថ្នាក់រៀន។ |

**២. ដោះស្រាយសេចក្តីត្រូវការរបស់កុមារពិការ**

ប្រព័ន្ធសាលារៀនបានផ្តល់ផលវិជ្ជមានសម្រាប់រតនៈដែលជាក្មេងប្រុសពិការភ្នែកអស់រយៈពេលសិក្សា ៣ឆ្នាំមកហើយ ដោយទទួលបានសម្ភារជំនួយដូចជាឧបករណ៍សរសេរអក្សរប្រៃយ៍ និងឧបករណ៍គិតលេខ(ក្បាច់)។ ឥឡូវរតនៈមានអាយុ១៥ឆ្នាំរៀនថ្នាក់ទី៤ ។ នៅក្នុងម៉ោងសិក្សា គ្រូចល័តម្នាក់បានជួយរតនៈមួយទល់នឹងមួយដើម្បីជួយរតនៈរៀនមេរៀនឱ្យទាន់គេ និងមានបំណិនជាក់លាក់។ មិនមានមេរៀន ឬលំហាត់ត្រូវបានរៀបចំពិសេសសម្រាប់តែរតនៈនោះទេ ប៉ុន្តែវិធីសាស្ត្របង្រៀនត្រូវបានកែសម្រួលសម្រាប់ភាពអន់ខ្សោយរបស់រតនៈ។ ការគាំទ្រប្រែប្រួលផ្អែកតាមការអភិវឌ្ឍរបស់រតនៈ។ ដំបូងការគាំទ្រធ្វើឡើងប្រចាំថ្ងៃ ឥឡូវនេះការគាំទ្រធ្វើឡើងប្រចាំសប្តាហ៍។ គ្រូបង្រៀនចល័តជួយគ្រូបង្រៀនប្រចាំថ្នាក់របស់រតនៈ តាមរយៈការផ្តល់យោបល់ និងបច្ចេកទេស ដូចជាការអានឱ្យឮនូវអ្វីដែលបានសរសេរនៅលើក្តារខៀន និយាយឡើងវិញឱ្យបានញឹកញាប់ និងផ្តល់ពេលបន្ថែមដល់រតនៈសរសេរអក្សរប្រៃយ៍ ឬប្រើប្រាស់ឧបករណ៍គិតលេខ។ ការជួយគាំទ្ររវាងមិត្តភក្តិក៏ត្រូវបានបង្កើតផងដែរ ដូច្នេះសិស្សផ្សេងទៀតអាចជួយរតនៈអំឡុងម៉ោងសិក្សានៅពេលរតនៈត្រូវការការពន្យល់បន្ថែម ឬការណែនាំ និងនៅពេលគ្រូបង្រៀនចល័តអវត្តមាន។ គ្រូបង្រៀនចល័តក៏ត្រូវមានតួនាទីកំណត់សេចក្តីត្រូវការជាក់លាក់របស់កុមារពិការផងដែរលើការថែទាំសុខភាព និងស្មារតីតិសម្បទា។

**តើកត្តាអ្វីខ្លះដែលជំរុញឱ្យរតនៈទទួលបានការអប់រំ?**

| កម្រិតយុទ្ធសាស្ត្រ | កម្រិតបុគ្គល |
|---|---|
| ប្រព័ន្ធគ្រូបង្រៀនចល័តត្រូវបានបង្កើតឡើង | រតនៈត្រូវបានបង្រៀនពីរបៀបប្រើអក្សរប្រៃយ៍ |
| សាលារៀនត្រៀមខ្លួនក្នុងការទទួលកុមារដែលត្រូវការសម្ភារជំនួយ | គ្រូបង្រៀនចល័តជួយរតនៈតែម្នាក់ |
| គ្រូបង្រៀនរបស់រតនៈទទួលបានការបណ្តុះបណ្តាល អំពីការប្រើអក្សរប្រៃយ៍ | ប្រព័ន្ធគាំទ្រមិត្តភក្តិត្រូវបានបង្កើតឡើងដើម្បីឱ្យសិស្សដទៃអាចជួយរតនៈបាន |
| គ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលអំពីការអប់រំបរិយាបន្ន | សេចក្តីត្រូវការបន្តបន្ទាប់របស់រតនៈត្រូវបានពិនិត្យពិចារណាជាប្រចាំ |
| ប្រព័ន្ធគាំទ្ររវាងមិត្តភក្តិត្រូវបានបង្កើតឡើង។ | ប្រព័ន្ធគាំទ្រប្រែប្រួលផ្អែកតាមសេចក្តីត្រូវការរបស់រតនៈ។ |

**ចូរកត់សម្គាល់ថា ករណីសិក្សាទាំងនេះមិនបានផ្តល់ព័ត៌មានអំពីការកែប្រែយុទ្ធសាស្ត្រផ្សេងនោះទេ គឺបានត្រឹមតែកម្រិតសាលារៀន និងសហគមន៍ប៉ុណ្ណោះ។ ករណីសិក្សាទាំងនេះគឺជាឧទាហរណ៍ល្អនៃគំនិតច្នៃប្រឌិតកម្រិតតូច។**

# ផ្នែកទី២

# ការស្វែងយល់អំពីវិធីបង្រៀនអប់រំបរិយាបន្ន

# មេរៀនទី៧ ការបង្ហាញវិធីបង្រៀនការអប់រំបរិយាបន្ន





© Michael Pitt

## សេចក្តីផ្តើម

ផ្នែកនេះមានមេរៀនចំនួន១២ដែលផ្តោតលើបញ្ញត្តិថ្មីៗអំពីវិធីបង្រៀនការអប់រំបរិយាបន្ន។

ដូច Florian និង Black-Hawkins[29] លើកឡើងថា "ជំនួសឱ្យការផ្តល់នូវអ្វីដែលខុសប្លែកសម្រាប់កុមារដែលជួបការពិបាកនៅក្នុងការរៀន ***វិធីបង្រៀនការអប់រំបរិយាបន្នព្យាយាមពង្រីកអ្វីដែលមានស្រាប់ឱ្យបានទៅដល់អ្នកគ្រប់គ្នា*** "។ នៅពេលកុមារជួបប្រទះការពិបាកនៅក្នុងការរៀន វាមិនមានប្រយោជន៍អ្វីនោះទេប្រសិនបើមិនធ្វើសកម្មភាពអ្វីសោះ។ មេរៀនទាំង១២ខាងក្រោមអាចឱ្យគ្រូបង្រៀនយល់ដឹងអំពីអ្វី ដែលពួកគេអាចធ្វើបានដើម្បីធានាបានថាកុមារទាំងអស់នៅក្នុងថ្នាក់រៀនអាចរៀនបាន។

វាមានប្រយោជន៍ក្នុងការគិតអំពីអ្វីដែលមិនមែនជាវិធីបង្រៀនការអប់រំបរិយាបន្ន និងអ្វីជាវិធីបង្រៀនការអប់រំបរិយាបន្ន ដូចការពណ៌នាខាងក្រោម[30]៖

វិធីបង្រៀនការអប់រំបរិយាបន្នមិនទទួលយកឬបដិសេធ៖

- ទស្សនៈ ដែលគិតថាកុមារមានសមត្ថភាពថេរតែមួយ
- ការរៀនរបស់កុមារពេលបច្ចុប្បន្នអាចយកទៅព្យាករណ៍សក្តានុពលនាពេលអនាគត
- បញ្ញាអាចកំណត់តាមរយៈការធ្វើតេស្ត ផ្អែកលើជំនាញតក្កវិជ្ជា គណិតវិទ្យា ទាញហេតុផល។ ផ្ទុយមកវិញវិធីបង្រៀនការអប់រំបរិយាបន្នមានជំនឿថា៖
- សមត្ថភាពកុមារគ្រប់គ្នាក្នុងការរៀនមានការផ្លាស់ប្តូរ
- អ្វីដែលគ្រូបង្រៀនជ្រើសរើសធ្វើ ឬមិនធ្វើនាពេលបច្ចុប្បន្នអាចផ្លាស់ប្តូរសមត្ថភាពរៀនរបស់កុមារនាពេលអនាគត

វិធីបង្រៀនការអប់រំបរិយាបន្នអាចត្រូវរៀបចំ និងអនុវត្តក្នុងរបៀបដែលពាក់ព័ន្ធ មានន័យគ្រប់គ្រាន់ និងអាចទទួលយកបានដោយកុមារទាំងអស់។ ការបន្តប្រើប្រាស់វិធីបង្រៀនបែបប្រពៃណីដែលកុមាររៀនរបៀបតែមួយដែលគ្រូបានបង្រៀនផ្តល់គុណវិបត្តិដល់កុមារដែលមានរបៀបរៀនខុសៗគ្នា។ ដូច្នេះថ្នាក់និងបរិយាកាសរៀនត្រូវផ្លាស់ប្តូរជាជាងរំពឹងថាកុមារទាំងអស់ត្រូវដាក់ពុម្ពតែមួយដូចគ្នា។

សកម្មភាពនៅក្នុងមេរៀនទី១២នៅផ្នែកទី២គរុសិស្សនឹងមានឱកាសរៀនបញ្ញត្តិ ដែលអាចឱ្យពួកគេអនុវត្តវិធីបង្រៀនការអប់រំបរិយាបន្នបាន ដូច្នេះគរុសិស្សត្រូវយល់ដឹងពី៖

- ចរិតលក្ខណៈនៃគ្រូបង្រៀនបរិយាបន្ន
- វិធីដែលគ្រូបង្រៀនអាចបំពេញសេចក្តីត្រូវការផ្សេងៗនៅក្នុងថ្នាក់រៀន
- ពហុបញ្ញា
- របៀបរៀន

---

[29] ពិពណ៌នាដោយសង្ខេបនូវអត្ថន័យនៃគរុកោសល្យបរិយាបន្ន និងបន្ទាប់មកកំណត់និយមន័យរបស់វាតាមរយៈការសួរ និងការឆ្លុះបញ្ចាំងនៅក្នុងអត្ថបទមួយនៅក្នុង British Educational Research Journal នៅក្នុងឆ្នាំ២០១១

[30] បទបង្ហាញដោយបណ្ឌិត Jennifer Spratt នៃសាកលវិទ្យាល័យ Aberdeen នៅក្នុង European Journal of Special Needs Education នៅក្នុងឆ្នាំ២០១៣

- ការកំណត់ឧបសគ្គដែលកុមារអាចមានក្នុងការរៀន
- មូលហេតុការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិតអាចលើកកម្ពស់ការរៀន
- ការដាក់បញ្ចូលកុមារទាំងអស់នៅក្នុងការរៀន តាមរយៈការប្រើប្រាស់ប្លង់សកលសម្រាប់ការរៀន (UDL)
- របៀបបង្កើតផែនការអប់រំសិស្សម្នាក់ៗមានប្រយោជន៍សម្រាប់គ្រូបង្រៀនដើម្បីតាមដានសេចក្ដីត្រូវការរបស់កុមារម្នាក់ៗដែលត្រូវការការគាំទ្របន្ថែម
- របៀបប្រើប្រាស់ "ការជួយជ្រោមជ្រែង" និង "ការញែកភាពខុសគ្នា" ធ្វើឱ្យសម្រេចបានការបំពេញសេចក្ដីត្រូវការរបស់កុមារទាំងអស់
- សារៈសំខាន់នៃជំនាញប្រាស្រ័យទាក់ទងសម្រាប់កុមារទាំងអស់ និងការបំពេញសេចក្ដីត្រូវការការប្រាស្រ័យទាក់ទងផ្សេងៗគ្នានៅក្នុងថ្នាក់រៀន
- ភាពខុសគ្នារវាងវិធីសាស្ត្ររៀនសកម្ម និងអកម្ម
- ប្រសិទ្ធភាពនៃការប្រើប្រាស់ការរៀនបែបសហការ
- ព័ត៌មានលម្អិតអំពីគន្លឹះនៃការបង្រៀនជាមូលដ្ឋានដែលអាចជួយកុមារពិការ
- របៀបផលិតសម្ភារបង្រៀន និងរៀនដោយខ្លួនឯង
- របៀបកំណត់ការគាំទ្របន្ថែមចាំបាច់សម្រាប់កុមារពិការ តាមរយៈការប្រើប្រាស់តារាងត្រួតពិនិត្យសាមញ្ញ
- ទីកន្លែងដែលគ្រូបង្រៀនអាចទៅរកការគាំទ្របន្ថែម ប្រសិនបើពួកគេត្រូវការ
- ឧបករណ៍ជំនួយផ្សេងៗ ដែលមានសម្រាប់កុមារ
- វិធីប្រើវិន័យវិជ្ជមាននៅក្នុងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព
- ភាពខុសគ្នារវាងទណ្ឌកម្ម និងវិន័យ
- វិធីប្រើប្រាស់ការវាយតម្លៃដោយត្រឹមត្រូវ និងផ្ដល់ដំណោះស្រាយសមស្រប ទោះបីនៅក្នុងការវាយតម្លៃការរៀន។

ឯកសារការអប់រំបរិយាបន្ននេះបានផ្ដល់ព័ត៌មានមូលដ្ឋានអំពីវិធីសាស្ត្របង្រៀនការអប់រំបរិយាបន្នខាងលើតែប៉ុណ្ណោះ។ វាពឹងផ្អែកទៅលើគ្រូបង្រៀនក្នុងការរៀនសូត្របន្ថែមអំពីចំណុចទាំងអស់នេះតាមរយៈឯកសារអានបន្ថែមដែលបានផ្ដល់ឱ្យ និងតាមរយៈការស្រាវជ្រាវនៅលើអ៊ីនធើណែត។

## ឯកសារអានសម្រាប់ផ្នែកទី២៖

(សម្ភារបង្រៀន និងរៀនទាំងអស់ និងឯកសារអានមាននៅក្នុង DVD)

- ឯកសារបោះពុម្ពទីភ្នាក់ងារអភិវឌ្ឍអ៊ីរ៉ុបអំពីការអប់រំសេចក្តីត្រូវការពិសេសឈ្មោះ "លក្ខណៈសម្បត្តិនៃគ្រូបង្រៀនបរិយាបន្ន"(មេរៀនទី៧)
- "កូនសៀវភៅបច្ចេកទេស គ្រូបង្រៀន ការបង្រៀន និងគរុកោសល្យកុមារមជ្ឈមណ្ឌលបែបបរិយាបន្ន Webinar -12 បទដ្ឋាន 2.3"" របស់អង្គការ UNICEF' (មេរៀនទី ៧)
- ឯកសារបោះពុម្ពអង្គការ UNESCO ឈ្មោះ "ទទួលយកភាពចម្រុះ ឧបករណ៍សម្រាប់បង្កើតបរិស្ថានអ្នកសិក្សាមេត្រី និងបរិយាបន្នសម្រាប់សិស្ស" (មេរៀនទី ៧)
- ឯកសារបោះពុម្ពក្រសួងអប់រំ ប្រទេសម៉ាលឌីវ និង UNICEF ឈ្មោះ ការបង្រៀន និងរៀនបែបមជ្ឈមណ្ឌល
- បទបង្ហាញ និងកំណត់ត្រាសិក្ខាសាលាស្តីពីរបៀបរៀនដោយសកលវិទ្យាល័យ Wilfrid Laurier University កាណាដា (មេរៀនទី១១)
- សមាគមការលេងអន្តរជាតិ (២០១៤) សេចក្តីប្រកាសស្តីពីសារៈសំខាន់នៃការលេង (មេរៀនទី១០)
- សៀវភៅមគ្គុទេសក៍ស្តីពីការរៀនតាមរយៈសិល្បៈច្នៃប្រឌិតដោយ Epic Arts និង Aide et Action. (មេរៀនទៅ១០)
- សៀវភៅមគ្គុទេសក៍ស្តីពីការរៀនតាមរយៈលេងដោយ Epic Arts និង Aide et Action. (មេរៀនទៅ១០)
- ជំរុញការបញ្ចេញគំនិតបែបសិល្បៈ និងច្នៃប្រឌិតរបស់កុមារ ដោយLearning Links, អូស្ត្រាលី (មេរៀនទី១០)



## សកម្មភាព ៧.១ លក្ខណៈសម្បត្តិគ្រូបង្រៀនបរិយាបន្ន

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង៖**

- កំណត់លក្ខណៈសម្បត្តិគ្រូបង្រៀនបរិយាបន្ន
- ប្រៀបធៀបគ្រូបង្រៀនបរិយាបន្ន និងគ្រូបង្រៀនដែលនាំឱ្យមានការផាត់ចេញ។

**សម្ភារបង្រៀន និងរៀន៖**

- ល្បែងប័ណ្ណ

**សកម្មភាពបង្រៀន ៖**

ក. ឱ្យគរុសិស្សពិភាក្សាតាមក្រុមតូចធ្វើចំណែកថ្នាក់លក្ខណៈសម្បត្តិគ្រូបង្រៀនបរិយាបន្ន និងគ្រូបង្រៀនដែលនាំឱ្យមានការផាត់ចេញ

( សកម្មភាពនេះត្រូវបានកែសម្រួលពីការបូកបញ្ចូលគ្នា នៃអង្គការ UNICEF[31] និងអង្គការUNICEF/ក្រសួងអប់រំប្រទេសម៉ាល់ឌីវ[32])

ខ.តំណាងក្រុមរាយការណ៍

គ. សំយោគ

ខ្លឹមសារក្នុងប័ណ្ណមានដូចខាងក្រោម

| | |
|---|---|
| គ្រូបង្រៀនរបស់ខ្ញុំអនុញ្ញាតឱ្យខ្ញុំចែករំលែកគំនិតយោបល់នៅក្នុងថ្នាក់ | គ្រូបង្រៀនរបស់ខ្ញុំវាយខ្ញុំ នៅពេលខ្ញុំមិនអាចឆ្លើយសំណួរបានទាន់ពេល |
| គ្រូបង្រៀនរបស់ខ្ញុំធ្វើសញ្ញា និងនិយាយក្នុងពេលជាមួយគ្នា នៅពេលបង្រៀនយើង ពីព្រោះយើងមានសិស្សដែលមានបញ្ហាស្តាប់នៅក្នុងថ្នាក់ | គ្រូបង្រៀនរបស់ខ្ញុំនិយាយទៅកាន់ឪពុកម្តាយ និងគ្រូបង្រៀនដទៃទៀតប្រសិនបើពួកគេត្រូវការព័ត៌មានបន្ថែមអំពីខ្ញុំ |
| គ្រូបង្រៀនរបស់ខ្ញុំគោរពខ្ញុំ និងមិនខឹង នៅពេលខ្ញុំបាត់បង់ការផ្តោតអារម្មណ៍នៅក្នុងថ្នាក់ | គ្រូបង្រៀនរបស់ខ្ញុំមិនបញ្ឈប់សិស្សដទៃដែលចំអកខ្ញុំនៅពេលខ្ញុំឆ្លើយខុស |
| គ្រូបង្រៀនរបស់ខ្ញុំឱ្យយើងស្វែងរកវិធី ដែលយើងម្នាក់ៗរៀនមានប្រសិទ្ធភាពជាងគេនិងបង្ហាញយើងនូវវិធីរៀនបានល្អ | គ្រូបង្រៀនរបស់ខ្ញុំប្រើប្រាស់វិធីសាស្ត្រផ្សេងៗបង្រៀនយើងលើមេរៀនដដែលដូច្នេះយើងទាំងអស់គ្នាអាចរៀនបាន |
| គ្រូបង្រៀនរបស់ខ្ញុំមិនអនុញ្ញាតឱ្យយើងនិយាយនៅក្នុងថ្នាក់រៀនលើកលែងតែយើងឆ្លើយសំណួររបស់គាត់ | គ្រូបង្រៀនរបស់ខ្ញុំឱ្យយើងធ្វើការជាក្រុម និងឱ្យយើងជួយគ្នាទៅវិញទៅមកក្នុងការរៀន |
| នៅពេលយើងមិនគោរពវិន័យនៅក្នុងថ្នាក់ គ្រូបង្រៀនរបស់ខ្ញុំឱ្យយើងដាក់ទណ្ឌកម្មខ្លួនឯង។ | គ្រូបង្រៀនខ្ញុំលើកទឹកចិត្តឱ្យយើងចាប់ដៃគូជាមួយមិត្តភក្តិដែលអាចពន្យល់បានល្អ និងជួយយើងឱ្យយល់កិច្ចការដែលពិបាក |
| គ្រូបង្រៀនរបស់ខ្ញុំបង្កើតសកម្មភាព | គ្រូបង្រៀនខ្ញុំស្រែក និងហៅយើងអាក្រក់ |

[31] ក្រសួងអប់រំប្រទេសម៉ាល់ឌីវនិង UNICEF (២០១០) *បទដ្ឋានបង្រៀន និងរៀនសិស្សមជ្ឈមណ្ឌល* ២.៣ ទំព័រ ៧&៨

[32] UNICEF ប្រទេសម៉ាសេដូនី (២០១២) *មេរៀនទី៤នៃវគ្គបណ្តុះបណ្តាលគ្រូបង្រៀនអប់រំបរិយាបន្ន*

| | |
|---|---|
| ឱ្យយើងច្រៀង និងគូរគំនូរ | ប្រសិនបើយើងមានកំហុស ឬសុំឱ្យពន្យល់អ្វីមួយម្តងទៀត |
| គ្រូបង្រៀនរបស់ខ្ញុំតែងតែប្រើប្រាស់ទូរស័ព្ទដៃ ជំនួសឱ្យការបង្រៀនយើង | គ្រូបង្រៀនខ្ញុំសរសើរតែសិស្សពូកែ |
| គ្រូបង្រៀនរបស់ខ្ញុំមានផ្ទាំងរង្វាន់លើជញ្ជាំង ដែលមានឈ្មោះអ្នកដែលធ្វើល្អជាងគេក្នុងមុខវិជ្ជាម្នាក់ៗ អ្នកដែលរីកចម្រើនគួរឱ្យកោតសរសើរ និងអ្នកដែលមានគំនិតច្នៃប្រឌិតឱ្យមានប្រយោជន៍ និងជាសមាជិកក្រុមល្អ | ពេលខ្លះគ្រូបង្រៀនខ្ញុំបង្រៀនមេរៀននៅក្រៅថ្នាក់រៀន<br>គ្រូបង្រៀនខ្ញុំចំណាយពេលវេលាយូរ ក្នុងការដាក់ពិន្ទុ ឬកិច្ចការផ្ទះរបស់យើង |
| គ្រូបង្រៀនខ្ញុំលើកទឹកចិត្តខ្ញុំឱ្យមករៀន ទោះបីខ្ញុំមិនចង់ក៏ដោយ | គ្រូបង្រៀនខ្ញុំមិនអនុញ្ញាតឱ្យខ្ញុំទៅបន្ទប់ទឹក នៅពេលខ្ញុំចាំបាច់ត្រូវទៅ |
| គ្រូបង្រៀនខ្ញុំតែងតែឱ្យយើងអង្គុយ ជាជួរតាមលំដាប់អក្សរនៃឈ្មោះរបស់យើង | គ្រូបង្រៀនខ្ញុំតែងតែនិយាយថា អ្នកគ្រប់គ្នាសំខាន់ និងមានទេពកោសល្យពិសេស |
| គ្រូបង្រៀនខ្ញុំដាក់សិស្សរៀនយឺត និងសិស្សពិការនៅក្នុងក្រុមតែមួយ | គ្រូបង្រៀនខ្ញុំសរសេរមេរៀននៅលើក្តារខៀន និងឱ្យយើងអានឱ្យឮ និងអានសារឡើងវិញ |
| គ្រូបង្រៀនខ្ញុំស្តាប់ខ្ញុំ និងតែងតែញញឹម | គ្រូបង្រៀនខ្ញុំឱ្យតម្លៃដែលមិត្តរួមថ្នាក់ និងខ្ញុំមានសេចក្តីត្រូវការផ្សេងគ្នា |
| គ្រូបង្រៀនខ្ញុំបន្តរៀនអំពីការបង្រៀនពួកយើង។ | គ្រូបង្រៀនខ្ញុំដាក់ការងារឱ្យយើង និងបន្ទាប់មកចាកចេញពីថ្នាក់រៀន។ |

**ចម្លើយរំពឹងទុក៖**

| គ្រូបង្រៀនបរិយាប័ន្ន | គ្រូបង្រៀនដែលនាំឱ្យមានការផាត់ចេញ |
|---|---|
| គ្រូបង្រៀនរបស់ខ្ញុំអនុញ្ញាតឱ្យខ្ញុំចែករំលែក គំនិតយោបល់នៅក្នុងថ្នាក់ | គ្រូបង្រៀនរបស់ខ្ញុំវាយខ្ញុំ នៅពេលខ្ញុំមិនអាចឆ្លើយ សំណួរបានទាន់ពេល |
| គ្រូបង្រៀនរបស់ខ្ញុំធ្វើសញ្ញា និងនិយាយក្នុងពេលជាមួយគ្នានៅពេលបង្រៀនយើង ពីព្រោះយើងមានសិស្សដែលមានបញ្ហាស្តាប់នៅក្នុងថ្នាក់ | គ្រូបង្រៀនរបស់ខ្ញុំមិនបញ្ឈប់សិស្សដទៃដែលចំអកខ្ញុំនៅ ពេលខ្ញុំឆ្លើយខុស |
| គ្រូបង្រៀនរបស់ខ្ញុំគោរពខ្ញុំ និងមិនខឹង នៅពេលខ្ញុំបាត់បង់ការផ្តោតអារម្មណ៍នៅក្នុងថ្នាក់ | គ្រូបង្រៀនរបស់ខ្ញុំមិនអនុញ្ញាតឱ្យយើងនិយាយនៅក្នុងថ្នាក់ រៀន ដរាបណាយើងឆ្លើយសំណួររបស់គាត់ |
| គ្រូបង្រៀនរបស់ខ្ញុំឱ្យយើងស្វែងរកវិធី ដែលយើងម្នាក់ៗ រៀនមានប្រសិទ្ធភាពជាងគេ និងបង្ហាញយើងនូវវិធីសាស្ត្រសិក្សាល្អៗ | គ្រូបង្រៀនខ្ញុំស្រែក និងហៅយើងអាក្រក់ប្រសិនបើយើង មានកំហុសឬសុំឱ្យពន្យល់អ្វីមួយម្តងទៀត |
| គ្រូបង្រៀនរបស់ខ្ញុំឱ្យយើងធ្វើការជាក្រុម និងឱ្យយើងជួយគ្នាទៅវិញទៅមកក្នុងការរៀន | គ្រូបង្រៀនរបស់ខ្ញុំតែងតែប្រើប្រាស់ទូរស័ព្ទដៃជំនួសឱ្យការ បង្រៀនពួកយើង |
| នៅពេលយើងមិនគោរពវិន័យនៅក្នុងថ្នាក់ គ្រូបង្រៀនរបស់ខ្ញុំឱ្យយើងសម្រេចទណ្ឌកម្មខ្លួនឯង។ | គ្រូបង្រៀនខ្ញុំចំណាយពេលវេលាយូរក្នុងការដាក់ពិន្ទុ សៀវភៅ ឬកិច្ចការផ្ទះរបស់យើង |

| | |
|---|---|
| គ្រូបង្រៀនខ្ញុំលើកទឹកចិត្តឱ្យយើងចាប់ដៃគូជាមួយមិត្តភក្តិ ដែលអាចពន្យល់បានល្អ និងជួយយើងឱ្យយល់កិច្ចការដែលពិបាក | គ្រូបង្រៀនខ្ញុំមិនឱ្យខ្ញុំទៅបន្ទប់ទឹក នៅពេលខ្ញុំចាំបាច់ត្រូវទៅ |
| គ្រូបង្រៀនរបស់ខ្ញុំបង្កើតសកម្មភាព ឱ្យយើងច្រៀង និងគូរគំនូរ | |
| គ្រូបង្រៀនរបស់ខ្ញុំមានផ្ទាំងរង្វាន់លើជញ្ជាំង ដែលមានឈ្មោះអ្នកដែលធ្វើល្អជាងគេក្នុងមុខវិជ្ជាម្នាក់ៗ អ្នកដែលរីកចម្រើនគួរឱ្យកោតសរសើរ និងអ្នកដែលថ្ងៃប្រឹងប្រែងឧស្សាហ៍ជួយយកអាសារ និងជាសមាជិកក្រុមល្អ | គ្រូបង្រៀនខ្ញុំដាក់សិស្សរៀនយឺត និងសិស្សពិការ នៅក្នុងក្រុមតែមួយ |
| ពេលខ្លះគ្រូបង្រៀនខ្ញុំបង្រៀនមេរៀននៅក្រៅថ្នាក់រៀន | គ្រូបង្រៀនខ្ញុំសរសេរមេរៀននៅលើក្តារខៀន និងឱ្យយើងអានឱ្យឮ និងអានសារឡើងវិញ |
| គ្រូបង្រៀនខ្ញុំលើកទឹកចិត្តខ្ញុំឱ្យមករៀន ទោះបីខ្ញុំមិនចង់ | |
| គ្រូបង្រៀនខ្ញុំឱ្យតម្លៃដែលមិត្តរួមថ្នាក់របស់ខ្ញុំ និងខ្ញុំមាន សេចក្តីត្រូវការផ្សេងគ្នា | គ្រូបង្រៀនខ្ញុំដាក់ការងារឱ្យយើង និងបន្ទាប់មកចាក ចេញពីថ្នាក់រៀន |
| គ្រូបង្រៀនខ្ញុំបន្តរៀនអំពីការបង្រៀនពួកយើង | |
| គ្រូបង្រៀនរបស់ខ្ញុំនិយាយទៅកាន់ឪពុកម្តាយ និងគ្រូបង្រៀនដទៃទៀត ប្រសិនបើពួកគេត្រូវការ ព័ត៌មានបន្ថែមអំពីខ្ញុំ | |

## ចំណុចគន្លឹះ:[33]

- ការអប់រំបរិយាបន្នគឺជាការទទួលខុសត្រូវរបស់គ្រូបង្រៀនទាំងអស់។
- ការអប់រំរិយាបន្នគឺជាដំណើរការជានិរន្ត គ្រូបង្រៀនត្រូវមានឆន្ទៈរៀនជំនាញ និងចំណេះដឹងថ្មី ពីព្រោះមិនមានជំនាញ និងចំណេះដឹងជាក់លាក់តែមួយដែលគ្រូបង្រៀនអាចទទួលបាន ដើម្បីឱ្យក្លាយជាគ្រូបង្រៀនបរិយាបន្ននោះទេ។
- ការអប់រំបរិយាបន្នទាមទារការឆ្លុះបញ្ចាំងជាបន្តបន្ទាប់សម្រាប់គ្រូបង្រៀនឆ្លុះបញ្ចាំងអំពីសេចក្តីត្រូវការចម្រុះគ្នារបស់សិស្សនៅក្នុងថ្នាក់រៀន។
- តម្លៃ និងឥរិយាបថបរិយាបន្នមានសារៈសខាន់សម្រាប់គ្រូបង្រៀនបរិយាបន្ន។

[33] កែសម្រួលពី UNICEF (២០១៤) – Webinar 12 – គ្រូបង្រៀន គរុកោសល្យ និងការបង្រៀនកុមារមជ្ឈមណ្ឌលបែបបរិយាបន្ន – គោលការណ៍ណែនាំ ទំព័រ ៨

## សកម្មភាព ៧.២  ការបំពេញតម្រូវការផ្សេងៗគ្នារបស់កុមារ

## រយៈពេល៖ ៤៥នាទី

## វត្ថុបំណង៖

- កំណត់បានរបៀបដែលគ្រូបង្រៀនអាចបំពេញតម្រូវការផ្សេងៗគ្នារបស់កុមារនៅក្នុងថ្នាក់រៀន។

## សម្ភារបង្រៀន និងរៀន៖

- វីដេអូអង្គការ UNICEF ឈ្មោះជីវិត ២ ដែលនៅចម្ងាយ២ម៉ែយ៍ពីគ្នា
- ផ្ទាំងរូបភាព INEE ឈ្មោះគ្រូបង្រៀនអាចជួយអ្នកគ្រប់គ្នារៀន
- ផ្ទាំងរូបភាពរបស់អង្គការ World Vision ឈ្មោះកុមារប្រទេសអាមេនីបញ្ចេញមតិយើងជឿថា គ្រូបង្រៀនល្អ ...

## សកម្មភាពបង្រៀន៖

- បញ្ចាំងវីដេអូ ជីវិត ២ ដែលនៅចម្ងាយ២ម៉ែយ៍ពីគ្នា
- ពិភាក្សាសំណួរ៖
  តើតម្លៃ ជំនាញ និងឥរិយាបថគ្រូបង្រៀនរបស់ Laura និង Carlos មានឥទ្ធិពលដល់ការរៀនរបស់ពួកគេយ៉ាងដូចម្ដេច?
- តំណាងគរុសិស្សរាយការណ៍
- សំយោគ

*ចម្លើយរំពឹងទុក*

- គ្រូបង្រៀនជឿថា កុមារពិការមានសិទ្ធិទទួលបានការអប់រំ។
- ពួកគេធានាថា Laura និងCarlos អាចចូលរួមនៅក្នុងការរៀន។
- ពួកគេជំរុញឱ្យ Laura និង Carlos មានសេចក្ដីប្រាថ្នាដោយLaura ចង់ក្លាយជាគិលានុបដ្ឋាកយិកា និង Carlos ចង់ក្លាយជាគ្រូពេទ្យ។
- អ្នកទាំងពីរនិយាយថា ការអត់ធ្មត់របស់គ្រូបង្រៀនជួយពួកគេក្នុងការរៀន។
- អ្នកទាំងពីរត្រូវបានជួយដោយគ្រូបង្រៀន សម្រាប់ Carlos គ្រូពន្យល់ច្រើនដង និងសម្រាប់ Laura ផ្ដល់ពេលវេលាច្រើនឱ្យសរសេរ។
- គ្រូបង្រៀនគឺជាគំរូល្អសម្រាប់សិស្សដទៃ។
- Laura និង Carlos គោរពគ្រូបង្រៀនពួកគេ ដែលបង្ហាញថាគ្រូបង្រៀនក៏គោរពពួកគេផងដែរ។

ពាក្យនិយាយរបស់កុមារពីផ្ទាំងរូបភាពទាំងពីរ៖

- គ្រូបង្រៀនគួរធ្វើការងារដើម្បីសិស្ស និងមិនមែនដើម្បីតែប្រាក់នោះទេ។
- គ្រូបង្រៀនគួរចាប់អារម្មណ៍លើលទ្ធផល (លទ្ធផលសិក្សា) របស់សិស្សទាំងអស់។
- មិនឱ្យនរណាម្នាក់ឯកោ។
- គាំទ្រកុមារដែលមានការលំបាកទៅសាលារៀន តាមរយៈទាក់ទងកុមារដទៃឱ្យជួយ។
- ចាត់ទុកសិស្សទាំងអស់ដោយស្មើភាព។
- គ្រូបង្រៀនហៅឈ្មោះសិស្សគ្រប់គ្នា ដូច្នេះត្រូវការពេលវេលាដើម្បីស្គាល់ពួកគេ។

# មេរៀនទី៨ ការស្វែងយល់ពហុបញ្ញា និងរបៀបរៀន





© Michael Pitt

## សកម្មភាព ៨.១ ការស្វែងយល់បញ្ញត្តិពហុបញ្ញា

**រយៈពេល៖ ៤៥នាទី**

**វត្ថុបំណង៖**

- កំណត់បានបញ្ញត្តិពហុបញ្ញា
- រៀបចំយុទ្ធវិធីសម្រាប់សិស្សដែលមានពហុបញ្ញាផ្សេងៗគ្នា។

**សម្ភារបង្រៀន និងរៀន៖**

- ឯកសារអានរបស់Howard Grant
- តារាងផ្ទៀងផ្ទាត់Sandrine Boah-Jacquot

**សកម្មភាពបង្រៀន ៖**

ក. ឱ្យគរុសិស្សអានព័ត៌មានអំពីពហុបញ្ញាតាមក្រុម

ខ. ឱ្យគរុសិស្សតាមក្រុមបំពេញឈ្មោះពហុបញ្ញា ដែលត្រូវទៅនឹងខ្លឹមសារដែលពិពណ៌នា

គ. តំណាងក្រុមរាយការណ៍

ឃ. សំយោគ

(ប្រសិនបើមានលទ្ធភាព គរុសិស្សអាចចូលទៅកាន់អ៊ីនធើណែតដើម្បីធ្វើតេស្តខ្លួនឯង តើពហុបញ្ញារបស់ពួកគេមួយណាខ្លាំងជាង។ ការធ្វើតេស្តនេះអាចបំពេញបាននៅលើអាសយដ្ឋានគេហទំព័រនេះ៖ http://www.literacynet.org/mi/assessment/findyourstrengths.html)

**សារគន្លឹះ៖**

- អ្នកគ្រប់គ្នារៀនខុសៗគ្នា និងមានពហុបញ្ញាផ្សេងៗគ្នា។
- ពហុបញ្ញាមិនដំណើរការដាច់ដោយឡែកពីគ្នានោះទេ ហើយបុគ្គលអាចមានចំណង់ចំណូលចិត្តលើពហុបញ្ញាមួយចំនួននៃពហុបញ្ញារបស់ពួកគេ។
- កុមារដែលរៀនគណិតលេខពូកែមិនមែនមានន័យថា មានបញ្ញាឆ្លាតវៃជាងកុមារដែលមានការលំបាកក្នុងការគណលេខនោះទេ។
- កុមារដែលមានពិការភាពដូចគ្នាមិនមានពហុបញ្ញាដូចគ្នានោះទេ។
- កុមារអាចរៀនអភិវឌ្ឍពហុបញ្ញា ដែលមិនមែនជាចំណុចខ្លាំងរបស់ពួកគេ។

## ពហុបញ្ញា ដោយ Howard Grant[34]

**បញ្ញាខាងភាសា** (អ្នកពូកែខាងពាក្យ)ទាក់ទងទៅនឹងការងាយយល់ដឹងភាសានិយាយ និងសរសេរ សមត្ថភាពក្នុងការរៀនភាសា និងសមត្ថភាពក្នុងការប្រើភាសាដើម្បីសម្រេចគោលដៅ។ បញ្ញានេះរួមមាន សមត្ថភាពប្រើប្រាស់ភាសាប្រកបដោយប្រសិទ្ធភាពដើម្បីបញ្ចេញមតិយោបល់បែបវោហាសាស្ត្រ និងជាកាព្យនិទាន ហើយភាសាត្រូវបានប្រើប្រាស់ជាមធ្យោបាយដើម្បីចងចាំព័ត៌មាន។ អ្នកនិពន្ធ កវី មេធាវី និងវាគ្មិនស្ថិតក្នុង ចំណោមអ្នកដែលលោក Howard Gardner មើលឃើញថាជាបុគ្គលដែលមានបញ្ញាខាងភាសាខ្ពស់។

**បញ្ញាខាងតក្កគណិតវិទ្យា** (អ្នកពូកែខាងលេខ)សំដៅទៅដល់សមត្ថភាពវិភាគបញ្ហាបែបតក្កវិទ្យាបំពេញ ការងារគណិតវិទ្យា និងអង្កេតបញ្ហាបែបវិទ្យាសាស្ត្រ។ នៅក្នុងពាក្យសំដីរបស់ Howard Gardner បញ្ញានេះ ពាក់ព័ន្ធទៅដល់សមត្ថភាពរកឃើញគំរូធ្វើសុភវិនិច្ឆ័យបែបអនុមានញែក និងគិតបែបតក្កវិទ្យា។ បញ្ញានេះភាគ ច្រើនទាក់ទងទៅនឹងការគិតបែបវិទ្យាសាស្ត្រ និងគណិតវិទ្យា។

**បញ្ញាខាងតូរ្យតន្ត្រី** (អ្នកពូកែខាងតូរ្យតន្ត្រី)ទាក់ទងទៅនឹងជំនាញក្នុងការសម្តែង ការនិពន្ធបទភ្លេង និងការពេញចិត្តគំរូលំនាំតូរ្យតន្ត្រី ។ វាគ្របដណ្តប់សមត្ថភាពសម្គាល់ និងតាក់តែងការលើកដាក់សំឡេង និងចង្វាក់តន្ត្រី។ យោងតាម Howard Gardner បញ្ញាតូរ្យតន្ត្រីមានទ្រង់ទ្រាយស្របគ្នាជាមួយបញ្ញាខាងភាសា។

**បញ្ញាខាងកាយសម្បទា** (អ្នកពូកែខាងកាយសម្បទា)សំដៅទៅដល់សក្តានុពលនៃការប្រើប្រាស់រាង កាយទាំងមូល ឬផ្នែកនៃរាងកាយដើម្បីដោះស្រាយបញ្ហា។ បញ្ញានេះគឺជាសមត្ថភាពក្នុងការប្រើប្រាស់សមត្ថភាព សតិបញ្ញាដើម្បីធ្វើចលនារាងកាយ។ Howard Gardner យល់ឃើញថាសកម្មភាពសតិបញ្ញា និងរាងកាយ ពាក់ព័ន្ធនឹងគ្នា។

**បញ្ញាខាងមើលលំហ** (អ្នកពូកែខាងមើលរូបភាព)ទាក់ទងទៅនឹងសក្តានុពលក្នុងការស្គាល់ និងប្រើគំរូ លំហទូលាយ និងកន្លែងរួមតូច។

**បញ្ញាខាងទំនាក់ទំនង** (អ្នកពូកែខាងទំនាក់ទំនងជាមួយមនុស្ស)ទាក់ទងទៅនឹងសមត្ថភាពក្នុងការយល់ ដឹងអំពីចេតនា ការជំរុញទឹកចិត្ត និងបំណងប្រាថ្នារបស់មនុស្សដទៃ។ បញ្ញានេះអាចឱ្យមនុស្សធ្វើការប្រកបដោយ ប្រសិទ្ធភាពជាមួយអ្នកដទៃ។ អ្នកអប់រំ អ្នកលក់ មេដឹកនាំសាសនា និងនយោបាយ និងអ្នកប្រឹក្សាទាំងអស់ ត្រូវការបញ្ញាខាងទំនាក់ទំនងល្អ។

**បញ្ញាខាងអារម្មណ៍ ឬក្នុងចិត្ត** (អ្នកពូកែខាងអារម្មណ៍ក្នុងចិត្ត)ពាក់ព័ន្ធនឹងសមត្ថភាពយល់ពីខ្លួនឯង យល់ដឹងអារម្មណ៍ ការភ័យខ្លាច និងការជំរុញទឹកចិត្តរបស់នរណាម្នាក់។ ផ្អែកតាមទស្សនៈរបស់ Howard Gardner បញ្ញានេះទាក់ទងទៅនឹងគំរូនៃការធ្វើការប្រកបដោយប្រសិទ្ធភាពរបស់ខ្លួនយើង និងអាចប្រើប្រាស់ ព័ត៌មានទាំងនោះ ដើម្បីចាត់ចែងជីវិតរបស់យើង។

**បញ្ញាខាងធម្មជាតិ** (អ្នកពូកែខាងធម្មជាតិ)ពាក់ព័ន្ធនឹងការសង្កេតការយល់ដឹង និងការរៀបចំលំនាំនៅ ក្នុងបរិយាកាសធម្មជាតិ។ របស់មួយចំនួនដែលជាចំណាប់អារម្មណ៍បុគ្គលមានបញ្ញាខាងធម្មជាតិ មានរុក្ខជាតិ សត្វ អាកាសធាតុ សមុទ្រ និងភ្នំ។

[34] ព័ត៌មាននេះមានដកស្រង់ពីគេហទំព័រអនឡាញ Infed.org/mobi/howard-gardner-multiple-intelligences-and-education/

## បំពេញឈ្មោះពហុបញ្ញាដែលត្រូវទៅនឹងខ្លឹមសារខាងក្រោម[35]

ក. ....................................................
- ការពិភាក្សា
- ការបង្រៀនដោយមិត្តភក្តិ
- ការសង្ខេបជាក្រុម
- គម្រោងជាក្រុម
- ការសម្ដែងតួ
- កិច្ចសម្ភាសន៍
- លេងជាកេម

ខ. ....................................................
- កត់ត្រាសកម្មភាពប្រចាំថ្ងៃផ្ទាល់ខ្លួន
- សកម្មភាពត្រិះរិះពិចារណា
- ការស្រាវជ្រាវ
- គូរដោយសេរី
- ការអានដោយស្ងៀមស្ងាត់
- ការបង្រៀនសិស្សក្មេងៗ

គ. ....................................................
- ការបង្ហាញ
- ដ្យាក្រាម
- ផែនទី
- គំនូរ
- លាយពណ៌
- ការសរសេរអត្ថបទ

ឃ. ....................................................
- ចម្រៀង
- ចង្វាក់ភ្លេង
- ការរាំ
- កំណាព្យ
- អានឱ្យឮទាំងអស់គ្នា
- ទះដៃ

ង. ....................................................
- បង្កើតនាឡិកា
- ការពិភាក្សា
- ល្បែងប័ណ្ណ
- ល្បែងយុទ្ធសាស្ត្រ (ឧ. ល្បែងអុក)
- ការគណនាតាមនព្វន្តសាស្ត្រ
- ការដោះស្រាយបញ្ហា

ច. ....................................................
- ចម្រៀង
- ល្បែងគូសពាក្យ
- កំណាព្យ
- បទបង្ហាញផ្ទាល់មាត់
- ការពិភាក្សា
- ការអានរឿង
- ការសម្ដែងតួ

ឆ. ....................................................
- ការសង្កេត
- ការសាងសង់
- ការចាត់ក្រុម ឬប្រភេទ
- ការវិភាគ
- ការកំណត់
- ស្វែងរកគំរូប្រហែល

ជ. ....................................................
- ការធ្វើត្រាប់
- ការសម្ដែងតួ
- ការធ្វើកាយវិការ
- ការពិភាក្សាជាក្រុម
- ការលេងកីឡា
- ការដោះប្រស្នា

**ចម្លើយរំពឹងទុក៖**
ក-៧ បញ្ញាខាងអារម្មណ៍ ឬក្នុងចិត្ត ខ-៦ បញ្ញាខាងទំនាក់ទំនង គ-៣ បញ្ញាខាងមើលលំហ ឃ-៥ បញ្ញាខាងតូរតន្ត្រី ង-២ បញ្ញាខាងតក្កគណិតវិទ្យា ច-១ បញ្ញាខាងភាសា ឆ-៨ បញ្ញាខាងធម្មជាតិ ជ-៤ បញ្ញាខាងកាយសម្បទា

[35] សកម្មភាពនេះមានដកស្រង់ពីមេរៀនបណ្ដុះបណ្ដាលគ្រូបង្រៀន៖ ប្រទេសស៊ូដង់ខាងត្បូង ដោយ Sandrine Bohan-Jacqout

## សកម្មភាព ៨.២  ការទាញយកប្រយោជន៍ពីរបៀបរៀនខុសៗគ្នា

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង៖**

- កំណត់បានពីរបៀបរៀនខុសៗគ្នា របស់កុមារនៅក្នុងថ្នាក់រៀនដើម្បីរៀបចំកិច្ចតែងការ។

**សម្ភារបង្រៀន និងរៀន៖**

- ប័ណ្ណល្បែងប៊ីងហ្គោ

**សកម្មភាពបង្រៀន ៖**

ក. ណែនាំគរុសិស្សលេងល្បែងប៊ីងហ្គោ
   - ត្រូវដើរជុំវិញក្នុងថ្នាក់រៀន និងស្វែងរកគរុសិស្សផ្សេងទៀត ដែលមានរបៀបរៀនត្រូវជាមួយនឹងជាមួយការពណ៌នាក្នុងប័ណ្ណល្បែង។
   - ត្រូវចុះហត្ថលេខាលើការពណ៌នានៅពេលរកឃើញគូផ្គូរផ្គង (ការពណ៌នាមួយត្រូវឱ្យមានហត្ថលេខាតែមួយប៉ុណ្ណោះ)។ នរណាដែលមានហត្ថលេខា៣នៅជួរដេក ឬជួរបញ្ឈរ ឬជួរបញ្ឆៀងមុនគេត្រូវស្រែកថា "ប៊ីងហ្គោ"។

ខ. បង្ហាញព័ត៌មានដោយសង្ខេបអំពីរបៀបរៀន និងឱ្យគរុសិស្សអានខ្លឹមសារលម្អិតជាកិច្ចការផ្ទះ។

គ. ប្រសិនបើគរុសិស្សអាចចូលទៅកាន់អ៊ីនធើណែតបានពួកគេអាចពិនិត្យមើលតើពួកគេមានរបៀបរៀនអ្វីដោយបំពេញតេស្តនៅគេហទំព័រខាងក្រោម៖
   http://www.personal.psu.edu/bxb11/LSI/LSI.htm[36]
   **(លំហាត់នៅក្នុងផ្នែក គ អាចធ្វើនៅពេលផ្ទាល់ខ្លួន)**

> របៀបរៀនគឺជាវិធីដែលបុគ្គលម្នាក់
> យល់ដឹង បញ្ចេញមតិយោបល់
> និងចងចាំព័ត៌មាន

- សកលវិទ្យាល័យ Wilfrid Laurier, ប្រទេសកាណាដា[37]

---

[36] តេស្តអនឡាញ ដើម្បីពិនិត្យមើលរបៀបរៀន បង្កើតដោយ Brett Brixler នៃសកលវិទ្យាល័យ Penn State ជាសាកលវិទ្យាល័យស្រាវជ្រាវសាធារណៈក្នុងរដ្ឋ Pennsylvania

[37] ដកស្រង់សម្ដីពីសិក្ខាសាលារៀបចំដោយសាកលវិទ្យាល័យ Wilfrid Laurier

## ល្បែងប៊ីងហ្គោ របៀបរៀន[38]

| | | |
|---|---|---|
| ចង់ស្តាប់ការបង្រៀន សុន្ទរកថា ឬសំឡេងថត ជាងអានសៀវភៅ អំពីខ្លឹមសារដូចគ្នា | លេងវត្ថុនៅក្នុងដៃ នៅក្នុងម៉ោងរៀន | គិតថា វិធីដែលល្អបំផុតក្នុង ការចងចាំគឺការសម្រៃ រូបភាពនៅក្នុងខួរក្បាល |
| ចូលចិត្តលេងល្បែងផ្គុំរូប ប្រស្នា និងសកម្មភាព ដោះស្រាយបញ្ហា | ចាំបានល្អបំផុត តាមរយៈការសរសេរ ច្រើនដង | រៀនប្រកបអក្សរ តាមរយៈដាក់ម្រាមដៃ វត់តាមអក្សរ |
| ស្ទាត់ជំនាញ និងចូលចិត្តបង្កើតគំនូស តាង និងតារាង | ចូលចិត្តអានឯកសារ ពាក់ព័ន្ធនានាដោយ ស្ងប់ស្ងាត់ | ចូលចិត្តព័ត៌មាន ដែលត្រូវបានបង្ហាញ ជាមួយការប្រើប្រាស់ ឧបករណ៍ជំនួយការមើល |
| ចូលចិត្តហាត្ថកម្ម ឬបង្កើតរបស់ផ្សេងៗ | ចាប់បានការបង្ហាញ ទិសដៅផ្ទាល់មាត់ ជាងការសរសេរ | រៀនបានច្រើនពីការ ពិភាក្សា និងពន្យល់ ព័ត៌មានជាក្រុម |

[38] ដកស្រង់ពីមេរៀនបណ្តុះបណ្តាលគ្រូបង្រៀនបរិយាបន្ន មេរៀនទី៤ "ពិនិត្យ និងកំណត់សេចក្តីត្រូវការនៃការរៀន UNICEF ប្រទេសម៉ាសេដូនី សៀវភៅមគ្គុទេសក៍គ្រូបង្រៀន & ឯកសារផ្តល់ឱ្យដោយ Nafisa Baboo ខែមករា ២០១២

**របៀបរៀន៖ របៀបរៀនមានបីយ៉ាងដូចពណ៌នាខាងក្រោម៖**

**១. អ្នករៀនបែបសោតវិញ្ញាណ៖** ប្រសិនបើអាច គ្រូបង្រៀនជួយសិស្សថតសំឡេងមេរៀន ហើយបន្ទាប់មកពួកគេអាចស្ដាប់ម្ដងទៀត ដើម្បីយល់អ្វីដែលពួកគេប្រហែលមិនយល់នៅក្នុងម៉ោងសិក្សា។ គ្រូបង្រៀនគួរឱ្យអ្នករៀនបែបសោតវិញ្ញាណកត់ត្រា ដើម្បីឱ្យពួកគេអាចអភិវឌ្ឍរបៀបរៀនផ្សេងទៀត។ គ្រូបង្រៀនអាចជួយអ្នករៀនបែបសោតវិញ្ញាណនៅក្នុងថ្នាក់រៀន ដោយឱ្យពួកគេសង្ខេបមេរៀន និងអានឡើងវិញឱ្យឮនៅចុងម៉ោងសិក្សា។ អ្នករៀនបែបសោតវិញ្ញាណចូលចិត្តស្ដាប់ចម្រៀងតិចៗនៅពេលរៀន ប៉ុន្តែការធ្វើបែបនេះអាចពិបាកអនុវត្តនៅក្នុងថ្នាក់រៀន នៅពេលដែលតន្ត្រីអាចរំខានសិស្សដទៃទៀត។

**២. អ្នករៀនបែបចក្ខុវិញ្ញាណ៖** គ្រូបង្រៀនគួរបញ្ចូលតារាងផែនទី ផ្ទាំងហ្វ៊ីល ក្រដាសកត់ត្រា និងប័ណ្ណបង្ហាញនៅក្នុងសកម្មភាពមេរៀន ដើម្បីជាប្រយោជន៍ដល់អ្នករៀនបែបចក្ខុវិញ្ញាណ។ គ្រូបង្រៀនអាចជួយអ្នករៀនបែបចក្ខុវិញ្ញាណ ដោយឱ្យពួកគេស្រមៃរូបភាព ពាក្យ ឬបញ្ញត្តិនៅក្នុងខួរក្បាលរបស់ពួកគេ។ អ្នករៀនបែបចក្ខុវិញ្ញាណគួរសរសេរអ្វីគ្រប់យ៉ាងដើម្បីពួកជារូបភាពឡើងវិញញឹកញាប់។

**៣. អ្នករៀនបែបកាយវិញ្ញាណ៖** អ្នករៀនបែបកាយវិញ្ញាណចូលចិត្តប្រើប្រាស់របស់ធ្វើចលនាសាងសង់ ឬបង្ហាញអ្វីដែលពួកគេបានរៀនជាក់ស្ដែង។ គ្រូបង្រៀនអាចជួយអ្នករៀនបែបកាយវិញ្ញាណ ដោយឱ្យពួកគេសរសេរពាក្យនៅពេលពួកគេអានពាក្យទាំងនោះ។ ការធ្វើបែបនេះជួយអ្នករៀនបែបកាយវិញ្ញាណសរសេរព័ត៌មានដែលត្រូវរៀនច្រើនដង។ គ្រូបង្រៀនគួរផ្ដល់ក្រដាសសរសេរសម្រាប់សកម្មភាពនេះ។ ការសរសេរ និងរក្សាកំណត់ត្រាមានសារៈសំខាន់ណាស់សម្រាប់អ្នករៀនបែបកាយវិញ្ញាណ។ គ្រូបង្រៀនអាចឱ្យពួកគេបង្កើតក្រដាសមេរៀនដែលពួកគេអាចប្រើប្រាស់បាននៅពេលក្រោយ។

## **សារគន្លឹះ**[39]:

- អ្នករៀនជាច្រើនប្រើប្រាស់របៀបរៀនផ្សេងៗគ្នា ដើម្បីបង្កើនប្រសិទ្ធភាពការរៀនរបស់ពួកគេ។
- មិនត្រូវសន្មតថា អ្នករៀនប្រើប្រាស់តែរបៀបរៀនដែលជាចំណង់ចំណូលចិត្តរបស់ពួកគេនោះទេ អ្នករៀនភាគច្រើនប្រើប្រាស់របៀបរៀនផ្សេងៗគ្នា។
- ការកត់ត្រាមេរៀនជួយអ្នករៀនទាំងអស់ ទោះបីអ្នករៀនមានរបៀបរៀន ចំណង់ចំណូលចិត្តបែបណាក៏ដោយ។

[39] ដកស្រង់ពីមេរៀនបណ្ដុះបណ្ដាលគ្រូបង្រៀនអប់រំបរិយាបន្ន មេរៀនទី៤ សរសេរដោយ Nafisa Baboo

# មេរៀនទី៩ ការកំណត់ឧបសគ្គចំពោះការរៀន





© Michael Pitt

## សកម្មភាព ៩.១ ការកំណត់ឧបសគ្គចំពោះការរៀន

### រយៈពេល៖ ៤៥ នាទី

### វត្ថុបំណង៖

- កំណត់បានឧបសគ្គចំពោះការរៀនដែលកុមារជួបប្រទះ។

### សម្ភារបង្រៀន និងរៀន៖

- ករណីសិក្សា
- វីដេអូឈ្មោះ "ប្លង់សកលសម្រាប់ការរៀន (UDL): កាត់បន្ថយឧបសគ្គ"[40]

### សកម្មភាពបង្រៀន៖

ក. ចែករំលែកដ្យាក្រាមនៅទំព័របន្ទាប់ដែលបង្ហាញអំពីឧបសគ្គផ្សេងៗជាមួយគរុសិស្ស និងពន្យល់ដ្យាក្រាម និងសារគន្លឹះនោះដោយសង្ខេប។

ខ. ពិភាក្សាក្រុម (មួយករណីសិក្សាមួយក្រុម)

សំណួរពិភាក្សា

- តើឧបសគ្គអ្វីខ្លះដែលកុមារជួបប្រទះ?
- សរសេរឈ្មោះកុមារនៅក្នុងករណីសិក្សាខាងលើផ្គូផ្គងជាមួយឧបសគ្គ។

គ. តំណាងក្រុមរាយការណ៍

ឃ.សំយោគ

ង. បញ្ចាំងវីដេអូមានចំណងជើង "ប្លង់សកលសម្រាប់ការរៀន (UDL) ៖ ឧបសគ្គចំពោះការរៀន"។

**ឧបសគ្គ** [41]




[40] វីដេអូយូធូបដោយ Brandy Antonia ផលិតក្នុងឆ្នាំ២០១៣

[41] សកម្មភាពត្រូវបានកែសម្រួលពីមេរៀនទី៤ នៃការអប់រំបណ្តុះបណ្តាលគ្រូបង្រៀន សម្រាប់ UNICEFក្រសួងប្រទេសម៉ាសេដូនី

## សារគន្លឹះ

យើងត្រូវតែមានវិធីសាស្ត្រគ្រប់ជ្រុងជ្រោយចំពោះការអភិវឌ្ឍ និងការរៀន ហើយនេះមានន័យថា យើងត្រូវពិចារណាឧបសគ្គទាំងអស់ខាងក្រោម៖

- ស្ថានភាពនយោបាយ
- សហគមន៍
- ផ្ទះ គ្រួសារ
- សាលារៀន
- ថ្នាក់រៀន
- មិត្តភក្តិ
- កុមារម្នាក់ៗ

យើងត្រូវឈប់គិតថា ឧបសគ្គបណ្តាលមកតែពីកុមារ។

## សារៈសំខាន់នៃការវាយតម្លៃ [42]

សិស្សដែលមានតម្រូវការគាំទ្របន្ថែមគឺជាក្រុមអ្នករៀនផ្សេងៗគ្នា។ ដើម្បីគ្រូបង្រៀនអាចលុបបំបាត់ឧបសគ្គដែលសិស្សមានក្នុងការរៀនពួកគេត្រូវធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្ន។ ដោយសារមិនមានវត្តមានអ្នកវាយតម្លៃប្រកបដោយវិជ្ជាជីវៈ អ្នកចិត្តសាស្ត្រ ឬអ្នកព្យាបាលផ្នែកអប់រំនៅក្នុងប្រទេស កម្ពុជា គ្រូបង្រៀនអាចធ្វើការវាយតម្លៃជាមូលដ្ឋានដោយពិចារណាចំណុចខាងក្រោម៖

- តើសិស្សពូកែខាងអ្វី? តើផ្នែកណាដែលពួកគេអាចអភិវឌ្ឍបន្ថែម?
- តើអ្វីដែលពួកគេចូលចិត្ត និងមិនចូលចិត្ត?
- តើអ្វីជាការរំពឹងទុក ឬក្តីសុបិន្តដែលពួកគេចង់ធ្វើ?

គ្រួសារ មិត្តភក្តិ និងបងប្អូនចូលរួមរកចម្លើយសម្រាប់សំណួរទាំងនេះ។ គ្រូបង្រៀនបរិយាបន្នត្រូវចេះរកដំណោះស្រាយ។

[42] ដកស្រង់ពី Sandrine Bohan-Jacquot (២០១៤) *មេរៀនបណ្តុះបណ្តាលគ្រូបង្រៀន–ប្រទេសស៊ូដង់ខាងត្បូង* ទំព័រ ៧៨

# ករណីសិក្សា

**ករណីសិក្សាទី១៖**

សុភាពរៀនថ្នាក់ទី១។ គ្រូបង្រៀនរបស់នាងត្អូញត្អែរថា នាងឆាឆៅខ្លាំង និងមិនស្តាប់បង្គាប់។ នាងមិនដែលស្តាប់ការបង្រៀន និងរំខានថ្នាក់រៀននៅក្នុងម៉ោងនិទានរឿងនិងតន្ត្រី។ នាងយកចិត្តទុកដាក់នៅពេលអ្នកឈរពីមុខនាង និងនិយាយក្នុងសំឡេងម៉ឺងម៉ាត់និងឮខ្លាំងៗ។ នាងមិនចូលចិត្តនិយាយជាមួយកុមារដទៃ និងចូលចិត្តលេងតែម្នាក់ឯង។ កុមារផ្សេងទៀតខ្លាចជាប់ពាក់ព័ន្ធជាមួយនាង ដោយសារគ្រូបង្រៀនបង្ហាញអារម្មណ៍មិនចូលចិត្តនាង។ លំនឹងរបស់សុភាពទន់ខ្សោយ ហើយនាងមិនចូលចិត្តសកម្មភាពកីឡា។ ជាញឹកញាប់នាងមានជំងឺផ្តាសាយ និងហ៊ឹងត្រចៀក។ ឪពុកម្តាយរបស់សុភាពបាននាំនាងទៅគ្លីនិកជាច្រើនលើក ប៉ុន្តែគ្រូពេទ្យឱ្យទិញតែថ្នាំផ្សះ ។ ឪពុកម្តាយរបស់សុភាព គេចវេសពីគ្រូបង្រៀនរបស់សុភាពពីព្រោះគ្រូបង្រៀនមើលងាយពួកគាត់ និងធ្វើឱ្យពួកគាត់មានអារម្មណ៍ថាជាឪពុកម្តាយអាក្រក់។

**តើអ្វីជាឧបសគ្គចំពោះការរៀនដែលសុភាពជួបប្រទះ?**

**តើអ្នកគិតថា ឧបសគ្គចម្បងគឺជាអ្វី?**

**ករណីសិក្សាទី២៖**

សំណាងមានអាយុ១៤ឆ្នាំ ហើយថ្មីៗនេះត្រូវបានដាក់នៅក្នុងសាលារៀនពិសេសមួយ។ សំណាងមានពិការភាពសតិបញ្ញា។ ឪពុកម្តាយរបស់សំណាងមិនមានការងារធ្វើ ហើយឪពុកផឹកតែស្រា។ គ្រួសាររបស់សំណាងបានផ្លាស់មកនៅទីក្រុងបីឆ្នាំមុនដើម្បីស្វែងរកស្ថានភាពរស់នៅប្រសើរជាងមុន។ អ្នកជិតខាងបានប្រាប់ថា សំណាងនិងប្អូនប្រុសស្រីរបស់សំណាងជាញឹកញាប់នៅក្រៅសាលារៀន និងលេងនៅក្បែរផ្ទះនៅពេលថ្ងៃ។ គេបានត្អូញត្អែរពីការលួច និងក្មេងពាល។ ម្តាយរបស់សំណាងនិយាយថា បញ្ហាពិតប្រាកដនោះគឺសំណាងមិនចង់ទៅសាលា ពីព្រោះត្រូវបានគេធ្វើបាបនៅលើរថយន្តក្រុងនិងនៅក្នុងថ្នាក់រៀន។ កុមារផ្សេងទៀតចំអកអំពីរបៀបនិយាយ និង សម្លៀកបំពាក់របស់សំណាង។

**តើអ្វីជាឧបសគ្គពិតប្រាកដចំពោះការរៀន និងការអភិវឌ្ឍរបស់សំណាង?**

**ករណីសិក្សាទី៣៖**

ប្រសិទ្ធិមានអាយុ១១ឆ្នាំ និងរៀនថ្នាក់ទី៥។ វារងរបួសមិនអាចព្យាបាលបាននៅក្នុងគ្រោះថ្នាក់បង្កដោយរថយន្ត ហើយឥឡូវត្រូវប្រើរទេះជនពិការ។ បន្ទាប់ពីគ្រោះថ្នាក់ ប្រសិទ្ធិបានត្រឡប់មកសាលារៀនចាស់របស់វា និងត្រូវបានស្វាគមន៍ដោយអ្នកទាំងអស់គ្នា។ បន្ទាប់ពីគ្រោះថ្នាក់វាជួបការលំបាកក្នុងការសិក្សាពីព្រោះមិនបានធ្វើកិច្ចការផ្ទះជាច្រើន។ ជាមួយការជួយរបស់គ្រូបង្រៀន និងមិត្តរួមថ្នាក់ប្រសិទ្ធិបានរៀនជិតទាន់មេរៀន និងអាចបន្តរៀនទៅដល់ថ្នាក់ទី៦។ប៉ុន្តែថ្នាក់ទី៦នៅជាន់ខាងលើនិងមិនមានជម្រាល ម្យ៉ាងទៀតគ្រូបង្រៀនថ្នាក់ទី៦មិនចង់ផ្លាស់ប្តូរថ្នាក់រៀនជាមួយគ្រូបង្រៀនជាន់ផ្ទាល់ដី ពីព្រោះគាត់បានបង្រៀននៅថ្នាក់ជាន់លើអស់រយៈពេល៦ឆ្នាំមកហើយ។ នាយកសាលាបានប្រាប់ឪពុកម្តាយរបស់ប្រសិទ្ធិថាប្រសិទ្ធិគួរត្រូវបញ្ជូនទៅសាលារៀនពិសេសប្រសើរជាង។ គាត់គិតថាប្រសិទ្ធិអាចទទួលបានប្រយោជន៍ច្រើនពីការព្យាបាល និងសម្ភារបរិក្ខារពិសេសទាំងអស់ដែលមាននៅសាលារៀនពិសេស។

**តើឧបសគ្គអ្វីចំពោះតម្រូវការរៀន និងការអភិវឌ្ឍ ដែលត្រូវដោះស្រាយ?**

**ករណីសិក្សាទី៤៖**

ម៉ារុងមានអាយុ៧ឆ្នាំនិងរៀនថ្នាក់ទី២។ វាមានការលំបាកលើមុខវិជ្ជាគណិតវិទ្យា។ ជាញឹកញាប់ម៉ារុងមិនបានបញ្ចប់កិច្ចការរបស់វា និងមិនចូលចិត្តម៉ោងសិក្សាគណិតវិទ្យា។ វាពូកែអក្សរសាស្ត្រជាង ហើយវាមានមោទនភាពលើសមត្ថភាពអានរបស់វា។ ការសរសេរក៏គ្មានបញ្ហាផងដែរ ប្រសិនបើម្រាមដៃរបស់ម៉ារុងមិនមានបញ្ហា ។ គ្រូបង្រៀនរបស់វាបានត្អូញត្អែរពីការសរសេរអក្សរមិនមានរបៀបរៀបរយ និងលើកទឹកចិត្តវាឱ្យកាន់ខ្មៅដៃសរសេរបានត្រឹមត្រូវ។ គ្រូបង្រៀនរបស់វាដឹងថាម៉ារុងមានសក្តានុពល ប៉ុន្តែមិនដឹងអំពីវិធីជួយវាឱ្យបានល្អប្រសើរជាងនេះ។ ម៉ារុងមិនដែលចូលរៀនសាលាមត្តេយ្យ និងចាប់ផ្តើមចូលរៀនថ្នាក់ទី១ នៅពេលវាមានអាយុ៥ឆ្នាំ។ វារស់នៅជាមួយជីដូនជីតារៀងរាល់សប្តាហ៍ ពីព្រោះឪពុកម្តាយរបស់វាធ្វើការថែមម៉ោងនៅមន្ទីរពេទ្យ។

**តើឧបសគ្គមួយណាចំពោះតម្រូវការរៀន និងការអភិវឌ្ឍ ដែលត្រូវការដោះស្រាយ?**

*ចម្លើយរំពឹងទុក*

សរសេរឈ្មោះកុមារនៅក្នុងករណីសិក្សាខាងលើផ្គូផ្គងជាមួយឧបសគ្គ

| ឈ្មោះកុមារ | ឧបសគ្គចំពោះការរៀន និងការអភិវឌ្ឍ |
|---|---|
| **ប្រសិទ្ធិ** | - បញ្ហាចលនា<br>- ឥរិយាបថគ្រូបង្រៀន និងនាយកសាលា<br>- កង្វះគោលនយោបាយការអប់រំបរិយាបន្ននៅក្នុងសាលារៀន<br>- រចនាសម្ព័ន្ធខ្វះខាត |
| **ម៉ារ៉ុង** | - មិនមានសេវាអភិវឌ្ឍកុមារតូច<br>- ខ្សោយបំណិនចលនាតូច<br>- កង្វះការគាំទ្រពីគ្រួសារលើការអប់រំ<br>- កង្វះការគាំទ្រ និងការបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀន<br>- កង្វះធនធានមនុស្ស |
| **សំណាង** | - ពិបាកក្នុងការរៀន<br>- ភាសា<br>- បទដ្ឋានខុសគ្នានៅក្នុងសាលារៀនជនបទ និងទីក្រុង<br>- ភាពក្រីក្រ និងគ្រឿងញៀននៅក្នុងគ្រួសារ<br>- ស្ថានភាពសេដ្ឋកិច្ចសង្គមខ្សត់ខ្សោយនៅក្នុងតំបន់នោះ<br>- ការរើសអើងរបស់សហគមន៍ |
| **សុភាព** | - បញ្ហាស្តាប់<br>- សេវាថែទាំសុខភាពមិនល្អនៅក្នុងសហគមន៍<br>- ឥរិយាបថគ្រូបង្រៀន<br>- ឪពុកម្តាយខ្វះព័ត៌មាន និងជំនាញ<br>- ខ្សោយសាច់ដុំ<br>- ចរិតលក្ខណៈ និងវប្បធម៌សាលារៀនអវិជ្ជមាន និងរើសអើង |

# សេចក្ដីសង្ខេបនៃឧបសគ្គចំពោះការអប់រំបរិយាបន្ន [43]

**គោលនយោបាយ និងសេដ្ឋកិច្ចសង្គម៖** ច្បាប់ ឬបទបញ្ញត្តិមិនមានលក្ខណៈបរិយាបន្ន កង្វះមូលនិធិ កង្វះឆន្ទៈគោលនយោបាយដើម្បីអនុវត្តការផ្លាស់ប្ដូរសម្រាប់ការអប់រំបរិយាបន្ន។

**សហគមន៍៖** ការរើសអើង ភាពខុសគ្នានៃវប្បធម៌ ប្រពៃណីក្នុងតំបន់ ឥរិយាបថអវិជ្ជមាន។

**គ្រួសារ៖** ភាពក្រីក្រ កង្វះការអប់រំ និងចំណេះដឹង ជំនឿក្នុងការបកស្រាយបែបប្រពៃណី ជម្លោះ កង្វះការថែទាំ ឥរិយាបថអវិជ្ជមាន។

**សាលារៀន៖** តម្លៃ ទីកន្លែង ការរៀបចំ ទំហំការងារ ភាពងាយស្រួល ទំហំថ្នាក់រៀន ធនធាន។

**ថ្នាក់រៀន៖** ភាពងាយស្រួលទាំងរូបវន្ត និងការរៀន ការបណ្ដុះបណ្ដាលការអប់រំរិយាបន្នសម្រាប់គ្រូបង្រៀន ទំហំថ្នាក់រៀនដែលមានឥទ្ធិពលដល់ការរៀនសកម្ម បំពេញសេចក្ដីត្រូវការរបស់កុមារម្នាក់ៗ សម្ភារ បង្រៀន និងរៀន។

**មិត្តភក្តិ៖** ការចំអក ឥរិយាបថអវិជ្ជមាន។

**បុគ្គលខ្លួនឯង៖** ឧបសគ្គខាងលើទាំងអស់មានផលប៉ះពាល់ទ្វេដងដល់ឧបសគ្គរបស់បុគ្គលចំពោះការអប់រំបរិយាបន្ន។



[43] ដកស្រង់ពីកូនសៀវភៅទី៣របស់ UNESCO: *ឱ្យកុមារទាំងអស់ទៅសាលារៀន និងការរៀន* ទំព័រ ១១

# មេរៀនទី១០ ការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិត



© Michael Pitt



© Jodie Davies

## សកម្មភាព ១០.១ ការកំណត់និយមន័យនៃការលេង

**រយៈពេល៖ ២០នាទី**

**វត្ថុបំណង៖**

- កំណត់បានពីនិយមន័យនៃការលេង។

**សម្ភារបង្រៀន និងរៀន៖**

- បណ្តុំពាក្យដែលជានិយមន័យនៃការលេង។

**សកម្មភាពបង្រៀន៖**

ក. ឱ្យគរុសិស្សម្នាក់ៗផ្តល់ពាក្យមួយ ដែលជានិយមន័យនៃការលេង

ខ. ផ្តុំជាបណ្តុំពាក្យជាមួយចម្លើយដែលទទួលបាន
(ប្រសិនបើពួកគេឆ្លើយជាប្រយោគ សង្ខេបប្រយោគនោះជាពាក្យមួយ)

គ. សំយោគ
( ប្រសិនបើមានពេលវេលានៅសល់ ឱ្យពួកគេប្រៀបធៀបរូបភាពទាំងពីរ ឬរក្សារូបភាពទាំងពីរនោះដើម្បីប្រៀបធៀបនៅពេលក្រោយ)។

សារគន្លឹះ៖ សារៈប្រយោជន៍នៃការលេងមាននៅក្នុងផ្នែកទាំងបួន៖[44]

១. ជួយសម្រួលការប្រាស្រ័យទាក់ទង រួមទាំងការបញ្ចេញគំនិតផ្ទាល់ខ្លួន
២. ជំរុញសុខមាលភាពផ្លូវចិត្ត និងអាចកាត់បន្ថយ និងគ្រប់គ្រងការតានតឹងផ្លូវអារម្មណ៍
៣. លើកកម្ពស់ទំនាក់ទំនងសង្គម ពង្រឹងភាពស្រឡាញ់ និងលើកកម្ពស់ការយល់ចិត្ត
៤. បង្កើនកម្លាំងចិត្តរួមទាំងការលើកកម្ពស់សមត្ថភាពដោះស្រាយបញ្ហាដោយច្នៃប្រឌិត និងភាពអត់ធន់។

ការលេងក៏មានគុណប្រយោជន៍ជាច្រើន ដល់ការអភិវឌ្ឍខាងការយល់ដឹង និងខាងភាសា។ ការលេងក៏ផ្តល់ឱកាសអនុវត្តកិច្ចការនៅក្នុងបរិយាកាសមួយដែលមានសុវត្ថិភាពដែលអាចពិបាកសម្រេចបាននៅក្នុងបរិយាកាសផ្សេងទៀត។

[44] Schaefers and Drewes (២០១៤) ពិពណ៌នាចំណុចទាំងនេះ នៅក្នុងការស្រាវជ្រាវរបស់ពួកគេអំពី ប្រសិទ្ធភាពនៃការលេង

## បណ្តុំពាក្យតំណាងឱ្យការពិភាក្សាលើនិយមន័យនៃការលេង [45]




[45] ដកស្រង់ពី 'ស្វែងយល់ការលេង' វគ្គអនឡាញ ដោយសកលវិទ្យាល័យ Sheffield ក្នុងឆ្នាំ២០១៦

## សកម្មភាព ១០.២ ការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិតនៅក្នុងកម្មវិធីសិក្សា

**រយៈពេល៖ ៤៥នាទី**

**វត្ថុបំណង៖**

- កំណត់បានពីការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិតនៅក្នុងកម្មវិធីសិក្សា។

**សម្ភារបង្រៀន និងរៀន៖**

- វីដេអូ "មាត្រា៣១ សិទ្ធិក្នុងការលេង"[46] ដោយសមាគមការលេងអន្តរជាតិ។
- វីដេអូ ដោយអង្គការ UNICEF កុមារគ្រប់គ្នាមានសិទ្ធិក្នុងការលេង។
- វីដេអូដោយ Play Around the World Canada ឈ្មោះការលេងជុំវិញពិភពលោក ឆ្នាំ២០១៦។
- វីដេអូការដាក់បញ្ចូលសិល្បៈ ដើម្បីពង្រីកការយល់ដឹងខ្លឹមសារស្នូល[47]
- មេរៀនដកស្រង់ពីសៀវភៅ "រៀនតាមរយៈការលេង" បោះពុម្ពដោយអង្គការសាលារៀនទន្សាយ ក្រោមភាពជាដៃគូជាមួយអង្គការ Aide et Action
- មេរៀនដកស្រង់ពីសៀវភៅ "រៀនតាមរយៈសិល្បៈច្នៃប្រឌិត" បោះពុម្ពដោយ Epic Arts ក្រោមភាពជាដៃគូជាមួយអង្គការ Aide et Action

**សកម្មភាពបង្រៀន៖**

ក. បញ្ចាំងវីដេអូស្ដីពី "មាត្រា៣១ សិទ្ធិក្នុងការលេង" និងវីដេអូឈ្មោះ "ការដាក់បញ្ចូលសិល្បៈ ដើម្បីពង្រីកការយល់ដឹងខ្លឹមសារស្នូល"។ ដូច្នេះគរុសិស្សយល់ពីគោលបំណងសម្រាប់ការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិត។

ខ. សំណួរបំផុស

តើការរៀនតាមរយៈការលេង និងសិល្បៈច្នៃប្រឌិតមានលក្ខណៈយ៉ាងដូចម្ដេច?

ឃ. ឱ្យគរុសិស្សអនុវត្តសកម្មភាពរៀនតាមរយៈការលេងដូចខាងក្រោម៖

### ប្រាប់ពេលវេលា [48]

តើម៉ោងប៉ុន្មានហើយបងខ្លា?

**១. ក្រុមគោលដៅ៖ ក្រុមសមាជិកច្រើន**

**២. កម្រិត៖**

- ថ្នាក់មត្តេយ្យ៖ ចម្ងាយខ្លី បង្ហាញលេខទៅសិស្ស
- ថ្នាក់ទី១៖ ចម្ងាយមធ្យម បង្ហាញនាឡិកាទៅសិស្ស

[46] វីដេអូដោយសមាគមការលេងអន្តរជាតិ

[47] វីដេអូអនឡាញ ផលិតដោយ Educo(បានធ្វើបច្ចុប្បន្នភាព) ស្ដីពីរបៀបសិល្បៈច្នៃប្រឌិតអាចប្រើប្រាស់ ដើម្បីបង្រៀនខ្លឹមសារកម្មវិធីសិក្សា

[48] សកម្មភាពត្រូវបានដកស្រង់ពីសៀវភៅមគ្គុទេសក៍ "ការរៀនតាមរយៈការលេង" បង្កើតដោយអង្គការសាលារៀនទន្សាយនិង Aide et Action ក្នុងឆ្នាំ២០១៦

| សៀវភៅសិក្សា | ជំពូក | មេរៀន | ទំព័រ |
|---|---|---|---|
| គណិតវិទ្យា | | ១៥ | ៧៣ |

**៣. វត្ថុបំណង៖**

សិស្សនឹងមាន៖

- ជំនាញខាងការប្រាស្រ័យទាក់ទង៖ សួរ និងឆ្លើយសំណួរ
- ជំនាញខាងការយល់ដឹង៖ រាប់លេខ
- ជំនាញខាងការយល់ដឹង៖ ធ្វើតាមការណែនាំ



**៤. សម្ភារ៖** នាឡិកា

**៥. សកម្មភាព៖**

| | |
|---|---|
| ១ | ឱ្យសិស្សឈរជាជួរដែលមានចម្ងាយ៥ ឬ៦ម៉ែត្រពីគ្នា |
| ២ | ជ្រើសរើសសិស្សម្នាក់ឱ្យឈរទៅម្ខាងដោយបែរខ្នងទៅក្រុមដើម្បីដើរតួជា "ខ្លា" |
| ៣ | ឱ្យសិស្សឈរជាជួរពីក្រោយខ្នងរបស់ខ្លា និងសួរ "តើម៉ោងប៉ុន្មានហើយបងខ្លា?" ចម្លើយគឺអាស្រ័យលើខ្លា ឧទាហរណ៍ម៉ោង១ ម៉ោង២ ម៉ោង៣ ។ល។ |
| ៤ | ឱ្យសិស្សបោះជំហានដូចគ្នាទៅនឹងម៉ោងដែលនិយាយដោយខ្លា។ ឧទាហរណ៍ នៅពេលខ្លានិយាយម៉ោង៣សិស្សត្រូវដើរ៣ជំហានទៅមុខ។ |
| ៥ | ឱ្យសិស្សបន្តធ្វើរហូតដើរដល់ខ្សែបន្ទាត់បញ្ចប់។ ពួកគេក្លាយជាមាន់។ |
| ៦ | គ្រូត្រូវប្រាប់ខ្លាឱ្យចាប់មាន់។ |
| ៧ | ខ្លាព្យាយាមចាប់មាន់ដែលរត់គេចពីខ្លា។ |
| ៨ | នៅពេលនរណាម្នាក់ត្រូវចាប់បាន ម្នាក់នោះនឹងត្រូវដើរតួជាខ្លានៅជុំបន្ទាប់។ |
| ៩ | ប្រសិនបើខ្លាមិនអាចចាប់នរណាបាន គេនឹងបន្តដើរតួជាខ្លាតទៅទៀត។ |

ប្រភព៖ ការលេងជុំវិញពិភពលោក

## សារគន្លឹះស្តីពីការរៀនតាមសិល្បៈច្នៃប្រឌិត [49]

សារៈសំខាន់នៃសិល្បៈច្នៃប្រឌិតអាចជួយកុមារអភិវឌ្ឍផ្នែកដូចខាងក្រោម៖ ការអភិវឌ្ឍផ្នែករាងកាយ ការអភិវឌ្ឍផ្នែកសង្គម ការអភិវឌ្ឍការយល់ដឹង ការអភិវឌ្ឍផ្លូវចិត្ត ប្រឌិតញាណ និងការពិសោធ។

[49] សៀវភៅមគ្គុទេសក៍ "ការរៀនតាមរយៈសិល្បៈច្នៃប្រឌិត (មិនទាន់បោះពុម្ព) បង្កើតដោយ Epic Arts និង Aide et Action

## មេអំបៅស្រស់ស្អាត[50]

**មេរៀន៖**

វិទ្យាសាស្ត្រ៖ ធម្មជាតិពិភពលោក

គណិតវិទ្យា៖ ស៊ីម៉េទ្រី

**វត្ថុបំណង**៖ បង្កើតមេអំបៅស្រស់ស្អាត ផ្អែកលើការសង្កេតមេអំបៅ

**សិស្សនឹងមាន៖**

- បំណិនការយល់ដឹង៖ បំណិនសង្កេត បំណិនចលនាតូច
- បំណិនរាងកាយ៖ ភាពរៀសដៃ និងភ្នែក

**សម្ភារ៖**

- រូបភាពមេអំបៅ ក្រដាសសម្រាប់ធ្វើស្លាបមេអំបៅ បំពង់ក្រដាសរឹង ជក់ ការ ថ្នាំពណ៌សុវត្ថិភាព

| | |
|---|---|
| ១ | គ្រូបង្រៀនរៀបចំរូបភាពមេអំបៅមួយចំនួន ដែលរួមមានទ្រង់ទ្រាយមេអំបៅងាយស្រួល និងស្មុគ្រស្មាញ ដូច្នេះសកម្មភាពអាចផ្តល់ឱ្យសម្រាប់ប្រភេទសមត្ថភាពសិស្សផ្សេងៗគ្នា |
| ២ | រូបភាពមេអំបៅត្រូវបង្ហាញទៅដល់សិស្សទាំងអស់ ហើយឱ្យសិស្សពិពណ៌នាអ្វីដែលពួកគេសង្កេត |
| ៣ | សិស្សត្រូវបែងចែកជាក្រុមដែលមានសមត្ថភាពចម្រុះ និងជ្រើសរើសមេអំបៅដើម្បីសិក្សា ផ្អែកតាមកម្រិតជំនាញរបស់ពួកគេ |
| ៤ | សិស្សចាប់ផ្តើមដោយសង្កេតស្លាបមេអំបៅ និងលាបពណ៌វា |
| ៥ | នៅពេលថ្នាំពណ៌ស្ងួត សិស្សរៀបចំបំពង់ក្រដាសរឹង ដើម្បីបង្កើតដងខ្លួនមេអំបៅ |
| ៦ | នៅពេលផ្គុំចូលគ្នា មេអំបៅស្រស់ស្អាតអាចត្រូវបង្ហាញ និងអាចប្រើ ដើម្បីបង្ហាញពិភពធម្មជាតិ ឬស៊ីម៉េទ្រី។ |

[50] Ibid, នេះគឺឧទាហរណ៍នៃមេរៀននៅក្នុងសៀវភៅមគ្គុទេស

# មេរៀនទី១១ ការដាក់បញ្ចូលកុមារទាំងអស់នៅក្នុងការរៀន







© Michael Pitt

## សកម្មភាព ១១.១ ការឆ្លើយតបទៅនឹងភាពចម្រុះនៅក្នុងថ្នាក់រៀន

### រយៈពេល៖៤៥នាទី

### វត្ថុបំណង៖

- ពិពណ៌នាបានពីគោលការណ៍នៃប្លង់សកលសម្រាប់ការរៀន (UDL)។

### សម្ភារបង្រៀន និងរៀន៖

- វីដេអូចំនួន២ខ្សែ "ក្រឡេកមើលគោលការណ៍ប្លង់សកលសម្រាប់ការរៀន (UDL)"[51] និង "គោលការណ៍ និងការអនុវត្តប្លង់សកលសម្រាប់ការរៀន (UDL)"[52]
- ឯកសារអានដោយ CAST នៅទំព័របន្ទាប់

### សកម្មភាពបង្រៀន៖

ក. គរុសិស្សអានព័ត៌មានផ្តល់ឱ្យស្តីពីគោលការណ៍ប្លង់សកលសម្រាប់ការរៀន (UDL) ។

ខ. បញ្ចាំងវីដេអូឈ្មោះ "ក្រឡេកមើលគោលការណ៍ប្លង់សកលសម្រាប់ការរៀន (UDL)" និង "គោលការណ៍ និងការអនុវត្តប្លង់សកលសម្រាប់ការរៀន(UDL)" ផលិតដោយមជ្ឈមណ្ឌលជាតិនៃប្លង់សកលសម្រាប់ការរៀន (UDL) និងអាចស្វែងរកបាននៅក្នុងឌីវីឌី។

គ. ពិភាក្សាក្រុម

*សំណួរ*

- ចូរបង្កើតផ្ទាំងរូបភាពស្តីពីប្លង់សកលសម្រាប់ការរៀន (UDL)។ ផ្ទាំងរូបភាពដែលគួរឱ្យចាប់អារម្មណ៍ និងមានពាក្យមួយចំនួនឆ្លើយតបនឹងសំណួរខាងក្រោម៖
  - តើអ្វីជាការផ្តល់មធ្យោបាយច្រើនបែបនៃការបង្ហាញ?(រៀនអ្វី?)
  - តើអ្វីជាការផ្តល់មធ្យោបាយច្រើនបែបនៃសកម្មភាព និងការបញ្ចេញគំនិត? ("របៀប"នៃការរៀន)
  - តើអ្វីជាការផ្តល់មធ្យោបាយច្រើនបែបនៃការចូលរួម? ("ហេតុអ្វី" នៃការៀន)។

### ប្លង់សកលសម្រាប់ការរៀន [53]

ប្លង់សកលសម្រាប់ការរៀន (UDL)គឺជាគម្រោងដែលដោះស្រាយឧបសគ្គចម្បង ដើម្បីជំរុញអ្នករៀនពូកែនៅក្នុងបរិយាកាសបង្រៀនមិនបត់បែនកម្មវិធីសិក្សាមួយតម្រូវអ្នករៀនទាំងអស់។ វាគឺជាកម្មវិធីសិក្សាមិនមានភាពបត់បែន ដែលបណ្តាលឱ្យមានឧបសគ្គដែលមិនបានរំពឹងទុកដល់ការរៀន។ អ្នករៀន "ដែលស្ថិតក្នុងក្រុមភាគតិច" ដូចជាសិស្សមានប្រាជ្ញាឆ្លាតវៃពីកំណើតឬមានពិការភាពគឺជាក្រុមងាយរងគ្រោះជាងគេ។ ប៉ុន្តែសូម្បីតែសិស្សដែលត្រូវបានកំណត់ជា "សិស្សមធ្យម" ប្រហែលជាមិនត្រូវបានបំពេញសេចក្តីត្រូវការរៀនរបស់ពួកគេផងដែរដោយសារការរៀបចំកម្មវិធីសិក្សាមិនល្អ។

[51] វីដេអូស្តីពី "ក្រឡេកមើក UDL" ផលិតដោយ CAST (២០១០)

[52] វីដេអូស្តីពី "គោលការណ៍ និងការអនុវត្ត UDL" ផលិតដោយ CAST (២០១០)

[53] កែសម្រួលពីព័ត៌មានអនឡាញនៅលើគេហទំព័រ មជ្ឈមណ្ឌលជាតិសម្រាប់ UDL ដែលមានប្រភពពី CAST (២០១២)

## គោលការណ៍បីនៃប្លង់សកលសម្រាប់ការរៀន (UDL)

### គោលការណ៍ទី១៖ ផ្តល់មធ្យោបាយច្រើនបែបនៃការបង្ហាញ (រៀនអ្វី ?)

អ្នករៀនមានភាពខុសគ្នា ក្នុងរបៀបដែលពួកគេសង្កេត និងយល់ព័ត៌មាន ។ ឧទាហរណ៍អ្នកដែលពិបាកផ្នែកវិញ្ញាណ (ឧ. ពិការភ្នែក ឬគថ្លង់) ពិបាកក្នុងការរៀន (ឧ. វិបត្តិក្នុងការអាន ឬសរសេរ (Dyslexia) ភាពខុសគ្នាខាងភាសា ឬវប្បធម៌ជាដើមអាចទាមទារមធ្យោបាយយល់ខ្លឹមសារផ្សេងៗគ្នា។ អ្នកខ្លះអាចទទួលព័ត៌មានបានរហ័ស និងងាយតាមរយៈការមើល ឬស្តាប់ ជាជាងតាមរយៈអត្ថបទសរសេរ។ បន្ថែមពីលើនេះ ការរៀន និងការផ្ទេរចំណេះដឹងកើតឡើងនៅពេលការបង្ហាញច្រើនបែបត្រូវបានប្រើប្រាស់ ពីព្រោះអាចឱ្យសិស្សធ្វើការភ្ជាប់ចំណុចរវាងគោលគំនិតមួយ និងគោលគំនិតច្រើន។ ជារួមមិនមានមធ្យោបាយបង្ហាញតែមួយណាដែលមានប្រសិទ្ធភាពសម្រាប់អ្នករៀនទាំងអស់នោះទេ ការផ្តល់ជម្រើសសម្រាប់ការបង្ហាញមានសារៈសំខាន់។

**មធ្យោបាយច្រើនបែបនៃការបង្ហាញ៖**
ផ្តល់វិធីផ្សេងៗសម្រាប់សិស្សដើម្បីទទួលព័ត៌មាននិង ចំណេះដឹង

### គោលការណ៍ទី២៖ ផ្តល់មធ្យោបាយច្រើនបែបនៃសកម្មភាព និងការបញ្ចេញគំនិត (របៀបនៃការរៀន)

អ្នករៀនមានភាពខុសគ្នានៅក្នុងរបៀបដែលពួកគេអាចធ្វើសកម្មភាពនៅក្នុងបរិយាកាសរៀន និង បញ្ចេញគំនិតនូវអ្វីដែលពួកគេដឹង។ ឧទាហរណ៍អ្នកដែលមានបញ្ហាចលនាធ្ងន់ធ្ងរ ដូចជាជំងឺខូចប្រព័ន្ធបញ្ជាចលនាសាច់ដុំខួរក្បាល (cerebral palsy) អ្នកដែលមានការពិបាកខាងសមត្ថភាពចាត់ចែងនិងយុទ្ធសាស្ត្រ (វិបត្តិមុខងារប្រតិបត្តិ (executive function disorders)) អ្នកដែលមានរបាំងភាសាជាដើមបំពេញកិច្ចការរៀនខុសៗគ្នា។ អ្នកខ្លះអាចបញ្ចេញគំនិតបានល្អតាមរយៈការសរសេរ ប៉ុន្តែមិនបានល្អក្នុងការនិយាយ និងអាចមានករណីផ្ទុយមកវិញ។ វាក៏ត្រូវទទួលស្គាល់ផងដែរថាសកម្មភាពនិងការបញ្ចេញគំនិតទាមទារយុទ្ធសាស្ត្រ ការអនុវត្តនិងការរៀបចំចាត់ចែង ហើយនេះជាផ្នែកមួយទៀតដែលអ្នករៀនអាចខុសពីគ្នា។ ជាក់ស្តែង មិនមានសកម្មភាព និងការបញ្ចេញគំនិតតែមួយដែលមានប្រសិទ្ធភាពសម្រាប់អ្នករៀនទាំងអស់នោះទេ ដូច្នេះការផ្តល់ជម្រើសសម្រាប់សកម្មភាព និងការបញ្ចេញគំនិតមានសារៈសំខាន់។

**របៀបច្រើនបែបនៃសកម្មភាព និងការបញ្ចេញគំនិត**
អនុញ្ញាតឱ្យសិស្សបង្ហាញនៅក្នុងវិធីផ្សេងៗនូវអ្វីដែលពួកគេបានរៀន

**គោលការណ៍ទី៣៖ ផ្ដល់មធ្យោបាយច្រើនបែបនៃការចូលរួម ("ហេតុអ្វី" នៃការរៀន)**

ចេតនាជាធាតុផ្សំដ៏សំខាន់មួយនៃការរៀន ហើយអ្នករៀនអាចខុសគ្នាខ្លាំងនៅក្នុងរបៀបដែលពួកគេអាចត្រូវបានចូលរួមឬជំរុញឱ្យរៀន។ មានប្រភពជាច្រើនដែលអាចមានឥទ្ធិពលដល់ភាពខុសគ្នារបស់ចេតនារបស់បុគ្គលរួមមានសរសៃប្រសាទ វប្បធម៌ ភាពពាក់ព័ន្ធផ្ទាល់ខ្លួន ចំណូលចិត្តផ្ទាល់ខ្លួន សាវតា ចំណេះដឹងជាមួយនឹងកត្តាផ្សេងៗទៀតដែលបង្ហាញនៅក្នុងគោលការណ៍ណែនាំនេះ។ អ្នករៀនខ្លះចូលរួមយ៉ាងសកម្មឯកឯង និងថ្មីប្លែក ចំណែកអ្នករៀនផ្សេងទៀតមិនចូលរួម និងថែមទាំងភ័យខ្លាចទិដ្ឋភាពនោះដោយចូលចិត្តសកម្មភាពជាទម្លាប់ជាក់លាក់ច្រើនជាង។ អ្នករៀនខ្លះអាចចូលធ្វើការម្នាក់ឯង ចំណែកអ្នករៀនផ្សេងទៀតចូលចិត្តធ្វើការជាមួយមិត្តភក្តិរបស់ពួកគេ។ ជាក់ស្ដែងមិនមានរបៀបនៃការចូលរួមតែមួយដែលមានប្រសិទ្ធភាពសម្រាប់អ្នករៀនទាំងអស់នោះទេ ដូច្នេះការផ្ដល់ជម្រើសសម្រាប់ការចូលរួម មានសារៈសំខាន់។

**មធ្យោបាយច្រើនបែបនៃការចូលរួម**

រៀបចំមេរៀនឱ្យចាប់អារម្មណ៍ ដោយពិចារណាលើអ្វីដែលជំរុញសិស្សខុសៗគ្នានៅក្នុងថ្នាក់រៀន។

## គោលការណ៍ប្លង់សកលសម្រាប់ការរៀន (UDL) [54]

| I. ផ្ដល់មធ្យោបាយច្រើនបែបនៃការបង្ហាញ | II. ផ្ដល់មធ្យោបាយច្រើនបែបនៃសកម្មភាពនិងការបញ្ចេញគំនិត | III. ផ្ដល់មធ្យោបាយច្រើនបែបនៃការចូលរួម |
|---|---|---|
| ១. ផ្ដល់ជម្រើសសម្រាប់គំនិត | ១. ផ្ដល់ជម្រើសសម្រាប់សកម្មភាពរាងកាយ | ១. ផ្ដល់ជម្រើសសម្រាប់ការជ្រើសរើសចំណង់ចំណូលចិត្ត |
| ២. ផ្ដល់ជម្រើសសម្រាប់ភាសា និងសញ្ញា | ២. ផ្ដល់ជម្រើសសម្រាប់ជំនាញបញ្ចេញគំនិតនិងភាពស្ទាត់ជំនាញ | ២. ផ្ដល់ជម្រើសសម្រាប់ការគាំទ្រកិច្ចខិតខំប្រឹងប្រែង និងការតស៊ូ |
| ៣. ផ្ដល់ជម្រើសម្រាប់ការយល់ដឹង | ៣. ផ្ដល់ជម្រើសសម្រាប់មុខងារប្រតិបត្តិ | ៣. ផ្ដល់ជម្រើសសម្រាប់ការចាត់ចែងឬគ្រប់គ្រងខ្លួនឯង |

[54] បទបង្ហាញដោយសាស្ត្រាចារ្យ Barge ប្រើប្រាស់ Cast (២០០៨) ប្លង់សាកលសម្រាប់ការរៀន កំណែទី១ Wakefield: MA

# មេរៀនទី១២  ការអនុវត្តការជួយជ្រោមជ្រែង និងភាពផ្សេងៗគ្នារបស់សិស្ស



ការជួយជ្រោមជ្រែង



ថ្នាក់រៀនដែលសិស្សមានភាពផ្សេងៗគ្នា

## សកម្មភាព ១២.១ ការប្រើប្រាស់ការជួយជ្រោមជ្រែងនៅក្នុងមេរៀន

## រយៈពេល៖ ៣០នាទី

## វត្ថុបំណង៖

- ប្រាប់បានពីការជួយជ្រោមជ្រែងសិស្សសម្រាប់ការរៀនបរិយាបន្ន។

## សម្ភារបង្រៀន និងរៀន៖

- វីដេអូឈ្មោះ "ការជួយជ្រោមជ្រែង សម្រាប់ភាពជោគជ័យ" ផលិតដោយ Alberta Education.[55]

## សកម្មភាពបង្រៀន៖

ក. បញ្ចាំងវីដេអូឈ្មោះ "ការជួយជ្រោមជ្រែង សម្រាប់ភាពជោគជ័យ"

ខ. ពិភាក្សាក្រុមតូចៗ និងឆ្លើយសំណួរ

**សំណួរ**

១.ដូចម្តេចដែលហៅថាការជួយជ្រោមជ្រែង?

២.តើការជួយជ្រោមជ្រែង មានឥទ្ធិពលអ្វីខ្លះក្នុងការរៀបចំកិច្ចតែងការបង្រៀន?

៣.ពិពណ៌នាឧទាហរណ៍មួយពីរបៀបនៃការជួយជ្រោមជ្រែង ។

ឧទាហរណ៍មួយចំនួននៃចម្លើយរំពឹងទុកសម្រាប់ចំណុចទី ៣

**ផ្តល់គម្រុយ៖** គ្រូបង្រៀនបានឮកុមារម្នាក់រាប់ចំនួនឡានដឹកទំនិញខុស។ អ្នកគ្រូនោះសួរសិស្ស តើមានឡានដឹកទំនិញចំនួនប៉ុន្មាន? កុមារនិយាយថាមានចំនួន៨។ អ្នកគ្រូឱ្យកុមារនោះរៀបឡានដឹកទំនិញជាជួរ។ បន្ទាប់មកឱ្យកុមារនោះប៉ះឡានដឹកទំនិញនោះម្តងមួយនៅពេលរាប់។

**ផ្តល់ចម្លើយច្រើនបែប៖** ថ្នាក់រៀនមួយកំពុងរៀនអំពីជីវិតក្នុងមហាសមុទ្រ។ គ្រូបង្រៀនសួរអ្វីដែលរស់នៅក្នុងមហាសមុទ្រ។ សិស្សឆ្លើយថា ត្រី។ គ្រូបង្រៀនសួរ តើមានអ្វីផ្សេងទៀត? នៅពេលមិនមានចម្លើយ គ្រូបង្រៀននិយាយថា ខ្ញុំនឹងឱ្យឈ្មោះសត្វបី សត្វកង្កែប សត្វគោ និងត្រីឆ្លាម ប្រាប់ខ្ញុំតើសត្វមួយណារស់នៅក្នុងមហាសមុទ្រ។

**លើកទឹកចិត្តឱ្យសិស្សប្រើប្រាស់ធនធានផ្សេងទៀត៖** សិស្សបានរៀនអំពីការកែច្នៃឡើងវិញ ហើយនៅពេលចាប់ផ្តើមមេរៀនបន្ទាប់ គ្រូបង្រៀនសួរសិស្សម្នាក់ តើអ្វីដែលនាងនឹងកែច្នៃឡើងវិញ។ សិស្សមិនអាចឆ្លើយបាន។ គ្រូបង្រៀននាំសិស្សនោះទៅជ្រុងផ្នែកធនធាន ហើយឱ្យនាងមើលសៀវភៅស្តីពី ការកែច្នៃឡើងវិញ។

*"ការបង្រៀនបែបជួយជ្រោមជ្រែងផ្តល់ឱ្យសិស្សនូវការគាំទ្រត្រឹមត្រូវ ដែលពួកគេត្រូវការដើម្បីចូលរួមនៅក្នុងការរៀនបំពេញកិច្ចការលំបាក ឬរៀនបញ្ញត្តិថ្មីៗ"* ។

- ដកស្រង់ចេញពី Alberta Education[56]

[55] មួយនៃបណ្តុំវីដេអូស្តីពីការអប់រំបរិយាបន្ន ផលិតដោយនាយកដ្ឋានអប់រំ Alberta

[56] ដកស្រង់ពី *គោលការណ៍ណែនាំការពិភាក្សាស្តីពីការអប់រំបរិយាបន្ន* របស់ Alberta Education

## សារគន្លឹះ

ការបង្រៀនល្អជាការបង្កើតការរៀនចាប់ផ្តើមពីអ្វីដែលបានដឹង ឬអ្វីដែលអាចធ្វើបាន ទៅអ្វីដែលថ្មី។

- គ្រូបង្រៀនចាប់ផ្តើមពីចំណុចខ្លាំង និងសេចក្តីត្រូវការរបស់សិស្ស និងបន្ទាប់មកផ្តល់ "ការជួយជ្រោមជ្រែង" សម្រាប់សិស្សម្នាក់ៗ និងជាក្រុម ដើម្បីជួយបង្កើតការរៀនថ្មី។
- ការជួយជ្រោមជ្រែងការរៀន រួមមានការកសាង និងជំរុញចំណេះដឹងមានស្រាប់ ការធ្វើជាគំរូ ការអនុវត្តដោយមានការណែនាំ ការរំឭក ការបង្រៀនពីវិធីរៀបចំរូបភាព និងការប្រើប្រាស់បច្ចេកវិទ្យា ដូចជាឧបករណ៍អានអក្សរ។
- ការជួយជ្រោមជ្រែងប្រកបដោយប្រសិទ្ធភាពផ្តល់ជំនួយកែតម្រូវពិសេសឈរលើមូលដ្ឋានតម្រូវការ ការគ្រប់គ្រង ការខកបំណង កសាងទំនុកចិត្តអ្នករៀន និងប្រើប្រាស់មតិយោបល់ត្រឡប់ ដូច្នេះសិស្សអាចយល់អំពីអ្វីដែលពួកគេកំពុងធ្វើ និងរបៀបណាពួកគេអាចធ្វើឱ្យប្រសើរជាងនេះ។
- ការបង្រៀនជាផ្នែកៗ ជាការកសាងឯករាជ្យភាព តាមរយៈផ្លាស់ប្តូរការទទួលខុសត្រូវសម្រាប់ការរៀនពីគ្រូបង្រៀនទៅសិស្ស។ នៅពេលសមត្ថភាពសិស្សប្រសើរឡើង ការបង្រៀនជាផ្នែកៗអាចត្រូវបានកាត់បន្ថយ ឬដកចេញ។
- សម្រាប់សិស្សដែលមានការលំបាកក្នុងការរៀន កម្រិតនៃការជួយជ្រោមជ្រែងអាចប្រែប្រួល ប៉ុន្តែការគាំទ្រអាចត្រូវបន្តឱ្យមាន ដើម្បីឱ្យសិស្សអាចចូលរួមដោយសកម្មនៅក្នុងការរៀន និងរីកចម្រើនទៅមុខ។
- ដើម្បីបង្កើនភាពជោគជ័យរបស់សិស្សឱ្យអស់លទ្ធភាព ការប្រើប្រាស់ការជួយជ្រោមជ្រែងណាមួយក៏ដោយរួមទាំងបច្ចេកវិទ្យាត្រូវបូកបញ្ចូលរួមគ្នាជាមួយការបង្រៀនប្រកបដោយប្រសិទ្ធភាព។

## សកម្មភាព ១២.២ ការសម្របសម្រួលភាពផ្សេងៗគ្នារបស់សិស្សនៅក្នុងថ្នាក់រៀន

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង៖**

- ប្រើប្រាស់ការសម្របសម្រួលភាពផ្សេងៗគ្នាសម្រាប់ការរៀនបរិយាបន្ន។

**សម្ភារបង្រៀន និងរៀន ៖**

- វីដេអូឈ្មោះ "ប្រើប្រាស់ការបង្រៀនឆ្លើយតបសេចក្តីត្រូវការសិស្សម្នាក់ៗ"[57]

**សកម្មភាពបង្រៀន៖**

ក. បញ្ចាំងវីដេអូ

ខ. ឱ្យគរុសិស្សម្នាក់ៗ គូសធាតុផ្សំមួយណានៅក្នុងមេរៀន ដែលមានភាពផ្សេងៗគ្នាគូសប្រអប់ដែលអ្នកគិតថាត្រឹមត្រូវ[58]

គ.សំយោគ

[57] បណ្តុំវីដេអូស្តីពី ការអប់រំបរិយាបន្នរបស់ Alberta Education

[58] សកម្មភាពកែសម្រួលពីមេរៀនបណ្តុះបណ្តាលគ្រូបង្រៀន៖ ប្រទេសស៊ូដង់ខាងត្បូង របស់ Bohan-Jacquot ទំព័រ ៨៦

**ចម្លើយរំពឹងទុក**

| | ធាតុផ្សំនៃការបង្រៀនដែលមានភាពផ្សេងៗគ្នា | បាទ/ចាស | ទេ |
|---|---|---|---|
| ១ | ការរៀបចំកិច្ចតែងការបង្រៀន | ✓ | |
| ២ | ការកំណត់វត្ថុបំណងនៃមេរៀន | | ✓ |
| ៣ | សម្ភារបង្រៀន និងរៀនដែលប្រើប្រាស់នៅក្នុងមេរៀន | ✓ | |
| ៤ | កិច្ចការដាក់ឱ្យសិស្ស | ✓ | |
| ៥ | ការផ្តល់ការជួយគាំទ្រក្នុងកម្រិតផ្សេងៗគ្នា | ✓ | |
| ៦ | ការរៀបចំថ្នាក់រៀន | ✓ | |
| ៧ | ការវាយតម្លៃសិស្ស | ✓ | |
| ៨ | ការធ្វើការងារក្រុមដោយមានភាពបត់បែន | ✓ | |

## សារគន្លឹះ៖ [59]

**ការសម្របសម្រួលតាមភាពផ្សេងៗគ្នារបស់សិស្ស**

- **បរិយាកាស៖** អាចជួយឱ្យគ្រូបង្រៀនរៀបចំបរិយាកាសរៀនដែលទទួលស្គាល់ និងឱ្យតម្លៃភាពខុសគ្នាលើចំណុចខ្លាំងនៃការរៀន សេចក្តីត្រូវការ ចំណាប់ចំណូលចិត្ត និងសមត្ថភាពរបស់សិស្ស។ អាចនៅក្នុងថ្នាក់រៀន ឬក្រៅថ្នាក់រៀនអាស្រ័យលើមេរៀន។
- **ខ្លឹមសារ៖** អាចជួយគ្រូបង្រៀនជ្រើសរើសធនធានរៀន រៀបចំផែនការការបង្រៀន និងពិចារណាលើការកាត់បន្ថយខ្លឹមសារ ដើម្បីគាំទ្រការរៀនរបស់សិស្ស។
- **ដំណើរការ៖** គឺជាការដឹងថាតើសិស្សជាអ្នករៀនប្រភេទណា ជ្រើសរើសយុទ្ធវិធីបង្រៀនច្រើនបែប និងរៀបចំការងារជាក្រុមដោយបត់បែន។
- **ផលិតផល៖** គឺជាការវាយតម្លៃការរៀនដោយសិស្ស និងអាចត្រូវបានបង្ហាញនៅក្នុងវិធីផ្សេងៗ ឧ. ការបង្កើតផ្ទាំងរូបភាព ការគូររូប ការលាបពណ៌ ការសម្តែងតួ ។ល។

[59] កែសម្រួលពីគោលការណ៍ណែនាំបង្រៀនរបស់ Alberta Education ស្តីពី វិធីអប់រំបរិយាបន្ន

## សកម្មភាព ១២.៣ ការរៀបចំកិច្ចតែងការ ដោយមានការជួយជ្រោមជ្រែង និងសម្របសម្រួលតាមភាពផ្សេងៗគ្នារបស់សិស្ស

**រយៈពេល៖ ៩០នាទី**

**វត្ថុបំណង៖**

- រៀបចំកិច្ចតែងការបង្រៀនដោយការជួយជ្រោមជ្រែង និងសម្របសម្រួលតាមភាពផ្សេងៗគ្នា។

**សម្ភារបង្រៀន និងរៀន៖**

- បទបង្ហាញ កែសម្រួលពីការជួយជ្រោមជ្រែង និងញែកភាពខុសគ្នា [60] ដោយ Lisa Coons នាយកដ្ឋានអប់រំរដ្ឋ Tennessee [61]
- ការពន្យល់នៃការបង្រៀនបែបអនុមានរួម និងអនុមានញែក [62]
- ឧទាហរណ៍ទម្រង់កិច្ចតែងការបង្រៀន[63]

**សកម្មភាពបង្រៀន៖**

ក. បទបង្ហាញកែសម្រួលស្តីពី ប្លង់សកលសម្រាប់ការរៀន ដែលប្រើប្រាស់ការជួយជ្រោមជ្រែង និងភាពផ្សេងៗគ្នាទៅដល់គរុសិស្ស ។

ខ. រៀបចំកិច្ចតែងការបង្រៀនស្តីពីការរៀនលេខពី១ ដល់១០ជាក្រុម។

គ. តំណាងក្រុមរាយការណ៍

ឃ. សំយោគ

(ប្រាប់គរុសិស្សថា ពួកគេមានថ្នាក់រៀនដែលមានសិស្ស៤០នាក់ត្រូវបង្រៀន និងនៅក្នុងថ្នាក់រៀនអ្នកមានសិស្សម្នាក់ដែលមានបញ្ហាមើល ហើយអាចអានបានតែអក្សរធំៗ សិស្សម្នាក់ទៀតមានបញ្ហាបញ្ញាតិចតួច ប៉ុន្តែរៀនពូកែដោយប្រើប្រាស់សម្ភាររូបភាព។) ឱ្យគរុសិស្សរៀបចំកិច្ចតែងការបង្រៀនតាមទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាដោយពិចារណាលើទម្រង់របស់Sandrine Bohan-Jacquot។

[60] បទបង្ហាញដោយ Lisa Coons (ត្រូវបានធ្វើបច្ចុប្បន្នភាព) *ការបង្រៀនស្នូល៖ យុទ្ធសាស្ត្រសាលារៀនទូលំទូលាយ* នាយកដ្ឋានអប់រំ រដ្ឋTennessee

[61] បទបង្ហាញដោយ Lisa Coons (ត្រូវបានធ្វើបច្ចុប្បន្នភាព) *ការបង្រៀនស្នូល៖ យុទ្ធសាស្ត្រសាលារៀនទូលំទូលាយ* នាយកដ្ឋានអប់រំ រដ្ឋTennessee

[62] កែសម្រួលពី http://sites.educ.ualberta.ca/staff/olenka.bilash/Best%20of%20Bilash/inductivedeductive.html

[63] ដកស្រង់ពី Sandrine Bohan-Jacquot (២០១៤) មេរៀនបណ្តុះបណ្តាលគ្រូបង្រៀន៖ ប្រទេសស៊ូដង់ខាងត្បូង ទំព័រ ៨៣

## អនុមានរួម និងអនុមានញែកសម្រាប់ការបង្រៀន [64]




រូបភាពទី១៖ ការរៀនបែបអនុមានរួម និងអនុមានញែក កែសម្រួលពី
http://www.sasked.gov.sk.ca/docs/policy/approach/instrapp05.html

[64] កែសម្រួលពី http://sites.educ.ualberta.ca/staff/olenka.bilash/Best%20of%20Bilash/inductivedeductive.html

## ១. ទម្រង់កិច្ចតែងការបង្រៀន[65]

ទម្រង់កិច្ចតែងការបង្រៀនខាងក្រោមនេះបង្ហាញវិធីសាស្ត្ររៀបចំដើម្បីគាំទ្រអ្នក ប៉ុន្តែវាគ្រាន់តែជាទម្រង់ឧទាហរណ៍ប៉ុណ្ណោះ។ ដូច្នេះវាអាចត្រូវបានកែប្រែធ្វើឱ្យងាយស្រួល ឬកែសម្រួលទៅតាមស្ថានភាព (ឧ. ប្រសិនបើរៀបចំផែនការសម្រាប់ការបង្រៀននៅក្រៅថ្នាក់រៀន)។

| | | |
|---|---|---|
| ទម្រង់កិច្ចតែងការបង្រៀន | | |
| ប្រធានបទនៃមេរៀន៖<br>.................................................... | | |
| កាលបរិច្ឆេទ | វត្ថុបំណងនៃមេរៀន៖<br>ការពិបាករំពឹងទុក៖<br>នៅពេលបញ្ចប់មេរៀន សិស្សអាច៖ | |
| រយៈពេល | ជំហាន | ឧបករណ៍ជំនួយ<br>(តារាងសម្ភារ) |
| ៥នាទី | ជំហានទី១៖ រំឭកមេរៀនម៉ោងមុន | |
| ១០នាទី | ជំហានទី២៖ បង្ហាញប្រធានបទ<br>អ្នកអាចបង្ហាញប្រធានបទបែបអនុមានរួម<br>ឬអនុមានញែក | |
| ៥នាទី | ជំហានទី៣៖ ផ្តល់ឧទាហរណ៍មួយចំនួននៅលើក្តារខៀន | |
| ៥នាទី | ជំហានទី៤៖ ឱ្យសិស្សទាយវិធាននពីឧទាហរណ៍ | |
| ១០នាទី | ជំហានទី៥៖ សរសេរវិធាននៅលើក្តារខៀន | |
| ៥នាទី | ជំហានទី៦៖ ពិនិត្យការយល់ដឹងវិធាន និងផ្តល់ពេលវេលាសម្រាប់សំណួរ | |
| ១០នាទី | ជំហានទី៧៖ ផ្តល់លំហាត់ដើម្បីអនុវត្តវិធាន។<br>ដាក់លំហាត់ ផ្អែកតាមការពិបាក (ពីស្រួលជាងគេទៅពិបាកជាងគេ)<br>- ប្រើសកម្មភាពសប្បាយ សំណួរខ្លីៗ ល្បែងផ្គូផ្គង | |

[65] ដកស្រង់ពី Sandrine Bohan-Jacquot (២០១៤) មេរៀនបណ្តុះបណ្តាលគ្រូបង្រៀន៖ ប្រទេសស៊ូដង់ខាងត្បូង ទំព័រ ៨៣

| | |
|---|---|
| | សកម្មភាពរៀបតាមប្រភេទ ចំរៀង<br>សកម្មភាពរៀបឱ្យផ្គុំយ សរសេរប្រយោគ ប្រើកំណាព្យ<br>ការសម្តែងតួ ។ល។<br>-គិតអំពីរបៀបអ្នករៀបចំសិស្ស (ឧ.ការរៀបចំក្រុម) |
| ៥នាទី | ជំហានទី៨៖ វាយតម្លៃការរៀន ដើម្បីឱ្យដឹងថា<br>ការរៀនបានកើតមានឡើងឬទេ។<br>គិតអំពីរបៀបអ្នកនឹងវាយតម្លៃលទ្ធផលនៃការរៀន។ |
| ៥នាទី | ជំហានទី៩៖ ចុងក្រោយសង្ខេបមេរៀន<br>និងចំណុចសំខាន់ដែលត្រូវចងចាំ។ |
| គន្លឹះ: | • ត្រូវធានាថាសិស្សគ្រប់គ្នាចូលរួម<br>• រក្សាតុល្យភាពពេលវេលារវាងការនិយាយ ការសរសេរ ការស្តាប់ និងការអាន<br>• បែងចែកក្រុមតាមចំណង់ចំណូលចិត្ត មិត្តភាព សមត្ថភាព ឬរបៀបរៀន<br>• ផ្សារភ្ជាប់លំហាត់ទៅនឹងជីវិតជាក់ស្តែង (ឧ. ប្រើស្ថានភាពជាក់ស្តែង ឈ្មោះកុមារពិត នៅក្នុងប្រយោគលំហាត់ ប្រយោគ រៀបរាប់ការងារចុះទៅកន្លែង ។ល។) |
| កំណត់សម្គាល់ | ព័ត៌មានបន្ថែមដែលត្រូវគិត (ឧ. ប្រាប់ឪពុកម្តាយជាមុន សម្រាប់សកម្មភាពក្រៅថ្នាក់រៀន សម្រាប់ឱ្យក្មេងយកអ្វីមួយពីផ្ទះ ។ល។) |

**ឧទាហរណ៍នៃការប្រើប្រាស់ប្លង់សកលសម្រាប់ការរៀន (UDL) ដើម្បីបំពេញសេចក្តីត្រូវការខុសៗគ្នានៃកុមារនៅក្នុងថ្នាក់រៀន**

**ថ្នាក់ទី៣ មុខវិជ្ជា៖** វិទ្យាសាស្ត្រ **បទដ្ឋាន៖ ៦.២៣** វដ្តជីវិតរុក្ខជាតិ
**គោលបំណង៖** ស្រាវជ្រាវ និងបង្ហាញព័ត៌មានអំពីផ្កា

| សម្ភារ និង វិធីសាស្ត្រ | ឧបសគ្គចម្បង ឬ ឱកាសបាត់បង់ | ដំណោះស្រាយ |
|---|---|---|
| សៀវភៅសិក្សា | Kevinពិបាកមើលអត្ថបទទំហំតូច Billមិនបានយកជំនាញរូបភាពមកប្រើប្រាស់ Brian-ពិបាកយល់អត្ថន័យពាក្យ | • អត្ថបទអេឡិចត្រូនិចជាមួយឧបករណ៍អានអត្ថបទ ដើម្បីអានឱ្យឮ<br>• CD-ROOM ឬសព្វវចនាធិប្បាយគេហទំព័របណ្តុំរូបភាព<br>• CD-ROOM ភាសាអេស្បាញអំពីផ្កា អាសយដ្ឋានភ្ជាប់ទៅកាន់គេហទំព័រអេស្បាញ |
| ការធ្វើបទបង្ហាញទៅកាន់សិស្សទាំងអស់ | Joseពិបាកយល់អត្ថន័យ Helenអារម្មណ៍មិនមូល អាចមិនចាប់បានព័ត៌មាន Kiwaអារម្មណ៍មិនមូល អាចមិនចាប់បានព័ត៌មាន | • ផ្តល់ការបកប្រែពាក្យបច្ចេកទេសអេស្បាញអង់គ្លេសជាមួយឧបករណ៍អានអត្ថបទ<br>• ផ្តល់ផែនទីគោលគំនិតនៃគំនិតសំខាន់ៗ គ្រោងឆ្អឹងអត្ថបទអេឡិចត្រូនិចជាមួយឧបករណ៍អានអត្ថបទ ដែលសិស្សអាចប្រើប្រាស់បាន |
| ការស្រាវជ្រាវនៅបណ្ណាល័យ | Brainមានបញ្ហាចាប់យកខ្លឹមសារ Kiwaមិនអាចដកស្រង់ខ្លឹមសារសំខាន់របស់គម្រោង | • គ្រោងឆ្អឹងដែលត្រូវបានបំពេញមួយចំនួន គេហទំព័រដែលមានភ្ជាប់ជាមួយធនធានបណ្តុំធនធានអ៊ីនធឺណិត សព្វវចនាធិប្បាយអ៊ីនធឺណិត ឬជាCD-ROOM អាសយដ្ឋានភ្ជាប់ទៅកាន់គ្រោងឆ្អឹងផ្នែកសំខាន់ៗនៃគម្រោង |
| សរសេររបាយការណ៍ | Saritaការពិបាកបញ្ចេញគំនិតរបស់នាង Jakeទម្រង់មិនបានយកទេពកោសល្យសិល្បៈមកប្រើប្រាស់ | • កម្មវិធីវាយអត្ថបទដែលមានមុខងារត្រួតពិនិត្យការប្រកបអក្សរ<br>• កម្មវិធីវាយអត្ថបទតាមការនិយាយ<br>• កម្មវិធីរូបភាពKid Pix |

| | | |
|---|---|---|
| **គូររូបផ្កា** | Phillipពិបាកក្នុងការគូររូប | ការសរសេរអត្ថបទ ការជ្រើសរើសរូបភាពដើម្បីប្រើនៅក្នុងរបាយការណ៍ |
| **រាយការណ៍ផ្ទាល់មាត់អំពីផ្កា** | Jorgeទម្រង់មិនបានយកទេពកោសល្យតួរ្យតន្ត្រីមកប្រើប្រាស់ Brainអាចមានអារម្មណ៍ភ័យខ្លាច | • ផ្តល់នូវជម្រើសនៃការផ្សាយបន្តផ្ទាល់ឬចាក់បទភ្លេងជាផ្នែកមួយនៃបទបង្ហាញ<br>• ចាប់ដៃគូជាមួយ Brain និងJames ដែលអាចជួយគេបាន |
| **គម្រោងឯករាជ្យ** | Jamesមិនបានប្រើប្រាស់ជំនាញដឹកនាំ និងសហការរបស់ខ្លួន<br><br>Helenមានការពិបាកធ្វើការតែម្នាក់ឯង<br>Elizabethចំណេះដឹងជ្រាលជ្រៅអំពីរុក្ខជាតិ | • លើកទឹកចិត្តឱ្យ James គាំទ្រសិស្សដទៃនៅពេលពួកគេកំពុងធ្វើការ<br>• ត្រូវស្វែងរកផ្នែកនៃគម្រោង ដែលជាចំណាប់អារម្មណ៍សម្រាប់ Helen និងពិនិត្យឱ្យបានញឹកញាប់។ ផ្តល់បទបង្ហាញជាមួយការកត់ត្រា។<br>• ឱ្យ Elizabeth ធ្វើការជាដៃគូជាមួយ Jose ដើម្បីចែករំលែកចំណេះដឹង និងការចាប់អារម្មណ៍ |

**ឧទាហរណ៍នៃការជួយជ្រោមជ្រែង**

| **ការជួយជ្រោមជ្រែង** | **របៀបប្រើប្រាស់ការជួយជ្រោមជ្រែងនៅក្នុងមេរៀន** |
|---|---|
| ឧទាហរណ៍ | ផ្តល់គំរូ រូបភាព វត្ថុពិតប្រាកដប្រសិនបើអាចធ្វើទៅបាន |
| ការពន្យល់ | ការពន្យល់លម្អិត ការណែនាំជាលាយលក្ខអក្សរ ការណែនាំផ្ទាល់មាត់ |
| ឯកសារមេរៀន | ក្រដាសមេរៀនអាចផ្តល់ឱ្យមុន ឬក្រោយមេរៀន |
| គម្រុយណែនាំ | ផ្តល់គម្រុយ ឧទាហរណ៍ ប្រើប្រាស់ escape key ស្វែងរកប្រធាននៃកិរិយាសព្ទ |
| ការធ្វើត្រាប់ | ចង្អុល សួរសំណួរ "តើតួអង្គធ្វើសកម្មភាពដូចម្តេច?" ឬនិយាយ |
| ប័ណ្ណសំណួរ | សម្រាប់សិស្សនៅក្នុងក្រុមសហការ សួរគ្នាទៅវិញទៅមក |
| សំណួរបំពេញ | ផ្តល់ប្រយោគដែលមិនពេញលេញ ដែលសិស្សត្រូវបំពេញ ដើម្បីការយល់ឱ្យបានស៊ីជម្រៅ |
| រឿង | បង្កើតរឿង ដែលគ្របដណ្តប់ខ្លឹមសារមេរៀន និងធ្វើវាឱ្យទាក់ទងទៅនឹងសិស្ស |
| ការជួយជ្រោមជ្រែងរូបភាព | រូបភាព ដ្យាក្រាម វីដេអូ |

# មេរៀនទី១៣ ការអភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងល្អ






© Jodie Davies

## សកម្មភាព ១៣.១ ការយល់ដឹងជំនាញចាំបាច់សម្រាប់ការប្រាស្រ័យទាក់ទង[66]

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង ៖**

- ពិពណ៌នាបានអំពីមូលហេតុដែលយើងប្រាស្រ័យទាក់ទង
- កំណត់បានជំនាញផ្សេងៗ ចាំបាច់សម្រាប់ការប្រាស្រ័យទាក់ទង ប្រកបដោយប្រសិទ្ធភាព។

**សម្ភារបង្រៀន និងរៀន៖**

- ពីរ៉ាមីតការប្រាស្រ័យទាក់ទង
- បទបង្ហាញបន្ថែមស្តីពីការប្រាស្រ័យទាក់ទងនៅក្នុងថ្នាក់រៀន[67]

**សកម្មភាពបង្រៀន ៖**

ក. សំណួរបំផុស

ហេតុអ្វីមនុស្សប្រាស្រ័យទាក់ទងគ្នា?

ខ. ឱ្យអានសារជាបុគ្គលរួចសួរ

<u>សំណួរ</u>

តើមានមធ្យោបាយអ្វីផ្សេងទៀតដែលយើងប្រើប្រាស់ដើម្បីប្រាស្រ័យទាក់ទង?

គ. ឱ្យគរុសិស្សចាប់ដៃគូ (ចំណាយពេល៣នាទី) និយាយទៅកាន់អ្នកក្បែរខ្លួន ដោយប្រាប់អំពីគ្រួសាររបស់ពួកគេរួចសួរ

<u>សំណួរ</u>

តើជំនាញអ្វីចាំបាច់នៅក្នុងការប្រាស្រ័យទាក់ទងនេះ?

ឃ. ឱ្យគរុសិស្សប្រៀបធៀបសេចក្តីសន្និដ្ឋានរបស់ពួកគេជាមួយព័ត៌មានអំពីពីរ៉ាមីតប្រាស្រ័យទាក់ទងក្នុងសៀវភៅសិក្សា ។

- ប្រសិនបើនៅសល់ពេលវេលា អ្នកអាចចែករំលែកបទបង្ហាញ ដោយ Kate Hanley នៃ OIC ប្រទេសកម្ពុជា។

> "ការនិយាយគឺជាផ្នែកតូចមួយនៃរបៀបដែលយើងប្រាស្រ័យទាក់ទង"
>
> \- អនាមិក

[66] សកម្មភាពទាំងអស់ត្រូវបានកែសម្រួលពីវគ្គបណ្តុះបណ្តាលការព្យាបាលបែបនិយាយ និងបែបភាសា ធ្វើឡើងនៅប្រទេសកម្ពុជា ដោយ Jodie Davies, Alice King, Raj Cheema និង Emma Whittingham, អ្នកព្យាបាលបែបនិយាយ និងបែបភាសា មកពីសាកលវិទ្យាល័យ City ទីក្រុងឡុង

[67] បទបង្ហាញដោយ Kate Hanley អ្នកព្យាបាលបែបនិយាយ និងបែបភាសា ដែលស្ម័គ្រចិត្តនៅ OIC ក្នុងឆ្នាំ២០១៥

## ពីរ៉ាមីតប្រាស្រ័យទាក់ទង [68]




[68] ដកស្រង់ពី Speech Therapy blog នៅលើគេហទំព័រ Ladybug House Healthcare for Kids

## សកម្មភាព ១៣.២ ការកំណត់ការពិបាកនៃការប្រាស្រ័យទាក់ទង

## រយៈពេល៖ ៤៥នាទី

## វត្ថុបំណង ៖

- កំណត់បានប្រភេទនៃការពិបាកក្នុងការប្រាស្រ័យទាក់ទងផ្សេងៗ
- កំណត់បានចំណុចខ្លាំង និងសេចក្ដីត្រូវការនៅក្នុងការប្រាស្រ័យទាក់ទង។

## សម្ភារបង្រៀន និងរៀន៖

- ពីរ៉ាមីតប្រាស្រ័យទាក់ទង
- វីដេអូផលិតដោយអ្នកព្យាបាលបែបនិយាយ និងភាសា (SaLT) ពីសាកលវិទ្យាល័យ City ទីក្រុងឡុងផលិតនៅអង្គការសាលារៀនទន្សាយ[69]

## សកម្មភាពបង្រៀន៖

ក. ឱ្យគរុសិស្សមើលកម្រិតផ្សេងៗគ្នានៅក្នុងពីរ៉ាមីតប្រាស្រ័យទាក់ទង។

ខ. សួរសំណួរបំផុស

តើកុមារអាចមានការពិបាកអ្វីខ្លះក្នុងការប្រាស្រ័យទាក់ទង?

គ. បញ្ចាំងវីដេអូពីរនាទីដំបូង (ផលិតដោយអ្នកព្យាបាលបែបនិយាយ និងភាសា (SaLT) នៅអង្គការសាលារៀនទន្សាយ) រួចសួរសំណួរខាងក្រោម៖

តើកុមារមានចំណុចខ្លាំងដូចម្ដេចខ្លះក្នុងការប្រាស្រ័យទាក់ទង ?

តើកុមារមានតម្រូវការគាំទ្រអ្វីបន្ថែមទៀត ?

ឃ. បន្ទាប់មកឱ្យគរុសិស្សបំពេញក្នុងប្រអប់ រួចប្រៀបធៀបចម្លើយរបស់ពួកគេទៅនឹងសារគន្លឹះនៅទំព័របន្ទាប់។




[69] វីដេអូផ្សព្វផ្សាយដោយអ្នកព្យាបាលដោយនិយាយ និងភាសា Kijowska et al ពីសាកលវិទ្យាល័យស៊ីធី នៅទីក្រុងឡុងផលិតនៅអង្គការសាលារៀនទន្សាយ ក្នុងឆ្នាំ២០០៩

**ចម្លើយរំពឹងទុក៖**

ចំណុចខ្លាំងរបស់កុមារ៖ ជំនាញទំនាក់ទំនងនៅដំណាក់កាលដំបូង យកចិត្តទុកដាក់ និងស្តាប់អាចយល់សំណួរ។ តម្រូវការរបស់កុមារ៖ ពីពីរ៉ាមីតប្រាស្រ័យទាក់ទង សេចក្តីត្រូវការគឺការនិយាយ សំឡេង និងការសន្ទនានិងរបៀបប្រាស្រ័យទាក់ទងដោយប្រើប្រាស់រូបភាព និងរៀនបញ្ចេញសំឡេងតាមរយៈធាតុចូលនៃការរៀនបែបនិយាយ និងភាសា។

មើលវីដេអូពីនាទី28:30 ដល់30:30 ដែលបង្ហាញរបៀបកុមារអាចសន្ទនាដោយប្រើប្រាស់ "**សៀវភៅប្រាស្រ័យទាក់ទង**" ដែលរៀបចំពិសេសសម្រាប់កុមារនោះ។

## សារគន្លឹះសម្រាប់កំណត់ចំណុចខ្លាំង និង តម្រូវការការគាំទ្រ

- ការយល់ដឹងអំពីចំណុចនេះជួយយើងឱ្យគាំទ្រកុមារអភិវឌ្ឍជំនាញប្រាស្រ័យទាក់ទងដោយឯករាជ្យ។
- ជាការល្អក្នុងការប្រើប្រាស់ពីរ៉ាមីតប្រាស្រ័យទាក់ទង និងឧទាហរណ៍ពីអ្វីដែលអ្នកបានឃើញកុមារធ្វើដើម្បីបង្កើតរូបភាពនៃចំណុចខ្លាំង និងតម្រូវការរបស់ពួកគេ។
- យើងអាចប្រើផ្នែកខ្លាំងរបស់ពួកគេ ដើម្បីដោះស្រាយផ្នែកតម្រូវការ
- ការដឹងអំពីចំណុចខ្លាំង និងតម្រូវការជួយយើងមើលឃើញការផ្លាស់ប្តូរ និងការអភិវឌ្ឍរបស់កុមារ

ឧ. ដើម្បីពិនិត្យមើល តើពួកគេអាចរៀនបានយូរ ឬតើពួកគេត្រូវការរំឭកឡើងវិញតិចតួចដើម្បីចូលរួមនៅក្នុងសកម្មភាពមួយ។

## សកម្មភាព ១៣.៣ ការបំពេញតម្រូវការគាំទ្រការប្រាស្រ័យទាក់ទង

**រយៈពេល៖ ៦០នាទី**

**វត្ថុបំណង ៖**

- កំណត់បានប្រភេទឧបករណ៍ប្រាស្រ័យទាក់ទងផ្សេងៗ។

**សម្ភារបង្រៀន និងរៀន៖**

- រូបភាពឧបករណ៍ជំនួយប្រាស្រ័យទាក់ទងផ្សេងៗ
- ឧបករណ៍ជំនួយមើលកម្ពុជា [70]
- វីដេអូមានចំណងជើង "វីដេអូផលិតដោយអ្នកព្យាបាល ពីអង្គការសាលារៀនទន្សាយពីនាទី២៤ ដល់នាទី២៨:៣០ ដើម្បីរៀនអំពីប្រព័ន្ធប្រាស្រ័យទាក់ទងផ្លាស់ប្តូររូបភាព (PECS) និងរបៀបប្រើប្រាស់សៀវភៅប្រាស្រ័យទាក់ទង។

**សកម្មភាពបង្រៀន៖**

ក. សួរសំណួរបំផុស៖
តើឧបករណ៍ជំនួយការប្រាស្រ័យទាក់ទងអ្វីខ្លះដែលអ្នកធ្លាប់ឃើញ?

ខ. ឱ្យគរុសិស្សមើលរូបភាពនៅក្នុងសៀវភៅសិក្សាដើម្បីកំណត់ឧបករណ៍ជំនួយការប្រាស្រ័យទាក់ទង ។

គ. សំយោគ។

ឃ. បញ្ចាំងវីដេអូ ដើម្បីស្វែងយល់បន្ថែមអំពីប្រព័ន្ធប្រាស្រ័យទាក់ទងផ្លាស់ប្តូររូបភាព។

ង. ឱ្យគរុសិស្សប្រើប្រាស់ភាសាសញ្ញា ដើម្បីប្រកបឈ្មោះរបស់ពួកគេ។

ច. ឱ្យពួកគេរៀនអំពីឧបករណ៍ជំនួយការប្រាស្រ័យទាក់ទងទាំងអស់ផ្សេងទៀតនៅទំព័របន្ទាប់។

[70] ឧបករណ៍ជំនួយការមើលកម្ពុជា បង្កើតដោយ Eastern Health Services ក្នុងឆ្នាំ២០០៧

<table>
<tr><td>ក<br></td><td>ខ<br></td></tr>
<tr><td>គ<br></td><td>ឃ<br></td></tr>
<tr><td>ង<br></td><td>ច<br></td></tr>
<tr><td>ឆ<br></td><td>ជ<br></td></tr>
<tr><td colspan="2">ចម្លើយ៖ ក ខ ឆ = ឧបករណ៍ព័ត៌មានវិទ្យា គ = កាលវិភាគរូបភាព ឃ = ក្តារប្រាស្រ័យទាក់ទង<br>ង = ការប្រកបអក្សរដោយម្រាមដៃ ច=ឧបករណ៍ជំនួយស្តាប់ ជ = ស្លេត និង ស្តាយឡាស</td></tr>
</table>

## សារគន្លឹះក្នុងការប្រាស្រ័យទាក់ទង[71]

- ឈរឱ្យសមរម្យនៅមុខកុមារ នៅពេលនិយាយនៅកាន់ពួកគេ ដើម្បីឱ្យកុមារទាំងអស់អាចមើលឃើញអ្នក។
- និយាយឱ្យច្បាស់ និងឮ។
- ប្រើប្រាស់ពាក្យសាមញ្ញ និងប្រយោគខ្លីៗ។
- ផ្តល់ការណែនាំម្តងមួយៗ ។
- ប្រើប្រាស់វិធីប្រាស្រ័យទាក់ទងផ្សេងៗ។
- និយាយព័ត៌មានសាឡើងវិញ។
- មានមូលហេតុជាច្រើននាំឱ្យមានការប្រាស្រ័យទាក់ទង។ ការប្រាស្រ័យទាក់ទង គឺជាផ្នែកសំខាន់មួយនៃជីវិតរបស់យើង។
- កុមារដែលមិនយល់ អាចមានការពិបាករៀនមេរៀន។
- ធ្វើការប្រាស្រ័យទាក់ទងរបស់អ្នកឱ្យសាមញ្ញ នៅពេលអ្នកធ្វើការជាមួយនរណាម្នាក់មានការពិបាកខាងបញ្ញា។
- ជាការល្អត្រូវអនុវត្តការនិយាយ ទោះបីនៅក្នុងករណីកុមារនិយាយមិនច្បាស់ក៏ដោយ។
- ប្រសិនបើការនិយាយមិនច្បាស់ លើកទឹកចិត្តឱ្យកុមារនោះប្រើប្រាស់កាយវិការ និងសញ្ញាអមជាមួយការនិយាយ។
- ប្រាប់សារៈសំខាន់ទៅកាន់កុមារ ដោយនិយាយថា "ស្តាប់ដោយប្រុងប្រយ័ត្ន"។
- ពិនិត្យការយល់ដឹងរបស់កុមារ ដោយឱ្យពួកគេនិយាយសាឡើងវិញនូវអ្វីដែលអ្នកបានពន្យល់។
- លើកទឹកចិត្តកុមារឱ្យសួរ ប្រសិនបើពួកគេមិនយល់ ដោយលើកដៃសួរ ។
- ឱ្យមិត្តរួមថ្នាក់ និងបងប្អូនប្រុសស្រីប្រាស្រ័យទាក់ទងជាមួយកុមារ ដែលមានការពិបាកក្នុងការប្រាស្រ័យទាក់ទង។
- ប្រើប្រាស់កាយវិការ ឧ. ទៅជិតសិស្សដែលខ្មាសអៀន ដើម្បីផ្តល់ការគាំទ្រផ្លូវចិត្តហើយលើកទឹកចិត្ត។
- ផ្តល់រយៈពេលច្រើនជាង៣០វិនាទី ដល់កុមារដើម្បីឆ្លើយសំណួរ។
- កុមារនឹងមានទំនុកចិត្តកាន់តែខ្លាំង ក្នុងការឆ្លើយប្រសិនបើពួកគេមិនខ្លាចថាត្រូវបានចំអក ដាក់ទណ្ឌកម្ម ឬធ្វើឱ្យអាម៉ាស់មុខនៅមុខសិស្សក្នុងថ្នាក់រៀន។
- សរសើរ និងលើកទឹកចិត្តកុមារ។

[71] កែសម្រួលពីវគ្គបណ្តុះបណ្តាលដោយ Alice King, Raj Cheema និងEmma Whittingham នៅប្រទេសកម្ពុជា សម្រាប់ CCOSC នៅឆ្នាំ២០១៦

# ប័ណ្ណប្រាស្រ័យទាក់ទងរូបភាពកម្ពុជា[72]

## BASICS


YES / បាទ / ចាស់


NO / ទេ


UNSURE / មិនច្បាស់ប្រាកដ


NO SMOKING / កុំពិសាបារី


STOP / ឈប់


CALL NURSE / ទូរស័ព្ទហៅគិលានុបដ្ឋាក


TOILET / បង្គន់


HELP / សូមជួយផង


MEALS AREA / កន្លែងបរិភោគអាហារ


THERAPY / ការព្យាបាលដោយវិធីហាត់ប្រាណ


BED PAN / កន្ថោរ


BRUSH / ក្រាសសិតសក់


SHOWER / ទឹកផ្កាឈូក


HOT DRINK / ភេសជ្ជៈក្តៅ


COLD DRINK / ភេសជ្ជៈត្រជាក់


HUNGRY/ ឃ្លាន


WATER / ទឹក


TOOTH BRUSH / ច្រាសដុសធ្មេញ


TELEVISION / ទូរទស្សន៍


TELEPHONE / ទូរស័ព្ទ

© Eastern Health 2007

[72] ទំព័រដំបូងនៃប័ណ្ណកម្ពុជា បង្កើតដោយ Eastern Health Service នៅរដ្ឋ New South Wales ប្រទេសអូស្ត្រាលី

## សញ្ញាព្យញ្ជនៈខ្មែរ[73]




[73] សញ្ញាព្យញ្ជនៈ បង្កើតដោយអង្គការគ្រួសារថ្មី

## សញ្ញាមួយចំនួនសម្រាប់អ្នក និងគរុសិស្សអនុវត្ត:[74]

| | | |
|---|---|---|
|  |  |  |
| សញ្ញា | គថ្លង់ | បង្រៀន |
|  |  |  |
| ឆ្មា | ផ្លែឈើ | ឈ្មោះ |
|  |  |  |
| កម្ពុជា | សិស្ស | សប្បាយ |
|  |  |  |
| ឆ្កែ | សួស្តី | ក្មេងស្រី |
|  |  |  |
| ក្មេងប្រុស | លេង | អរគុណ |

[74] ដកស្រង់ពីសៀវភៅការអប់រំបញ្ចូលគ្នា (២០១២) មេរៀនទី៧



© Michael Pitt

# អក្សរប្រៃយ៍ខ្មែរ
# KHMER **BRAILLE** SYSTEM

Krousar Thmey គ្រួសារថ្មី

## ព្យញ្ជនៈខ្មែរ | KHMER **CONSONANTS**




## ជើងព្យញ្ជនៈខ្មែរ | KHMER LEGS **CONSONANTS**



ICEVI THE NIPPON FOUNDATION

# អក្សរស្ទាបខ្មែរ
## KHMER **BRAILLE** SYSTEM

Krousar Thmey
គ្រួសារថ្មី

### ស្រៈខ្មែរ | KHMER **VOWELS**



### ស្រៈពេញតួខ្មែរ | KHMER FULL **VOWELS**



# មេរៀនទី១៤ ការប្រើប្រាស់វិធីបង្រៀន និងរៀនសកម្ម





© Michael Pitt

## សកម្មភាព ១៤.១ ការកំណត់វិធីបង្រៀន និងរៀនសកម្ម និងអកម្ម

### រយៈពេល៖៣០នាទី

### វត្ថុបំណង៖

- កំណត់បានពីវិធីបង្រៀន និងរៀនសកម្ម និងអកម្ម។

### សម្ភារបង្រៀន និងរៀន៖

- សាជីនៃការរៀន[75]

### សកម្មភាពបង្រៀន ៖

ក. ឱ្យគរុសិស្សអានដ្យាក្រាមសាជីនៃការរៀន

ខ. ឱ្យគរុសិស្សបំពេញតារាងត្រួតពិនិត្យ




---

[75] ដកស្រង់ពី *សម្ភារសោតទស្សន៍នៅក្នុងការបង្រៀន* របស់ Edgar Dale ទំព័រ១០៨

**បំពេញតារាងត្រួតពិនិត្យខាងក្រោម៖**[76]

ចូរគូសក្នុងប្រអប់តើវិធីមួយណាសកម្ម ឬអកម្ម និងបន្ទាប់មកផ្តល់គុណសម្បត្តិ និងគុណវិបត្តិនៃវិធីម្នាក់ៗ ។

| វិធី | សកម្ម | អកម្ម | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|---|---|
| ការធ្វើសុន្ទរកថា | | | | |
| កិច្ចពិភាក្សា | | | | |
| ការងារជាក្រុម | | | | |
| ការចែករំលែកគំនិត | | | | |
| សោតទស្សន៍ | | | | |
| ករណីសិក្សា | | | | |
| ការបង្ហាញ | | | | |
| គម្រោងស្រាវជ្រាវ | | | | |
| វាគ្មិន | | | | |
| ការអាន | | | | |
| ការហ្វឹកហាត់ | | | | |
| ការសម្តែងតួ | | | | |
| ទស្សនកិច្ចសិក្សា | | | | |
| បង្រៀនអ្នកដទៃ | | | | |
| ការសង្កេត | | | | |
| ការរៀនបែបមិត្តជួយមិត្ត | | | | |
| ការរៀនដោយទន្ទេញ | | | | |

**ចម្លើយរំពឹងទុក៖** អ = អកម្ម      ស = សកម្ម

[76] កែសម្រួលពីមេរៀនការអប់រំបរិយាបន្នប្រទេសស៊ុយអែតខាងត្បូងរបស់ Sandrine Bohan-Jacquot ទំព័រ៩៧

| វិធីសាស្ត្រ | អ | ស | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|---|---|
| ការធ្វើសុន្ទរកថា | √ | | ទទួលព័ត៌មានច្រើននៅក្នុងរយៈពេលខ្លីអ្នកពូកែនិយាយអាចមានប្រសិទ្ធភាព | ពិបាកសម្រាប់អ្នករៀនបែបកាយវិញ្ញាណត្រូវចាប់យកព័ត៌មានច្រើនពេក |
| កិច្ចពិភាក្សា | | √ | អាចបកស្រាយ ពង្រីកការយល់ដឹង អាចរៀនពីអ្នកដទៃ | មនុស្សដែលមានកង្វល់តែនឹងខ្លួនឯងអាចរៀនខ្មាសខ្លាំងក្នុងការចូលរួមជម្រៅនៃការពិភាក្សាពឹងផ្អែកលើចំណេះដឹង និងការយល់ដឹង |
| ការងារជាក្រុម | | √ | អាចជំរុញឱ្យមានការចូលរួមខ្លាំង ការរៀនពីសិស្សផ្សេង ការធ្វើការងារជាក្រុម ការដោះស្រាយបញ្ហា | អាចចំណាយពេលវេលាយូរដើម្បីឱ្យសមាជិកក្រុមមានអារម្មណ៍ស្និទ្ធស្នាលនឹងគ្នា |
| ការចែករំលែកគំនិត | | √ | អាចជំរុញឱ្យមានការចូលរួមខ្លាំង អាចបង្កើតគំនិត និងដំណោះស្រាយច្រើន | សម្រាប់អ្នករៀនមួយចំនួនអាចពិបាកនិយាយនៅក្នុងក្រុមដែលមានគ្នាច្រើន |
| សោតទស្សន៍ | √ | | មានប្រសិទ្ធភាពល្អសម្រាប់អ្នករៀនបែបចក្ខុវិញ្ញាណ | ប្រសិនបើគុណភាពវីដេអូមិនល្អអាចធ្វើឱ្យរំខាន |
| ករណីសិក្សា | | √ | រៀនពីការផ្តល់ឧទាហរណ៍ជាក់ស្តែង និងអាចអនុវត្តងាយស្រួល | សម្រាប់អ្នករៀនដែលមិនពូកែអានប្រហែលជាពិបាក |
| ការបង្ហាញ | √ | | ល្អសម្រាប់អ្នករៀនបែបកាយវិញ្ញាណ និងចក្ខុវិញ្ញាណ ពួកគេអាចមើលឃើញដំណើរការ និងជំហានពាក់ព័ន្ធ | មិនមានប្រសិទ្ធភាព សម្រាប់អ្នកដែលត្រូវការដឹងទ្រឹស្តីមុន |
| គម្រោងស្រាវជ្រាវ | | √ | ល្អសម្រាប់ស្វ័យសិក្សា និងការប្រមូលព័ត៌មានលើប្រធានបទណាមួយ | មិនល្អនៅក្នុងករណីដែលមិនមានធនធាន និងអ៊ីនធើណែត |
| វាគ្មិន | √ | | ផ្តល់ទស្សនៈផ្ទាល់ខ្លួន និងអនុញ្ញាតឱ្យមានការសួរសំណួរ និងការរៀន។ | ប្រសិនបើវាគ្មិនមិនមានចំណេះដឹងល្អ នោះនឹងមិនមានការរៀននោះទេ។ |
| ការអាន | √ | | មានប្រសិទ្ធភាពសម្រាប់ស្វ័យសិក្សា សម្រាប់អ្នកដែលចូលចិត្តការអាន។ | មិនមានប្រសិទ្ធភាព សម្រាប់អ្នករៀនដែលសមត្ថភាពការអាននៅខ្សោយ។ |

| | | | | |
|---|---|---|---|---|
| កាហ្វឹកហាត់ | | √ | ល្អបំផុតសម្រាប់ការរៀនបែបពិសោធន៍ | អាស្រ័យលើធនធាន សម្ភារ និងឱកាសដែលមាន |
| ការសម្តែងតួ | | √ | វិធីល្អដើម្បីទទួលបានបទពិសោធន៍អំពីជីវិតជាក់ស្តែងល្អសម្រាប់អ្នករៀនបែបកាយវិញ្ញាណចងចាំបានយូរ | មនុស្សមួយចំនួនអាចស្រគត់ស្រគំ និងអាចពិបាកបង្ហាញ និងទប់អារម្មណ៍ |
| ទស្សនកិច្ចសិក្សា | √ | | ល្អសម្រាប់ការរៀនអំពីតថភាព ទទួលបានគំនិតល្អៗ | អាស្រ័យថាតើទស្សនកិច្ចសិក្សាធ្វើឡើងនៅក្នុងសាលារៀនដែលមានការអនុវត្តល្អឬទេ |
| បង្រៀនអ្នកដទៃ | | √ | បទពិសោធចងចាំបានយូរ និងសម្រាប់អ្នករៀនដែលចូលចិត្តស្រាវជ្រាវ វិធីរៀននេះមានប្រសិទ្ធភាពល្អ។ | អាស្រ័យថាតើអ្នករៀនអាចស្រាវជ្រាវ និងមានទំនុកចិត្តដើម្បីបង្រៀនឬទេ។ |
| ការសង្កេត | √ | | ល្អសម្រាប់ការរៀនអំពីតថភាព ទទួលបានគំនិតល្អៗ | អាស្រ័យថាតើការសង្កេតធ្វើឡើងនៅក្នុងសាលារៀនដែលមានការអនុវត្តល្អឬទេ |
| ការរៀនបែបមិត្តជួយមិត្ត | | √ | ល្អក្នុងការកសាងទំនាក់ទំនង ល្អក្នុងការរិះគន់ដោយវិជ្ជមាន | មិនល្អសម្រាប់អ្នករៀនដែលមិនមានទំនុកចិត្ត ឬសម្រាប់អ្នករៀនដែលមិនអាចទទួលយកភាពខុសគ្នា។ |
| ការរៀនដោយទន្ទេញ | √ | | អាចទទួលបានចំណេះដឹងទ្រឹស្តី | មិនយល់មេរៀន។ |

## សកម្មភាព ១៤.២ ការប្រើប្រាស់វិធីរៀនបែបសហការប្រកបដោយប្រសិទ្ធភាព
## រយៈពេល៖ ៤៥នាទី
## វត្ថុបំណង ៖

- កំណត់បានវិធីរៀនបែបសហការ ដោយធ្វើការងារក្រុម និងមិត្តជួយមិត្តឱ្យបានត្រឹមត្រូវ។

## សម្ភារបង្រៀន និងរៀន៖

- ឯកសារអានពីការរៀនបែបសហការ [77]
- វីដេអូមានចំណងជើង "ការបង្រៀនដោយពិភាក្សាក្រុមបង្កើតកិច្ចសហការរវាងសិស្ស"[78]
- វីដេអូស្តីពីការប្រើប្រាស់ការបង្រៀនតាមភាពផ្សេងៗគ្នា[79] ពន្យល់ការងារជាក្រុម
- វីដេអូឈ្មោះការអនុវត្តល្អពីអង្គការ Handicap International លេខ៥ ការគាំទ្ររវាងមិត្តភក្តិ[80]

## សកម្មភាពបង្រៀន៖

ក. ឱ្យគរុសិស្សចំណាយពេលពីរ បីនាទីអានព័ត៌មានពីការរៀនបែបសហការ។

ខ. បញ្ចាំងវីដេអូស្តីពីការរៀនបែបសហការ។

គ. បញ្ចាំងវីដេអូស្តីពីការប្រើប្រាស់ការបង្រៀនឆ្លើយតបសេចក្តីត្រូវការសិស្សម្នាក់ៗ និងវីដេអូការគាំទ្ររវាងមិត្តភក្តិ។

ឃ. ឱ្យគរុសិស្សអានកថាខណ្ឌ ២ និង ៣ និងសួរសំណួរខាងក្រោម៖

- តើការរៀនបែបសហការ គឺជាអ្វី?
- តើអ្វីគឺជាឥទ្ធិពលនៃការរៀនបែបសហការ ឬការងារជាក្រុម?

ង. ឱ្យគរុសិស្សបំពេញសំណួរខ្លីៗ ។

### ១ តើការរៀនបែបសហការគឺជាអ្វី?

ការរៀនបែបសហការគឺផ្អែកលើទស្សនៈថា ចំណេះដឹងគឺជាការបង្កើតសង្គម។ សកម្មភាពសហការជាទូទៅមានមូលដ្ឋានលើគោលការណ៍បួន៖

- អ្នករៀនគឺជាចំណុចផ្តោតសំខាន់នៃការបង្រៀន។
- ទំនាក់ទំនង និង"ការធ្វើសកម្មភាព"គឺជាចំណុចសំខាន់បំផុត។
- ការធ្វើការងារជាក្រុមគឺជារបៀបរៀនសំខាន់។
- វិធីសាស្ត្រជាប្រព័ន្ធ ដើម្បីបង្កើតដំណោះស្រាយចំពោះបញ្ហាជាក់ស្តែងគួរដាក់បញ្ចូលទៅក្នុងការរៀន។

ការរៀនបែបសហការអាចកើតឡើងរវាងមិត្តភក្តិ ឬជាក្រុម។ ការរៀន ឬការបង្រៀនរវាងមិត្តភក្តិគឺជាប្រភេទនៃការរៀនបែបសហការ ដែលសិស្សធ្វើការជាដៃគូ ឬក្រុមតូចៗ ដើម្បីពិភាក្សាទស្សនទាន ឬស្វែងរកដំណោះស្រាយចំពោះបញ្ហា។ ការរៀនបែបនេះច្រើនកើតឡើងនៅក្នុងម៉ោងរៀនបន្ទាប់ពីសិស្សត្រូវបានបង្ហាញ

---

[77] ធនធានអនឡាញកែសម្រួលពីសាកលវិទ្យាល័យ Cornell មជ្ឈមណ្ឌលសម្រាប់ឧត្តមភាពការបង្រៀន

[78] វីដេអូអនឡាញ CAST *បង្រៀនការងារជាក្រុម៖ កសាងការសហការនៃសិស្ស* ផ្សព្វផ្សាយថ្ងៃទី១២ ឧសភា ២០១៦

[79] វីដេអូស្តីពី ការអប់រំបរិយាបន្ន ដោយនាយកដ្ឋានអប់រំ Alberta បោះពុម្ពផ្សាយក្នុងឆ្នាំ២០១៥

[80] វីដេអូស្តីពី ការអនុវត្តល្អ ក្នុងការអប់រំបរិយាបន្ន ផលិតដោយ Handicap International កម្ពុជា ចាប់ផ្តើមនៅចំណុច២១:៣៣នាទី នៅក្នុងវីដេអូ

សម្ភារសិក្សាតាមរយៈការអាន ឬវីដេអូមុនម៉ោងរៀន និង ឬតាមរយៈការបង្រៀនរបស់គ្រូ។ ស្រដៀងគ្នាជាមួយទស្សនៈ គ្នាច្រើនប្រសើរជាងម្នាក់ឯង គ្រូបង្រៀនជាច្រើនបានរកឃើញថា តាមរយៈការបង្រៀនបែបមិត្តជួយមិត្ត (សិស្សបង្រៀនគ្នាទៅវិញទៅមក) ដោយដោះស្រាយការយល់ច្រឡំ ។

តើអ្វីគឺជាឥទ្ធិពលនៃការរៀនបែបសហការ ឬការងារជាក្រុម?

ការស្រាវជ្រាវបង្ហាញថា បទពិសោធអប់រំដែលសកម្ម ទាក់ទងនឹងសង្គម និងបរិបទ មានការចូលរួម ហើយសិស្សមានភាពម្ចាស់ការ នាំឱ្យការរៀនបានស៊ីជម្រៅ។ អត្ថប្រយោជន៍នៃការរៀនបែបសហការរួមមាន៖

- ការអភិវឌ្ឍការគិតខ្ពស់ ការប្រាស្រ័យទាក់ទងផ្ទាល់មាត់ ការគ្រប់គ្រងខ្លួនឯង និងជំនាញដឹកនាំ។
- ការលើកកម្ពស់ទំនាក់ទំនងរវាងសិស្ស និងអ្នកបណ្តុះបណ្តាល។
- បង្កើនការចងចាំ ទំនុកចិត្ត និងការទទួលខុសត្រូវរបស់សិស្ស។
- ទទួលបានបទពិសោធ និងបង្កើនការយល់ដឹងពីទស្សនៈផ្សេងៗគ្នា
- ការត្រៀមខ្លួនសម្រាប់ស្ថានភាពសង្គម និងការងារជាក់ស្តែង។

**សារគន្លឹះ**

វិធីទាំងនេះមិនមែនជាវិធីជំនួសឱ្យការបង្រៀននោះទេ ប៉ុន្តែជាវិធីបន្ថែមពីលើសកម្មភាពបង្រៀន និងរៀន។

**២. ការងារជាក្រុម:**[81]

ក្នុងនាមជាគ្រូបង្រៀន អ្នកបានផ្តល់ឱកាសឱ្យសិស្សធ្វើការជាក្រុម នេះមិនមែនមានន័យថា អ្នកកំពុងប្រើប្រាស់វិធីបង្រៀនបរិយាបន្ននោះទេ។ វាក៏មិនមែនគ្រាន់តែការផ្តុំតួរួមគ្នានោះទេ។ ការធ្វើការងារជាក្រុមត្រូវតែគ្រោងដោយប្រុងប្រយ័ត្ន។ ការស្រាវជ្រាវត្រូវធ្វើឡើងដោយប្រើប្រាស់ការអនុវត្តផ្អែកលើភស្តុតាង ហើយគ្រូបង្រៀនគួរពិចារណាចំណុចខាងក្រោម៖

**ភាពបត់បែន**៖ ការរៀបចំការងារជាក្រុមគួរមានភាពបត់បែន ដែលសិស្សផ្សេងៗគ្នាអាចចូលរួមក្នុងក្រុមផ្សេងៗគ្នា។ ការធ្វើបែបនេះផ្តល់ឱកាសដល់សិស្សទាំងអស់ស្គាល់គ្នានៅក្នុងថ្នាក់រៀន និងរៀនពីជំនាញផ្សេងៗពីគ្នាទៅវិញទៅមកនៅក្នុងក្រុម។ វាក៏ផ្តល់ឱកាសដល់សិស្សធ្វើការជាមួយសិស្សដទៃដែលពួកគេមានអារម្មណ៍ស្និទ្ធស្នាល ក៏ដូចជាសិស្សដែលប្រកួតប្រជែងបែបវិជ្ជមានជាមួយពួកគេ។

**ការបង្កើតជាក្រុមផ្សេងៗ៖** វាអាចជាការបង្រៀនសិស្សទាំងអស់ ការបង្រៀនជាក្រុមតូចៗបង្រៀនជាដៃគូរវាងសិស្សនិងសិស្ស និងការបង្រៀនមួយទល់មួយអាស្រ័យលើសេចក្តីត្រូវការរបស់កុមារនៅក្នុងមេរៀនខុសៗគ្នា។

**ការប្រើប្រាស់ពហុបញ្ញា**៖ យើងបានពិភាក្សាពហុបញ្ញានៅក្នុងមេរៀនទី៨រួចហើយ និងបានដឹងពីជំនាញ និងពហុបញ្ញារបស់គេដែលដើរតួសំខាន់នៅក្នុងការបង្កើតក្រុម ។

**តម្រូវការរៀន ចំណាប់អារម្មណ៍ និងចំណង់ចំណូលចិត្ត៖** ការធ្វើការងារជាក្រុមត្រូវពិចារណាកត្តាទាំងបីនេះផងដែរ ពីព្រោះសម្រាប់មេរៀនខ្លះវាអាចមានប្រយោជន៍ ក្នុងការរៀបចំការងារជាក្រុមផ្អែកលើតម្រូវ

[81] សរសេរចេញពីវីដេអូ និងចំណុចបន្ថែម ដកស្រង់ចេញពី UNESCO (២០១៥ កំណែអនឡាញ) ទទួលយកភាពចម្រុះ ជំពូកទី៥ ទំព័រ៥

ការរៀន។ ឧទាហរណ៍ក្រុមតូចមួយ ដែលពិបាកក្នុងការគុណលេខ ការរៀបចំក្រុមបែបនេះគ្រូបង្រៀនអាចបង្កើតសម្ភារ បង្រៀន និងរៀនជាក់លាក់សម្រាប់ក្រុមនេះ។

**<u>តួនាទី និងការទទួលខុសត្រូវ</u>៖** មជ្ឈមណ្ឌលបច្ចេកវិទ្យាអនុវត្តពិសេស (CAST) ផ្តល់ឧទាហរណ៍មួយនៅក្នុងវីដេអូរបស់ពួកគេ ដែលផ្តល់តួនាទី និងការទទួលខុសត្រូវទៅដល់សមាជិកក្រុម។ ឧទាហរណ៍ក្នុងវីដេអូតួនាទីបីត្រូវបានកំណត់គឺតួនាទីជាអ្នកសួរ អ្នកបកស្រាយ និងអ្នកសង្ខេប។ គ្រូបង្រៀនផ្តល់ការណែនាំច្បាស់លាស់សម្រាប់តួនាទីខុសៗគ្នានេះ។ ការងារត្រូវតែពិបាកបន្តិច ដើម្បីទាមទារឱ្យមានការបញ្ចេញមតិច្រើននិងអាចឱ្យក្រុមកសាងចំណេះដឹងជាមួយគ្នា។ ប្រសិនបើក្រុមណាមួយពិបាកឆ្លើយសំណួរពួកគេអាចទៅរកក្រុមមួយទៀតដើម្បីដឹងថាពួកគេដោះស្រាយបញ្ហាយ៉ាងដូចម្តេច។ ការធ្វើបែបនេះអនុញ្ញាតឱ្យសិស្សរៀនពីសិស្សដទៃ និងបន្ទាប់មកអនុវត្តការយល់ដឹងថ្មីរបស់ពួកគេ។ តួនាទីអាចផ្លាស់ប្តូរ ប្រសិនបើសមាជិកក្រុមគិតថាចាំបាច់ ប៉ុន្តែអ្នកគ្រប់គ្នាគួរទទួលបានឱកាសដឹកនាំក្រុម ដើម្បីអភិវឌ្ឍជំនាញទាំងនោះ។

"នៅពេលអ្នកបានធ្វើសកម្មភាពដើម្បីឱ្យដឹងចម្លើយ
ចម្លើយនឹងនៅជាមួយអ្នកយូរអង្វែងជាងពេលគ្រូបង្រៀនប្រាប់អ្នក" ដោយសិស្សសាលារៀន
*University Park Campus*

<u>គោលការណ៍មូលដ្ឋានសម្រាប់ក្រុមការងារ</u>៖[82]

១. ស្តាប់ដោយយកចិត្តទុកដាក់ គោរពអ្នកដទៃនៅពេលពួកគេនិយាយ ប៉ុន្តែត្រូវចូលរួមឱ្យបានពេញលេញ។

២. និយាយពីបទពិសោធរបស់អ្នកផ្ទាល់ ("ខ្ញុំ" ជំនួសឱ្យ "ពួកគេ")។

៣. កុំធ្វើការវាយប្រហារបុគ្គល ផ្តោតតែទៅលើគំនិតមិនមែនបុគ្គល។

**៣. ការគាំទ្របែបមិត្តជួយមិត្ត**

នេះគឺជាសកម្មភាពទៅវិញទៅមកផ្តល់ប្រយោជន៍សងខាង និងទាក់ទងទៅនឹងការចែករំលែកចំណេះដឹង គំនិត និងបទពិសោធរវាងសិស្ស។ សិស្សរៀនបានច្រើនតាមរយៈការពន្យល់គំនិតរបស់ពួកគេដល់សិស្សដទៃ និងតាមរយៈការចូលរួមនៅក្នុងសកម្មភាព ដែលពួកគេអាចរៀនពីមិត្តរបស់ពួកគេ។ ពួកគេទាំងសងខាងចូលរួមក្នុងការរៀនដើម្បីរៀន។ មិត្តភក្តិគឺជាមនុស្សស្ថិតនៅស្ថានភាពស្រដៀងគ្នា និងមិនមានអំណាចទៅលើគ្នាទៅវិញទៅមក។[83] ការពន្យល់របស់មិត្តភក្តិទៅវិញទៅមកអាចសម្រេចជោគជ័យ នៅពេលគ្រូបង្រៀនជួបការពិបាក ហើយនេះអាចមកពីពួកគេប្រើប្រាស់បទពិសោធរបស់ពួកគេ និងភាសាកុមារមេត្រី។

**សំណួរសម្រាប់ការរៀនបែបសហការ៖**

[82] ដកស្រង់ពី UNESCO (២០១៥ កំណែអនឡាញ) ទទួលយកភាពចម្រុះ ជំពូកទី៥ ទំព័រ២៣

[83] ដកស្រង់ពីការរៀនកម្រិតមិត្តភក្តិ៖ ការអប់រំឧត្តមសិសក្សា: *រៀនពីគ្នា និងជាមួយគ្នា* ដោយ Baid, D., Cohen, R. និង Sampson, J. (២០០២)

សូមគូសខុស ឬ ត្រូវ សម្រាប់ប្រយោគនីមួយៗ

| ល.រ | ប្រយោគ | ត្រូវ | ខុស |
|---|---|---|---|
| ១. | វិធីរៀនបែបសហការគឺជាការជំនួសឱ្យការបង្រៀន។ | | |
| ២. | ក្រុមអាចត្រូវបង្កើត និងទុកឱ្យដោះស្រាយបញ្ហាដោយក្រុមខ្លួនឯង។ | | |
| ៣. | ក្រុមដដែលធ្វើការជាមួយគ្នាពេញមួយឆ្នាំ ។ | | |
| ៤. | ការដឹងអំពីសិស្សនៅក្នុងថ្នាក់រៀន និងពហុបញ្ញាជួយដល់ការបង្កើតក្រុម។ | | |
| ៥. | វាមានប្រយោជន៍ ក្នុងការកំណត់គោលការណ៍មូលដ្ឋានសម្រាប់ការងារក្រុម។ | | |
| ៦. | ការរៀនបែបមិត្តជួយមិត្តមានន័យថាម្នាក់មានអំណាចជាងម្នាក់ទៀត។ | | |
| ៧. | មិត្តភក្តិម្នាក់ត្រួតត្រាលើអ្នកដទៃ និងនិយាយតែម្នាក់ឯង។ | | |
| ៨. | គ្រូបង្រៀនដាក់កិច្ចការ និងចាកចេញពីថ្នាក់រៀន ។ | | |
| ៩. | គ្រូបង្រៀនត្រូវរៀបចំ ត្រៀមឯកសារបង្រៀនជាមុន ។ | | |
| ១០. | មិត្តភក្តិអាចជាអ្នកជំនួសគ្រូបង្រៀនបាន។ | | |

**ចម្លើយរំពឹងទុក**

ត្រូវ៖ ៤ ៥ និង៩ ខុស៖ ១ ២ ៣ ៦ ៧ ៨ និង១០

## មេរៀនទី១៥  ការផលិតសម្ភារបង្រៀន និងរៀននៅមូលដ្ឋាន





## សកម្មភាព ១៥.១ ការផលិតសម្ភារបង្រៀន និងរៀននៅមូលដ្ឋាន (TLMs)

**រយៈពេល៖ ២០នាទី**

**វត្ថុបំណង៖**

- ប្រាប់បានពីសារប្រយោជន៍ក្នុងការផលិតសម្ភារបង្រៀន និងរៀននៅមូលដ្ឋាន។

**សម្ភារបង្រៀន និងរៀន៖**

- វីដេអូឈ្មោះ "បន្ទប់ធនធានល្អបំផុត"[84]
- វីដេអូឈ្មោះ "ស្វែងរកសម្ភារបង្រៀន និងរៀន ពីសំរាម"[85]។

**សកម្មភាពបង្រៀន៖**

ក.បញ្ចាំងវីដេអូ ឈ្មោះ "បន្ទប់ធនធានល្អបំផុត"

ខ.ឱ្យគរុសិស្សកំណត់សម្ភារបង្រៀន និងរៀនយ៉ាងហោចណាស់ប្រាំមួយ នៅក្នុងវីដេអូ

<u>សំណួរ</u>

តើសម្ភារបង្រៀនទាំងនោះអាចកែច្នៃបានដូចម្ដេច សម្រាប់កុមារមានបញ្ហាមើល?

គ.បញ្ជាក់ថា សម្ភាររៀនទាំងអស់ត្រូវបានបង្កើតឡើងដោយសម្ភារដែលថោក អាចរកបាននៅតាមមូលដ្ឋាន

ឃ.បញ្ចាំងវីដេអូទី២ឈ្មោះ "ស្វែងរកសម្ភារបង្រៀន និងរៀនពីសំរាម"។

ង.ឱ្យគរុសិស្សចែករំលែកការរៀនរបស់ពួកគេពីវីដេអូ។

**លទ្ធផលរំពឹងទុក៖**

<u>សម្ភារបង្រៀន និងរៀនពីវីដេអូទី១៖</u>

ប័ណ្ណផ្គូផ្គងអក្សរ ល្បែងដើរដើម្បីរាប់លេខ កន្លែងអានដែលមានសម្ភារអាន កន្លែងសិស្សគូរគំនូរលាបពណ៌ ឆាកតុក្កតាសម្រាប់ប្រាប់រឿង ប័ណ្ណបីជ្រុង តារាងប្រើសម្រាប់គោលបំណងផ្សេងៗ គំរូបង្កើតទឹកភ្លៀងសិប្បនិម្មិត ឧបករណ៍វាស់ទឹកភ្លៀង។ល។

(សម្ភារបង្រៀន និងរៀន ក៏អាចបញ្ចូលអក្សរប្រៃយ៍ ដើម្បីឱ្យកុមារមានបញ្ហាមើលអាចប្រើប្រាស់បាន។)

<u>ការរៀនពីវីដេអូទី២៖</u>

ការបង្កើតសម្ភារបង្រៀន និងរៀន (TLM) ផ្ដល់ឱកាសរៀនបែបពិសោធន៍ ទាំងគ្រូបង្រៀន និងសិស្ស។

សម្ភារបង្រៀន និងរៀនអាចបង្កើតដោយតម្លៃថោក។

សម្ភារបង្រៀន និងរៀនអាចធ្វើពីសំរាមក៏មានន័យដែរថា សិស្សគ្រប់គ្នារៀនពីការប្រើប្រាស់សំរាមឡើងវិញ និងកាត់បន្ថយការបំពុលដោយសំណល់។

ទាំងគ្រូបង្រៀន និងសិស្សមានមោទនភាពក្នុងការបង្កើតសម្ភាររៀនដោយខ្លួនឯង។

សម្រាប់អ្នករៀនបែបកាយវិញ្ញាណ ការធ្វើគំរូពិសោធន៍វិទ្យាសាស្ត្រ ជាសកម្មភាពរៀនដ៏ល្អប្រសើរ។

---

[84] វីដេអូយូធូប ផលិតដោយ Ruchika Gupta នៅខែមិថុនា ឆ្នាំ២០១៥ បង្ហាញពីសម្ភារបង្រៀន និងរៀនក្នុងតំបន់ទាំងអស់

[85] វីដេអូយូធូប សាលាបឋមសិក្សា Langmadung ប្រទេសប៊ូតាន នៅខែកញ្ញា ឆ្នាំ២០១៤ បង្ហាញពីសម្ភារបង្រៀន និងរៀនពីសំរាម

## សកម្មភាព ១៥.២[86] ការផលិតសម្ភារបង្រៀន និងរៀនដោយខ្លួនឯង

**រយៈពេល៖ ៤៥នាទី**

**វត្ថុបំណង ៖**

- ផលិតបានសម្ភារបង្រៀន និងរៀននៅមូលដ្ឋានដោយខ្លួនឯង។

**សម្ភារបង្រៀន និងរៀន៖**

- វីដេអូផ្នែកទី៧ ឈ្មោះ "ការបង្កើតឧបករណ៍បង្រៀន"[87]

**សម្មភាពបង្រៀន៖**

ក.បញ្ចាំងវីដេអូខាងលើ

ខ.ឱ្យគរុសិស្សធ្វើការជាដៃគូ ឬជាក្រុមមានសមាជិក៣នាក់ផលិតសម្ភារបង្រៀន និងរៀនដើម្បីបង្រៀនមេរៀនខាងក្រោម៖

- វដ្តនៃជីវិតរុក្ខជាតិ
- ផ្នែកនៃរាងកាយរបស់យើង
- ច្រើនជាង ឬតិចជាង
- ការគណនា លេខគុណ
- ការរៀនអានឈ្មោះសត្វ
    - ➢ **ត្រូវប្រាប់គរុសិស្សស្វែងរកធនធានត្រៀមទុក ដើម្បីបង្កើតសម្ភារបង្រៀន និងរៀន (ឬដាក់ជាកិច្ចការផ្ទះ) ។**



© Michael Pitt

[86] សកម្មភាពនេះត្រូវបានដកស្រង់ចេញពីមេរៀនបណ្តុះបណ្តាលគ្រូបង្រៀនរបស់ Sandrine Bohan-Jacquot –ស៊ូដង់ខាងត្បូង ទំព័រ១០៨
[87] វិដេអូដោយ Handicap International កម្ពុជា ឈ្មោះការអនុវត្តការអប់រំបរិយាបន្នល្អ ការបង្កើតឧបករណ៍បង្រៀន ចាប់ពី ៣៤.៥៤នាទី

# មេរៀនទី១៦  ការកំណត់ និងការផ្ដល់ការគាំទ្រចាំបាច់បន្ថែម














## សកម្មភាព ១៦.១ ការកំណត់ និងផ្ដល់ការគាំទ្រចាំបាច់បន្ថែម

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង៖**

- កំណត់បានពីកុមារមានបញ្ហា និងតម្រូវការគាំទ្រ។

**សម្ភារបង្រៀន និងរៀន៖**

- តារាងត្រួតពិនិត្យ សម្រាប់កំណត់កុមារមានបញ្ហា[88]
- តារាងទីកន្លែងស្វែងរកការគាំទ្រ

**សកម្មភាពបង្រៀន៖**

ក.ឱ្យពួកគេអានតារាងត្រួតពិនិត្យ និងទីកន្លែងដែលអ្នកអាចស្វែងរកការគាំទ្រចាំបាច់។

ខ.ឱ្យពួកគេអានករណីសិក្សាខ្លីៗ និងកំណត់ទីកន្លែងដែលពួកគេត្រូវទៅ ដើម្បីស្វែងរកការគាំទ្រ។

**តារាងត្រួតពិនិត្យ សម្រាប់កំណត់កុមារមានបញ្ហា**

| ក | បញ្ហាមើល (ខ្សោយគំហើញ) | បាទ/ចាស | ទេ |
|---|---|---|---|
| | ឈរចម្ងាយ៣ម៉ែត្រពីកុមារ និងលើកដៃរបស់អ្នកឡើង។ បន្ទាប់មកលើកម្រាមដៃខ្លះឡើងលើ។ តើកុមារមានការពិបាករាប់ម្រាមដៃរបស់អ្នកនៅចម្ងាយនេះឬទេ? | | |
| | តើកុមារដើរប៉ះវត្ថុផ្សេងៗ ឬដើរបុកអ្នកដទៃជាញឹកញាប់ដែរឬទេទោះបីជានៅកន្លែងដែលមានពន្លឺគ្រប់គ្រាន់ក៏ដោយ? | | |
| | តើកុមារញីភ្នែកញឹកញាប់ដែរឬទេ? | | |
| | តើកុមារមានស្មារតីសមាធិញឹកញាប់ដែរឬទេ នៅពេលចម្លងកិច្ចការពីក្តារខៀន? | | |
| | តើកុមារមានងាកទៅរកពន្លឺដែរឬទេ? | | |
| | តើកុមារមានការពិបាកពេលមើលអក្សរលើក្តារខៀនពីកន្លែងអង្គុយរបស់ខ្លួនដែរឬទេទោះបីអង្គុយនៅខាងមុខក៏ដោយ? | | |
| | តើកុមារមានការពិបាកពេលសម្គាល់វត្ថុដែលនៅឆ្ងាយពីខ្លួនឬទេ? | | |
| | តើកុមារមានការពិបាក នៅពេលធ្វើកិច្ចការ ដែលតម្រូវឱ្យមើលវត្ថុនៅជិតភ្នែកឬទេ (ដោតអំបោះចូលម្ជុល)? | | |
| | តើកុមារកាន់សៀវភៅមើលជិតភ្នែកពេក (ចម្ងាយពីភ្នែក២០សម ឬតិចជាង)? | | |
| សម្គាល់៖ ប្រសិនបើមានចម្លើយ "បាទ/ចាស" ចំនួន៤ កុមារអាចមានបញ្ហាមើល | | | |

[88] ដកស្រង់ពីសៀវភៅការអប់រំបញ្ចូលគ្នា ផលិតដោយ បណ្ឌិត Maya Kalyanpur ទំព័រ៤៩-៥០

| | | | |
|---|---|---|---|
| ខ | បាត់បង់ការស្ដាប់ (ពិបាកស្ដាប់) | បាទ/ចាស | ទេ |
| | តើកុមារពិបាកស្ដាប់នៅពេលអ្នកនិយាយទៅរកគេពីក្រោយខ្នងដែរឬទេ? | | |
| | នៅពេលអ្នកហៅកុមារពីបន្ទប់មួយផ្សេងទៀត តើកុមារអាចឆ្លើយតបបានឬទេ? | | |
| | តើកុមារមានផ្សៀងត្រចៀកស្ដាប់ឬទេ? | | |
| | តើកុមារនិយាយឮខ្លាំងពេកឬទេ? | | |
| | តើកុមារនិយាយឮតិចពេកឬទេ? | | |
| | តើកុមារបែរមុខ និងហាក់បីដូចជាប្រើត្រចៀកតែម្ខាងស្ដាប់ឬទេ? | | |
| | តើកុមារឆ្លើយមិនចំនឹងសំណួរឬទេ? | | |
| | តើកុមារពិបាកក្នុងការយកចិត្តទុកដាក់ស្ដាប់គ្រូពន្យល់ដែរឬទេ? | | |
| សម្គាល់: ប្រសិនបើមានចម្លើយ "បាទ/ចាស" ចំនួន៣ កុមារអាចមានបញ្ហាស្ដាប់ | | | |
| គ | បញ្ហាចលនា | បាទ/ចាស | ទេ |
| | តើកុមារពិបាកបម្លាស់ទី ឬពិបាកប្រែផ្នែកណាមួយនៃរាងកាយដែរឬទេ? | | |
| | តើមានផ្នែកណាមួយនៃអវយវៈរបស់កុមារត្រូវពិការ ឬបាត់បង់ឬទេ? | | |
| | តើកុមារដើរមិនរួច ឬពិបាកធ្វើចលនាដៃជើងឬទេ? | | |
| | តើពេលដើរកុមារមានការកន្ត្រាក់ ឬដួលភ្លាមៗដែរឬទេ? | | |
| | តើកុមារត្រូវការឈើច្រត់សម្រាប់ដើរឬទេ? | | |
| សម្គាល់: ប្រសិនបើមានចម្លើយណាមួយ "បាទ/ចាស" កុមារអាចមានបញ្ហាចលនា | | | |
| ឃ | បញ្ហាបញ្ញា | បាទ/ចាស | ទេ |
| | នៅពេលដែលអ្នកប្រាប់កុមារឱ្យធ្វើអ្វីមួយ តើកុមារហាក់ដូចជាមិនយល់នូវអ្វីដែលអ្នកកំពុងនិយាយដែរឬទេ បើធៀបទៅនឹងកុមារដទៃដែលមានអាយុដូចគ្នា? | | |
| | តើកុមារមានការពិបាកក្នុងការរៀនឬទេ បើធៀបជាមួយកុមារដទៃដែលមានអាយុដូចគ្នា? | | |
| | តើកុមារធ្លាប់ប្រកាច់ ឬបាត់បង់ស្មារតីដោយពេលដែរឬទេ? | | |
| | តើកុមារនិយាយមានលក្ខណៈខុសប្លែកពីកុមារដទៃដែលមានអាយុដូចគ្នាឬទេ? | | |
| | តើកុមារផ្លាស់ទីមានលក្ខណៈខុសប្លែកពីកុមារដទៃដែលមានអាយុដូចគ្នាឬទេ? | | |
| | តើកុមារចូលចិត្តលេងតែម្នាក់ឯង ឬលេងមានលក្ខណៈខុសប្លែកពីកុមារដទៃទៀតដែលមានអាយុដូចគ្នាដែរឬទេ? (ឧទាហរណ៍៖ ពិបាកយល់ពីរបៀបលេងល្បែងផ្សេងៗ)។ | | |

| | | | |
|---|---|---|---|
| | សម្រាប់កុមារដែលមានអាយុ៦ឆ្នាំ និងលើសពីនេះ៖<br>តើកុមារមានបម្រុងប្រយ័ត្នរយៈពេលខ្លី ឬការចងចាំខ្សោយឬទេ ឧទាហរណ៍ តើពួកគេពិបាកបំពេញតេស្តនេះឬទេ?<br>ប្រាប់កុមារថា គេនឹងត្រូវនិយាយពាក្យចំនួន៥ឱ្យដូចតាមលំដាប់ ដែលអ្នកបាននិយាយ។<br>ផ្ទះ សៀវភៅ គោ ដើមឈើ គ្រួសារ។ បន្ទាប់មកប្រាប់កុមារថា គេនឹងត្រូវនិយាយលេខចំនួន៥ ឱ្យដូចតាមលំដាប់ដែលអ្នកបាននិយាយ ២ ៥ ៣ ៤ ៨ | | |
| សម្គាល់៖ ប្រសិនបើមានចម្លើយ "បាទ ឬចាស" ចំនួន៤ កុមារអាចមានបញ្ហាបញ្ញា | | | |
| **ង** | **ការពិបាកក្នុងការប្រាស្រ័យទាក់ទង (និយាយ)** | | |
| | តើកុមារនិយាយត្រដិត ឬនិយាយរដាក់រដុបឬទេ? ឧទាហរណ៍៖ បញ្ចេញសំឡេង "ខ-ខ-ខ" | | |
| | តើកុមារដែលគ្រប់អាយុចូលរៀនមានការពិបាកក្នុងការនិយាយពាក្យ និងមានបាត់បង់សូរមួយចំនួននៅពេលដែលកុមារកំពុងនិយាយ? ឧទាហរណ៍៖ ជំនួសឱ្យពាក្យ "ទុក កុមារនិយាយថា "ទក់" ឬជំនួសឱ្យពាក្យថា "ទៅផ្សារ" កុមារនិយាយថា "ទៅសា"។ | | |
| | តើកុមារចង្អុល ឬប្រើភាសាសញ្ញាជំនួសឱ្យពាក្យដើម្បីប្រាស្រ័យទាក់ទងឬទេ? | | |
| សម្គាល់៖ ប្រសិនបើមានចម្លើយ "បាទ ឬចាស" ចំនួន១ កុមារអាចមានបញ្ហានិយាយ | | | |

## ទីកន្លែង ដើម្បីស្វែងរកការគាំទ្របន្ថែមសម្រាប់កុមារមានបញ្ហា ជនជាតិភាគតិច និងកុមារលើសអាយុ

| តើការគាំទ្រអ្វីដែលត្រូវការ? | តើអ្វីដែលអាចធ្វើបាន? |
|---|---|
| សម្រាប់កុមារមានបញ្ហាចលនា | |
| ប្រសិនបើកុមារត្រូវការពិនិត្យ និងអាចត្រូវការអវយវៈ សិប្បនិម្មិត ឧបករណ៍គាំទ្រ អវយវៈ ឬរទេះរុញ ឬការវះកាត់ | អាសយដ្ឋានទំនាក់ទំនង៖<br>សាលារៀន The Cambodian School of Prosthetics and Orthotics<br>ផ្ទះលេខ 20C ក្រុមទី3 ផ្លូវខ្ទង់ងៀប សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ភ្នំពេញ កម្ពុជា<br>ទូរស័ព្ទ +855 23 881 494<br>គេហទំព័រ www.cspo.org.kh<br>សូមទំនាក់ទំនងទៅអាសយដ្ឋានខាងលើ ដើម្បីប្រាប់ពួកគេឱ្យដឹងថា កុមារមានបញ្ហាចលនា ដែលត្រូវការឧបករណ៍ជំនួយ ឬប្រាប់ឱ្យគ្រួសារកុមារទៅមន្ទីរពេទ្យបង្អែកតាមមូលដ្ឋាន។ |
| ប្រសិនបើកុមារត្រូវការរទេះរុញ ឬជម្រាល | អង្គការក្រៅរដ្ឋាភិបាល ដូចជាអង្គការ Cambodia Trust នឹងជួយកសាងជម្រាលដោយឥតគិតថ្លៃ ប្រសិនបើអ្នកទាក់ទងពួកគេតាមរយៈសាលារៀន The Cambodian School of Prosthetics and Orthotics អាសយដ្ឋានទំនាក់ទំនងលម្អិតខាងលើ |

| | |
|---|---|
| ប្រសិនបើកុមារត្រូវការមធ្យោបាយធ្វើដំណើរ ឬត្រូវការអ្នកជួយរុញរទេះរុញទៅសាលា | រកមើលមិត្តរួមថ្នាក់ ឬសិស្សច្បងអាចជួយ។ នៅក្នុងសាលារៀនមួយ នាយកសាលាបានជួយដឹកសិស្សពិការឱ្យជិះមកជាមួយទាំងទៅទាំងមក។ រទេះរុញរបស់សិស្សត្រូវបានរក្សាទុកនៅសាលារៀន។ នៅក្នុងករណីខ្លះ អង្គការក្រៅរដ្ឋាភិបាល ដូចជាអង្គការ Handicap International បារាំង នឹងផ្តល់មធ្យោបាយធ្វើដំណើរ ឬរៀបចំរទេះរុញចំនួន២។ ទំនាក់ទំនងពួកគេនៅអាសយដ្ឋានផ្ទះលេខ 9AB, ផ្លូវលេខ 446 ភ្នំពេញ<br>លេខទូរស័ព្ទ 023 217 300 |
| **សម្រាប់កុមារមានបញ្ហាមើល** | |
| ប្រសិនបើកុមារត្រូវការពិនិត្យកម្រិតបញ្ហាមើល និងអាចត្រូវការវ៉ែនតាកែវពង្រីកឬការវះកាត់ | សូមទំនាក់ទំនង: មូលនិធិ Fred Hollows ប្រអប់សំបុត្រលេខ518 ទន្លេបាសាក់ ភ្នំពេញ ទូរស័ព្ទលេខ 023 987 831 និង 023 993 157<br>អ៊ីម៉ែល cambodia@hollows.org<br>ទំនាក់ទំនងទៅអាសយដ្ឋានខាងលើ ដើម្បីឱ្យពួកគេដឹងថាមានកុមារមានបញ្ហាមើលដែលអាចត្រូវការឧបករណ៍ជំនួយ ឬប្រាប់ឱ្យគ្រួសារកុមារទៅមន្ទីរពេទ្យបង្អែកតាមមូលដ្ឋាន។ |
| ប្រសិនបើកុមារត្រូវការមធ្យោបាយធ្វើដំណើរទៅសាលារៀនពីព្រោះពួកគេមិនអាចធ្វើដំណើរដោយខ្លួនឯងបាន | អាចរកសិស្សអាយុច្រើនជាងឱ្យជួយ |
| ប្រសិនបើកុមារត្រូវការរៀនអាន និងសរសេរអក្សរប្រៃយ៍ ហើយត្រូវការស្លេត និងស្តាយឡូស | សូមទំនាក់ទំនងអង្គការគ្រួសារថ្មី ផ្ទះលេខ145 ផ្លូវ132 សង្កាត់ទឹកល្អក់ 1 ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ 1393<br>ទូរស័ព្ទលេខ +855 (0) 23 880 503. |
| **សម្រាប់កុមារមានបញ្ហាស្តាប់** | |
| ប្រសិនបើកុមារត្រូវការពិនិត្យកម្រិតបញ្ហាស្តាប់ និងអាចត្រូវការឧបករណ៍ជំនួយស្តាប់ | សូមទំនាក់ទំនងអង្គការ All Ears Cambodia ផ្ទះលេខ109z ផ្លូវ 228 (ផ្លូវសម្តេចមង្គល អៀម) ទូរស័ព្ទលេខ 012 624 530<br>អ៊ីម៉ែល clinic@allearscambodia.org<br>ទំនាក់ទំនងទៅអាសយដ្ឋានខាងលើ ដើម្បីឱ្យពួកគេដឹងថាមានកុមារមានបញ្ហាស្តាប់ត្រូវការឧបករណ៍ជំនួយ ឬប្រាប់ឱ្យគ្រួសារកុមារឱ្យទៅមន្ទីរពេទ្យបង្អែកតាមមូលដ្ឋាន ។ |
| ប្រសិនបើកុមារ ឬគ្រូបង្រៀនត្រូវការរៀនភាសាសញ្ញា | សូមទំនាក់ទំនងអង្គការគ្រួសារថ្មី អាសយដ្ឋានខាងលើ |

| | |
|---|---|
| **សម្រាប់កុមារមានបញ្ហានិយាយ** | |
| ប្រសិនបើកុមារត្រូវការពិនិត្យ និងអាចត្រូវការវះកាត់ ឬការព្យាបាលបែបនិយាយ | សូមទំនាក់ទំនង ១. អង្គការសាលាទន្សាយ បុរីជាតិសម្រាប់ទារកនិងកុមារ ផ្លូវឌួងងៀប ១១ ភ្នំដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ភ្នំពេញ<br>ទូរស័ព្ទលេខ +855 (0) 12 369 376,<br>+855 (0) 23 6666 317 +(855) 93 851 047<br>២. OIC ផ្ទះលេខ468, ផ្លូវត្រសក់ផ្អែម (63) ភ្នំពេញ<br>អ៊ីម៉ែល hello@oiccambodia.org<br>៣. មូលនិធិកុមារពិការ #43 ផ្លូវវត្តសារ៉ាវ័ន្ត 178 ខណ្ឌដូនពេញ ភ្នំពេញ<br>ទូរស័ព្ទលេខ + 855 (0) 23 210447<br>ទូរស័ព្ទដៃលេខ + 855 (0) 12 843466 |
| **សម្រាប់កុមារមានបញ្ហាបញ្ញា** | |
| ប្រសិនបើកុមារត្រូវការពិនិត្យ | សូមទំនាក់ទំនង មជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត សម្រាប់កុមារ និងមនុស្សពេញវ័យ (CCAMH) មន្ទីរពេទ្យជ័យជំនះ តាខ្មៅ ខេត្តកណ្តាល<br>ទូរស័ព្ទលេខ 023 300 534<br>អ៊ីម៉ែល ccamh-admin@caritascambodia.org |
| **សម្រាប់កុមារមានជំងឺអូទីស្សឹម (Autism)** | |
| ប្រសិនបើកុមារត្រូវការការគាំទ្រ | ទំនាក់ទំនង CCAMH អង្គការសាលាទន្សាយ និងមូលនិធិកុមារពិការ អាសយដ្ឋានខាងលើ |
| **សម្រាប់កុមារមានជំងឺផៀក (albinism)** | |
| ប្រសិនបើកុមារត្រូវការការគាំទ្រ | ទំនាក់ទំនងអង្គការគ្រួសារថ្មី អាសយដ្ឋានខាងលើ |
| **សម្រាប់កុមារជនជាតិភាគតិច** | |
| ប្រសិនបើកុមារត្រូវការការគាំទ្រ | ក្រសួងអប់រំ យុវជន និងកីឡា ជាមួយការគាំទ្រនៃអង្គការ CARE បានបង្កើតកម្មវិធីអប់រំពហុភាសា។ គ្រូបង្រៀនអាចទាក់ទង TTD SED ឬ PTTCs សម្រាប់ព័ត៌មានបន្ថែម។ |
| **សម្រាប់កុមារលើសអាយុ (អាយុ២ឆ្នាំច្រើនជាងមិត្តភក្តិ)** | |
| | សម្រាប់កម្មវិធីបង្រៀនថ្នាក់គួប គ្រូបង្រៀនអាចទាក់ទង TTD ឬ PTTCs។<br>សម្រាប់កម្មវិធីរៀនពន្លឿន គ្រូបង្រៀនអាចទាក់ទង PED អង្គការPSE<br>លេខទូរស័ព្ទ 023 996 660 |

អង្គការផ្សេងៗទៀត ដែលផ្តល់សេវាសម្រាប់កុមារពិការ

AAR Japan (កណ្តាល) ០១៦ ៤០០ ៥៦៦

CRS (តាកែវ) 023 211 165

DDSP (ពោធិសាត់) 052 951 495

Save the Children 023 223 403/4/5/6

Epic Arts (កំពត) 033 555 5201

Damnoek Toek (ភ្នំពេញថ្មី) 012 985 384

## តើអ្នកគួរទំនាក់ទំនងនរណា?

| ករណីសិក្សា | អង្គការ |
|---|---|
| កុសលតែងតែញញីភ្នែក នៅពេលអានអក្សរនៅលើក្តារខៀន ហើយកុសលនៅតែមិនអាចឃើញអ្វីដែលនៅលើក្តារខៀន | គ្រួសារថ្មី<br>Fred Hollows |
| សុភាពមើលទៅដូចជាយកចិត្តទុកដាក់នៅក្នុងថ្នាក់រៀន ប៉ុន្តែនៅពេលសួរសំណួរ នាងមិនយល់អំពីអ្វីដែលគ្រូសួរ។ នាងមានការពិបាកក្នុងការចាប់បានអ្វីគ្រប់យ៉ាងទាំងអស់ ដែលបាននិយាយនៅក្នុងថ្នាក់រៀន។ នាងអាចមានបញ្ហាស្តាប់។ | All Ears Cambodia<br>គ្រួសារថ្មី |
| វណ្ណៈមិនអាចអង្គុយនៅឱ្យស្ងៀម វាមិនអាចឆ្លើយនៅពេលហៅឈ្មោះវា និងមិនមានមិត្តភក្តិ។ វាធ្វើចលនាដដែលៗ។ វណ្ណៈអាចមានជំងឺអូទីស្សឹម (Autism) ។ | សាលាទន្សាយ<br>CCAMH |
| ឯក វីសុត មានជំងឺដោនស៊ីនដ្រូម (Down's Syndrome) និងមានបញ្ហាបញ្ញាតិចតួច។ | សាលាទន្សាយ<br>KPF និង CCAMH |
| សុខុម មិនអាចដើរបាន ដោយសារជើងរបស់នាងកោង និងមិនលូតលាស់ពេញលេញ។ នាងពិបាកទៅសាលារៀន និងចូលទៅក្នុងថ្នាក់រៀន។ | The Cambodia School of Prosthetics and Orthotics |
| សា វីម មិននិយាយ ហើយគេមិនប្រាកដថា តើនេះបណ្តាលមកពីវាមិនអាចស្តាប់បាន ឬវាមានបញ្ហាក្នុងការនិយាយ។ សាវីមឆ្លើយនៅពេលគេហៅឈ្មោះ។ | CCAMH<br>សាលាទន្សាយ |

## សកម្មភាព ១៦.២ ការស្វែងយល់ពីប្រភេទពិការភាពខុសៗគ្នា មួយចំនួន

**រយៈពេល៖ ៤៥នាទី**

**វត្ថុបំណង៖**

- កំណត់បានប្រភេទពិការភាពខុសៗគ្នារបស់កុមារ។

**សម្ភារបង្រៀន និងរៀន៖**

- រូបភាព និងការពិពណ៌នានៃប្រភេទពិការភាពខុសៗគ្នា
- ប្រកាសអន្តរក្រសួងស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព (នៅក្នុងឌីវីឌី)

**សកម្មភាពបង្រៀន៖**

ក.ឱ្យគរុសិស្ស អានការពិពណ៌នានៃប្រភេទពិការភាពខុសៗគ្នា

**កំណត់ប្រភេទពិការភាព**[89]

| ប្រភេទពិការភាព | រូបភាព |
|---|---|
| **ជំងឺខួចប្រព័ន្ធបញ្ជាចលនាសាច់ដុំខួរក្បាល Cerebral palsy (CP)** គឺជាវិបត្តិនៃចលនា និងការគ្រប់គ្រងសាច់ដុំ (ភាពរស់រវើក) ដែលបង្កឡើងដោយរបួស ឬការខូចខាតខួរក្បាលដែលភាគច្រើនកើតឡើងមុន ឬអំឡុងពេលកើត។ នៅក្នុងប្រទេសកម្ពុជា ជំងឺខួចប្រព័ន្ធបញ្ជាចលនាសាច់ដុំខួរក្បាល ក៏អាចកើតឡើងផងដែរលើទារក ឬក្មេងតូចក្រោមអាយុ៣ឆ្នាំ ដែលកើតគ្រុនផ្តាសាយធ្ងន់ធ្ងរដែលមិនបានព្យាបាល។ អាស្រ័យលើភាពធ្ងន់ធ្ងរ កុមារមួយចំនួនដែលកើតជំងឺខួចប្រព័ន្ធបញ្ជាចលនាសាច់ដុំខួរក្បាល ក្រៅពីពិការរាងកាយ កុមារខ្លះទៀតមិនអាចដើរ និយាយ ហូបអាហារ ឬលេង ដោយសារភាពធ្ងន់ធ្ងរនៃការខូចខាតទៅដល់ខួរក្បាលរបស់ពួកគេ។ **មិនមែនកុមារទាំងអស់ដែលកើតជំងឺខួចប្រព័ន្ធបញ្ជាចលនាសាច់ដុំខួរក្បាល មានពិការភាពបញ្ញានោះទេ។** |  |
| | |

[89] កែសម្រួលពីសៀវភៅមគ្គុទេសក៍ស្តីពីការអប់រំបរិយាបន្ន ភាគ២ របស់ Kiran Dattani Pitt's ផលិតសម្រាប់ Aide et Action និងកម្មវិធីដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា (២០១៦)

| ប្រភេទពិការភាព | រូបភាព |
|---|---|
| **ជំងឺទឹកដក់ក្នុងខួរក្បាល**(Hydrocephalus)<br>បង្កឡើងដោយការស្ទះសារធាតុរាវនៅក្នុងក្បាល។ ជាធម្មតា ខួរក្បាលរបស់យើងត្រូវបានការពារ ដោយសារធាតុរាវនេះ និងផលិតសារធាតុរាវថ្មី និងបញ្ចេញសារធាតុរាវចាស់ ទៅក្នុងសរសៃឈាម។ ពេលខ្លះ ដោយសារកត្តាមួយចំនួន វាធ្វើឱ្យសារធាតុលើសមិនត្រូវបានបញ្ចេញ និងជាលទ្ធផល ធ្វើឱ្យមានសារធាតុរាវលើសនៅក្នុងខួរក្បាល។ សារធាតុរាវលើស នេះបង្កើតសម្ពាធលើខួរក្បាល និងបង្កការខូចខាតដល់ខួរក្បាល។ |  |
| **ជំងឺស្កន់** (Epilepsy) គឺជាស្ថានភាពសរសៃប្រសាទ ដែលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ។ នៅពេលដែលបុគ្គល ម្នាក់ត្រូវបានវិនិច្ឆ័យថាមានជំងឺស្កន់គឺពីព្រោះពួកគេមាន ការប្រកាច់ម្តងហើយម្តងទៀត ដែលបណ្តាលមកសកម្មភាពអគ្គិសនី និងគីមីមិនប្រក្រតីនៅក្នុងខួរក្បាល។ អាស្រ័យលើផ្នែកនៃខួរក្បាល ដែលសកម្មភាពមិនប្រក្រតីកើតឡើង ស្មារតី ចលនា ឬសកម្មភាព របស់បុគ្គលនោះអាចត្រូវបានប៉ះពាល់ និងប្រែប្រួលពីរបីវិនាទី ឬពីរបីនាទី។ ការប្រកាច់អាចកើតឡើងជាច្រើនទម្រង់ និងអាចប៉ះពាល់មនុស្សខុសៗគ្នា។ |  |
| **ជំងឺដោនស៊ីនដ្រូម** (Down's syndrome) គឺជាវិបត្តិហ្សែន ដែលបណ្តាលមកពីសារធាតុហ្សែនបន្ថែម នៅលើក្រូម៉ូសូមទី២១។ គេមិនបានដឹងថា តើសារធាតុហ្សែនត្រូវបានបន្ថែមយ៉ាងដូចម្តេច ហើយដោយសារមូលហេតុនេះ កុមារមានជំងឺដោនស៊ីនដ្រូម មានលក្ខណៈសណ្ឋានដូចៗគ្នា។ កុមារមានជំងឺដោនស៊ីនដ្រូម មានភាព ដូចគ្នាជាមួយឪពុកម្តាយរបស់ពួកគេ ច្រើនជាងរវាងកុមារ មានជំងឺនេះ។ វាមានភាពខុសប្លែកគ្នានៃកម្រិតភាពធ្ងន់ធ្ងន់នៃពិការភាព បញ្ញា និងពិការភាពការអភិវឌ្ឍ ហើយកុមារមួយចំនួនអាចមានបញ្ហា សុខភាពបន្ថែមទៀត។ វាគឺជាវិបត្តិហ្សែនពេញមួយជីវិត។ |  |

| ប្រភេទពិការភាព | រូបភាព |
| --- | --- |
| ជំងឺក្បាលតូច (Microcephaly)គឺជាស្ថានភាពប្រព័ន្ធប្រសាទដែលក្បាលរបស់ទារកមានទំហំតូចជាងទារកផ្សេងទៀតដែលមានអាយុ និងភេទដូចគ្នា។ ជាទូទៅ វាបណ្តាលមកពីខួរក្បាលមិនបានលូតលាស់នៅពេលដែលត្រូវលូតលាស់នៅក្នុងស្បូន។ ជាធម្មតា កុមារមានជំងឺ microcephalyមានពិការភាពបញ្ញា។ |  |
| **ជំងឺអូទីស្សឹម** (Autism) ត្រូវបានកំណត់ថាជាពិការ ភាពមានភាពអន់ខ្សោយបីផ្នែក។ ទោះបីជាកុមារទាំងអស់ ដែលមានជំងឺអូទីស្សឹមអន់ខ្សោយបីផ្នែកនេះក៏ដោយជំងឺនេះប៉ះពាល់កុមារម្នាក់ៗខុសៗគ្នា។ ការរៀនរបស់កុមារអូទីស្សឹមពាក់ព័ន្ធទៅនឹងកម្រិតជំងឺរបស់កុមារ។ នេះជាមូលហេតុ ដែលជំងឺត្រូវបានហៅថា វិបត្តិវិសាលគម (spectrum disorder)។ សូមកត់សម្គាល់ថា កុមារដែលមានជំងឺអូទីស្សឹមតិចតួចណាស់ដែលមានពិការភាពបញ្ញា។<br>ភាពអន់ខ្សោយទាំងបីផ្នែកនោះគឺ៖<br>• ការប្រាស្រ័យទាក់ទង<br>• ទំនាក់ទំនងសង្គម<br>• គំនិតមិនបត់បែន និងការពិបាកក្នុងមនោគតិសង្គម។ |  |
| **ពិបាកក្នុងការស្តាប់**៖ ការបាត់បង់ការស្តាប់ គឺជាអសមត្ថភាពទាំងស្រុង ឬដោយផ្នែក ក្នុងការស្តាប់សំឡេងក្នុងត្រចៀកម្ខាង ឬទាំងពីរ។ |  |

| ប្រភេទពិការភាព | រូបភាព |
| --- | --- |
| **ពិបាកក្នុងការមើល៖** ពិបាកក្នុងការមើលមានពីរប្រភេទ៖ **ខ្សោយគំហើញ** និង**ពិការភ្នែក**។<br>• ពាក្យ**ខ្សោយគំហើញ**ត្រូវបានប្រើប្រាស់ ដើម្បីពិពណ៌នាបញ្ហាគំហើញ ទោះបីជាពួកគាត់បានប្រើប្រាស់ឧបករណ៍ជំនួយ ឬការព្យាបាលហើយក៏ដោយ ក៏នៅតែមានបញ្ហាដដែល។ ពួកគេអាចត្រូវការកែសម្រួល ដូចជាអក្សរធំៗ ឬកៅអីនៅជួរមុខ ឬជិតបង្អួច។<br><br>**ពាក្យពិការភ្នែក** ត្រូវបានប្រើប្រាស់ ដើម្បីពិពណ៌នាបញ្ហាមើលនៅក្នុងករណីដែលបុគ្គលម្នាក់មើលឃើញតិចតួច(តែមិនដឹងថាជាអ្វី) ឬមិនឃើញសោះ។ ពួកគេអាចញែកតែពន្លឺ និងភាពងងឹតប៉ុណ្ណោះ ឬមិនមើលឃើញអ្វីផ្សេងទៀតទាំងអស់។ | <br> |
| **ជំងឺជ្រឿក** (Albinism) កើតឡើងនៅពេលសារធាតុ melanin ដែលជាសារធាតុកំណត់ពណ៌ស្បែក សក់ និងភ្នែកមានតិច ឬគ្មានសោះ។ មនុស្សភាគច្រើន ដែលមានជំងឺជ្រឿកងាយប្រតិកម្មនឹងពន្លឺថ្ងៃ និងមានហានិភ័យកើតជំងឺមហារីកស្បែក។ ជាទូទៅគំហើញរងការប៉ះពាល់តាមរយៈការប្រែប្រួលពន្លឺថ្ងៃ។ ជាទូទៅការប្រែប្រួលនៃពន្លឺថ្ងៃមានឥទ្ធិពលទៅលើគំហើញ។ មានស្ថានភាពភ្នែកដទៃផងដែរ ដូចជាការធ្វើចលនាភ្នែករហ័ស មិនអាចផ្តោតអារម្មណ៍ ម៉ូបជិត ឬម៉ូបឆ្ងាយ ប្រស្រីភ្នែកកោងខ្លាំងធ្វើឱ្យមើលឃើញព្រាលមិនច្បាស់ និងភ្នែកទាំងពីរមិនអាចផ្តោតលើវត្ថុតែមួយ។ |  |
| **ការពិបាកក្នុងការរៀន៖** ពិការភាពទាំងនេះ មិនអាចមើលឃើញនោះឡើយ<br>Dyscalulia សិស្សដែលមានការពិបាករៀនគណិតវិទ្យា អាចមានបញ្ហាក្នុងការដាក់តម្លៃលេខ ការប្រតិបត្តិសញ្ញា (+ - x ÷) និងការចងចាំព័ត៌មានជាលេខ (ដូចជា 5+5=10 ឬ 5x5=25)។<br>សិស្សក៏អាចមានបញ្ហាក្នុងរាប់លេខផងដែរ (ដូចជារាប់ម្តង២ ឬម្តង៥) ឬមានការពិបាកប្រាប់ម៉ោងពេល។ | |

| ប្រភេទពិការភាព | រូបភាព |
|---|---|
| **Dyspraxia** គឺជាវិបត្តិចលនាអវយវៈ ហើយវាអាចប៉ះពាល់បំណិនចលនាតូច និងធំ។ Dyspraxia មានភាពខុសគ្នាពីវិបត្តិចលនាផ្សេងទៀត ដូចជាជំងឺខួចប្រព័ន្ធបញ្ជាចលនាសាច់ដុំខួរក្បាល cerebral palsy។ សិស្សអាចមានការពិបាកមើលថែខ្លួនឯង ការសរសេរ  អាន ជិះកង់ លេង និងសកម្មភាពអប់រំ និងកំសាន្តផ្សេងទៀត។ Dyspraxia ក៏អាចប៉ះពាល់ការបញ្ចេញសំឡេងពាក្យ ការនិយាយ ការដឹងពីខ្លួនប្រាណ ទីលំហ និងការគិត។ គេគិតថា មូលហេតុមួយដែលបណ្តាលឱ្យកើតមានជំងឺ dyspraxia គឺដោយសារការបង្អាក់នៃការបញ្ជូនសារពីខួរក្បាលទៅខ្លួនប្រាណ។<br><br>**Dyslexia** គឺជាពិការភាពអាចំកំបាំង ហើយសិស្សដែលមានជំងឺ Dyslexia អាចរៀបអក្សរខុស នៅក្នុងពាក្យ និងរៀបពាក្យខុសនៅក្នុងប្រយោគ។ ពួកគេអាចមានការពិបាកជាមួយការប្រកបអក្សរ និងនៅពេលសរសេរ សិស្សអាចសរសេរអក្សរបញ្ច្រាស។ បញ្ហាការអានទូទៅកើតមាន នៅពេលមានការពិបាកក្នុងការយល់ទំនាក់ទំនងរវាងសំឡេង អក្សរ និងពាក្យ។ បញ្ហាសមត្ថភាពយល់ការអានកើតមាន នៅពេលមិនមានសមត្ថភាពយល់អត្ថន័យពាក្យ ឃ្លា និងកថាខណ្ឌ។<br><br>**Dysgraphia** គឺជាការពិបាកការរៀន នៅក្នុងបំណិនចលនាតូច ហើយវាប៉ះពាល់សមត្ថភាពសរសេរ។ កុមារសរសេរអក្សរមិនល្អរក្សាចន្លោះអក្សរមិនល្អ ដូច្នេះធ្វើឱ្យការសរសេរពួកគេមើលមិនដាច់។<br><br>**Attention Deficit Hyperactivity Disorder**: សិស្សមានការពិបាកផ្តោតអារម្មណ៍ ជ្រួលច្រាល ធ្វើអ្វីតាមតែសន្ទុះចិត្ត ប្លែក និងពុំអាចស្ងាត់បានអាចមកពីមានជំងឺ ADHD, ទោះបីប្រាប់ពួកគេអំពីអាកប្បកិរិយារបស់ពួកគេច្រើនយ៉ាងណាក៏ដោយ ក៏នឹងមិនធ្វើឱ្យពួកគេផ្លាស់ប្តូរអាកប្បកិរិយាដែលកើតឡើងនោះទេ ពីព្រោះសិស្សមិនអាចគ្រប់គ្រងខ្លួនឯងបាន។ សម្រាប់សិស្សដែលមើលទៅរវើរវាយ និងមិនបង្ហាញសកម្មភាពខ្លាំង ប៉ុន្តែមានអាការរោគមិនអាចផ្តោតអារម្មណ៍ ប្រុងស្មារតី ។ល។ ពួកគេមានជំងឺ ADD។ ពួកគេងាយបែកអារម្មណ៍ និងមិនអាចផ្តោតអារម្មណ៍ផ្ចិតផ្ចង់ខ្លាំង ដូច្នេះអាចមិនចាប់បានចំណុចសំខាន់នៅក្នុងការរៀន។ ពេលខ្លះ គ្រូបង្រៀនមិនអាចកត់សម្គាល់ថា កុមារនេះមាន ADDនោះទេ។ ADDអាចកើតឡើងព្រមគ្នាជាមួយជំងឺ dyslexia។ | |

## សកម្មភាព ១៦.៣ ការកំណត់ឈ្មោះឧបករណ៍ជំនួយ

**រយៈពេល៖ ៣០នាទី**

**វត្ថុបំណង៖**

- កំណត់បានពីឧបករណ៍ជំនួយផ្សេងៗ និងអត្ថប្រយោជន៍របស់វា។

**សម្ភារបង្រៀន និងរៀន៖**

- រូបភាពនៃឧបករណ៍ជំនួយផ្សេងៗ (សូមកត់សម្គាល់ថា ឧបករណ៍ជំនួយដើម្បីជួយការប្រាស្រ័យទាក់ទងភាគច្រើនត្រូវបានបង្ហាញនៅក្នុងសកម្មភាព ១៣.៣ រួចហើយ)។

**សកម្មភាពបង្រៀន៖**

ក.សួរសំណួរបំផុស

តើអ្នកស្គាល់ឧបករណ៍ជំនួយណាមួយឬទេ?

ខ.ឱ្យគរុសិស្សមើលរូបភាពនៃឧបករណ៍ជំនួយផ្សេងៗ និងនិយាយអំពីអត្ថប្រយោជន៍នៃឧបករណ៍ជំនួយនីមួយៗ។

គ.បន្ទាប់មក ពួកគេត្រូវអានករណីសិក្សា និងកំណត់តើឧបករណ៍ជំនួយអ្វី ដែលអាចជួយគាំទ្រកុមារ។ សូមមើលសកម្មភាព ១៣.៣

### អត្ថប្រយោជន៍នៃឧបករណ៍ និងបច្ចេកវិទ្យាជំនួយ[90]

ឧបករណ៍ និងបច្ចេកវិទ្យាជំនួយមានគោលបំណងចម្បងគឺធ្វើឱ្យប្រសើរឡើង ឬរក្សាការបំពេញមុខងារ និងឯករាជ្យភាពរបស់មនុស្ស ដើម្បីសម្រួលការចូលរួម និងធ្វើឱ្យសុខមាលភាពទាំងមូលប្រសើរឡើង។ ឧបករណ៍ និងបច្ចេកវិទ្យាទាំងនោះក៏អាចជួយការពារភាពអន់ខ្សោយ និងស្ថានភាពសុខភាពក្រោយកំណើត។ ឧទាហរណ៍នៃឧបករណ៍ជំនួយ រួមមានរទេះរុញសរីរាង្គសិប្បនិម្មិត ឧបករណ៍ជំនួយស្តាប់ ឧបករណ៍ជំនួយមើល និងកម្មវិធីកុំព្យូទ័រពិសេសដែលបង្កើនសមត្ថភាពការធ្វើចលនាបម្លាស់ទី ការមើល ការស្តាប់ និងការប្រាស្រ័យទាក់ទងជាដើម។

### អ្វីដែល UNCRPD ថ្លែងអំពីឧបករណ៍ជំនួយ[91]

រដ្ឋភាគីត្រូវលើកកម្ពស់ការអាចរកបាន ចំណេះដឹង និងការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាជំនួយ ដែលផលិតសម្រាប់មនុស្សពិការ ពីព្រោះឧបករណ៍និងបច្ចេកវិទ្យាទាំងនោះពាក់ព័ន្ធទៅដល់នីតិសម្បទា និងការស្តារនីតិសម្បទា។ គោលបំណងនោះគឺដើម្បីសម្រេចបាន និងរក្សាឯករាជ្យភាព បរិយាបន្នពេញលេញ និងការចូលរួមនៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិត។

---

[90] និយមន័យរបស់ WHO http://www.who.int/disabilities/technology/en/

[91] UNCRPD មាត្រា២៦ ស្តីពីនីតិសម្បទា និងការការស្តារនីតិសម្បទា កថាខណ្ឌទី៣

| | |
|---|---|
| ក. ក្បាច់គិតលេខសម្រាប់ជនពិការភ្នែក<br> | ខ.រទេះរុញ<br> |
| គ. សៀវភៅទំហំធំ<br><br> | ឃ. ជើងទម្រសម្រាប់អាន<br> |
| ង. សៀវភៅអក្សរប្រេយ៍<br> | ជ. ព័ត៌មានវិទ្យាសម្រាប់ជនពិការភ្នែក<br> |

| | |
|---|---|
| ឈ. ភាសាសញ្ញា<br> | ញ. កាលវិភាគរូបភាព<br> |
| ដ. ស្លេត និងស្តាយឡាស<br> | ឋ. អក្សរប្រៃយ៍<br> |
| ឌ. ឧបករណ៍ជំនួយស្តាប់<br>  | ឍ. ប្រព័ន្ធប្រាស្រ័យទាក់ទងផ្លាស់ប្តូររូបភាព<br><br> |

**សកម្មភាព ១៦.៤ ការពង្រីកការយល់ដឹងរបស់អ្នកអំពីការបង្រៀនកុមារពិការ**
**រយៈពេល៖ ៩០នាទី**
**វត្ថុបំណង៖**

- ពណ៌នាបានពីគន្លឹះជំនួយផ្សេងៗ ដើម្បីបង្រៀនកុមារ ដែលមានពិការភាពផ្សេងៗគ្នា។

**សម្ភារបង្រៀន និងរៀន៖**

- ឯកសារអាន
- វីដេអូដោយអង្គការ Handicap International ស្តីពីការអនុវត្តល្អនៅក្នុងការអប់រំបរិយាបន្ន

**សកម្មភាពបង្រៀន៖**

ក. បែងចែកគរុសិស្សជាក្រុមមានសមាជិក៥ ទៅ៦នាក់។
ខ. ឱ្យពួកគេអានគន្លឹះជំនួយក្នុងការបង្រៀនកុមារពិការ។
គ. ឱ្យគរុសិស្សពិភាក្សាសំណួរ៖
-ចូរពិភាក្សាដើម្បីរៀបចំគន្លឹះជំនួយការបង្រៀន ។
(ពួកគេត្រូវប្រើប្រាស់វិធីច្នៃប្រឌិតនៃការបង្រៀនសហការីរបស់ពួកគេ ការធ្វើត្រាប់តាម ការគូររូប ការដើរតួសម្តែងអំពីគន្លឹះជំនួយការបង្រៀន។ )
ឃ.តំណាងក្រុមឡើងបង្ហាញ
ង. សំយោគ
សម្រាប់យុទ្ធសាស្ត្ររៀនលម្អិត សូមមើលសៀវភៅការអប់រំបញ្ចូលគ្នា(សម្រាប់អ្នកសម្របសម្រួល) ផលិតក្នុងឆ្នាំ២០១២ ដោយក្រសួងអប់រំ យុវជន និងកីឡា ។

**គន្លឹះជំនួយបង្រៀនសម្រាប់កុមារពិការប្រភេទផ្សេងៗគ្នា[92]**

| កុមារមានបញ្ហាចលនា | កុមារមានបញ្ហាមើល |
|---|---|
| • ត្រូវធានាភាពងាយស្រួលចូលទៅថ្នាក់រៀន និងអគារសាលារៀនទាំងអស់ (ឧ. បន្ទប់ទឹក)<br>• រៀបចំថ្នាក់រៀន ដើម្បីឱ្យកុមារប្រើប្រាស់រទេះរុញ ឈើច្រត់ជាដើមអាចផ្លាស់ទីដោយឯករាជ្យ។<br>• ផ្តល់ពេលវេលាសម្រាក ពីព្រោះកុមារងាយហត់<br>• ស្វែងរកឧបករណ៍ជំនួយចាំបាច់៖ កៅអីរុញចុះឡើង គុសរសេរ ប៊ិកងាយចាប់កាន់ជាដើម<br>• ប្រើប្រាស់ក្តារប្រាស្រ័យទាក់ទងសម្រាប់កុមារមានការពិបាកក្នុងការនិយាយ (ឧ. សម្រាប់កុមារមានជម្ងឺ | • ដាក់កុមារអង្គុយនៅជួរខាងមុខ ឬនៅកន្លែងដែលពួកគេអាចមើលឃើញក្តារខៀន<br>• ត្រូវធានាថា ក្តារខៀនមានពណ៌ផ្ទុយគ្នាល្អជាមួយអក្សរសរសេរ<br>• ប្រើប្រាស់ភាសាពិពណ៌នា និងឈ្មោះ ជៀសវាងនិយាយ "នេះ" ឬ "នោះ"<br>• រកជំនួយអក្សរប្រែយ៍សម្រាប់កុមារពិការភ្នែក ឬអ្នកដែលមិនអាចមើលអក្សរធម្មតា<br>• រៀនអក្សរប្រែយ៍ វាងាយរៀន នៅពេលអ្នកអាច |

[92] កែសម្រួលពីសៀវភៅមគ្គុទេសក៍ ស្តីពីការអប់រំបរិយាបន្ន ភាគ២ ដោយ Kiran Dattani Pitt និងការបង្រៀនកុមារមានបញ្ហារៀនទាក់ទងនឹងពិការភាពដោយ Maya Kalyanpur

| | |
|---|---|
| ខួចប្រព័ន្ធបញ្ហាខួរក្បាល cerebral palsy)<br>• អនុញ្ញាតឱ្យមានពេលវេលាបន្ថែម ដើម្បីបញ្ចប់លំហាត់ និងកិច្ចការ ប្រសិនបើចាំបាច់<br>• ត្រូវធានាថា ពួកគេចូលរួមគ្រប់សកម្មភាពទាំងអស់ (សម្រាប់ព័ត៌មានបន្ថែមអំពីការកែសម្រួលសកម្មភាពកីឡាមើលសៀវភៅមគ្គុទេសក៍ការសប្បាយបរិយាបន្ន)<br>• ឱ្យមិត្តភក្តិចូលរួមជួយគាំទ្រ<br>• ប្រើប្រាស់ ICT ប្រសិនបើមាន | មើលឃើញ<br>• ផ្តល់ឧបករណ៍ជំនួយចាំបាច់៖ ស្លេត ស្តាយឡាស ឈើច្រត់ កែវពង្រីក វ៉ែនតា ជាដើម<br>• ផ្តល់ការបង្ហាញផ្លូវ និងការបណ្តុះបណ្តាលការធ្វើដំណើរ<br>• ទុកដាក់សម្ភារ សៀវភៅនៅកន្លែងដដែលងាយរក<br>• ត្រូវធានាថា កុមារដឹងការផ្លាស់ប្តូរ ការរៀបចំថ្នាក់ រៀន<br>• មានវ៉ែនតាការពារកម្តៅថ្ងៃ (និងរបស់ការពារស្បែកសម្រាប់កុមារដែលត្រូវការ (ឧ. កុមារមានជំងឺ ផឿក albinism)<br>• ត្រូវធានាថា បន្ទប់ស្ងប់ស្ងាត់<br>• ផ្តល់សម្ភារបង្រៀន និងរៀន ដែលសិស្សអាចចាប់ប៉ះបាន (ឧ. ទ្រង់ទ្រាយធរណីមាត្រ ផែនទីធ្វើពីឈើ រូបផ្គុំផ្នែករាងកាយ បន្ទះឈើសម្រាប់គិតលេខ។ល។)<br>• អានអក្សរសរសេរនៅលើក្តារខៀនឱ្យឮ<br>• ហៅចំឈ្មោះសិស្សដែលអ្នកនិយាយទៅកាន់ ដើម្បីឱ្យកុមារដឹងថា គេជានរណា<br>• ប្រើប្រាស់វត្ថុពិតប្រាកដ<br>• ផ្តល់ពេលវេលាឱ្យគ្រប់គ្រាន់ ពីព្រោះការសរសេរអក្សរប្រេយ៍ ចំណាយពេលវេលាច្រើន<br>• ប្រើប្រាស់ ICT ប្រសិនបើមាន |
| **កុមារមានបញ្ហាស្តាប់**<br>• ប្រើប្រយោគខ្លីៗ<br>• រៀបកន្លែងអង្គុយជារាងអក្សរ U ដើម្បីឱ្យកុមារមើលឃើញគ្នាទៅវិញទៅមក<br>• ពេលបង្រៀនគ្រូត្រូវឈរទល់មុខសិស្ស<br>• មើលទៅកាន់កុមារ នៅពេលនិយាយ<br>• និយាយយឺតៗ<br>• ប្រើប្រាស់ការធ្វើត្រាប់តាមកាយវិការ និងសញ្ញាធម្មជាតិ<br>• សរសេរព័ត៌មានសំខាន់ៗ ឬកត់ត្រានៅមុនម៉ោងរៀន | **កុមារមានបញ្ហាការអភិវឌ្ឍ**<br>• ប្រើប្រាស់ពាក្យ និងប្រយោគសាមញ្ញ<br>• គួរប្រើវត្ថុពិត<br>• ផ្តល់ការណែនាំឱ្យបានច្បាស់ ម្តងមួយៗ<br>• បំបែកកិច្ចការជាជំហានតូចៗ<br>• ផ្តល់ការអនុវត្តបន្ថែម<br>• ផ្តោតលើជំនាញប្រចាំថ្ងៃដែលសំខាន់សម្រាប់កុមារ<br>• និយាយព័ត៌មានសាឡើងវិញជាប្រចាំ<br>• ប្រើការគាំទ្រពីមិត្តភក្តិ<br>• សរសើរ និងលើកទឹកចិត្តឱ្យបានច្រើន |

| | |
|---|---|
| ដើម្បីជៀសវាងបែខ្នងទៅកសិស្សនៅពេលនិយាយ។ វាំងននក្តារខៀនអាចប្រើដើម្បីបាំងលំហាត់។<br>• ត្រូវចេះបត់បែនពេលវេលា<br>• ផ្តោតលើខ្លឹមសារជាងវេយ្យាករណ៍<br>• ប្រើប្រាស់ការណែនាំបែបរូបភាពឱ្យបានច្រើន ដូចជា ផែនទីគំនិត (mind maps) គំនូសតាង ចំណុចសំខាន់ៗ<br>• ស្វែងរកការគាំទ្រ(ភាសាសញ្ញា) និងលើកទឹកចិត្តការរៀនភាសាសញ្ញានៅក្នុងសាលារៀន<br>• រកមនុស្សពេញវ័យដែលមានបញ្ហាស្តាប់ ឱ្យជួបជាមួយកុមារនោះ។ | • មិនអើពើអាកប្បកិរិយាដែលមិនរំខានដល់ថ្នាក់រៀន<br>• បង្កើតផែនការសកម្មភាពសម្រាប់សិស្សម្នាក់ៗជាមួយគោលដៅជាក់ស្តែង ដើម្បីកុមារសម្រេច បាន<br>• លើកកម្ពស់ការយល់ដឹងនៅក្នុងថ្នាក់រៀនដើម្បីកុំឱ្យមានការសម្លុត ធ្វើបាប។ |
| **កុមារមានបញ្ហាសរសេរ ឬអាន** (dyslexia)<br>• មានការរំពឹងទុកខ្ពស់ ប៉ុន្តែសមស្រប<br>• ពន្យល់ឱ្យបានច្រើនដងជាមួយវិធីច្រើនបែប<br>• បង្កើតទម្លាប់បង្រៀនកុមារធ្វើកិច្ចការជាប្រព័ន្ធ<br>• ផ្តោតលើខ្លឹមសារជាងវេយ្យាករណ៍<br>• អនុញ្ញាតឱ្យសិស្សប្រើប្រាស់ប៊ិក ឬខ្មៅដៃដិតខ្លាំង នៅពេលសរសេរ ឬប្រើបន្ទាត់ ដើម្បីដេញតាមអក្សរនៅពេលអាន<br>• ប្រើប្រាស់ពណ៌ ដើម្បីគូសចំណាំពាក្យសំខាន់ៗ បង្កើតស្នាមគំរូដែលងាយស្រួលសម្គាល់ និងចងចាំ<br>• សសើរសិស្សសម្រាប់ស្នាដៃរបស់ពួកគេ និងឱ្យពួកគេអភិវឌ្ឍទេពកោសល្យ នៅក្នុងផ្នែកផ្សេងទៀត<br>• អនុញ្ញាតឱ្យសិស្សធ្វើការប្រឡងដោយផ្ទាល់មាត់ ឬផ្តល់អ្នកអាន និងអ្នកសរសេរដល់ពួកគេ | **កុមារមានបញ្ហារពឹស និងការផ្ចង់អារម្មណ៍** (ADHD)<br>• បំបែកកិច្ចការធំៗជាកិច្ចការតូចៗ និងកំណត់ពេលវេលាសម្រាប់ជំហានឬកិច្ចការតូចៗម្នាក់ៗ។<br>• អនុញ្ញាតឱ្យកុមារផ្លាស់ទី នៅពេលកំពុងរៀន<br>• ដាក់ការងារជួយសិស្សដទៃដល់សិស្សនោះ ពីព្រោះវានឹងផ្តល់ឱកាសឱ្យពួកគេផ្លាស់ទីបានខ្លះ<br>• អនុញ្ញាតឱ្យកុមារឆ្លើយផ្ទាល់មាត់<br>• ផ្តល់ពេលវេលាឱ្យបានច្រើន<br>• ប្រើប្រាស់សកម្មភាពរាងកាយ ដែលមានការធ្វើចលនា<br>• ធ្វើតារាងកិច្ចការ ប្រចាំថ្ងៃ |
| **កុមារមានជំងឺអូទីស្សឹម** (Autism)<br>• ស្វែងយល់ពីឪពុកម្តាយ បងប្អូន អំពីយុទ្ធវិធីល្អៗ ដើម្បីប្រើប្រាស់សមត្ថភាព និងចំណង់ចំណូលចិត្តរបស់ពួកគេ | **គថ្លង់ ពិការភ្នែក**<br>• ពិនិត្យផ្នែកស្តាប់ ឬមើលដែលមិនមានបញ្ហា<br>• ប្រើប្រាស់ផ្នែកស្តាប់ឬ មើលដែលមិនមានបញ្ហា ដើម្បីបង្កើតការប្រាស្រ័យទាក់ទង |

| | |
|---|---|
| • កុមារម្នាក់ៗមិនដូចគ្នាទេ ដូច្នេះត្រូវស្វែងយល់អំពីពួកគេឱ្យបានច្រើន<br>• មិនត្រូវខកចិត្ត ដោយសារកង្វះការប្រាស្រ័យទាក់ទង<br>• ព្យាយាម និងអត់ធ្មត់<br>• ផ្តល់សកម្មភាពជាទម្លាប់<br>• និយាយដដែលៗឡើងវិញ<br>• ប្រឹក្សាជាមួយអ្នកឯកទេស ប្រសិនបើអាច<br>• ស្វែងរកការគាំទ្រពីអ្នកជំនួយ អ្នកស្ម័គ្រចិត្ត<br>• កត់សម្គាល់អ្វីដែលសិស្សស្រឡាញ់ និងចូលចិត្ត ដើម្បីជំរុញ និងលើកទឹកចិត្តកិច្ចសហប្រតិបត្តិការ<br>• រៀបចំផែនការរៀន ទៅតាមសេចក្តីត្រូវការរបស់សិស្ស | • ត្រូវបង្កើតការប្រាស្រ័យទាក់ទងមូលដ្ឋានមុនពេលបង្រៀនសញ្ញាណាមួយ<br>• ការធ្វើសញ្ញា ឬប៉ះចាប់អក្សរនៅក្នុងដៃ ត្រូវបានប្រើជាការប្រាស្រ័យទាក់ទងនៅពេលខ្លះ<br>• មើលគន្លឹះជំនួយសម្រាប់អ្នករៀនមានបញ្ហាមើល ឬស្តាប់សម្រាប់គំនិតបន្ថែម |
| **កុមារពិបាកផ្នែកសង្គម អារម្មណ៍ និងអាកប្បកិរិយា**<br>• ពិនិត្យស្វែងរកការពិបាក<br>• ពិភាក្សាជាមួយកុមារ និងឪពុកម្តាយ ដើម្បីស្វែងរកយុទ្ធវិធីល្អបំផុត<br>• សួរកុមារផ្អែកតាមសមត្ថភាព<br>• ធ្វើឱ្យកុមារមានអារម្មណ៍ថា ត្រូវបានស្រឡាញ់ ចូលចិត្ត និងត្រូវបានឱ្យតម្លៃ<br>• ពន្យល់ឱ្យបានច្បាស់អំពីលទ្ធផលនៃអាកប្បកិរិយារបស់ពួកគេ ដើម្បីឱ្យកុមារទទួលខុសត្រូវសកម្មភាពរបស់ពួកគេ<br>• ត្រូវមានចម្លើយសមរម្យ ផ្តល់ដំណោះស្រាយសមស្រប "អ្នកអាចសម្រេចចិត្តមិនធ្វើលំហាត់នេះ និងបញ្ចប់វានៅពេលក្រោយ ឬក៏ធ្វើវានៅពេលឥឡូវ និងបន្ទាប់មកសម្រាកជាមួយអ្នកទាំងអស់គ្នា"<br>• បង្កើតបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្នាក់រៀនទាំងមូលជាមួយកុមារ | **ជំងឺស្កន់ (Epilepsy)**<br>• ដឹងអំពីអាការរោគនាំឱ្យប្រកាច់របស់សិស្ស និងថ្នាំព្យាបាល<br>• ត្រូវធានាថាសិស្សហ៊ានប្រាប់នៅពេលគេមានអារម្មណ៍នឹងមានការប្រកាច់កើតឡើង។<br>• ពន្យល់ពីស្ថានភាពទៅមិត្តរួមថ្នាក់ បំបាត់ជំនឿ និងការភ័យខ្លាច។<br>• ណែនាំបង្ហាញខ្លួនអ្នក និងសិស្សក្នុងថ្នាក់រៀនអំពីរបៀបដោះស្រាយការប្រកាច់<br>• គ្រប់គ្រងអារម្មណ៍<br>• បញ្ជាក់ប្រាប់កុមារដទៃថា វាគ្រាន់តែការប្រកាច់ប៉ុណ្ណោះ ហើយវានឹងបាត់ទៅវិញ<br>• យកចេញវត្ថុដែលអាចបង្ករបួសដល់កុមារ (តុ កៅអី...)<br>• ការពារក្បាលកុមារដោយក្រណាត់ ឬវត្ថុទន់ ឬដាក់ដៃរបស់អ្នកនៅជុំវិញក្បាលកុមារ<br>• ផ្អេកកុមារចំហៀង ដើម្បីកុំឱ្យទឹកមាត់ហូរចូលបំពង់កវិញ<br>• បន្ធូរខោអាវ<br>• ត្រូវនៅទីនោះរហូតដល់កុមារមានស្មារតីវិញ |

| | |
|---|---|
| | • មិនត្រូវផ្តល់ទឹក ឬភេសជ្ជៈ រហូតដល់ធូរស្បើយ<br>• កុំដាក់អ្វីនៅចន្លោះធ្មេញ<br>• បន្ទាប់មកជួបជាមួយឪពុកម្តាយអំពីការប្រើថ្នាំព្យាបាល |
| **ជំងឺស្បែក** (Albinism)<br>• ផ្តល់ពេលវេលា ដើម្បីកុមារសុំទៅនឹងការផ្លាស់ប្តូរពន្លឺពីខាងក្រៅមកខាងក្នុងថ្នាក់រៀន<br>• ឱ្យកុមារអង្គុយនៅកណ្តាលជិតជួរមុខជាមួយកុមារផ្សេងទៀត<br>• ផ្តល់ឯកសារអាន ដែលមានអក្សរធំល្មម<br>• ប្រើប្រាស់ក្រដាសពណ៌ស ឬពណ៌ត្នោតចាស់ កុំប្រើក្រដាសពណ៌ផ្សេង<br>• មិនត្រូវឱ្យសិស្សធ្វើការងារនៅក្រោមស្រមោលខ្លួនឯង ឬបែរមុខទៅពន្លឺ<br>• ត្រូវធានាថា ពួកគេមិនចាំបាច់អានច្រើនពេក ព្រោះវាធ្វើឱ្យភ្នែកពួកគេនឿយហត់ | |

## យុទ្ធវិធីសម្រាប់ជួយសិស្សពិការ[93]

នៅពេលយើងបង្កើតថ្នាក់រៀនបរិយាបន្ន និងព្យាយាមដាក់បញ្ចូលកុមារ ដែលមានសមត្ថភាពផ្សេងៗគ្នា យើងត្រូវការយុទ្ធវិធី ដើម្បីជួយកុមារទាំងនេះរៀនឱ្យអស់លទ្ធភាព។ យុទ្ធវិធីទាំងនេះរួមមាន៖

**លំដាប់៖** បំបែកកិច្ចការជាផ្នែកតូចៗ និងផ្តល់ការណែនាំ ឬការជំរុញមួយជំហានម្តងៗ

**ការអនុវត្តសាឡើងវិញ និងមតិត្រឡប់មកវិញ៖** ប្រើប្រាស់ការធ្វើតេស្តជំនាញប្រចាំថ្ងៃ ការអនុវត្តសាឡើងវិញ និងមតិត្រឡប់ប្រចាំថ្ងៃ

**ចាប់ផ្តើមពីតូច និងកសាង៖** បំបែកជំនាញគោលដៅជាផ្នែកតូចៗ ឬអាកប្បកិរិយា និងបន្ទាប់មកកសាងផ្នែកទាំងនោះរួមគ្នាឱ្យក្លាយតែមួយ។

**ការបន្ថយការលំបាក៖** រៀបចំលំដាប់កិច្ចការពីងាយស្រួលទៅលំបាក និងផ្តល់ការណែនាំខ្លីៗដែលចាំបាច់ប៉ុណ្ណោះ

**សួរសំណួរ៖** សួរសំណួរទាក់ទងនឹងដំណើរការ "យ៉ាងដូចម្តេច" ឬសំណួរទាក់ទងនឹងខ្លឹមសារ "តើជាអ្វី"

**រូបភាព៖**បញ្ជាក់រូបភាព ឬការបង្ហាញបែបរូបភាពផ្សេងទៀត

**ការណែនាំសម្រាប់ក្រុម៖** ផ្តល់ការណែនាំសម្រាប់ក្រុមតូចៗរបស់សិស្ស

**គ្រូបន្ថែម និងការចូលរួមរបស់មិត្តភក្តិ៖** ប្រើប្រាស់កិច្ចការផ្ទះ ឪពុកម្តាយ ឬអ្នកដទៃ ដើម្បីជួយក្នុងការបង្រៀន។

### យុទ្ធវិធី និងសកម្មភាពលម្អិតក្នុងការបង្រៀនកុមារពិការប្រភេទផ្សេងៗគ្នា

ទំព័របន្ទាប់ប្រាប់គន្លឹះជំនួយការបង្រៀនកុមារមានពិការភាពខុសៗគ្នា។ ដើម្បីទទួលបានព័ត៌មានបន្ថែមជាមួយសកម្មភាព ឧទាហរណ៍ និងករណីសិក្សា សូមមើលសៀវភៅការអប់រំបញ្ចូលគ្នាខាងក្រោម[94] ទាំងនេះគឺជាធនធានល្អសម្រាប់ព័ត៌មានលម្អិត ហើយត្រូវបានផលិតដោយ ក្រសួងអប់រំ យុវជន និងកីឡានៅក្នុងប្រទេសកម្ពុជា ។

---

[93] UNESCO (២០១៥) *ទទួលយកឧបករណ៍ភាពចម្រុះ:* ទំព័រ៣៧ អត្ថបទដកស្រង់ចេញពី Swanson HL (១៩៩៩) ជាគុផ្សំការបង្រៀន ដែលព្យាករណ៍លទ្ធផលព្យាបាលសិស្សមានពិការភាពការរៀន ការគាំទ្រសម្រាប់យុទ្ធសាស្ត្រចម្រុះ និងគំរូការបង្រៀនផ្ទាល់។ ការស្រាវជ្រាវ និងអនុវត្តការរៀន ១៤ (៣) ទំព័រ១២៩-១៤០

[94] សៀវភៅមគ្គុទេសទាំងអស់ត្រូវបានផលិតដោយបណ្ឌិត Maya Kalyanpur សម្រាប់ MoEYS ប្រទេសកម្ពុជា ឆ្នាំ២០១២

## គន្លឹះជំនួយសម្រាប់ការបង្រៀន និងរៀន[95]

- មេរៀនត្រូវគ្រោងជុំវិញ "គំនិតធំទូលាយ" ជាជាងព័ត៌មានដែលមិនភ្ជាប់គ្នា។ ការធ្វើបែបនេះ កុមារមានគំនិតចម្បងមួយ ដែលពួកគេអាចដាក់ព័ត៌មានថ្មីភ្ជាប់គ្នាជាមួយអ្វីដែលពួកគេបានដឹង។ គំនិតធំទូលាយអាចជា "ទឹកសំខាន់សម្រាប់ជីវិត" និងប្រធានបទអាចជា "ថ្ងៃនេះយើងនឹងរៀនអំពីរបៀបរក្សាទឹកឱ្យស្អាត"។
- យើងត្រូវពិចារណាសេចក្តីត្រូវការការអភិវឌ្ឍរបស់កុមារ។ កុមារមួយចំនួនត្រូវការពេលវេលាច្រើនជាងកុមារផ្សេងទៀតដើម្បីអភិវឌ្ឍ។
- យើងត្រូវតែជាអ្នកសម្របសម្រួលនៃការរៀន និងទទួលស្គាល់ចរិតលក្ខណៈពិសេសរបស់សិស្ស។ បរិយាកាសនៃការរៀនគួរគាំទ្រដល់សិស្សទាំងអស់។
- សិស្សត្រូវនិយាយជាមួយគ្រូបង្រៀនរបស់ពួកគេទាំងអស់គ្នា និងជាមួយគ្នាទៅវិញទៅមក ពេលធ្វើសកម្មភាពដែលផ្តោតទាំងទៅលើបុគ្គល និងក្រុម។
- យើងត្រូវរៀបចំផែនការសកម្មភាព ដែលលើកទឹកចិត្តកុមារទាំងអស់ឱ្យធ្វើការជាក្រុម ដូចជាការងារជាដៃគូ ឬជាក្រុមតូចៗលើកិច្ចការពាក់ព័ន្ធនានា។
- សិស្សត្រូវអាចយល់ដឹងថាកម្មវិធីសិក្សាមានប្រយោជន៍សម្រាប់ពួកគេត្រូវបានលើកទឹកចិត្តឱ្យសួរសំណួរ និងពិចារណាព័ត៌មាន និងអាចបង្កើនការយល់ដឹងរបស់ពួកគេលើប្រធានបទ។
- យើងត្រូវសួរសំណួរល្អៗ ដើម្បីឱ្យសិស្សអាចពន្យល់គំនិតរបស់ពួកគេ។
- ជំនួសឱ្យការសួរសំណួរ ដែលទាមទារចម្លើយ "បាទ ចាស" ឬ "ទេ" យើងត្រូវសួរសំណួរបើក ដើម្បីអនុញ្ញាតឱ្យកុមារបញ្ចេញគំនិតយោបល់របស់ពួកគេ ឧទាហរណ៍យើងអាចសួរសំណួរដែលបញ្ចប់ដោយ "តើអ្នកគិតយ៉ាងដូចម្តេច?"
- សំណួរពិចារណាត្រឹមត្រូវ ដែលសួរដោយគ្រូបង្រៀន និងការពិភាក្សាសកម្ម ក្នុងចំណោមសិស្សនឹងជួយជំរុញសិស្សឱ្យស្វែងរកព័ត៌មាន។ ការទំនាក់ទំនងជាមួយអ្នកដទៃ ការទទួលព័ត៌មានថ្មី និងការគិតពិចារណាគំនិតនានាជួយកុមារបង្កើតចំណេះដឹងថ្មី។

[95] UNESCO (២០១៥ ធនធានអនឡាញ) *ទទួលយកភាពចម្រុះ កូនសៀវភៅទី៤ បង្កើតថ្នាក់រៀនបរិយាបន្ន និងការរៀនមេត្រី* ទំព័រ១៥

## សកម្មភាព ១៦.៥  ការរៀបចំផែនការ ដើម្បីបំពេញសេចក្តីត្រូវការរបស់សិស្សម្នាក់ៗ

**រយៈពេល៖ ៩០នាទី**

**វត្ថុបំណង៖**

- រៀបចំបានផែនការអប់រំដើម្បីបំពេញសេចក្តីត្រូវការរបស់សិស្សម្នាក់ៗ (IEP)។

**សម្ភារបង្រៀន និងរៀន ៖**

- ករណីសិក្សា
- ព័ត៌មានអំពីផែនការអប់រំសម្រាប់សិស្សម្នាក់ៗ(IEP) និងទម្រង់ផែនការអប់រំសម្រាប់សិស្សម្នាក់ៗដោយ DAC

**សកម្មភាពបង្រៀន៖**

ក.  ឱ្យគរុសិស្សអានព័ត៌មាន និងទម្រង់ផែនការអប់រំសម្រាប់សិស្សម្នាក់ៗ (IEP)

ខ.  បន្ទាប់មក ពួកគេអានករណីសិក្សារបស់វ៉ានី[96]

គ.  បន្តអានផែនការអប់រំសម្រាប់វ៉ានី

ឃ. ពិភាក្សាក្រុម ដើម្បីបង្កើតផែនការអប់រំសម្រាប់សុខនី ដែលជាករណីសិក្សានៅទំព័របន្ទាប់

ង.  តំណាងក្រុមរាយការណ៍

ច. សំយោគ។

**គោលការណ៍គ្រឹះនៃផែនការអប់រំសម្រាប់សិស្សម្នាក់ៗ**




[96] កែសម្រួលពី DAC (២០០៣) ការបណ្តុះបណ្តាលការអប់រំបរិយាបន្នទៅកម្ពុជា មេរៀនទី៤

## ផែនការអប់រំសម្រាប់សិស្សម្នាក់ៗ (IEP)

ការរៀបចំផែនការអប់រំសម្រាប់សិស្សម្នាក់ៗគឺជាដំណើរការជានិរន្តរ៍ ហើយវាជាការអនុវត្តដែលល្អក្នុងការប្រើប្រាស់វាសម្រាប់កុមារទាំងអស់ដែលត្រូវការការគាំទ្របន្ថែម ដើម្បីឱ្យគ្រូបង្រៀនអាចតាមដានការរីកចម្រើន។ វាចាប់ផ្តើមជាមួយការពិចារណាចំណុចខ្លាំងរបស់កុមារ សេចក្តីត្រូវការរបស់ពួកគេ អ្វីដែលពួកគេចូលចិត្ត មិនចូលចិត្ត និងបំណងប្រាថ្នារបស់ពួកគេ និងប្រើប្រាស់ចំណុចទាំងនេះ ដើម្បីបង្កើតគោលបំណងនៃការរៀននៅក្នុងមុខវិជ្ជាផ្សេងៗ។ កុមារ ឪពុកម្តាយរបស់គេ គ្រូបង្រៀន អ្នកវិជ្ជាជីវៈពាក់ព័ន្ធផ្សេងទៀត មិត្តភក្តិ និងនៅពេលខ្លះបងប្អូនត្រូវចូលរួមនៅក្នុងការបង្កើតគោលដៅនៃការរៀនរួម។ ការធ្វើបែបនេះផ្តល់រូបភាពពិតប្រាកដនៃកុមារ និងអ្វីដែលពួកគេចង់សម្រេចបាន។

**គោលបំណង៖**

គោលបំណងសំខាន់នៃ IEP គឺផ្តល់គម្រោងមួយសម្រាប់គ្រូបង្រៀន និងឪពុកម្តាយ ដើម្បីបង្កើតនិងរៀបចំផែនការកម្មវិធីរៀនសម្រាប់សិស្សម្នាក់។ វាផ្តល់នូវសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរនូវអ្វីដែលកុមារនឹងរៀននៅក្នុងសាលារៀន និងរបៀបដែលកុមារនោះនឹងរៀន។ សម្ភារៀនបន្ថែម ឧបករណ៍ជំនួយ និងការកែសម្រួលដែលចាំបាច់សម្រាប់កុមារត្រូវបានដាក់បញ្ចូលនៅក្នុង IEP និងផ្សារភ្ជាប់ទៅនឹងកម្មវិធីសិក្សា។

**ការពិនិត្យឡើងវិញ៖**

IEP ត្រូវពិនិត្យឡើងវិញរៀងរាល់៦ខែម្តង និងល្អបំផុតរៀងរាល់៤ខែម្តង។ ការធ្វើបែបនេះអាចធ្វើការកែប្រែ និងកែតម្រូវប្រសិនបើកុមារត្រូវការយុទ្ធវិធីរៀនផ្សេង ដើម្បីសម្រេចគោលបំណងនៅក្នុងIEP។ ឧទាហរណ៍ពេលខ្លះគោលបំណងត្រូវផ្លាស់ប្តូរ ប្រសិនបើកុមារបានសម្រេចគោលបំណងរៀនទាំងអស់ និងតម្រូវឱ្យបង្កើតគោលបំណងថ្មី។ ការពិនិត្យឡើងវិញជានិរន្តរ៍ធ្វើឱ្យវាក្លាយជាឯកសាររស់រវើក។

**ការចូលរួមរបស់ឪពុកម្តាយ៖**

IEP ដើរតួសំខាន់សម្រាប់ឪពុកម្តាយ ដើម្បីទទួលបានព័ត៌មានអំពីអ្វីដែលកូនរបស់ពួកគេកំពុងរៀននៅសាលារៀន និងតើគេរៀនបានល្អប៉ុណ្ណា។ ជាធម្មតា កិច្ចប្រជុំជាប្រចាំជាមួយគ្រូបង្រៀនអាចឱ្យឪពុកម្តាយបន្តចូលរួមនៅក្នុងការអប់រំកូន។ ការកត់ត្រាស្នាដៃ ក៏ជាកត្តាជំរុញសម្រាប់កុមារផងដែរ។

## ករណីសិក្សារបស់សុខនី[97]

សុខនីមានអាយុ៥ឆ្នាំ។ នាងមានជំងឺខូចប្រព័ន្ធបញ្ជាចលនាសាច់ដុំខួរក្បាល (cerebral palsy) ដែលបានធ្វើឱ្យប៉ះពាល់ដល់ការនិយាយ និងការធ្វើចលនារបស់នាង។ ប្រសិនបើមិនមានជំងឺនេះទេ នាងមានភាពឆ្លាតវៃ។ គ្រួសារ និងអ្នកជិតខាងដឹងថានៅផ្ទះនាងអាចប្តូរប៉ុស្តិ៍ទូរទស្សន៍ និងប្រាស្រ័យទាក់ទងដោយប្រើប្រាស់សំឡេង ដែលនាងអាចបញ្ចេញបាន។ បុគ្គលិករបស់មូលនិធិកុមារពិការដឹងថា សុខនីអាចរៀនជាមួយកុមារដែលមានអាយុដូចគ្នាជាមួយនឹងនាង។ ជាមួយការគាំទ្ររបស់ពួកគេ នាងត្រូវបានផ្តល់រទេះរុញ និងអាចទៅសាលារៀនបាន។ គ្រូបង្រៀនរបស់នាងមិនដឹងពីរបៀបជួយនាងនោះទេ ដូច្នេះការបណ្តុះបណ្តាលត្រូវបានផ្តល់ឱ្យដោយមូលនិធិកុមារពិការ។ សុខនីត្រូវការទទួលបានមេរៀនទាំងអស់នៅក្នុងសាលារៀន។ គ្រូបង្រៀនត្រូវប្រើប្រាស់សម្ភារៈបង្រៀន និងរៀនជារូបភាពសម្រាប់នាង។

[97] ករណីសិក្សាផ្តល់ដោយមូលនិធិកុមារពិការ

## ផែនការអប់រំសម្រាប់សិស្ស  ហេង វ៉ានី

*វ៉ានីមានអាយុ៦ឆ្នាំ។ នាងទើបតែចូលរៀននៅសាលារៀន។ នាងអង្គុយនៅផ្នែកខាងក្រោយថ្នាក់រៀន និងកាន់សៀវភៅអានកៀកទៅនឹងមុខនាង ។ ជាញឹកញាប់ នាងដើរបុកគុ។ នៅពេលសិស្សដទៃកំពុងរៀនគណិតវិទ្យា វ៉ានីមិនចូលរួម ពីព្រោះលំហាត់ ត្រូវបានសរសេរនៅលើក្ដារខៀន។ ឥឡូវនាងមិនស្ថិតនៅក្នុងកម្រិតយល់ដឹងដូចគ្នាជាមួយសិស្សដទៃនោះទេ។*

| | |
|---|---|
| **ឈ្មោះ:** ហេង វ៉ានី<br>**អាយុ:** ៦ឆ្នាំ<br>**ថ្នាក់ទី:** ១ | **ការពិពណ៌នាតម្រូវការក្នុងការរៀន**<br>វ៉ានីមិនចូលរួមនៅក្នុងមេរៀនគណិតវិទ្យា។ នាងតាមមិនទាន់មិត្តរួមថ្នាក់របស់នាង។ នាងអាចមានបញ្ហាមើល។ |
| កាលបរិច្ឆេទវាយតម្លៃ | ថ្ងៃទី៥ ខែមេសា ឆ្នាំ២០០១ |

| គោលបំណង | ផែនការសកម្មភាព | កាលបរិច្ឆេទគោលដៅ | ការវាយតម្លៃ |
|---|---|---|---|
| វ៉ានីនឹងចូលរួមរៀននៅក្នុងមេរៀនគណិតវិទ្យា | - វ៉ានីនឹងអង្គុយនៅជួរខាងមុខនៃថ្នាក់រៀន ឬកន្លែងសមស្រប<br>- គ្រូបង្រៀននឹងសរសេរលេខធំៗ និងអានលំហាត់ឱ្យឮ<br>- វ៉ានីនឹងត្រូវបានផ្ដល់វត្ថុតូចៗ ដែលនាងអាចប៉ះបាន ដើម្បីរាប់លេខ (ឧ. ដុំថ្មតូចៗ)<br>- គ្រូបង្រៀននឹងនិយាយជាមួយឪពុកម្ដាយរបស់វ៉ានី និងណែនាំឱ្យនាំវ៉ានីទៅគ្លីនីកភ្នែកដែលនៅជិតផ្ទះបំផុត ដើម្បីទទួលការពិនិត្យ ភ្នែក<br>- គ្រូបង្រៀននឹងដាក់វ៉ានីឱ្យអង្គុយក្បែរសិស្សដែលពូកែគណិតវិទ្យា។ សិស្សនោះនឹងជួយអានលំហាត់ឱ្យឮ។ | នៅក្នុងរយៈពេល៣ខែ (ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០១) វ៉ានីនឹងចូលរួមនៅក្នុងមេរៀនគណិតវិទ្យា | ថ្ងៃទី១៥ ខែឧសភា វ៉ានីបានទៅពិនិត្យភ្នែកហើយ គ្រូពេទ្យនិយាយថា នាងមានបញ្ហាមើល និងត្រូវការវ៉ែនតា។<br>ថ្ងៃទី១០ ខែមិថុនា ឪពុកម្ដាយរបស់វ៉ានីទិញវ៉ែនតាឱ្យនាង។<br>ថ្ងៃទី២០ ខែមិថុនា វ៉ានីបានប្រើប្រាស់វ៉ែនតា។ នាងលែងដើរបុកគុកៅអីទៀតហើយ។<br>ថ្ងៃទី០៥ ខែកក្កដា វ៉ានីចូលរួមនៅក្នុងមេរៀនគណិតវិទ្យាប៉ុន្តែនៅតាមពីក្រោយមិត្តភក្តិរបស់នាង។ នាងត្រូវការជំនួយបន្ថែម។ |

## ផែនការអប់រំសម្រាប់សិស្សម្នាក់ៗ (ចម្លើយរំពឹងទុកសម្រាប់ករណីសិក្សារបស់សុខនី)

| | |
|---|---|
| សេចក្តីសង្ខេបនៃសេចក្តីត្រូវការ៖ សុខនីត្រូវការទៅសាលារៀន នាងត្រូវការមិត្តភក្តិជួយរុញរទេះរុញរបស់នាងនៅក្នុងថ្នាក់រៀន។ គ្រូបង្រៀន ត្រូវបង្កើតសម្ភារបង្រៀន និងរៀនជារូបភាព ដើម្បីឱ្យនាងអាចបង្ហាញថានាងយល់។ នាងអាចប្រើប្រាស់ដៃរបស់នាងចង្អុលចម្លើយត្រឹមត្រូវ និងនៅពេលគ្រូបង្រៀន និងមិត្តភក្តិយល់សំឡេងរបស់នាង នាងគួរអាចប្រើប្រាស់សំឡេងដើម្បីប្រាស្រ័យទាក់ទង។ | |
| ឈ្មោះ៖ សុខនី<br>អាយុ៖ ៥ឆ្នាំ<br>ថ្នាក់ទី៖ ១ | **ការពិពណ៌នាសេចក្តីត្រូវការរៀន៖** សម្ភារបង្រៀន និងរៀនជារូបភាព សៀវភៅប្រាស្រ័យទាក់ទង សម្ភារបង្រៀន និងរៀនដែលនាងអាចប្រើប្រាស់ |
| កាលបរិច្ឆេទវាយតម្លៃ | |

| គោលបំណង | ផែនការសកម្មភាព | កាលបរិច្ឆេទគោលដៅ | ការវាយតម្លៃ |
|---|---|---|---|
| រៀនតួអក្សរ<br><br>រៀនរាប់លេខពី១ ដល់ ១០<br><br>អាចផ្លាស់ទីនៅក្នុងថ្នាក់រៀន ។ល។ | គ្រូបង្រៀនត្រូវការរៀបចំសម្ភារបង្រៀន និងរៀនជាមួយរូបភាព ប័ណ្ណពាក្យចាប់ផ្តើមជាមួយតួអក្សរកំពុងរៀន។<br>គ្រូបង្រៀនត្រូវការផលិតសម្ភារបង្រៀន និងរៀន ដែលនាងអាចកាន់បានដុំគ្រួស សម្រាប់រាប់គម្របដប ។ល។<br>មិត្តភក្តិដែលអាចរុញរទេះរុញរបស់សុខនី | | |

# មេរៀនទី១៧  វិន័យវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព





© Michael Pitt

## សកម្មភាព ១៧.១ ការបង្កើនការយល់ដឹងពីទណ្ឌកម្មរាងកាយ

**រយៈពេល៖ ២០នាទី**

**វត្ថុបំណង៖**

- ប្រាប់បានពីទណ្ឌកម្មរាងកាយផ្ទុយនឹងច្បាប់នៅក្នុងប្រទេសកម្ពុជា
- កំណត់បានអំពីនិយមន័យទណ្ឌកម្មរាងកាយ។

**សម្ភារបង្រៀន និងរៀន៖**

- ផ្ទាំងនិយមន័យនៃទណ្ឌកម្មរាងកាយ ដែលរួមមានការធ្វើទុក្ខទោសរាងកាយ និងផ្លូវចិត្ត។

**សកម្មភាពបង្រៀន៖**

ក.សួរសំណួរបំផុស

តើអ្វីជាទណ្ឌកម្មរាងកាយ ?

ខ. ឱ្យគរុសិស្សអានតារាងខាងក្រោម[98]ដើម្បីអភិវឌ្ឍការយល់ដឹងឱ្យកាន់តែស៊ីជម្រៅ៖

ទណ្ឌកម្មរាងកាយគឺជាទណ្ឌកម្មណាដែលកម្លាំងរាងកាយត្រូវបានប្រើ ដើម្បីបង្កការឈឺចាប់។

- ទះកំផ្លៀង
- ទះស្រាលៗ
- ដាល់
- វាយដោយវត្ថុផ្សេងៗ
- ទាញត្រចៀក ឬសក់
- បង្ខំឱ្យកុមារស្ថិតនៅជំហរមួយពិបាកទ្រាំ
- បង្ខំឱ្យកុមារឈរនៅក្រោមកម្ដៅ ឬត្រជាក់ខ្លាំង
- ដាក់កុមារទៅក្នុងទូរដាំន ឬទូរចាន
- ...

ទណ្ឌកម្មរាងកាយក៏ជាទណ្ឌកម្មផ្លូវចិត្ត ដែលមិនប៉ះពាល់រាងកាយផងដែរ៖

- គំរាម
- ស្រែក
- ធ្វើឱ្យអាម៉ាស់មុខ
- ចំអក
- ជេរប្រមាថ
- មិនអើពើ ឬដាក់ឱ្យនៅម្នាក់ឯង
- ធ្វើឱ្យខ្មាសគេ
- លម្អៀង
- ...

[98] ដកស្រង់ពីសេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល ស្តីពីវិន័យបែបវិជ្ជមាន និងទណ្ឌកម្មរាងកាយប្រកបដោយប្រសិទ្ធភាពរបស់ MoEYS ទំព័រ២១

## សកម្មភាព ១៧.២ ការយល់ដឹងភាពខុសគ្នារវាងទណ្ឌកម្ម និងវិន័យ

## រយៈពេល៖ ៤៥នាទី

## វត្ថុបំណង ៖

- កំណត់បានភាពខុសគ្នារវាងទណ្ឌកម្ម និងវិន័យ។

## សម្ភារបង្រៀន និងរៀន៖

- ករណីសិក្សា សេណារីយ៉ូ មុន និងក្រោយ[99]

## សកម្មភាពបង្រៀន៖

ក.ឱ្យគុសិស្សអានករណីសិក្សា(សេណារីយ៉ូទាំងពីរ)

ខ.ឱ្យពួកគេកំណត់ តើលក្ខណៈវិជ្ជមានអ្វីនៃតារាងមានចំណងជើង "ភាពខុសគ្នារវាងវិន័យ និងទណ្ឌកម្ម" ដែលប៊ុនថេងប្រើប្រាស់ ដើម្បីកែប្រែអាកប្បកិរិយារបស់សុធា។

### អាកប្បកិរិយារបស់សុធាមុនអន្តរាគមន៍

"ខ្ញុំនឹងមិនទៅថ្នាក់របស់លោកហ្នឹងទេ! ខ្ញុំមិនចាំបាច់ត្រូវធ្វើអ្វីដែលអ្នកនិយាយនោះទេ!" ពួកគេបាននិយាយថា៖ ខ្ញុំពិការក្នុងការរៀន និងមានជំងឺ ADHD ស្អីគេនោះ"។ [ADHD គឺ Attention Deficit Hyperactivity Disorder]។

នៅពេលព្រឹកសុធារត់លើផ្លូវក្នុងសាលារៀនបុកកុមារដទៃនិងគ្រូបង្រៀន ដើរចូលទៅក្នុងថ្នាក់រៀននិយាយអំពីអ្វីដែលវានឹងមិនធ្វើ និងស្រែកឬរត់នៅជុំវិញថ្នាក់រៀននៅពេលវាចង់។ វាហៅមិត្តរួមថ្នាក់ថាជាសមាជិកក្រុមល្ងីល្ងើ និងជេរកុមារថ្នាក់ទីប្រាំមួយថាប្រព្រឹត្តិអំពើដែលខ្ញុំមិនដែលឮ រហូតដល់ខ្ញុំរៀនវិទ្យាល័យបានបីឆ្នាំ។ ប៊ុនថេងបាននិយាយថា "ខ្ញុំខឹងនឹងអាកប្បកិរិយារបស់វា។ ខ្ញុំចង់ស្អប់វាប៉ុន្តែខ្ញុំខកចិត្តនឹងវា ការខ្វះខាតជំនាញរបស់ខ្ញុំ និងប្រព័ន្ធអប់រំនេះ ខ្ញុំបានចេញពីសាលារៀននៅថ្ងៃនោះទាំងទឹកភ្នែក និងឈឺចាប់ដោយសារកុមារម្នាក់នេះ"។

សប្តាហ៍ថ្មីបានចាប់ផ្តើមដូចគ្នាទៅនឹងសប្តាហ៍មុន។ សុធានៅបន្តអាកប្បកិរិយារំខាន មិនគោរពវិន័យ និងធ្វើឱ្យអ្នកគ្រប់គ្នាស្ទើរតែឆ្កួត។ ប៉ុន្តែខ្ញុំបានគិតយ៉ាងច្រើនអំពីសុធានៅចុងសប្តាហ៍នេះ។ ខ្ញុំបានចាប់ផ្តើមគិតអំពីរបៀបដែលវាធ្វើឱ្យខ្ញុំមានអារម្មណ៍ជ្រុលជ្រួសដែលបង្ហាញឡើងនូវការខឹងសម្បារ និងក្តៅក្រហាយ។ យោងតាមសៀវភៅវិន័យសហការ អារម្មណ៍ដែលយើងមាននៅពេលសិស្សធ្វើសកម្មភាពមិនត្រឹមត្រូវផ្តល់ឱ្យយើងនូវតម្រុយអំពីគោលបំណងសិស្សសម្រាប់អាកប្បកិរិយាមិនល្អនោះ។ នៅពេលដែលយើងយល់ ហេតុអ្វីសិស្សនោះធ្វើអ្វីដែលវាកំពុងតែធ្វើ វានឹងងាយស្រួលដើម្បីរកមធ្យោបាយដោះស្រាយជាមួយវា។

---

[99] កែសម្រួលពីវិន័យវិជ្ជមាន នៅក្នុងថ្នាក់រៀនបរិយាបន្ន និងកុមារមេត្រី ដោយអង្គការ UNESCO ទំព័រ ៨-២៤

## អាកប្បកិរិយារបស់សុធាអំឡុងពេល និងក្រោយពេលអន្តរាគមន៍

ប៊ុនថេងបាននិយាយថា "ខ្ញុំបានដោះស្រាយបញ្ហានៅព្រឹកថ្ងៃពុធ ទោះបីសុធាធ្វើអ្វីក៏ដោយ ខ្ញុំនឹងមិនយកចិត្តទុកដាក់អាកប្បកិរិយាមិនល្អរបស់វានោះទេ។ ខ្ញុំនឹងមិនអើពើនឹងវា។ នៅពេលដែលវាចូលថ្នាក់រៀនយឺត១០នាទី ខ្ញុំធ្វើពើថាវាមិនបានចូលថ្នាក់រៀន។ សុធាធ្វើអ្វីៗទាំងអស់ លើកលែងតែស្រាតនៅម៉ោងរៀន។ វារត់ចុះឡើងនៅលើផ្លូវដើរ លេងសក់កុមារដទៃ ដើរសំដៅទៅទ្វារហាក់បីដូចវានឹងដើរចេញទៅក្រៅ និងថែមទាំងឡើងលើកៅអី។ ខ្ញុំមិនបាននិយាយអ្វីទាំងអស់។ សិស្សក្នុងថ្នាក់ទាំងអស់មើលមកខ្ញុំហាក់បីដូចជាខ្ញុំជាមនុស្សឆ្កួត។ ខ្ញុំបានពន្យល់ពួកគេថា ការងាររបស់យើងសំខាន់ជាងមិនត្រូវបង្អាក់ដោយអ្នកដែលមិនចង់រៀននោះទេ ដូច្នេះត្រូវបន្តរៀនធម្មតា។ ខ្ញុំសឹងតែថើបសិស្សគ្រប់គ្នាដែលទោះបីសុធាព្យាយាមរំខានពួកគេយ៉ាងណាក៏ដោយក៏ពួកគេមិនអើពើសកម្មភាពប៉ផ្លិចប៉ផ្លូចរបស់វាដែរ ។

អាកប្បកិរិយារបស់សុធាកាន់តែអាក្រក់ឡើង។ ពេញមួយម៉ោងរៀន សុធាសុំខ្ញុំទៅបន្ទប់ទឹក ទៅការិយាល័យជំនួយការនាយកសាលា និងទៅគុសន្តិសុខជាបន្តបន្ទាប់។ ខ្ញុំបន្តមិនអើពើ។ បន្ទាប់មករឿងអស្ចារ្យមួយបានកើតឡើង។ ជំនួសឱ្យការដើរចេញក្រៅវាអង្គុយចុះ។ នៅចុងម៉ោងពេលដែលខ្ញុំហៅឈ្មោះសិស្សឱ្យទៅផ្ទះ វាបានដើរមកកាន់ខ្ញុំ និងនិយាយថា "តើខ្ញុំអាចទៅដែរបានទេ? វារង់ចាំ នៅពេលដែលខ្ញុំហៅឈ្មោះសិស្សដទៃ វាសុំទៅ ប៉ុន្តែមិនចេញពីថ្នាក់រៀនរហូតដល់ខ្ញុំអនុញ្ញាតឱ្យ។

នៅថ្ងៃព្រហស្បតិ៍ សុធាមករៀនទាន់ពេល មានក្រដាស ខ្មៅដៃ និងសៀវភៅ។ វាអង្គុយចុះដោយស្ងៀមស្ងាត់ និងលើកដៃដើម្បីសួរសំណួរ។ នៅក្នុងរយៈពេលរៀនទាំងមូល វាមិនបានដើរចេញពីកៅអី ឬនិយាយ ដោយគ្មានការអនុញ្ញាត។ វារពឹសបន្តិច ប៉ុន្តែខ្ញុំយល់អំពីការលំបាក ដែលវាត្រូវអង្គុយនៅស្ងៀម។ វាមិនបានធ្វើកិច្ចការដែលដាក់ឱ្យនោះទេ ប៉ុន្តែខ្ញុំគិតថា ការគ្រប់គ្រងអាកប្បកិរិយារបស់ខ្លួនឯងគឺជាកិច្ចការសម្រាប់សុធា។

*<u>ដំណោះស្រាយរបស់ប៊ុនថេង</u>*៖ បានធានាថា គាត់បានឱ្យសិស្សផ្សេងទៀតមិនអើពើអាកប្បកិរិយារបស់សុធា។ សិស្សផ្សេងទៀតមិនអើពើអាកប្បកិរិយារបស់សុធាមិនមែនមិនអើពើសុធានោះទេ។ សម្រាប់កុមារទូទៅការទទួលបានប្រតិកម្មតបមកវិញពីមិត្តភក្តិមានសារៈសំខាន់ ដូច្នេះហើយនៅពេលវាមិនទទួលបានប្រតិកម្មតអ្វីសោះ វាបានបញ្ឈប់អាកប្បកិរិយាដែលបង្កការរំខាន និងមិនមានប្រយោជន៍សម្រាប់វា ដោយសារវាមិនទទួលបានការចាប់អារម្មណ៍អ្វីសោះ។ អាកប្បកិរិយាវិជ្ជមានរបស់វាទៅវិញនោះទេ ដែលត្រូវទទួលបានការចាប់អារម្មណ៍ ហើយវាត្រូវបានអនុញ្ញាតឱ្យទៅនៅពេលសុំទៅ និងរង់ចាំវេនរបស់វា។

## ភាពខុសគ្នារវាងវិន័យ និងទណ្ឌកម្ម

| វិន័យគឺ៖ | ទណ្ឌកម្មគឺ៖ |
|---|---|
| ផ្តល់ជម្រើសវិជ្ជមានដល់កុមារ | គ្រាន់តែប្រាប់កុំឱ្យធ្វើអ្វីមួយ |
| ទទួលស្គាល់ ឬផ្តល់រង្វាន់ដល់កិច្ចប្រឹងប្រែង និង អាកប្បកិរិយាល្អ | ប្រតិកម្មធ្ងន់ធ្ងរទៅនឹងអាកប្បកិរិយាមិនល្អ |
| កុមារគោរពវិន័យ ពីព្រោះពួកគេត្រូវបានពិភាក្សា និងយល់ព្រមធ្វើតាម | កុមារគោរពវិន័យ ពីព្រោះពួកគេត្រូវបានគំរាម ឬផ្តល់សំណូក |
| ចិតថេរ ការណែនាំម៉ឺងម៉ាត់ | ត្រួតត្រា បំបាក់មុខ ចំអក |
| វិជ្ជមាន គោរពកុមារ | អវិជ្ជមាន និងមិនគោរពកុមារ |
| មិនមានហឹង្សាទាំងរាងកាយ និងពាក្យសម្តី | ហឹង្សាទាំងរាងកាយ និងពាក្យសម្តីនិងទ្រគោះបោះបោក |
| លទ្ធផលសមហេតុផល ដែលទាក់ទងផ្ទាល់ទៅ នឹងអាកប្បកិរិយាមិនល្អ | លទ្ធផលមិនសមហេតុផល និងមិនទាក់ទងទៅនឹង អាកប្បកិរិយាមិនល្អ |
| នៅពេលកុមារត្រូវធ្វើការកែប្រែ នៅពេលអាកប្ប កិរិយារបស់គេប៉ះពាល់ដោយអវិជ្ជមានដល់អ្នកដទៃ | នៅពេលកុមារត្រូវបានដាក់ទណ្ឌកម្មសម្រាប់ការធ្វើបាប អ្នកដទៃជាជាងបង្ហាញពីរបៀបធ្វើការកែប្រែ |
| ស្វែងយល់សមត្ថភាព សេចក្តីត្រូវការ ស្ថានភាព និងដំណាក់កាលអភិវឌ្ឍកុមារ | ស្ថានភាព សមត្ថភាព និងសេចក្តីត្រូវការរបស់កុមារ មិនត្រូវបានយកមកពិចារណា |
| បង្រៀនកុមារឱ្យមានវិន័យផ្ទាល់ខ្លួន | បង្រៀនឱ្យកុមារមានអាកប្បកិរិយាល្អ បើមិនដូចនេះ នឹងអាចត្រូវទណ្ឌកម្ម នៅពេលមានអាកប្បកិរិយាមិនល្អ |
| ស្តាប់ និងធ្វើជាគំរូ | ស្តីបន្ទោសកុមារជាប្រចាំ សម្រាប់ការធ្វើខុសតិចតួច ធ្វើឱ្យពួកគេមិនអើពើ និងមិនស្តាប់ |
| ប្រើប្រាស់កំហុសជាឱកាសក្នុងការរៀន | បង្ខំកុមារឱ្យគោរពតាមវិន័យមិនសមហេតុផល "ពីព្រោះតែអ្នកនិយាយអញ្ចឹង" |
| ផ្តោតតែលើអាកប្បកិរិយាជាជាងលើកុមារ | រិះគន់កុមារជាជាងអាកប្បកិរិយារបស់កុមារ ៖ អ្នកឯងល្ងីល្ងើ អ្នកឯងខុស |

# មេរៀនទី១៨ ការវាយតម្លៃដោយសមធម៌





© Michael Pitt

## សកម្មភាព ១៨.១ ពន្យល់ការវាយតម្លៃដោយសមធម៌[100]

### រយៈពេល៖ ៣០នាទី

### វត្ថុបំណង ៖

- កំណត់បានពីមូលហេតុដែលយើងត្រូវការប្រព័ន្ធវាយតម្លៃដោយសមធម៌។

### សម្ភារបង្រៀន និងរៀន៖

- រូបភាពតុក្កតា ដើម្បីចាប់ផ្តើមការពិភាក្សា
- ករណីសិក្សា

### សកម្មភាពបង្រៀន៖

ក.បង្ហាញរូបភាពតុក្កតាទៅកាន់គរុសិស្ស។ ឱ្យពួកគេប្រាប់អំពីអ្វីដែលពួកគេយល់ពីរូបភាពតុក្កតានេះ។
ខ.អានករណីសិក្សា និងឱ្យពួកគេស្វែងរកដំណោះស្រាយសម្រាប់សុខុម។




[100] កែសម្រួលពីមេរៀនបណ្តុះបណ្តាលគ្រូបង្រៀនរបស់ Sandrine Bohan-Jacquot សម្រាប់ប្រទេសស៊ូដង់ខាងត្បូង ទំព័រ ១២៨-១៣២

## ករណីសិក្សារបស់សុខុម

សុខុមយំ ពីព្រោះនាងធ្លាក់ការប្រឡងថ្នាក់ទី៣។ នាងទទួលបានពិន្ទុយ៉ាងល្អនៅឆមាសចុងក្រោយ ពីព្រោះនាងបានខិតខំយ៉ាងខ្លាំងពេញមួយឆ្នាំ។

បីសប្តាហ៍មុនពេលប្រឡងបញ្ចប់ ម្តាយរបស់នាងធ្លាក់ខ្លួនឈឺ ហើយសុខុមត្រូវមើលថែរក្សាម្តាយ និងប្អូនរបស់នាង។ នាងត្រូវចម្អិនអាហារ សម្អាត និងទទួលខុសត្រូវ ដើម្បីធានាថាម្តាយ និងប្អូនរបស់នាងមានអ្វីៗ ដែលពួកគេត្រូវការ។ នេះមានន័យថា នាងមិនអាចទៅសាលារៀន ហើយវាគឺជាពេលវេលាសំខាន់ ដែលមិត្តរួមថ្នាក់របស់នាងកំពុងត្រៀមខ្លួនសម្រាប់ការប្រឡង និងនៅពេលខ្លះពួកគេរំឭកមេរៀនជាមួយគ្នា និងដោយខ្លួនឯង។

យប់មុនថ្ងៃប្រឡង សុខុមមិនបានគេងពេញមួយយប់ ពីព្រោះម្តាយរបស់នាងឈឺកាន់តែខ្លាំង។ ដូច្នេះ ទោះបីសុខុមបានទៅប្រឡងក៏នាងមិនអាចផ្តោតអារម្មណ៍ ដោយសារនាងហត់នឿយខ្លាំង។ នាងដឹងចម្លើយច្រើន ប៉ុន្តែដោយសារភាពហត់នឿយ នាងមិនអាចបំពេញសំណួរប្រឡងបាននោះទេ។ នាងបានប្រឡងធ្លាក់។ ឥឡូវនាងមិនចង់ត្រឡប់ទៅសាលារៀនវិញទេ ពីព្រោះនាងអៀនខ្មាសដោយសារប្រឡងធ្លាក់ មិនបានរៀនជាមួយមិត្តភក្តិរបស់នាង និងត្រូវរៀនជាមួយសិស្សក្មេងៗ។

### សំណួរពិចារណា

- តើយុត្តិធម៌ឬទេដែលសុខុមត្រូវរៀនត្រួតថ្នាក់ នៅពេលដែលនាងធ្វើបានល្អនៅក្នុងការប្រឡងឆមាស និងអាចនឹងធ្វើបានល្អផងដែរ នៅក្នុងការប្រឡងបញ្ចប់?
- តើមានវិធីអ្វីផ្សេង ដើម្បីវាយតម្លៃសុខុមនិងកុមារដទៃទៀត ដែលស្ថិតនៅក្នុងស្ថានភាពដូចនាង?

## សកម្មភាព ១៨.២ ការផ្ដល់ដំណោះស្រាយសមស្របអំឡុងពេលប្រឡង[101]

## រយៈពេល៖ ៤៥នាទី

## វត្ថុបំណង៖

- ប្រាប់បានពីឧបសគ្គកុមារពិការជួបប្រទះអំឡុងពេលប្រឡង
- កំណត់បានពីដំណោះស្រាយសមស្រប អំឡុងពេលវាយតម្លៃ ឬពេលប្រឡង។

## សម្ភារបង្រៀន និងរៀន៖

- ផ្ទាំងនិយមន័យនៃដំណោះស្រាយសមស្រប
- ផ្ទាំងដំណោះស្រាយសមស្របនៅទំព័របន្ទាប់

## សកម្មភាពបង្រៀន៖

ក.ពិភាក្សាសំណួរ៖

- តើឧបសគ្គអ្វីខ្លះដែលកុមារពិការ៥ប្រភេទខាងក្រោមជួបប្រទះអំឡុងពេលប្រឡង?

  ១.សិស្សមានបញ្ហាមើល

  ២.សិស្សមានបញ្ហាស្ដាប់

  ៣.សិស្សមានបញ្ហាចលនា (ប្រើប្រាស់រទេះរុញ)

  ៤.សិស្សមានជំងឺ ADHD

  ៥.សិស្សស្នាក់នៅមន្ទីរពេទ្យ

- តើត្រូវសម្របសម្រួលដូចម្ដេច ដែលអាចផ្ដល់សមធម៌ដល់ពួកគេអំឡុងពេលប្រឡង?

ខ. តំណាងក្រុមរាយការណ៍

គ. សំយោគ

## អនុសាសន៍មួយចំនួន៖

ដំណោះស្រាយល្អបំផុតអាចស្វែងរកនៅកម្រិតមូលដ្ឋាន និងប្រសិនបើកុមារ ឪពុកម្ដាយរបស់ពួកគេ នាយកសាលា គណៈកម្មការទ្រទ្រង់សាលា(SSC) និងគ្រូបង្រៀនចូលរួមនៅក្នុងការសម្រេចអ្វីដែលមានប្រសិទ្ធភាពល្អបំផុតសម្រាប់កុមារ។ ដំណើរការទាំងមូលត្រូវតែជាដំណើរការអាចធ្វើទៅបាន។

### និយមន័យនៃដំណោះស្រាយសមស្រប[102]

"ដំណោះស្រាយសមស្រប" មានន័យថាការកែប្រែ និងសម្របសម្រួលចាំបាច់ ដែលមិនជាការដាក់បន្ទុកហួសហេតុនៅក្នុងករណីត្រូវការណាមួយ ដើម្បីធានាដល់ជនពិការនូវការពេញចិត្ត ឬការអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដោយស្មើគ្នាជាមួយអ្នកដទៃ។

---

[101] Ibid ទំព័រ១៣២-១៣៣

[102] និយមន័យដកស្រង់ចេញពី UNCRPD ទំព័រ៤

**អនុសាសន៍មួយចំនួនសម្រាប់ដំណោះស្រាយនៅមូលដ្ឋាន៖**

**សិស្សមានបញ្ហាមើល**អាចទទួលបានប្រយោជន៍ពី៖

- ត្រូវធានាថា ការចូលទៅកាន់ទីកន្លែងប្រឡងងាយស្រួល និងមានសុវត្ថិភាព។
- ត្រូវធានាថា មានអ្នកជួយឬអ្នកនាំផ្លូវ ប្រសិនបើសិស្សនោះមិនស្គាល់ទីកន្លែង ឬត្រូវការគាំទ្រសម្រាប់ការ ណែនាំផ្លូវ។
- បកប្រែវិញ្ញាសាប្រឡងជាអក្សរប្រៃយ៍ និងត្រៀមអ្នកកែកិច្ចការប្រឡងអាចអានអក្សរប្រៃយ៍បាន ប្រសិនបើ សិស្សពិការភ្នែក ឬសរសេរអក្សរធំ និងមានកែវពង្រីក ប្រសិនបើសិស្សខ្សោយគំហើញ។
- ត្រូវធានាថាមានវត្តមានអ្នកអាន ដែលអាចអានសំណួរ និងសរសេរចម្លើយ ដែលសិស្សផ្តល់ឱ្យដោយផ្ទាល់មាត់របស់សិស្ស។ ត្រូវចងចាំថា អ្នកអាន អ្នកសរសេរត្រូវការ ការណែនាំមួយចំនួន និងការអនុវត្តបំពេញមុខងារនេះ។
- ត្រូវធានាថា មានរូបភាពនៅក្នុងការប្រឡងហើយរូបភាពត្រូវបានពន្យល់ឱ្យបានច្បាស់ទៅកាន់ សិស្ស ឬផលិតឡើង វិញជាសម្ភារដែលសិស្សអាចដឹងបាន។
- ផ្តល់ពេលវេលាបន្ថែម។

**សិស្សប្រើប្រាស់រទេះរុញ** អាចទទួលបានប្រយោជន៍ពី៖

- ពិនិត្យមើលភាពងាយស្រួលនៃអគារ។
- រៀបចំការប្រឡងនៅជាន់ផ្ទាល់ដី។
- រៀបចំជម្រាល ប្រសិនបើអគារមិនមាន។
- ឱ្យសិស្សអង្គុយនៅកន្លែងដែលពួកគេចង់អង្គុយ។
- ផ្តល់ពេលឈប់សម្រាក ដោយមានការត្រួតពិនិត្យ។

**សិស្សមានបញ្ហាស្តាប់** អាចទទួលបានប្រយោជន៍ពី៖

- ផ្តល់អ្នកបកប្រែភាសាសញ្ញា (ផ្អែកតាមកម្រិតធ្ងន់ធ្ងរនៃពិការភាពសោតវិញ្ញាណ)។
- ធានាផ្តល់កៅអីនៅជួរមុខ ដើម្បីឱ្យសិស្សយល់ការណែនាំទាំងអស់ក្នុងស្ថានភាពល្អ។
- ផ្តល់ពេលវេលាបន្ថែម។
- ប្រសិនបើអាច អនុញ្ញាតឱ្យឆ្លើយដោយនិយាយ (នៅក្នុងភាសាសញ្ញា) ជាជាងការសរសេរ។
- ប្រសិនបើមិនមែនជាប្រធានបទប្រឡងមិនត្រូវគិតពីការប្រកបអក្សរ (ហើយដកពិន្ទុ) ពីព្រោះកុមារពិការ សោតវិញ្ញាណមានការពិបាកច្រើនក្នុងការប្រកបអក្សរ។
- ប្រើប្រាស់រូបភាពឱ្យបានច្រើនបំផុត ដើម្បីជួយដល់ការយល់ដឹងរបស់សិស្ស ។

**សិស្សមានជំងឺ ADHD** អាចទទួលបានប្រយោជន៍ពី៖

- ធានាថាបន្ទប់ប្រឡងស្ងាត់។
- ពិភាក្សាជាមួយអ្នកវិជ្ជាជីវៈ គ្រូបង្រៀន អ្នកព្យាបាលជាមុន ដើម្បីប្រមើលមើលការពិបាករបស់សិស្សដែលអាចមាន និងកំណត់ការឆ្លើយតបដែលល្អបំផុត។
- ស្នើសុំការគាំទ្រពីអ្នកវិជ្ជាជីវៈ ប្រសិនបើអាចជួយសិស្សឱ្យផ្តោតអារម្មណ៍។

- ផ្តល់ពេលវេលាបន្ថែម។
- អនុញ្ញាតឱ្យសិស្សផ្លាស់ទីនៅក្នុងថ្នាក់រៀន ប្រសិនបើចាំបាច់។
- អនុញ្ញាតឱ្យសម្រាក ប្រសិនបើចាំបាច់។

**សិស្សដែលឈឺ និងចូលសម្រាកនៅមន្ទីរពេទ្យ** អាចទទួលបានប្រយោជន៍ពី៖

- ពិនិត្យមើលថា តើការប្រឡងអាចពន្យារពេល សម្រាប់សិស្សនោះទេ។
- ពិភាក្សា ដើម្បីឱ្យសិស្សប្រឡងនៅមន្ទីរពេទ្យ ក្រោមការត្រួតពិនិត្យ។
- ផ្តល់ការប្រឡងពីចម្ងាយ។

**អនុសាសន៍ទូទៅ**

- សិស្សពិការត្រូវទទួលបានការកែតម្រូវការវាយតម្លៃសមស្រប ផ្អែកតាមសេចក្តីត្រូវការរបស់ពួកគេ (ឧ. ការផ្តល់ពេលវេលាបន្ថែម ការសរសេរអក្សរប្រែយ៍ បុគ្គលិកជំនួយសម្រាប់ការអាន ឬសរសេរក្នុងការប្រឡង ការផ្លាស់ប្តូរបន្ទប់ប្រឡង វិធីឆ្លើយសំណួរដោយជម្រើសផ្សេងដូចជា ឆ្លើយផ្ទាល់មាត់ជំនួសឱ្យការសរសេរ ។ល។
- គួរមានភាពបត់បែន ដើម្បីជានាភាពងាយស្រួលសម្រាប់សិស្ស និងគ្រូបង្រៀនពិការ។
- សិស្ស គ្រូបង្រៀនត្រូវប្រាប់សាលារៀន នាយកដ្ឋានប្រឡង នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ (TTD) នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានអប់រំពិសេស និងសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត (PTTC) នៅពេលចុះឈ្មោះចូលរៀន ដើម្បីពិភាក្សា ការកែតម្រូវចាំបាច់។
- បែបបទនៃការប្រឡងគួរត្រូវបានពិភាក្សាជាមួយនាយកដ្ឋានប្រឡងជាមុន។
- សុំយោបល់ពីគ្រូបង្រៀនជាមុន ដើម្បីផ្តល់ការកែតម្រូវដែលមានប្រសិទ្ធភាពបំផុត។
- បង្កើតគោលការណ៍ណែនាំសម្រាប់លទ្ធភាពកែតម្រូវ។



© Michael Pitt

# ផ្នែកទី៣
# ការក្លាយខ្លួនជាគ្រូបង្រៀនសកម្ម

# មេរៀនទី១៩ ការរៀនបែបសកម្ម






© Michael Pitt

## សេចក្តីផ្តើមផ្នែកទី៣៖

ឯកសារនេះរៀបរាប់អំពីរបៀបដែលគ្រូបង្រៀនអាចបង្កើតការអប់រំបរិយាបន្ននៅក្នុងការបង្រៀន និងការបង្ហាញបញ្ញត្តិផ្សេងៗ។ ឯកសារនេះផ្តល់ឱ្យគរុសិស្សនូវគំនិតថ្មីៗ និងការយល់ដឹងជាមូលដ្ឋាន ដែលពួកគេអាចបង្រៀន ដោយប្រើប្រាស់វិធីបង្រៀនការអប់រំបរិយាបន្ន ដែលផ្តល់ប្រយោជន៍ដល់កុមារទាំងអស់នៅក្នុងថ្នាក់រៀន។

គោលគំនិតថ្មីៗជាច្រើនត្រូវបានបង្ហាញនៅក្នុងរយៈពេលមួយខ្លី វាអាចគួរឱ្យបារម្ភ ប៉ុន្តែគរុសិស្សត្រូវដឹងផងដែរថា ការក្លាយខ្លួនជាគ្រូបង្រៀនអប់រំបរិយាបន្នត្រូវការពេលវេលាច្រើន ហើយការអនុវត្តវិធីបង្រៀនការអប់រំបរិយាបន្នដែលបានសិក្សាថ្មីៗគឺជាមធ្យោបាយល្អក្នុងការអភិវឌ្ឍ។

គ្រូបង្រៀនដែលចេញថ្មីក៏ត្រូវបន្តរៀនជានិរន្តរ៍ និងស្រាវជ្រាវវិធីបង្រៀនអប់រំបរិយាបន្នទាំងនេះជាប្រចាំ ហើយឌីវីឌីធនធានផ្តល់ឯកសារអានបន្ថែមក៏ដូចជាវីដេអូផ្សេងទៀតដែលគ្រូបង្រៀនអាចរៀនបាន។ បន្ថែមពីលើនេះ ក៏មានគេហទំព័រមានប្រយោជន៍ដែលផ្តល់ករណីសិក្សាស្តីពីវិធីបង្រៀនការអប់រំបរិយាបន្ន ក៏ដូចជាគេហទំព័របង្កើតដោយអង្គការ UNESCO ដែលមានប្រយោជន៍ ពីព្រោះវាបានបង្ហាញឧទាហរណ៍ពីប្រទេសដទៃ។ អាសយដ្ឋានគេហទំព័រគឺhttp://www.unescobkk.org/education/literacy-and-lifelong-learning/flexible-learning-strategies/

មធ្យោបាយដែលមានប្រសិទ្ធភាពមួយទៀតសម្រាប់គ្រូបង្រៀនគឺតាមរយៈការសហការជាមួយមិត្តរួមការងាររបស់ពួកគេ។ មធ្យោបាយនេះអាចទៅធ្វើបានតាមរយៈ "ការរៀនបែបសកម្ម" ដូចដែលបានពិពណ៌នានៅក្នុងសកម្មភាព ៩.១។ សកម្មភាពនេះក៏ផ្តល់គំរូបង្ហាញគ្រូបង្រៀនអំពីវិធីដែលគ្រូបង្រៀនអាចក្លាយជាអ្នកដឹកនាំនៅក្នុងការដាក់បញ្ចូលកុមារទាំងអស់នៅក្នុងការអប់រំ។ ទោះបីវាហាក់បីដូចជាមិនអាចធ្វើទៅរួចនៅក្នុងបរិបទប្រទេសកម្ពុជាក៏ដោយ ប្រសិនបើគ្រូបង្រៀនអាចប្រើប្រាស់ពេលវេលាប្រចាំខែរបស់ពួកគេខ្លះ នៅថ្ងៃព្រហស្បតិ៍ដើម្បីជួបជុំគ្នា និងពិភាក្សាបញ្ហាប្រឈមដែលពួកគេជួបប្រទះ និងស្វែងរកដំណោះស្រាយដោយខ្លួនឯង និងរៀនសូត្រពីគ្នាទៅវិញទៅមក។

គ្រូបង្រៀនក៏នឹងជួបប្រទះស្ថានភាពប្លែកថ្មី និងប្រហែលជាមិនទាន់មានដំណោះស្រាយសម្រាប់ស្ថានភាពនេះ ដូច្នេះការប្រើប្រាស់ការរៀនបែបសកម្មអាចមានប្រយោជន៍ខ្លាំងសម្រាប់គ្រូបង្រៀន។

នៅក្នុងសកម្មភាព ១៩.២ គំរូមួយឈ្មោះ "រង្វង់ដំណោះស្រាយ" ត្រូវបានបង្ហាញ។ គំរូនេះងាយស្រួលក្នុងការប្រើប្រាស់ ហើយវាជាមធ្យោបាយមានប្រសិទ្ធភាពមួយ សម្រាប់គ្រូបង្រៀនស្វែងរកដំណោះស្រាយ។

ប្រសិនបើគ្រូបង្រៀនអាចអនុវត្តប្រើប្រាស់គំរូនេះជាប្រចាំជាមួយគ្រូបង្រៀនដទៃ នៅរៀងរាល់ពេលប្រជុំថ្ងៃព្រហស្បតិ៍ វាអាចធ្វើឱ្យគ្រូបង្រៀនងាយក្លាយជាគ្រូបង្រៀនការអប់រំបរិយាបន្ន។

## សកម្មភាព ១៩.១ ការពន្យល់ការរៀនជានិរន្ត
## រយៈពេល៖ ៣០នាទី
## វត្ថុបំណង ៖

- កំណត់បានពីរបៀបរៀនជានិរន្ត តាមរយៈការរៀនបែបសកម្ម។

## សម្ភារបង្រៀន និងរៀន៖

- ដ្យាក្រាម "ការគ្រោងផ្លូវដើរ"
- ឯកសារអានស្តីពី "គ្រូបង្រៀនជាអ្នកដឹកនាំ"
- ការពន្យល់ និងគំរូនៃការរៀនបែបសកម្ម។

## សកម្មភាពបង្រៀន៖

ក. សួរគរុសិស្ស ថាតើពួកគេចង់រៀនបន្តទៀតឬទេ នៅពេលក្លាយជាគ្រូបង្រៀនហើយ។
ប្រសិនបើចម្លើយគឺ "បាទ/ចាស" ត្រូវសួរបន្ត៖
១.តើអ្វីដែលពួកគេចង់រៀន?
២.តើទីកន្លែងណាដែលពួកគេចង់រៀន?
(សរសេរចម្លើយនៅលើក្តារខៀន )

ខ. បង្ហាញដ្យាក្រាម "ការគ្រោងផ្លូវដើរ"

គ. ឱ្យគរុសិស្សពិភាក្សាជាក្រុមតូចៗ លើសំណួរ៖
តើគំរូនេះមានន័យដូចម្តេច?

ឃ. គរុសិស្សអានឯកសារដើម្បីជំរុញការពិភាក្សា និងបង្កើតចក្ខុវិស័យរួមមួយ។

ង. បង្ហាញគំរូការរៀនបែបសកម្ម និងពន្យល់ថាតើវាមានន័យយ៉ាងដូចម្តេច។

> "ការរៀនបែបសកម្ម ទាក់ទងទៅនឹងការដោះស្រាយបញ្ហាពិតប្រាកដ ការផ្តោតលើការរៀន និង អនុវត្តដំណោះស្រាយ។ វាគឺជាប្រភេទនៃការរៀនតាមរយៈការធ្វើ"
>
> ដោយមូលនិធិអន្តរជាតិនៃការរៀនបែបសកម្ម ( International Foundation of Action Learning )

ចម្លើយរំពឹងទុក

ក.អាស្រ័យលើគរុសិស្ស

ខ.មានដូចខាងក្រោម៖ ការបណ្តុះបណ្តាលបន្ថែមនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត (PTTC) ការបណ្តុះបណ្តាលបន្ថែមនៅសាកលវិទ្យាល័យ អ៊ីធឺណែត ការអានសៀវភៅ ។ល។

# ការគ្រោងផ្លូវដើរ[103]




103 ដកស្រង់ពី " គ្រូបង្រៀនជាអ្នកដឹកនាំ" ដោយ David Towell និង Heidy Araque បទពិសោធរបស់ពួកគេនៅក្នុងប្រទេស កូឡុំប៊ី និងប្រទេសម៉ិចស៊ីចកូ នៅក្នុងឆ្នាំ២០១២, ទំព័រ៣.

## គំរូការរៀនបែបសកម្ម[104]







## វដ្តនៃការរៀនបែបសកម្ម[105]

ការរៀនបែបសកម្មគឺជាដំណើរការដែលទាក់ទងទៅនឹងការដោះស្រាយបញ្ហាប្រឈម ដែលបុគ្គលជួបប្រទះ ដោយប្រើប្រាស់ចំណេះដឹង និងជំនាញរបស់ក្រុមមនុស្សដែលមានជំនាញក្នុងការសួរ នៅក្នុងរបៀបដែលអាចឱ្យបុគ្គលនោះរកដំណោះស្រាយដោយខ្លួនឯង។ ការរៀនបែបសកម្មអនុវត្តទៅតាមដំណើរការ ដែលត្រូវបានបង្ហាញនៅក្នុងដ្យាក្រាម និងទាក់ទងទៅនឹងការបង្កើតពេលវេលាដើម្បីឆ្លុះបញ្ចាំងលើសកម្មភាពធ្វើឡើង និងទាញយកការរៀនសូត្រពីការឆ្លុះបញ្ចាំង និងអនុវត្តការរៀននោះជាក់ស្តែង។ ការរៀននេះដាក់ឱ្យអនុវត្តនៅកម្រិតបុគ្គល ហើយលទ្ធផលប្រែប្រួលទៅតាមការងាររបស់ពួកគេ តាមរយៈការឆ្លុះបញ្ចាំង។

---

[104] ដកស្រង់ពី Action Learning Associates on http://www.actionlearningassociates.co.uk/action-learning/

[105] ដកស្រង់ចេញពីគោលការណ៍ណែនាំ INTRAC ទំព័រ១

### សកម្មភាព ១៩.២ ការស្វែងរកដំណោះស្រាយដោយខ្លួនឯង

### រយៈពេល៖ ៤៥នាទី

### វត្ថុបំណង ៖

- កំណត់បានពី "រង្វង់ដំណោះស្រាយ" ដោយខ្លួនឯង។

### សម្ភារបង្រៀន និងរៀន៖

- ឯកសារណែនាំប្រើប្រាស់ "រង្វង់ដំណោះស្រាយ"[106]
- វីដេអូឈ្មោះ "កសាងចលនាគ្រូបង្រៀន"[107]។

### សកម្មភាពបង្រៀន៖

ក.ឱ្យគរុសិស្សបង្កើតក្រុម ដែលមានសមាជិកពី៥ទៅ៩នាក់

ខ.ពន្យល់ដោយសង្ខេបអំពីអ្វីដែលក្រុមនីមួយៗនឹងត្រូវធ្វើ

គ.សម្របសម្រួលសកម្មភាព "រង្វង់ដំណោះស្រាយ" និងធ្វើទៅតាមពេលវេលាណែនាំ

ឃ.ប្រសិនបើនៅសល់ពេលបង្ហាញវីដេអូ ឈ្មោះ "កសាងចលនាគ្រូបង្រៀន" ។



© Miranda Shusterman

[106] គោលការណ៍ណែនាំរង្វង់ដំណោះស្រាយ (ធ្វើបច្ចុប្បន្នភាព) ដោយ បណ្ឌិត Loiuse McDonell (អ្នកចិត្តសាស្ត្រអប់រំ).

[107] វីដេអូ ផ្សព្វផ្សាយដោយ Stir Foundation និងផលិតដោយ Jagriti Rawal នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ https://www.youtube.com/watch?v=dWL9s-75-B0&t=49s

# រង្វង់ដំណោះស្រាយ



រង្វង់ដំណោះស្រាយគឺជាឧបករណ៍ដែលត្រូវបានបង្កើតឡើង ដើម្បីជួយមនុស្សដោះស្រាយបញ្ហានៅក្នុងជីវិត ឬការងារ។ វាល្អបំផុតសម្រាប់ប្រើជាមួយក្រុម ដែលមានសមាជិកពី៥ ទៅ៩នាក់។

**រយៈពេល៖** ៣០នាទី

**ធនធាន៖** អ្នកបង្ហាញបញ្ហា
អ្នកសម្របសម្រួលដំណើរការ (អ្នកមើលរចនាសម្ព័ន្ធ និងអ្នកមើលពេលវេលា)
អ្នកកត់ត្រា (ដើម្បីកត់ត្រាខ្លឹមសារ នៅក្នុងទម្រង់រូបភាព)
និងក្រុមមនុស្សចែករំលែកដំណោះស្រាយច្នៃប្រឌិត (សម្គាល់៖ អ្នកក្រៅអាចជួយបានច្រើនជាមួយឧបករណ៍នេះ។ ព្យាយាមបន្ថែមមនុស្ស ដែលមានទេពកោសល្យថ្មី ដែលមិនដឹងអ្វីទាំងអស់អំពីបញ្ហា)
ក្រដាសធំមួយផ្ទាំង និងប៊ិក។ កន្លែងងាយស្រួលជួបគ្នា។
ប្រើរយៈពេល៣០នាទី។

**ត្រៀមខ្លួន៖**

១. កំណត់អ្នកបង្ហាញបញ្ហា អ្នកសម្របសម្រួលដំណើរការ និងអ្នកកត់ត្រា។

២. ឯកភាពលើវិធានមួយចំនួន សម្រាប់ដំណើរការក្រុមវិធានសាមញ្ញពីរបី ដែលនឹងជួយឱ្យសមាជិកម្នាក់ៗរបស់ក្រុមមានអារម្មណ៍ងាយស្រួល។

៣. អ្នកសម្របសម្រួលដំណើរការ ពន្យល់រចនាសម្ព័ន្ធ នៃជំហានទាំងបួននៃរង្វង់ដំណោះស្រាយ រួមទាំងរំឭកម៉ោងពេល ។

**ជំហានទី១ (៦នាទី)**



អ្នកបង្ហាញបញ្ហាមានរយៈពេល៦នាទីដោយមិនត្រូវបានបង្អាក់ដើម្បីបង្ហាញបញ្ហា។ ការងាររបស់អ្នកសម្របសម្រួលដំណើរការគឺមើលពេលវេលា និងធានាថាមិនមាននរណាម្នាក់បង្អាក់។ ឱ្យពួកគេអង្គុយជិតគ្នាដើម្បីឱ្យពួកគេអាចស្តាប់គ្នាទៅវិញទៅមក ។ អ្នកកត់ត្រាត្រូវកត់ត្រា។ សមាជិកក្រុមត្រូវស្តាប់។ ប្រសិនបើអ្នកបង្ហាញបញ្ហាឈប់និយាយមុនអស់រយៈពេល៦នាទី អ្នកគ្រប់គ្នាត្រូវនៅស្ងៀមស្ងាត់រហូតដល់៦នាទី។ អ្នកបង្ហាញបញ្ហាមានពេល៦នាទីដោយមិនត្រូវបានបង្អាក់។ អ្នកសម្របសម្រួលដំណើរការ ចាំមើលពេលវេលាស្ងៀមស្ងាត់ឱ្យអ្នកបង្ហាញបញ្ហា។

**ជំហានទី២ (៦នាទី)**



អ្នកបង្ហាញបញ្ហាស្តាប់ដោយមិនបង្អាក់អ្នកដទៃ។ គាត់មិនត្រូវនិយាយ ឬឆ្លើយតបនោះទេ។ អ្នកផ្សេងទៀតនៅក្នុងក្រុមចែករំលែកគំនិតអំពីដំណោះស្រាយច្នៃប្រឌិតចំពោះបញ្ហាដែលទើបតែត្រូវបានបង្ហាញ។ វាមិនមែនជាពេលវេលាដើម្បីបកស្រាយបញ្ហា ឬសួរសំណួរនោះទេ។ វាមិនមែនជាពេលវេលាថ្លែងសុន្ទរកថា ឬផ្តល់ដំបូន្មាននោះទេ។ អ្នកសម្របសម្រួលដំណើរការត្រូវធានាថា នេះគឺជាការស្វែងរកគំនិតថ្មី។ អ្នកគ្រប់គ្នាមានឱកាសផ្តល់គំនិតល្អៗ។ មិនត្រូវឱ្យនរណាម្នាក់និយាយតែឯងនោះទេ។

**ជំហានទី៣ (៦នាទី)**



ឥឡូវក្រុមអាចធ្វើការពិភាក្សា ដែលត្រូវដឹកនាំដោយអ្នកបង្ហាញបញ្ហា។ នេះគឺជាពេលវេលាស្វែងរក និងបកស្រាយបញ្ហា។ ត្រូវផ្តោតតែលើចំណុចវិជ្ជមាន និងមិនត្រូវផ្តោតលើអ្វីដែលមិនអាចធ្វើបាននោះទេ។ អ្នកបង្ហាញបញ្ហាដឹកនាំដោយកំណត់គំនិតដែលគួរឱ្យចាប់អារម្មណ៍ ឬប្លែកពីគេ ឬគួរចង់សាកល្បង ឬគួរច្នៃជាដំណោះស្រាយសម្រាប់ធ្វើសកម្មភាព។

**ជំហានទី៤ (៦នាទី)**



អ្នកបង្ហាញបញ្ហា និងក្រុមទាំងមូលត្រូវសម្រេចលើជំហានដំបូង ដែលអាចធ្វើទៅបាននៅក្នុងរយៈពេល៣ថ្ងៃខាងមុខ (និងល្អបំផុត ក្នុងរយៈពេល២៤ម៉ោងខាងមុខ)។ ជំហាននេះមានសារៈសំខាន់ខ្លាំង។ ការស្រាវជ្រាវបង្ហាញថា បើជំហានដំបូងមិនត្រូវបានធ្វើឡើងភ្លាមនោះទេ មនុស្សនឹងមិនចេញផុតពីទម្លាប់ ឬការជាប់គាំងនោះទេ។

អ្នកបង្ហាញបញ្ហាត្រូវជ្រើសរើសអ្នកបង្ហាត់បង្រៀនពីក្នុងក្រុមដែលស្ម័គ្រចិត្ត ទូរស័ព្ទ ឬជួបបុគ្គលនោះនៅពេលវេលាជាក់លាក់ណាមួយ (ក្នុងរយៈពេល១ថ្ងៃ ទៅ៣ថ្ងៃខាងមុខ) និងពិនិត្យមើល ប្រសិនបើបុគ្គលនោះអាចអនុវត្តជំហានដំបូងរបស់គេ។ ការធ្វើបែបនេះបង្កើតការជំរុញការគាំទ្រវិជ្ជមានក្នុងការធ្វើសកម្មភាព។

ចុងក្រោយ ក្រុមចែករំលែកពាក្យ (សមាជិកម្នាក់ៗជ្រើសរើសពាក្យមួយ ដើម្បីពិពណ៌នាពីបទពិសោធន៍) ហើយអ្នកកត់ត្រាកត់ត្រាឱ្យបានពេញលេញទៅដល់អ្នកបង្ហាញបញ្ហា។ ប្រសិនបើក្រុមមានសមាជិកច្រើនក្រុមតូចៗត្រូវត្រឡប់មកកាន់ក្រុមធំវិញ សួរសំណួរ និងបន្តទៅមកទៀត។

**គន្លឹះមានប្រយោជន៍៖**

- គោរពវិធាន វាមានប្រសិទ្ធភាពសម្រាប់អ្នក
- ការសម្របសម្រួលកាន់តែច្បាស់លាស់ រង្វង់ដំណោះស្រាយនឹងកាន់តែប្រសើរ
- មិនត្រូវឱ្យសមាជិក "បកស្រាយ" នៅចន្លោះជំហានទី១ និងទី២
- នៅក្នុងជំហានទី៣ផ្តោតទៅលើអ្វីដែលវិជ្ជមាន អាចធ្វើទៅបាន មិនទៅលើអ្វីដែលបានបរាជ័យហើយនោះទេ។
- ទាមទារឱ្យសមាជិកត្រូវស្តាប់
- ប្រើសម្ពាធពេលវេលា ដើម្បីជំរុញទៅមុខមិនត្រូវឱ្យពេលវេលាខាតបង់នោះទេ។

**លទ្ធផល៖**



ជាទូទៅ លំហាត់នេះបង្កើតសកម្មភាព។ វាមិនធានាបង្កើតដំណោះស្រាយនោះទេ ប៉ុន្តែអាចឱ្យមនុស្សលែងជាប់គាំង យ៉ាងហោចណាស់បែរទៅរកមធ្យោបាយប្លែកថ្មី ដើម្បីក្រឡេកមើលស្ថានភាព ឬជំហានបន្ទាប់ដែលសមហេតុផល។ ពេលខ្លះមនុស្សរកឃើញថា តាមរយៈការគោរពតាមវិធាននៃលំហាត់នេះ និងផ្តោតលើបញ្ហាជាមួយក្រុមតូច គំនិតថ្មីអាចកើតឡើងយ៉ាងឆាប់រហ័ស។ វាអាចទៅរួចក្នុងការដើរឱ្យផុតពីឧបសគ្គធ្ងន់ធ្ងរ និងរំដោះខ្លួនដើម្បីសាកល្បងជម្រើសថ្មី។

**ប្រុងប្រយ័ត្ន៖**

រង្វង់ដំណោះស្រាយគឺជាឧបករណ៍ដ៏ល្អដើម្បីប្រើប្រាស់នៅពេលអ្នកមិនប្រាកដថាគួរចាប់ផ្តើមពីចំណុចណា វាឆាប់រហ័សនិងអាចឱ្យមនុស្សផ្តោតអារម្មណ៍ដោយវិជ្ជមាន។ ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើអ្នកដឹងថាបញ្ហាដែលអ្នកកំពុងដោះស្រាយមានលក្ខណៈស្មុគស្មាញ អ្នកអាចជ្រើសរើសប្រើប្រាស់ MAP PATH ឬឧបករណ៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយជាងនេះ។

## សេចក្ដីសន្និដ្ឋាន

ប្រទេសកម្ពុជាស្ថិតនៅលើផ្លូវបង្កើតការអប់រំបរិយាបន្នសម្រាប់កុមារពិការ ចាប់តាំងពីឆ្នាំ២០០៣ ជាមួយការបង្កើតកម្មវិធីសិក្សាអប់រំបរិយាបន្នសម្រាប់កុមារមានសេចក្ដីត្រូវការអប់រំពិសេស។ ក្រោយមកទៀត សៀវភៅការអប់រំបញ្ចូលគ្នាត្រូវបានបង្កើតនៅក្នុងឆ្នាំ២០១២។ បន្ទាប់មកសៀវភៅការអប់រំបញ្ចូលគ្នាសម្រាប់កុមារមានបញ្ហាបញ្ញា កុមារមានបញ្ហាស្ដាប់ និងកុមារមានបញ្ហាមើលត្រូវបានបង្កើតឡើង។ ប៉ុន្តែឯកសារទាំងនេះផ្ដោតសំខាន់លើការសិក្សាប្រភេទពិការ និងផ្ដល់គន្លឹះបង្រៀនមួយចំនួនសម្រាប់ប្រភេទពិការផ្សេងៗ។ ការធ្វើបែបនេះបានធ្វើឱ្យគ្រូបង្រៀនមិនច្បាស់ក្នុងការបង្រៀនកុមារដែលមានសេចក្ដីត្រូវការរៀនខុសៗគ្នា និងពិការខុសៗគ្នានៅក្នុងថ្នាក់រៀនបរិយាបន្ន។

ឯកសារនេះត្រូវបានកែតម្រូវតាមរយៈការផ្ដល់ឱ្យគ្រូបង្រៀននូវចំណេះដឹង និងបំណិនអំពីវិធីបង្រៀនអប់រំបរិយាបន្នមានសារៈសំខាន់សម្រាប់ការរៀនរបស់កុមារទាំងអស់ និងមិនមែនសម្រាប់តែកុមារពិការនោះទេ។

ឯកសារនេះអាចជួយឱ្យសម្រេចបានលទ្ធផលយ៉ាងច្រើន ប៉ុន្តែវាគ្រាន់តែជាចំណុចចាប់ផ្ដើមប៉ុណ្ណោះ និងរំពឹងថានាពេលអនាគតប្រទេសកម្ពុជានឹងបន្តដើរនៅលើផ្លូវឆ្ពោះទៅកាន់ការអប់រំបរិយាបន្ន និងបង្កើតកម្មវិធីបណ្ដុះ បណ្ដាលសម្រាប់គរុសិស្សផ្អែកលើការអប់រំបរិយាបន្នជាមូលដ្ឋានគ្រឹះ ដើម្បីឱ្យការអប់រំបរិយាបន្នមិនត្រូវបានមើលឃើញថាគ្រាន់តែជាការបន្ថែម និងមានប្រយោជន៍សម្រាប់តែកុមារពិការ។

ការអប់រំបរិយាបន្នដែលប្រើប្រាស់គោលនយោបាយសាលាកុមារមេត្រី និងវិធីបង្រៀនការអប់រំបរិយាបន្នផ្ដល់អត្ថប្រយោជន៍ដល់កុមារទាំងអស់។

កុមារដែលគ្មានការអប់រំ ប្រៀបដូចជាបក្សីគ្មានស្លាប

សុភាសិតប្រជាជនទីបេ

### សារសម្រាប់គ្រូបង្រៀន

កុមារគ្រប់រូបស័ក្ដិសមទទួលបានគ្រូបង្រៀនដែលជឿជាក់លើពួកគេ។

ចូរធ្វើជាគ្រូបង្រៀនម្នាក់នោះ។

អនាមិក

## តារាងត្រួតពិនិត្យចុងក្រោយសម្រាប់គ្រូបង្រៀនប្រើប្រាស់ ដើម្បីពិនិត្យមើលការអនុវត្តរបស់ការអប់រំបរិយាបន្ន[108]

| ល.រ | សូចនាករ | បាទ/ចាស | ទេ | ភស្តុតាង |
|---|---|---|---|---|
| ១ | ថ្នាក់រៀនមានលក្ខណៈស្វាគមន៍ | | | ថ្នាក់រៀនស្អាត ស្នាដៃរបស់សិស្សត្រូវបានដាក់បង្ហាញ សម្ភារបង្រៀន និងរៀនមាននៅក្នុងថ្នាក់រៀន ហើយសិស្សអាចប្រើប្រាស់បាន |
| ២ | គ្រូបង្រៀនកំណត់កុមារដែលមានឧបសគ្គក្នុងការរៀន | | | មានព័ត៌មានគ្រួសៗអំពីសិស្សទាំងអស់ |
| ៣ | គ្រូបង្រៀនដោះស្រាយឧបសគ្គ ដោយផ្តល់ការគាំទ្រចាំបាច់ | | | ផែនការអប់រំសម្រាប់សិស្សម្នាក់ៗ |
| ៤ | គ្រូបង្រៀនប្រាប់ការពិបាកដែលពួកគេមាននៅក្នុងការបង្រៀនទៅថ្នាក់លើ | | | តារាងសេចក្តីត្រូវការនៃការរៀនរបស់សិស្សម្នាក់ៗ ត្រូវបានបំពេញ និងមានភស្តុតាងនៃការបញ្ជូនទៅកាន់អ្នកផ្តល់សេវាដែលពាក់ព័ន្ធ |
| ៥ | កំណត់ត្រាច្បាស់លាស់នៃការគាំទ្រចាំបាច់ និងសម្ភារប្រើប្រាស់ត្រូវបានរក្សាដោយគ្រូបង្រៀន | | | តារាងសិស្សងាយរងគ្រោះត្រូវបានរក្សាសម្រាប់ការតាមដាន |
| ៦ | គ្រូបង្រៀនអញ្ជើញឪពុកម្តាយ និងអ្នកជំនាញផ្សេងទៀត ដើម្បីពិភាក្សាអំពីការរីកចម្រើន និងតម្រូវការការគាំទ្រ | | | កំណត់ហេតុកិច្ចប្រជុំ បញ្ជីវត្តមាន |
| ៧ | គ្រូបង្រៀនរៀបចំកិច្ចតែងការ និង កម្មវិធីសិក្សាដោយគិតដល់របៀបរៀនរបស់កុមារ | | | កិច្ចតែងការ សៀវភៅកិច្ចការសិស្ស កំណត់ត្រាវាយតម្លៃ |
| ៨ | គ្រូបង្រៀនប្រើប្រាស់វិន័យវិជ្ជមាន ដើម្បីដោះស្រាយអាកប្បកិរិយាមិនល្អ | | | មិនមានការត្អូញត្អែរពីទណ្ឌកម្មរាងកាយ កុមារសប្បាយចិត្តទៅសាលារៀន |
| ៩ | គ្រូបង្រៀនប្រើគោលការណ៍ប្លង់សកល | | | កិច្ចតែងការ សម្ភារបង្រៀន និងរៀន |
| ១០ | គ្រូបង្រៀនប្រើការជួយជ្រោមជ្រែង និងភាពផ្សេងៗគ្នា | | | កិច្ចតែងការ ផែនការអប់រំសម្រាប់សិស្សម្នាក់ៗ និងសម្ភារបង្រៀន និងរៀន |

[108] កែសម្រួលពី UNICEF's webinar series Webinar 14 whish ត្រូវបានប្រើប្រាស់នៅបញ្ជីត្រួតពិនិត្យបរិយាបន្នរបស់ប្រទេសអាហ្វ្រិកខាងត្បូង ទំព័រ ៣៦-៣៧

# សេចក្តីថ្លែងអំណរគុណ

ការរៀបចំ ចងក្រងឯកសារការអប់រំបរិយាបន្ននេះត្រូវបានចូលរួមចំណែកជាធាតុចូលពីនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹការ នាយកដ្ឋានអប់រំពិសេស អង្គការគ្រួសារថ្មី និងគ្រូឧទ្ទេសសាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្តដែលបង្រៀនអំពីការអប់រំបរិយាបន្ន អង្គការដៃគូអភិវឌ្ឍដែលធ្វើការលើការអប់រំបរិយាបន្ន រួមមានអង្គការ AAR Japan Catholic Relief Services អង្គការជនពិការកម្ពុជា មូលនិធិកុមារពិការ អង្គការពន្លឺសម្រាប់ពិភពលោក អង្គការសាលារៀនទទន្សាយ និងអង្គការ Save the Children។ ធាតុចូលពីអង្គការខាងលើ និងបុគ្គលិករបស់ពួកគេពិតជាមានតម្លៃយ៉ាងខ្លាំង។ គំនិត និងឧបករណ៍ពីប្រភពជាច្រើនត្រូវបានប្រើប្រាស់នៅក្នុងការរៀបចំចងក្រងឯកសារនេះ រួមមាន៖

Alberta Education (២០១៥) *បណ្តុំវីដេអូការអប់រំបរិយាបន្ន* ការជួយជ្រោមជ្រែងសម្រាប់ភាពជោគជ័យរបស់រដ្ឋាភិបាល Alberta

Alberta Education (២០១៥) *បណ្តុំវីដេអូការអប់រំបរិយាបន្ន* ប្លង់សកលរដ្ឋាភិបាល Alberta

Alberta Education (២០១៥) *បណ្តុំវីដេអូការអប់រំបរិយាបន្ន* ការប្រើប្រាស់ការបង្រៀនស្របទៅតាមភាពផ្សេងៗគ្នារបស់សិស្ស(differentiated instruction) រដ្ឋាភិបាល Alberta

Baboo N. (២០១២) មេរៀនទី៤៖ *ការពិនិត្យ និងកំណត់សេចក្តីត្រូវការសិក្សា* UNICEF Macedonia (២០១២) *មេរៀនបណ្តុះបណ្តាលគ្រូបង្រៀនអប់រំបរិយាបន្ន* UNICEF: Macedonia

Bohan-Jacquot, S. (២០១៤) "*ការអប់រំការបណ្តុះបណ្តាលគ្រូបង្រៀនស៊ូដង់ខាងត្បូង មេរៀនបណ្តុះបណ្តាលសម្រាប់មេរៀនការសិក្សាវិជ្ជាជីវៈសម្រាប់ការអប់រំបរិយាបន្ន*" Norad មូលនិធិ Stromme ក្រសួងអប់រំស៊ូដង់ខាងត្បូង អង្គការ Light for the World

មជ្ឈមណ្ឌលបច្ចេកវិទ្យាអនុវត្តពិសេស (CAST) (២០១០) "*ក្រឡេកមើលប្លង់សកលសម្រាប់ការរៀន (UDL)*" វីដេអូអនឡាញ

មជ្ឈមណ្ឌលបច្ចេកវិទ្យាអនុវត្តពិសេស (CAST) (២០១០) "*ប្លង់សកលសម្រាប់ការរៀន គោលការណ៍ និងការអនុវត្ត*" វីដេអូអនឡាញ

មជ្ឈមណ្ឌលបច្ចេកវិទ្យាអនុវត្តពិសេស (CAST) (២០១២) ប្លង់សកលសម្រាប់ការរៀន http://www.cast.org/our-work/about-udl.html#.

INEE (២០០៩) ការអប់រំក្នុងស្ថានភាពគ្រោះអាសន្ន ដាក់បញ្ចូលអ្នកគ្រប់គ្នានៅក្នុងការអប់រំ INEE គោលការណ៍ណែនាំសម្រាប់ការអប់រំបរិយាបន្ន UNHCR ទីក្រុងហ្សឺណែវ

Kalyanpur,M. (២០១២) ការបង្រៀនសិស្សមានបញ្ហាសិក្សាទាក់ទងនឹងពិការភាព MoEYS ភ្នំពេញ

Kaplan, I. and Lewis, I. (២០១៣) *លើកកម្ពស់ការអប់រំគ្រូបង្រៀនបរិយាបន្ន គោលការណ៍ណែនាំតស៊ូមតិទី៣ ស្តីពីកម្មវិធីសិក្សា* UNESCO បាងកក

Towell, D. and Araque, H. (២០១២) *គ្រូបង្រៀនជាអ្នកដឹកនាំ៖ ផ្លូវឆ្ពោះទៅកាន់ការអប់រំបរិយាបន្ន* មជ្ឈមណ្ឌលសម្រាប់អនាគតបរិយាបន្ន & Towell, D. (ថ្ងៃទី៤ កញ្ញា ២០១៣) *គ្រូបង្រៀនជាអ្នកដឹកនាំ មជ្ឈមណ្ឌលសម្រាប់អនាគតបរិយាបន្ន* (ធនធានអនឡាញ)

https://centreforinclusivefutures.wordpress.com/page/3/

UNESCO (២០១៥) *ទទួលយកភាពចម្រុះ បង្កើតបរិស្ថានមេត្រីសម្រាប់ការរៀនបញ្ចូលគ្នា* UNESCO

(២០០៥) " គោលការណ៍ណែនាំសម្រាប់បរិយាបន្ន ការធានាការទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា" បោះពុម្ពដោយ UNESCO បារាំង

UNESCO (២០១៦) *គោលការណ៍ណែនាំគោលនយោបាយស្តីពីបរិយាបន្ននៅក្នុងការអប់រំ* UNESCO បារាំង

UNESCO (២០១៥) សៀវភៅទី៣ នាំកុមារទាំងអស់ទៅក្នុងសាលារៀន និងការសិក្សា UNESCO បារាំង

UNICEF (២០១៤) គ្រូបង្រៀនបរិយាបន្ន សិស្សមជ្ឈមណ្ឌល និងគរុកោសល្យ Webinar 12 កូនសៀវភៅបច្ចេកទេស NY សហរដ្ឋអាមេរិក ទំព័រ. ៣២

សាកលវិទ្យាល័យ Sheffield (២០១៦) ស្វែងយល់ការលេង វគ្គអនឡាញ Massive Open

អង្គការក្រៅរដ្ឋាភិបាលជាច្រើនមិនត្រឹមតែបានចូលរួមនៅក្នុងដំណើរការពិនិត្យឡើងវិញនោះទេ ប៉ុន្តែក៏បានផ្តល់ករណីសិក្សា និងអនុញ្ញាតឱ្យយើងខ្ញុំថតរូប ដូច្នេះសូមថ្លែងអំណរគុណជាពិសេសដល់លោក Tomoko Sonada នៃអង្គការ AAR ជប៉ុន និងលោក បុត្រ វិមាន នៃមូលនិធិកុមារពិការ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ការផ្តល់ធាតុចូលរបស់ Jodie Davies, Alison King, Raj Cheema និង Emma Whittingham មកពីកម្មវិធីស្ម័គ្រចិត្តរបស់សាកលវិទ្យាល័យស៊ីធី (City University) ដែលបានបណ្តុះបណ្តាលបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ក្នុងការព្យាបាលដោយការនិយាយ និងការប្រើប្រាស់ភាសា (Speech and Language Therapy) នៅប្រទេសកម្ពុជាក្នុងឆ្នាំ២០១៦។ បុគ្គលិកមកពីកម្មវិធីដៃគូរួមគ្នាផ្តល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា ហើយការស្ម័គ្រចិត្តនេះត្រូវបានរៀបចំដោយអង្គការ Aide et Action។

យើងខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសដល់លោក Michael Pitt ដែលបានប្រើប្រាស់ពេលវេលាផ្ទាល់ខ្លួនថតរូបកុមារនៅសាលានានានៅក្នុងប្រទេសកម្ពុជា។

លោកស្រី គីរ៉ាន ដាតានី ភីត

# ឯកសារយោង


Alberta Education (2015) *Inclusive Education Video Series* - Scaffolding for success Alberta Government

Alberta Education (2015) *Inclusive Education Video Series* - Universal Design Alberta Government

Alberta Education (2015) *Inclusive Education Video Series* - Using Differentiated Instruction Alberta Government

Alkazi, R. M. and Aggarwal, S. (2014-2015) *Fourth Annual Report: The Status of Inclusive Education*

Antonio, B. (2013) "UDL: Removing Barriers" online video posted on YouTube.

Baboo N. (2012) *Module 4: Screening and Identification of Learning Needs* in: UNICEF Macedonia (2012) *Inclusive Education Teacher Training Modules* UNICEF: Macedonia.

Bohan-Jacquot, S. (2014) '*South Sudan Teacher Training Education: Training Module for Professional Studies Unit for Inclusive Education'* Norad, Stromme Foundation, Ministry of Education South Sudan, Light for the World, pg.14.

Bouille, S (2013) *Developing an Itinerant Teacher that Supports a Twin-Track Approach to Inclusive Education, Cambodia* Enabling Education Review Issue 2, EENET: Manchester

Bondy, E., Ross, D., Adams, A., Nowak, R., Brownell, M., Hoppey, D., Kuhel, K., McCallum, C. and Stafford, L. (2007) Personal Epistemologies and Learning to Teach. Teacher Education and Special Education: The Journal of the Teacher Education Division of the Council for Exceptional Children, 30, 67

Bixler, B. (undated online resource) *Learning Style Inventory* Penn State University, Pennsylvania.

Casperbear (2011) *Andy Using PECS Part 2* YouTube.

Centre for Applied Special Technology (2008) *"Using Universal Design for Learning: Version 1"* Wakefield: MA.

Centre for Applied Special Technology (CAST) (2010) *"UDL at a glance"* online video.

Centre for Applied Special Technology (CAST) (2010) *"UDL: Principles and Practice"* online video.

Centre for Applied Special Technology CAST (2012) *Universal Design for Learning* http://www.cast.org/our-work/about-udl.html#.

CBM (2012) *Inclusion made Easy: A quick programme guide to disability in development* CBM: Germany

Coons, L. (undated) *Core Instruction: School-wide Strategies* Department of Education, Tennessee.

Dale, E. (1969) 3rd Edition *Audio-Visual Learning Materials in Teaching* New York: Holt, Rinehart & Winston.

Davies, J., King, A., Cheema, R., Whittingham, E. (2016) *5 day training in Speech and Language Therapy in Cambodia* City University: London.

Eastern Health Services (2007) *Cambodian Visual Aids* Canada.

Florian, L. and Black-Hawkins, K., (2011) Exploring Inclusive Pedagogy. British Educational Research Journal, 37(5), pp. 813-828.

Grimes, P. (2008) *A Quality Education for All* Save the Children, Norway and SIDA: Laos pgs 127-129

Gupta, R. (June 2015) *The Best Resource Room Ever: You can take so many ideas to make TLM* Primary School in India. YouTube video https://www.youtube.com/watch?v=MhU2-RZa82o&t=183s

Hanley, K. (2015) *Communication in the Classroom* Power-point presentation OIC: Cambodia.

Hughes, B. (2002) *A Playworker's Taxonomy of Play Types*. (2nd ed.) Play Education.

INEE (2009) *Education in Emergencies: Including Everyone in Education* INEE Pocket Guide to Inclusive Education UNHCR: Geneva.

Kalyanpur, M. (2012) *Teaching Students with Learning Problems Related to Disability* MoEYS: Phnom Penh.

Kaplan, I. and Lewis, I. (2013) *Promoting Inclusive Teacher Education, Advocacy Guide 3 on Curriculum* UNESCO: Bangkok

Kijowska, L., Askew, L., Fraser, K., Martin, H. and Gillet, K (2009) Video titled City-Cambodia Speech and Language Therapy Project RSO: Cambodia

Knowles, M. (2010) *Adult Learning Processes: Pedagogy and Andragogy* Taylor and Frances online resource.

Korthagen, F., Loughran, J. and Lunenberg, M. (2005) Teaching teachers: Studies into the expertise of teacher educators. Teaching and Teacher Education, 21 (2), 107-115

Ladybug House Healthcare for Kids (online blog) *Communication Pyramid* Keilor East: Australia.

Langmadung Primary School, Bhutan (Sept. 2014) *Discovering Teaching and Learning Materials from Waste* YouTube video. https://www.youtube.com/watch?v=Ght0C-eS3EU

McDonell, L (undated online resource) *Solution Circle Guidelines*

Ministry of Education, Maldives and UNICEF (2010) *Learner Centred Teaching and Learning - Standard 2.3 Teaching and Learning Strategies* UNICEF: Maldives

Ministry of Education Youth and Sports (2015), Cambodia *Positive Discipline and Effective Classroom Management. Guide for Facilitators* MoEYS: Phnom Penh

National Centre for Universal Design for Learning online resource http://www.udlcenter.org/aboutudl/whatisudl/3principles

OECD (2010) Educating Teachers for Diversity. Meeting the Challenge. Paris: OECD CERI, http://www.oecd.org/document/38/0,3343,en_2649_35845581_44572006_1_1_1_1, 00.html

Pierpoint, J, O'Brien, J. and Forest, M. Save the Children (2008) *Making Schools Inclusive* Save the Children: London, UK.

Pitt, K. D. (2016) *Manual and Guide on Inclusive Education (Part 2)* Aide et Action and Cambodian Consortium for Out of School Children: Phnom Penh

Save the Children/EENET (2002) *Schools for All* Poster

Schaefer, C.E. & Drewes, A.A. (eds) (2014) *The Therapeutic Powers of Play: Twenty Core Agents of Change*. (2nd edition) Hoboken, New Jersey: Wiley.

Sierra, H. T. A and Towell, D. (2011) Advancing Inclusive Education for the Future for an Inclusive Future London: Centre for Inclusive Futures

Stubbs, S. (2008) *Inclusive Education*: *Where there are Few Resources* The Atlas Alliance: Oslo, Norway

Towell, D. and Araque, H. (2012) *Teachers as Leaders: On a Journey to Inclusive Education* Centre for Inclusive Futures

Towell, D. (4 Sept. 2013) *Teachers as Leaders* Centre for Inclusive Futures (online resource) https://centreforinclusivefutures.wordpress.com/page/3/

Wilfrid Laurier University Workshop (2008) *Understanding Your Learning Style* Wilfrid Laurier University, Waterloo: Canada

UN (2008) *United Nations Convention on the Rights of Persons with Disability* UN: New York

UNESCO (2005) "Guidelines for Inclusion: Ensuring Access to Education for ALL" UNESCO Publishing, France.

UNESCO (2006) *Policy Guidelines on Inclusion in Education* UNESCO: France

UNESCO (2015 online resource) *Embracing Diversity: Creating Learner-Friendly Environments* UNESCO: Bangkok

UNESCO (2015) *Booklet 3: Getting All Children in School and Learning* UNESCO: Bangkok

UNICEF (2014) *'Teachers, Inclusive, Child Centred Teaching and Pedagogy: Webinar 12 – Companion Technical Booklet.'* NY, USA pg. 32

University of Sheffield (2016) *Exploring Play* Massive Open Online Course.